ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

# របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦
# ស្តីពី
# ការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
# ២០១៤-២០១៨

ជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព

ឆ្ពោះទៅប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

## អារម្ភកថា

ជានិច្ចកាល រាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់ខ្ជាប់នូវគោលនយោបាយអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ជាមួយនឹងស្មារតីសាមគ្គីជាតិមួយរឹងមាំតាមរយៈការប្រមូលកម្លាំងប្រជាជាតិទាំងមូលពីគ្រប់មជ្ឈដ្ឋាន គ្រប់និន្នាការនយោបាយ ទាំងក្នុង ទាំងក្រៅប្រទេសឲ្យទៅជាធ្លុងមួយក្រោមបាវចនា "**ជាតិ សាសនា ព្រះមហាក្សត្រ**" ដើម្បីធានាឯករាជ្យភាព អធិបតេយ្យភាព បូរណភាពទឹកដី សុខសន្តិភាព ភាពសុខដុម ប្រជាធិបតេយ្យ និង វឌ្ឍនភាពដ៏រុងរឿងថ្កើងថ្កាន។ ជាក់ស្តែង ដូចបានកំណត់ច្បាស់លាស់ក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨** (**ផយអជ ២០១៤-២០១៨**) គឺបានឆ្លុះបញ្ចាំងនូវការប្តេជ្ញាចិត្តដ៏មោះមុតរបស់រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតនូវសមិទ្ធផលធំៗជាច្រើន ក្នុងរយៈពេលពីរឆ្នាំកន្លះដំបូងនៃការអនុវត្ត **ផយអជ ២០១៤-២០១៨** ទោះបីជាត្រូវរែកពុននឹងបន្ទុកដ៏ធ្ងន់ចំនួនបី៖ (១) ការបន្តដោះស្រាយការងារជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយបរិយាប័ន្ន (២) ភាពចាំបាច់ក្នុងកិច្ចការពារបូរណភាពទឹកដី និង (៣) ការបង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ជាពិសេសសម្រាប់យុវវ័យក្នុងដំណាក់កាលនៃការប្រកួតប្រជែងទាំងក្នុងតំបន់និងសកល។ បញ្ហាទាំងនេះ បានកើតឡើងព្រមៗគ្នាដោយមិនបានដឹងមុនក៏ដោយ។ ជារួមបញ្ហាទាំងនេះមិនត្រឹមតែបានរាំងដល់ការសម្រេចបានគោលដៅអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានគំរាមបំផ្លាញសមិទ្ធផល ដែលយើងសម្រេចបានក្នុងរយៈពេលកន្លងមកទៀតផងដែរ។

បើទោះបីជួបនូវបញ្ហាប្រឈមមួយចំនួន រាជរដ្ឋាភិបាលកម្ពុជាសម្រេចបាននូវជោគជ័យធំៗគួរជាទីមោទនៈក្នុងរយៈពេលពាក់កណ្តាលអាណត្តិនៃ **ផយអជ ២០១៤- ២០១៨** ក្នុងការនាំប្រទេសជាតិទាំងមូលឲ្យបានឆ្លងផុតស្ថានភាពដ៏លំបាកទាំងនេះ និង ក្នុងការបង្កឲ្យមានបរិយាកាសអំណោយផលមួយសម្រាប់ការធានាឲ្យមានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការធ្វើឲ្យសេដ្ឋកិច្ចកម្ពុជាមានកំណើនថេររង្វង់៧%ជាបន្តទៀត និង ការសម្រេចបាននូវវឌ្ឍនភាពក្នុងដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដែលស្តែងឡើងតាមរយៈលទ្ធផលរួមនៃដំណើរការអភិវឌ្ឍន៍ គឺការកាត់បន្ថយភាពក្រីក្រក្នុងល្បឿនមួយដែលធ្វើឲ្យសម្រេចបាននូវចំណុចដៅនៃគោលដៅទី១ របស់**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** មុនឆ្នាំ២០១៥ ព្រមទាំងចំណុចដៅជាច្រើនទៀតរបស់**គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា** ជាពិសេសកម្ពុជាត្រូវបានអង្គការសហប្រជាជាតិជ្រើសជាប្រទេសគំរូ ដែលសម្រេចបាន**គោលដៅ**

អភិវឌ្ឍន៍សហស្សវត្សរ៍ ភាគច្រើន។ លើពីនេះ រាជរដ្ឋាភិបាលកម្ពុជា ក៏បានធ្វើឲ្យកម្ពុជាទទួលបាននូវភាពរឹងមាំក្នុងការធ្វើសមាហរណកម្មខ្លួនចូលទៅក្នុងតំបន់និងពិភពលោក ហើយកំពុងដើរតួនាទីយ៉ាងសកម្មក្នុងកិច្ចដំណើរការប្រកបដោយជវភាពនេះ ក្នុងឋានៈជាសមាជិកស្មើភាពនិងស្មើសិទ្ធិលើឆាកអន្តរជាតិ។

ទោះជាដូច្នេះក្តី ការងារដែលយើងទាំងអស់គ្នាត្រូវបន្តយកចិត្តទុកដាក់ដោះស្រាយនោះគឺ ការកំណត់យុទ្ធសាស្ត្រនិងគោលនយោបាយ ឲ្យបានត្រឹមត្រូវនិងសមស្របតាមបរិការណ៍សង្គម-សេដ្ឋកិច្ចជាក់ស្តែងរបស់យើង និងការអនុវត្តយុទ្ធសាស្ត្រនិងគោលនយោបាយទាំងនោះ ប្រកបដោយភាពស័ក្តិសិទ្ធិសំដៅធានាឲ្យបាននូវ សន្តិសុខនិងសណ្តាប់ធ្នាប់សង្គមដែលជា បុព្វបទសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយចីរភាពនិងសមធម៌។ ក្នុងន័យនេះ វឌ្ឍនភាពត្រូវតែបានជំរុញឲ្យលឿនជាងមុន មានមូលដ្ឋានទូលាយជាងមុន និងមានសមត្ថភាពប្រកួតប្រជែងជាងមុន នៅក្នុងវិស័យជាច្រើន ហើយបញ្ហាប្រឈមទាំងឡាយដែលកំពុងមាននិងដែលមានពីមុន ត្រូវដោះស្រាយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នា។ កំណែទម្រង់ជាច្រើនក្នុងការងារអភិបាលកិច្ច ត្រូវតែជំរុញល្បឿនបន្ថែមទៀត ដែលក្នុងនោះរួមមាន ការប្រកាសចេញនិងការដាក់ឲ្យអនុវត្តច្បាប់ជាមូលដ្ឋាន ការបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តគោលនយោបាយក្នុងការផ្តល់ និងការគ្រប់គ្រងសម្បត្តិនិងសេវាសាធារណៈ ការលើកកម្ពស់សមត្ថភាពជំនាញ ការធ្វើឲ្យប្រសើរឡើងជាងមុននូវការសម្របសម្រួលក្នុងចំណោមក្រសួង ស្ថាប័នទាំងឡាយរបស់រាជរដ្ឋាភិបាល ក៏ដូចជា ការជំរុញឲ្យមានការកែលម្អវិមជ្ឈការនិងវិសហមជ្ឈការ ហើយការអភិវឌ្ឍន៍ចំណុចស្នូលក្នុងការគ្រប់គ្រងវិស័យសាធារណៈ ជាពិសេសទៅលើតំបន់ជនបទ គឺជាការងារចាំបាច់ដែលនឹងជួយប្រែក្លាយតំបន់ទាំងនោះឲ្យទៅជាមជ្ឈមណ្ឌលដែលមានការអភិវឌ្ឍលឿនជាងមុន សម្រាប់ជំរុញកំណើនសេដ្ឋកិច្ច ហើយដែលនឹងជួយផងដែរដល់ការកាត់បន្ថយភាពក្រីក្រដែលភាគច្រើននៅមានកម្រិតខ្ពស់នៅតំបន់នោះ។ ការបន្តលើកកម្ពស់បន្ថែមទៀតលើវិស័យសង្គមកិច្ច ជាពិសេស វិស័យអប់រំនិងសុខាភិបាល និង លើសមភាពយេនឌ័រ ជាប្រការដែលត្រូវយកចិត្តទុកដាក់ដោះស្រាយឲ្យបានច្រើនជាងមុន។

ជារួម នៅក្នុងឆ្នាំកន្លងទៅនេះ ពិភពលោកបានជួបប្រទះនឹងការផ្លាស់ប្តូរជាច្រើន ដែលពោរពេញទៅដោយភាពច្របូកច្របល់ ដែលបានកើតឡើងភ្លាមៗ ដោយពុំអាចដឹងមុនបាន ដូចជា ការចាកចេញរបស់អង់គ្លេសពីសហគមន៍អឺរ៉ុប និង គោលនយោបាយផ្លាស់ប្តូរភ្លាមៗរបស់សហរដ្ឋអាមេរិក។ ដំណើរវិវឌ្ឍទាំងនេះ ពិតជាបានធ្វើឲ្យប៉ះពាល់ជាអវិជ្ជមានដល់បណ្តាប្រទេសភាគច្រើននៅលើពិភពលោក ជាពិសេស វាបានបង្កជាផលប៉ះពាល់អវិជ្ជមានដល់ដំណើរការនៃការកាត់បន្ថយភាពក្រីក្រ និង កំណើនសេដ្ឋកិច្ចដែលបានខិតខំនិងចំណាយធនធានជាច្រើនទើបអាចសម្រេចបាននាពេលកន្លងមក។

ដោយសារកម្ពុជាបានធ្វើសមាហរណកម្មកាន់តែច្រើនឡើង នៅក្នុងតំបន់និងពិភពលោក ដូច្នេះយើងក៏បានទទួលផលប៉ះពាល់ពីព្រឹត្តិការណ៍ទាំងនេះដែរ ជាពិសេស កំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

ការវិវឌ្ឍដូចបានពោលពីខាងដើម មិនមែនគ្រាន់តែជាបញ្ហាចម្បងធំៗដែលត្រូវប្រឈមនៅពេលខាងមុខនោះទេ ប៉ុន្តែក៏ផ្តល់ផងដែរនូវកាលានុវត្តភាពដ៏មានតម្លៃសម្រាប់ការកែប្រែទ្រង់ទ្រាយមូលដ្ឋានសេដ្ឋកិច្ចកម្ពុជាមានការអភិវឌ្ឍប្រកបដោយចីរភាព ដោយមិនពឹងផ្អែកតែលើវិស័យពីរឬបី ដែលអាចងាយរងផលប៉ះពាល់។ ដូច្នេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្តោតការយកចិត្តទុកដាក់លើកំណើនប្រកបដោយបរិយាប័ន្ន ពីវិស័យបណ្តាវិស័យដែលនៅមានសក្តានុពលខ្ពស់ និង មិនទាន់ប្រើប្រាស់អស់លទ្ធភាពនៅឡើយ និងលើការអភិវឌ្ឍនៅតំបន់ជនបទសំដៅពង្រីកមូលដ្ឋានសេដ្ឋកិច្ច និងដើម្បីធ្វើឲ្យកំណើននេះមានចីរភាពក្នុងរយៈពេលវែងក៏ដូចជា ការកាត់បន្ថយភាពក្រីក្រដែលនៅមានកម្រិតខ្ពស់នៅតំបន់ជនបទឲ្យបានឆាប់រហ័ស។ លទ្ធផលនឹងត្រូវអាចទទួលបានភ្លាមៗ តាមរយៈការបង្កើនផលិតភាពកសិកម្ម និង ការបង្កើនចំណូលប្រជាជននៅតំបន់ជនបទ ។

ខ្ញុំមានសេចក្តីរីករាយនឹងដាក់ចេញនូវ **របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ស្តីពីការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨** ដែលក្តោបយកនូវការវិវឌ្ឍទាំងអស់ដែលបានកើតមានឡើងចាប់តាំងពីខែមករា ឆ្នាំ២០១៤មក តាមរបៀបមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងមានគុណភាពផ្អែកខ្លឹមសារដោយមិនលម្អៀងទៅផ្នែកណាមួយ។ ឯកសារនេះ បង្ហាញពីរូបភាពរួមនៃស្ថានភាពរបស់កម្ពុជាទាំងមូលក្នុងគ្រប់ទិដ្ឋភាពទាំងអស់ ហើយផ្តល់នូវការណែនាំសម្រាប់ការអនុវត្តនៅពេលខាងមុខ។ របាយការណ៍នេះបានសង្កត់ធ្ងន់លើការកាត់បន្ថយភាពក្រីក្រឲ្យបានឆាប់រហ័ស តាមរយៈគោលនយោបាយនិងសកម្មភាពគាំទ្រអ្នកក្រ។ ក្នុងន័យនេះ ទាមទារឲ្យមានកំណើនម៉ាក្រូសេដ្ឋកិច្ចរឹងមាំ ដែលមានមូលដ្ឋានទូលាយជាងមុន មានសមត្ថភាពប្រកួតប្រជែងជាងមុន ព្រមទាំងមានមូលដ្ឋានប្រកបដោយពិពិធភាពនៅតំបន់ជនបទ និង ដែលផ្អែកលើការបង្កើនផលិតភាពកសិកម្ម រួមគ្នាជាមួយនឹងការធ្វើឲ្យប្រសើរឡើងនូវការគ្រប់គ្រងដីធ្លីនិងការជំរុញការអភិវឌ្ឍជនបទ។ **របាយការណ៍ពាក់កណ្តាលអាណត្តិឆ្នាំ២០១៦ ស្តីពីការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨** គឺជាឯកសារមួយយ៉ាងសំខាន់ និងជារបៀបវារៈការងារមួយដែលសំដៅឆ្ពោះទៅរកសកម្មភាពសម្រាប់រយៈពេលដ៏ឆាប់ខាងមុខ។

ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវដល់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាលកម្ពុជា និងដៃគូអភិវឌ្ឍន៍របស់យើងទាំងអស់ ឲ្យផ្តោតការយកចិត្តទុកដាក់លើលទ្ធផលដោយលើកកម្ពស់ប្រសិទ្ធភាពធនធានអភិវឌ្ឍន៍ដ៏មានកម្រិត ទាំងពីប្រភពហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ ទាំងពីប្រភពថវិកាជាតិ។

ថ្ងៃច័ន្ទ ៣រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១

រាជធានីភ្នំពេញ ថ្ងៃទី០៥ ខែមីនា ឆ្នាំ២០១៨

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា





# ព័ត៌មានសង្ខេបសំខាន់ៗស្តីពីព្រះរាជាណាចក្រកម្ពុជា

| ព័ត៌មានទូទៅ | ឆ្នាំ២០១៦ |
|---|---|
| ផ្ទៃដីសរុប៖ គ.ម.$^2$ | ១៨១ ០៣៥ |
| ចំនួនរាជធានី | ១ |
| ចំនួនខេត្ត | ២៤ |
| ចំនួនក្រុង | ២៦ |
| ចំនួនស្រុក | ១៥៩ |
| ចំនួនខណ្ឌ | ១២ |
| ចំនួនឃុំ | ១ ៤០៦ |
| ចំនួនសង្កាត់ | ២២៧ |
| ចំនួនភូមិ | ១៤ ៥១៤ |
| ប្រជាជនសរុប៖ ការធ្វើចំណោលឆ្នាំ២០១៦(លាននាក់) | ១៥,៥ |
| ដង់ស៊ីតេប្រជាជន(ក្នុង១គ.ម.$^2$) | ៨៦,៨(២០១៦) |
| បុរសធៀបនឹងស្ត្រី(ស្ត្រី១០០នាក់) | ៩៤,៩ |
| ប្រជាជនអាយុ០-១៤(%នៃប្រជាជនសរុប) | ២៨,៧ |
| ប្រជាជនអាយុ១៥-៦៤(%នៃប្រជាជនសរុប) | ៦៦,១ |
| ប្រជាជនអាយុ៦៥ឆ្នាំឡើងទៅ(%នៃប្រជាជនសរុប) | ៥,១ |
| អត្រាកំណើនប្រចាំឆ្នាំ | ១,៤៤ |
| អត្រាបង្កើតកូនសរុប(ក្នុងស្ត្រីម្នាក់)(កំណើតរស់) | ២,៦(២០១៦) |
| អាយុកាលមធ្យមសង្ឃឹមរស់ពីកំណើត៖ | |
| *ប្រុស(ឆ្នាំ)* | ៦៧,៧ |
| *ស្ត្រី(ឆ្នាំ)* | ៧១,៨ |
| ចំនួនគ្រួសារ | ៣ ២៨៨ ០៦៩ |
| ចំនួនគ្រួសារជាមធ្យម | ៤,៦ |
| អត្រាប្រជាជនក្នុងបន្ទុក | ៥១,២ |
| អត្រាផ្លាស់ទីលំនៅនៃប្រជាជនសរុប | ២៨,៩ |
| អត្រាប្រជាជនរស់នៅទីប្រជុំជន | ២១,៤ |
| អត្រាកំណើនប្រជាជនរស់នៅទីប្រជុំជន | ៣,៧១ |
| ឆ្នាំសារពើពន្ធ | មករា-ធ្នូ |
| រូបិយវត្ថុ | រៀល(៛) |

# មាតិកា


| | ទំព័រ |
|---|---|
| **អារម្ភកថា** | i |
| **សញ្ញាជាតិនិងទង់ជាតិនៃព្រះរាជាណាចក្រកម្ពុជា** | iv |
| **គំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣** | v |
| **ព័ត៌មានសង្ខេបសំខាន់ៗស្តីពីព្រះរាជាណាចក្រកម្ពុជា** | vi |
| **មាតិកា** | vii |
| **បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ** | ix |
| **ខ្លឹមសារសង្ខេប** | xii |
| **ជំពូកទី១ សេចក្តីផ្តើម** | **១** |
| ១. ការអភិវឌ្ឍដោយមានផែនការចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០ | ១ |
| ២. យុទ្ធសាស្ត្រចតុកោណ | ៣ |
| ៣. គោលបំណងនៃការវាយតម្លៃពាក់កណ្តាលអាណត្តិ ឆ្នាំ២០១៦ ស្តីពីការអនុវត្ត ផយអជ ២០១៤-២០១៨ | ៤ |
| ៤. វិធីសាស្ត្រ | ៦ |
| ៥. ទម្រង់នៃរបាយការណ៍ | ៧ |
| **ជំពូកទី២ ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចកម្ពុជា** | **៨** |
| ១. សេចក្តីផ្តើម | ៨ |
| ២. អត្រាកំណើននៃផលិតផលក្នុងស្រុកសរុប(ផ.ស.ស.) | ៨ |
| ៣. ចំណូលនិងចំណាយថវិការដ្ឋ និងអតិផរណា | ១៤ |
| ៤. ភាពបើកចំហនៃសេដ្ឋកិច្ច | ១៧ |
| ៥. ជញ្ជីងទូទាត់កម្ពុជា | ១៨ |
| ៦. ភាពក្រីក្រនិងការងារ | ១៩ |
| ៧. សេចក្តីសន្និដ្ឋាន | ២០ |
| **ជំពូកទី៣ សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងអភិបាលកិច្ចនិងវិស័យសំខាន់ៗ** | **២២** |
| ១. សេចក្តីផ្តើម | ២២ |

២. អភិបាលកិច្ចល្អ៖ ស្នូលនៃយុទ្ធសាស្រ្តចតុកោណ ២២

៣. បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្រ្តចតុកោណទាំងមូល ៣៨

៤. ការលើកស្ទួយវិស័យកសិកម្ម ៥២

៥. ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ៧៥

៦. ការអភិវឌ្ឍវិស័យឯកជននិងការងារ ៩៣

៧. ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស ១០៦

៨. សេចក្តីសន្និដ្ឋានរួមស្តីពីសមិទ្ធផលនិងបញ្ហាប្រឈម ១៣២

**ជំពូកទី៤ ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ** **១៣៤**

១. សេចក្តីផ្តើម ១៣៤

២. សមិទ្ធផលសំខាន់ៗ ១៣៤

៣. បញ្ហាប្រឈម ១៣៦

៤. ដំណោះស្រាយ ១៣៨

៥. សកម្មភាពដែលត្រូវអនុវត្ត ១៣៩

៦. សេចក្តីសន្និដ្ឋាន ១៤១

**ជំពូកទី៥ ការងារដែលត្រូវអនុវត្តបន្តដល់ឆ្នាំ២០១៨និង តទៅមុខទៀត** **១៥៣**

១. សេចក្តីផ្តើម ១៥៣

២. បញ្ហាប្រឈមសំខាន់ៗ និងសំណើរដោះស្រាយ ១៥៣

៣. តម្លៃដែលត្រូវចំណាយ ធនធាន និង ការកំណត់កម្មវិធីចំណាយ ១៦៩

៤. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ១៧០

៣. សេចក្តីសន្និដ្ឋាន ១៧១

# បញ្ជីនៃតារាង រូបភាព ប្រអប់ និងឧបសម្ព័ន្ធ

## តារាង



| | | |
|---|---|---|
| តារាង ២.១ | ចំណែកវិស័យកសិកម្ម ឧស្សាហកម្ម និង សេវាកម្ម ក្នុង ផ.ស.ស. (គិតភាគរយ) | ១០ |
| តារាង ២.២ | កំណើន ផ.ស.ស. ពីឆ្នាំ២០១៣-២០១៨ | |
| តារាង ២.៣ | ការប៉ាន់ស្មានពីភាពក្រីក្រផ្អែកតាម អ.ស.ស.ក. ២០០៤ ២០០៧ និង ការព្យាករ ឆ្នាំ២០១០ | ១៦ |
| តារាង៣.១ | ប្រាក់បៀវត្សអប្បរមារបស់មន្ត្រីរាជការ | ៣០ |
| តារាង៣.២ | វឌ្ឍនភាពនៃស្នូលយុទ្ធសាស្ត្រចតុកោណ៖ អភិបាលកិច្ចល្អ | ៣៧ |
| តារាង៣.៣ | សូចនាករសំខាន់ៗក្នុងវិស័យធម្មការនិងសាសនា | ៤០ |
| តារាង៣.៤ | វឌ្ឍនភាពនៃសូចនាករស្តីពីភាពជាដៃគូក្នុងការអភិវឌ្ឍ | ៤៦ |
| តារាង៣.៥ | ផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ ២០១២-២០១៦ | ៥៤ |
| តារាង៣.៦ | ផ្ទៃដីកៅស៊ូ ឆ្នាំ២០១៤-២០១៥ | ៥៨ |
| តារាង៣.៧ | សូចនាករស្តីពីគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | ៦១ |
| តារាង៣.៨ | សូចនាករសំខាន់ៗរបស់ក្រសួងអភិវឌ្ឍន៍ជនបទ | ៧២ |
| តារាង៣.៩ | វឌ្ឍនភាពរបស់មុំទី១ នៃយុទ្ធសាស្ត្រចតុកោណ៖ ការលើកកម្ពស់វិស័យកសិកម្ម | ៧៤ |
| តារាង៣.១០ | ចំណាក់ថ្នាក់ផ្លូវ | ៧៦ |
| តារាង៣.១១ | លទ្ធភាពស្រោចស្រពប្រចាំឆ្នាំ | ៨១ |
| តារាង៣.១២ | ការជួសជុល ថែទាំសំណង់សិល្បការតាមឆ្នាំ | ៨២ |
| តារាង៣.១៣ | ចំនួនសហគមន៍កសិករប្រើប្រាស់ទឹកតាមឆ្នាំ | ៨២ |
| តារាង៣.១៤ | ការទប់ស្កាត់ទឹកជំនន់តាមឆ្នាំ | ៨៣ |
| តារាង៣.១៥ | ការទប់ស្កាត់ទឹកប្រៃតាមឆ្នាំ | ៨៣ |
| តារាង៣.១៦ | ផ្ទៃដីស្រូវសង្គ្រោះបានតាមឆ្នាំ | ៨៤ |
| តារាង៣.១៧ | ផ្ទៃដីស្រូវដែលបង្ហូរសង្គ្រោះតាមឆ្នាំ | ៨៤ |
| តារាង៣.១៨ | ចំនួនស្ថានីយបូមទឹកនិងម៉ាស៊ីនបូមទឹកដែលបានសាងសង់និងជួសជុល | ៨៤ |
| តារាង៣.១៩ | ទិន្នន័យនៃប្រភពអគ្គិសនីផ្សេងៗដែលផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅកម្ពុជា | ៨៨ |
| តារាង៣.២០ | ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង និង ប្រព័ន្ធចែកចាយអគ្គិសនី | ៨៩ |
| តារាង៣.២១ | សូចនាករស្តីពីអត្រាអ្នកប្រើប្រាស់ | ៩០ |
| តារាង៣.២២ | ទិន្នន័យស្តីពីការប្រើប្រាស់សេវាទូរគមនាគមន៍ | ៩១ |
| តារាង៣.២៣ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធឺណិត | ៩១ |

| | | |
|---|---|---|
| តារាង៣.២៤ | ការទទួលបានព័ត៌មានសាធារណៈ | ៩២ |
| តារាង៣.២៥ | សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម | ៩៦ |
| តារាង៣.២៦ | សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗក្នុងវិស័យអប់រំ យុវជន និង កីឡា | ១០៧ |
| តារាង៣.២៧ | សូចនាករសំខាន់ៗក្នុងវិស័យសុខាភិបាល | ១១៥ |
| តារាង៣.២៨ | វឌ្ឍនភាពរបស់មុំទី៤នៃយុទ្ធសាស្ត្រចតុកោណ៖ ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស | ១៣១ |
| តារាង៤.១ | សូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនៃរបាយការណ៍ពាក់កណ្ដាលអាណត្តិនៃការអនុវត្ត ផយអជ ២០១៤-២០១៨ | ១៤២ |
| **រូបភាព** | | |
| រូបភាព១.១ | គំនូសបំព្រួញនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ | |
| រូបភាព២.១ | អត្រាកំណើនក្នុង ផ.ស.ស. ត្រូវបានវាស់វែងប្រចាំឆ្នាំ ២០១០-២០១៨ | ១០ |
| រូបភាព២.២ | ផ.ស.ស. សម្រាប់ប្រជាជនម្នាក់ (គិតជាដុល្លារអាមេរិក) ២០១៣-២០១៧ | ១០ |
| រូបភាព៣.១ | ផលិតកម្មស្រូវនៅរដូវប្រាំងនិងរដូវវស្សា ឆ្នាំ២០១២-២០១៦ | ៥៥ |
| រូបភាព៣.២ | កំណើនសហគមន៍កសិកម្ម | ៥៦ |
| រូបភាព៣.៣ | ផលិតកម្មនិងការនាំចេញកៅស៊ូ | ៥៩ |
| រូបភាព៣.៤ | ស្ថានភាពជើងហោះហើរក្នុងស្រុកនិងអន្តរជាតិឆ្នាំ២០១៥ | ៨០ |
| **ឧបសម្ព័ន្ធ** | | |
| ឧបសម្ព័ន្ធទី១ | សូចនាករបន្ថែមសម្រាប់របាយការណ៍ពាក់កណ្ដាលអាណត្តិនៃការអនុវត្ត *ផ.យ.អ.ជ. ២០១៤-២០១៨* | ១៧៣ |
| ឧបសម្ព័ន្ធទី២ | ពាក្យបំព្រួញ | ១៨៣ |
| ឧបសម្ព័ន្ធទី៣ | គេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា | ១៨៥ |

# ជំពូកទី១

# សេចក្តីផ្តើម

## ១- ការអភិវឌ្ឍដោយមានផែនការចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០

១.១- រាជរដ្ឋាភិបាលកម្ពុជាបានធ្វើឲ្យមានការអភិវឌ្ឍដោយមានផែនការក្នុងក្របខ័ណ្ឌសេដ្ឋកិច្ចទីផ្សារ ចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៩០មក ដោយបានខិតខំប្រឹងប្រែងពុះពារនឹងបញ្ហាប្រឈមធំៗជាច្រើនក្នុងការបង្កើតឡើងនូវបុរេលក្ខខណ្ឌសម្រាប់ការស្តារឡើងវិញនូវសេដ្ឋកិច្ច ដែលត្រូវបានបំផ្លិចបំផ្លាញដោយសារសង្គ្រាមចាប់តាំងពីទសវត្សរ៍ឆ្នាំ១៩៧០និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ចសំដៅធ្វើឲ្យសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រនិងការធ្វើឲ្យសម្រេចបាននូវ*គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា(គ.អ.ស.ក.)*។

១.២- *ផែនការ៥ឆ្នាំចំនួនពីរលើក* ដែលមានឈ្មោះថា*ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច(ផ.អ.ស.ស.) លើកទី១* និង *លើកទី២* ត្រូវបានអនុវត្តនៅក្នុងអំឡុងឆ្នាំ១៩៩៦-២០០០និងអំឡុងឆ្នាំ២០០១-២០០៥ ដែលគោលដៅចម្បងស្ទើរតែទាំងអស់របស់ផែនការទាំងពីរនេះត្រូវបានសម្រេចបានដោយជោគជ័យ។ នៅក្នុងរយៈពេលនៃការអនុវត្តផែនការនេះរហូតដល់ឆ្នាំ២០០៨ កំណើនមធ្យមប្រចាំឆ្នាំនៃ*ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)*មានកម្រិតពី៧%ទៅ៨%។ *ផែនការ៥ឆ្នាំលើកទី៣* ដែលមានអាណត្តិកាលពីឆ្នាំ២០០៦-២០១០ មានឈ្មោះថា*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.)*ត្រូវបានបញ្ចប់នាឆ្នាំ២០០៨ មុនកាលកំណត់ដើម្បីបង្កលក្ខណៈដល់ការរៀបចំផែនការថ្មីមួយ ដែលមានអាណត្តិកាលស្របគ្នានឹងនីតិកាលរបស់រដ្ឋសភា។ ផែនការថ្មីដែលមានឈ្មោះថា *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣(ផ.យ.អ.ជ. បច្ចុប្បន្នកម្ម)* ត្រូវបានរៀបចំឡើងដើម្បីធ្វើជាផែនទីចង្អុលផ្លូវមួយសម្រាប់អនុវត្តបណ្តាគោលនយោបាយដែលជួយធ្វើឲ្យសម្រេចនូវគោលដៅនិងចំណុចដៅទាំងឡាយរបស់ *យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២* និង *គ.អ.ស.ក.*។ *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣* ក៏បានគិតគូរដោះស្រាយផងដែរនូវផលវិបាកនានាដែលបានកើតចេញពីវិបត្តិហិរញ្ញវត្ថុសកលលោកនិងការធ្លាក់ចុះផ្នែកសេដ្ឋកិច្ចសកលលោក ដោយហេតុថាព្រះរាជាណាចក្រកម្ពុជា ដែលជាប្រទេសមានសេដ្ឋកិច្ចតូចបើកទូលាយពិតជាមិនអាចរួចចាកផុតពីភាពងាយរងគ្រោះពីផលប៉ះពាល់នៃវិបត្តិពីខាងក្រៅនេះទេ។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំ *ផ.យ.អ.ជ.* ថ្មី *២០១៤-២០១៨* ដែលជាផែនទីចង្អុលផ្លូវមួយសម្រាប់អនុវត្តបណ្តាគោលនយោបាយ និងដើម្បីសម្រេចបាននូវគោលដៅនិងចំណុចដៅទាំងឡាយរបស់*យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣* និង ឆ្ពោះទៅសម្រេចឲ្យបានជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់។ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្ត ដំណើរការនៃចូលរួមដ៏ទូលំទូលាយនិងគ្រប់ជ្រុងជ្រោយពីអ្នកមានចំណែកពាក់ព័ន្ធនានា ក្នុងការរៀបចំ *ផ.យ.អ.ជ. ២០១៤-២០១៨* ហើយ ឯកសារនេះត្រូវបានអនុម័តដោយស្ថាប័ននីតិប្រតិបត្តិនិងស្ថាប័ននីតិប្បញ្ញត្តិទាំងពីរ( *រាជរដ្ឋាភិបាលកម្ពុជា រដ្ឋសភា ព្រឹទ្ធសភា*) និងត្រូវបានប្រកាសឲ្យប្រើដោយព្រះរាជក្រម ចុះថ្ងៃទី១៧ ខែ

កក្កដា ឆ្នាំ២០១៤។ ឯកសារនេះបានគូសបញ្ជាក់ថាប្រទេសជាតិទាំងមូលបានដាក់ចេញនូវគោលដៅច្បាស់លាស់និងសមស្របសម្រាប់ខ្លួនឯង។

១.៣- *ផ.យ.អ.ជ. ២០១៤-២០១៨* ត្រូវបានរៀបចំឡើងដោយផ្អែកលើ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* របស់រាជរដ្ឋាភិបាលកម្ពុជា ដែលនឹងត្រូវអត្ថាធិប្បាយនៅផ្នែកខាងក្រោម។ ផែនការនេះ តំណាងឲ្យការឯកភាពគ្នាដ៏ទូលំទូលាយមួយលើការអភិវឌ្ឍកម្ពុជាក្នុងពេលអនាគតនិងលើអាទិភាពនិងបំណងប្រាថ្នាទាំងឡាយរបស់ប្រជាជនកម្ពុជាភាគច្រើន។ ក្នុងនាមជាឯកសាររស់និងឯកសារដែលផ្ដោតលើសកម្មភាព *ផ.យ.អ.ជ.* បានកំណត់អាទិភាពនិងចំណុចដៅទាំងឡាយដែលមានលក្ខណៈប្រាកដនិយម ពោលគឺអាទិភាពនិងចំណុចដៅទាំងឡាយដែលអាចអនុវត្តនិងអាចសម្រេចបាននៅក្នុង អាណត្តិកាលនៃផែនការនេះ។

១.៤- ជំពូកទី៦នៃ *ផ.យ.អ.ជ. ២០១៤-២០១៨* បានគូសបញ្ជាក់ថាការតាមដានត្រួតពិនិត្យនិងការវាយតម្លៃលើការអនុវត្តសកម្មភាពនានាដែលត្រូវបានលើកឡើងនៅក្នុងផែនការនេះត្រូវធ្វើឡើង ដោយទៀងទាត់ដើម្បីធ្វើការកែសម្រួលវិធានការគោលនយោបាយមួយចំនួនឲ្យបានសមស្របនា ពេលពាក់កណ្ដាលអាណត្តិ សំដៅធ្វើឲ្យសម្រេចបាននូវគោលដៅនិងចំណុចដៅរបស់ផែនការនិងដើម្បីធ្វើការកែតម្រូវនានាដែលចាំបាច់សម្រាប់ការសម្របខ្លួនទៅនឹងស្ថានភាពជាក់ស្ដែងដែលកំពុងកើតមាននៅក្នុង បរិស្ថានជាតិនិងអន្តរជាតិ។ ដោយផ្អែកលើដំណាក់កាលនៃ *ផ.យ.អ.ជ.* ឥឡូវនេះ គឺជាពេលវេលាដែលត្រូវធ្វើការវាយតម្លៃលើស្ថានភាពរួមនៃការអនុវត្តផែនការនៅក្នុងរយៈពេល២-៣ឆ្នាំចុងក្រោយនេះ។

១.៥- របាយការណ៍នេះ គឺ *របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០១៦ស្ដីពីការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨* ។ ក្រសួងផែនការបានរៀបចំរបាយការណ៍នេះដោយមានកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយនឹងក្រសួងនិងស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីពិនិត្យមើលឡើងវិញនូវវឌ្ឍនភាពដែលមានមកទល់ពេលនេះ ក្នុងការធ្វើឲ្យសម្រេចបាននូវចំណុចដៅនានារបស់ផែនការតាមរយៈការអនុវត្តនូវយុទ្ធសាស្ត្រទាំងឡាយដែលត្រូវបានកំណត់សម្រាប់ការអភិវឌ្ឍវិស័យនិងអន្តរវិស័យ។ របាយការណ៍នេះ ក៏បានដាក់ចេញផងដែរនូវអនុសាសន៍ជាក់លាក់មួយចំនួនដើម្បីណែនាំពីការអនុវត្ត *ផ.យ.អ.ជ. ២០១៦-២០១៨* នៅក្នុងពាក់កណ្ដាលអាណត្តិបន្ទាប់ សំដៅធ្វើឲ្យប្រសើរឡើងនូវដំណើរការសេដ្ឋកិច្ចនិងជីវភាពរស់នៅរបស់ប្រជាជន។ លើសពីនេះទៀត *របាយការណ៍ពាក់កណ្ដាលអាណត្តិ* គឺជាផែនទីបង្ហាញផ្លូវមួយសម្រាប់រាជរដ្ឋាភិបាលកម្ពុជានិងអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់យកទៅប្រើប្រាស់ក្នុងដំណើរការនៃការរៀបចំផែនការអភិវឌ្ឍន៍ជាតិថ្មីបន្ទាប់ពីផែនការបច្ចុប្បន្ននេះ។ របាយការណ៍នេះត្រូវរៀបចំឡើងដើម្បីតាមដានត្រួតពិនិត្យនូវលទ្ធផលនិងផលប៉ះពាល់កម្រិតជាតិដែលបានកើតឡើងពីការអនុវត្ត *ផ.យ.អ.ជ. ហើយដើម្បីឆ្លើយតបទៅនឹងគោលបំណងនេះ* អគ្គនាយកដ្ឋានផែនការនៃក្រសួងផែនការ ត្រូវបាន

ទទួលការចាត់តាំងឲ្យដឹកនាំដំណើរការនៃការរៀបចំរបាយការណ៍នេះដោយធ្វើកិច្ចសម្របសម្រួល នូវរាល់ការងារពាក់ព័ន្ធទាំងឡាយជាមួយនឹងក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា។

## ២- យុទ្ធសាស្ត្រចតុកោណ

១.៦- *យុទ្ធសាស្ត្រចតុកោណ* គឺជាសំណុំរួមនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍នៅកម្ពុជានៅក្នុង រយៈពេលប៉ុន្មានឆ្នាំមុននេះ ហើយ *ផ.យ.អ.ជ. ២០១៤-២០១៨* ត្រូវបានរៀបចំឡើងស្របទៅតាមទម្រង់របស់យុទ្ធសាស្ត្រចតុកោណនេះ។ រាជរដ្ឋាភិបាលកម្ពុជាបានប្រកាសផ្សព្វផ្សាយ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* របស់ខ្លួនកាលពីខែកញ្ញា ឆ្នាំ២០១៣ ដែលជារបៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ចនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៥នៃរដ្ឋសភា(២០១៣-២០១៨)។ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាបានបង្ហាញនូវយុទ្ធសាស្ត្រនេះដល់រាជរដ្ឋាភិបាលថ្មីនិងបានបញ្ជាក់ថាកម្មវិធីនយោបាយនេះត្រូវបានគាត់តែងឡើងនិងអនុម័តតាមរយៈការវាយតម្លៃលទ្ធផលការងារដែលត្រូវបានអនុវត្តក្នុងនីតិកាលទី៣និងដោយផ្អែកលើឆន្ទៈនិងបំណងប្រាថ្នារបស់ប្រជាជន បរិការណ៍ជាតិនិងអន្តរជាតិ និងការធ្វើអាទិភាវូបនីយកម្មនូវបណ្តាយុទ្ធសាស្ត្រសម្រាប់វិស័យសំខាន់ៗ។ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* គឺជាឯកសារដែលត្រូវបានរៀបចំឡើងតាមរយៈការធ្វើបច្ចុប្បន្នកម្មនិងការសម្រិតសម្រាំងសម្រួចបន្ថែមលើយុទ្ធសាស្ត្រមុន(*យុទ្ធសាស្ត្រចតុកោណ*)សំដៅធ្វើឲ្យលេចចេញជាកញ្ចប់អាទិភាពតាមវិស័យសំខាន់នានាដែលមានលក្ខណៈជាប្រព័ន្ធស៊ីចង្វាក់ប្រទាក់ក្រឡាគ្នានិងយោងគ្នាទៅវិញទៅមក[១]។

១.៧- នៅក្នុងរូបបំប្រួញនៃយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ បានបង្ហាញពីការដាក់ចេញនូវយុទ្ធសាស្ត្រគន្លឹះ៤យ៉ាង សម្រាប់បន្តជំរុញដំណើរការគោលដៅអភិវឌ្ឍន៍របស់កម្ពុជា៖

- *ទី១* ធានាឲ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ៧% ប្រកបដោយចីរភាព បរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ តាមរយៈការធ្វើពិពិធកម្មនៃមូលដ្ឋានសេដ្ឋកិច្ចឲ្យបានទូលាយ និងមានសមត្ថភាពប្រកួតប្រជែងជាងមុន ក្នុងបរិការណ៍អតិផរណាមានកម្រិតទាបអាចគ្រប់គ្រងបាន អត្រាប្តូរប្រាក់មានស្ថិរភាព និងទុនបម្រុងមានកំណើនជាប្រចាំ។
- *ទី២* បង្កើតការងារឲ្យបានកាន់តែច្រើនឡើងជូនដល់ប្រជាជន ជាពិសេស សម្រាប់ស្រទាប់យុវជន តាមរយៈការបន្តខិតខំកែលម្អនិងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងការទាក់ទាញ និងការជំរុញលើកទឹកចិត្តដល់សកម្មភាពវិនិយោគទាំងវិនិយោគក្នុងប្រទេស ទាំងវិនិយោគមកពីក្រៅប្រទេស។
- *ទី៣* សម្រេចឲ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង១%ក្នុងមួយឆ្នាំ ក៏ដូចជាគោលដៅផ្សេងៗទៀត ដែលត្រូវបានកំណត់ក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងលើការអភិវឌ្ឍធនធានមនុស្ស ការគ្រប់គ្រងបរិស្ថាន និងការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាព។

---

[១] *ផ.យ.អ.ជ. បច្ចុប្បន្នកម្ម២០០៩-២០១៣ ទំព័រទី៣*

*ទី៤* បន្តពង្រឹងសមត្ថភាពនិងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ ទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ ដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃសេវាសាធារណៈ សំដៅបម្រើប្រជាជនឲ្យកាន់តែប្រសើរឡើង។

យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ មានភាពប្រទាក់ក្រឡាជាមួយគ្នា សម្រាប់ធ្វើឲ្យសម្រេចបាននូវផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមកិច្ចរយៈមធ្យម។

១.៨- សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានថ្លែងថា រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់នូវភាពចាំបាច់នៃការធានាសង្គតិភាពនៃឋានានុក្រម តួនាទី ខ្លឹមសារ និងភាពលំដាប់លំដោយរវាង *យុទ្ធសាស្ត្រចតុកោណ ផ.យ.អ.ជ.* និង យុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ព្រមទាំងឯកសារគោលនយោបាយដទៃទៀតដូចជា កម្មវិធីវិនិយោគនិងផែនការថវិកាជាដើម។ ប្រការនេះតម្រូវឲ្យរាជរដ្ឋាភិបាលកម្ពុជា ពិនិត្យមើលឡើងវិញនូវសង្គតិភាពនៃអាណត្តិកាលរបស់ *ផ.យ.អ.ជ.* ជាមួយនឹង *កម្មវិធីនយោបាយ* របស់ខ្លួន ដែលមាន *យុទ្ធសាស្ត្រចតុកោណ* ជា *របៀបវារៈគោលនយោបាយសង្គម សេដ្ឋកិច្ច*។ ដើម្បីធានានូវសង្គតិភាពនៃឯកសារគោលនយោបាយសំខាន់ៗរបស់រាជរដ្ឋាភិបាលកម្ពុជា សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន បានសង្កត់ធ្ងន់ថា *យុទ្ធសាស្ត្រនេះ* នឹងត្រូវបានអនុវត្តតាមរយៈ *ផ.យ.អ.ជ.*។ *ផ.យ.អ.ជ. ២០១៤-២០១៨* គឺជាឯកសារដែលត្រូវបានរៀបចំឡើងដោយផ្អែកលើ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣*។

## ៣- គោលបំណងនៃរបាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០១៦ស្ដីពីការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

១.៩- គោលបំណងសំខាន់នៃការវាយតម្លៃពាក់កណ្ដាលអាណត្តិនេះ គឺ៖

- វាយតម្លៃភាពពាក់ព័ន្ធនៃផ.យ.អ.ជ. ២០១៤-២០១៨ ដែលនៅក្នុងគោលបំណងនយោបាយនិងផែនការអាទិភាពដែលកំពុងត្រូវបានអនុវត្តដោយក្រសួងស្ថាប័ននានា និង អ្នកពាក់ព័ន្ធផ្សេងទៀត និង ពិនិត្យឡើងវិញផងដែរ (ដល់វិសាលភាពដែលអាចធ្វើបាន) តាមតម្រូវការអ្នកទទួលផល (ឧទាហរណ៍ ដូចជា ភាពជាម្ចាស់ និង សង្គតិភាព និង ការតម្រឹមតម្រង់)។
- វាយតម្លៃលទ្ធផលនិងវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ នៅក្នុងលក្ខខណ្ឌប្រសិទ្ធភាព (លទ្ធផលដែលសម្រេចបានធៀបនឹងលទ្ធផលដែលបានគ្រោងទុក) និងប្រសិទ្ធភាពនៃការអនុវត្ត (លទ្ធផលលទ្ធផលសម្រេចបាន ទល់នឹង ថវិកានិងធាតុចូលត្រូវបានប្រើ)។
- វាយតម្លៃសិទ្ធភាពនៅក្នុងរៀបចំ ផែនការ វិសាលភាព ការអនុវត្តនិងការគ្រប់គ្រងដោយមានការសន្និដ្ឋានអំពីលទ្ធភាពដែល ផ.យ.អ.ជ នេះនឹងបានសម្រេចផលប៉ះពាល់ដែលបានរំពឹងទុកនៅចុងបញ្ចប់នៃអាណត្តិ (ឆ្នាំ ២០១៨) នេះ។
- វាយតម្លៃនិរន្តរភាពនៃលទ្ធផលកម្មវិធីលើសពីការបញ្ចប់នៃវដ្តការធ្វើផែនការនាពេលបច្ចុប្បន្ន។
- ផ្តល់អនុសាសន៍ទាក់ទងនឹងការកែប្រែណាមួយឬការផ្លាស់ប្តូរតម្រូវឲ្យមាននៅក្នុងធ្វើផែនការ, ការគ្រប់គ្រង និងការអនុវត្ត ផ.យ.អ.ជ សម្រាប់រយៈពេលដែលនៅសល់ពាក់កណ្ដាលអាណត្តិ។

- ផ្តល់អនុសាសន៍សម្រាប់ការចូលរួមបន្ថែមទៀតជាមួយស្ថាប័នមិនមែនរដ្ឋាភិបាល (ឧទាហរណ៍ អង្គការសង្គមស៊ីវិល និងដៃគូរវាងវិស័យសាធារណៈនិងឯកជន) ក្នុងការអនុវត្តក្នុងអំឡុងពេលនៅសល់នៃអាណត្តិរបស់ ផ.យ.អ.ជ។

១.១០- ទិសដៅចម្បងៗរបស់របាយការណ៍ពាក់កណ្តាលអាណត្តិនេះគឺៈ

*១- ការអភិវឌ្ឍម៉ាក្រូសេដ្ឋកិច្ច* ផ្នែកនេះធ្វើការវាយតម្លៃពីដំណើរការរបស់សេដ្ឋកិច្ចនៅក្នុងកម្រិតម៉ាក្រូនូវកម្រិតប៉ាន់ស្មានរួម ធ្វើការវាយតម្លៃពីដំណើរការនិងបញ្ហានានានៅក្នុងពាណិជ្ជកម្មអន្តរជាតិ ធ្វើការវាស់វែងនូវទំហំនៃការគាំទ្រនៅក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (បំណុល ជំនួយឥតសំណង ជំនួយបច្ចេកទេស) និងធ្វើការពិនិត្យមើលពីស្ថានភាពហិរញ្ញវត្ថុ និងអត្រាប្តូរប្រាក់។

*២- អភិបាលកិច្ចល្អនិងបរិស្ថានអំណោយផល* ផ្នែកនេះរួមបញ្ចូលនូវកម្មវិធីកំណែទម្រង់សំខាន់ៗទាំងអស់ និងបរិស្ថានចាំបាច់ទាំងឡាយដែលអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រ។

*៣- វឌ្ឍនភាពតាមវិស័យ* ផ្នែកនេះបង្ហាញពីការវាយតម្លៃពីវឌ្ឍនភាពដែលបានកើតមានឡើងនៅក្នុងវិស័យមួយចំនួន រួមមាន វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជន និងការងារ និង ការអភិវឌ្ឍធនធានមនុស្ស ។

*៤- ស្ថានភាពនៃការងារអន្តរវិស័យ* ផ្នែកនេះអត្ថាធិប្បាយពីការវាយតម្លៃពីវឌ្ឍនភាពដែលបានកើតមានឡើងនៅក្នុងការងារអន្តរវិស័យមួយចំនួនដូចជា សមធម៌យេនឌ័រ បញ្ហាកុមារ ការអភិវឌ្ឍបែបវិមជ្ឈការនិងវិសហមជ្ឈការ ការអភិវឌ្ឍជនបទ ប្រជាជនដែលស្ថិតក្រោមខ្សែបន្ទាត់ភាពក្រីក្រ និងបញ្ហានានាដែលពាក់ព័ន្ធ(រួមទាំងការបែងចែកចំណូល) បញ្ហាប្រជាជន ការប្រើប្រាស់កម្លាំងពលកម្ម និងបរិស្ថាន(ទឹក ព្រៃឈើ ខ្យល់) និង បម្រែបម្រួលអាកាសធាតុ។

*៥- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ* ផ្នែកនេះបង្ហាញពីការវាយតម្លៃវឌ្ឍនភាព គ.អ.ស.ក ២០១៥។ បង្ហាញពីការវាយតម្លៃពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅក្នុងប្រទេសដោយមានការស្នើឡើងនូវជម្រើសដែលអាចធ្វើបាននៅក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រព័ន្ធនេះផងដែរ ជាពិសេស ការបន្តអនុវត្តពី គ.អ.ស.ក ទៅ*គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់កម្ពុជា(គ.អ.ច.ក)* សម្រាប់ឆ្នាំ ២០១៦-២០៣០។

*៦- តម្លៃដែលត្រូវចំណាយ ធនធាន និងការរៀបចំផែនការសម្រាប់ចំណាយធនធាន* ផ្នែកនេះលើកឡើង ពីការប៉ាន់ស្មានវាយតម្លៃពីតម្រូវការនិងទំហំនៃការប្រើប្រាស់ធនធានសម្រាប់អនុវត្តកម្មវិធីនានា (ការប៉ាន់ស្មានវាយតម្លៃជារួមដោយមិនធ្វើការបែងចែកតាមវិស័យ)។ ការប៉ាន់ស្មានវាយតម្លៃពី *ហិរញ្ញ*

*ឬទានសហប្រតិបត្តិការអភិវឌ្ឍន៍*និងការប្រើប្រាស់ធនធាននេះនឹងត្រូវអត្ថាធិប្បាយផងដែរ នៅក្នុងផ្នែកនេះ។

## ៤- វិធីសាស្ត្រ

១.១១- *របាយការណ៍ពាក់កណ្ដាលអាណត្តិឆ្នាំ២០១៦ស្ដីពីការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨* នេះនឹងធ្វើការវាយតម្លៃវឌ្ឍនភាពនៃការសម្រេចបានក្នុងការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨ យុទ្ធសាស្ត្រតាមវិស័យនានា ដោយពិនិត្យមើល ការសម្រេចបានគោលដៅអាទិភាព ចំណុចដៅនានា ដែលបានកំណត់នៅក្នុង *ក្របខ័ណ្ឌតាមដានត្រួតពិនិត្យនិងវាយតម្លៃ ផ.យ.អ.ជ. ២០១៤-២០១៨* ដោយផ្អែកលើប្រភពទិន្នន័យដែលមានថ្មីៗ។

១.១២- របាយការណ៍នេះ គឺមិនខុសពីរបាយការណ៍វាយតម្លៃមុនៗទេ គឺនឹងធ្វើការវាស់វែងផងដែរពីការអនុវត្តនៅកម្រិតម៉ាក្រូ។ *ផ.យ.អ.ជ. ២០១៤-២០១៨* បានកំណត់សូចនាករតាមដានស្នូលព្រមទាំងសូចនាករបន្ថែមទៀត។ គោលបំណងចម្បង របាយការណ៍ពាក់កណ្ដាលអាណត្តិ គឺដើម្បីវាយតម្លៃពី***លទ្ធផល*** និង***ផលប៉ះពាល់*** នៃផែនការ។ របាយការណ៍នេះ មិនបានបង្ហាញជាក់លាក់អំពី "ធាតុចូល" (ឧទាហរណ៍ ការចំណាយនានា)។ លទ្ធផលនិងផលប៉ះពាល់នៃផ.យ.អ.ជ. ២០១៤-២០១៨ គឺបានបង្ហាញក្នុង របាយការណ៍នេះតាមរយៈការវាស់វែងនៃបញ្ជីសូចនាករស្នូលនិងសូចនាករបន្ថែម។ ជាពិសេស របាយការណ៍នេះ ក៏បានបង្ហាញពី លទ្ធផលនៃការសម្រេចបាននិងបញ្ហាប្រឈមនានារបស់ គ.អ.ស.ក សម្រាប់ឆ្នាំ២០១៥។

១.១៣- របាយការណ៍នេះ ត្រូវបានរៀបចំឡើងដោយមានការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធជាមួយនឹងបណ្ដាក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជាដែលអនុវត្តផែនការនេះ ព្រមទាំងជាមួយនឹងដៃគូអភិវឌ្ឍនានាដែលពាក់ព័ន្ធនឹងដំណើរការនៃការងារផែនការនេះ។ ជាពិសេសរបាយការណ៍នេះ រៀបចំឡើងដោយមានមូលដ្ឋានមួយចំនួនដូចខាងក្រោម៖

- របាយការណ៍ដែលត្រូវបានរៀបចំដោយក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល។
- ការពិគ្រោះយោបល់ជាមួយនឹងក្រសួង ស្ថាប័ននានា។
- ពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍និងអង្គការសង្គមស៊ីវិលតាមរយៈដំណើរការនៃក្រុមការងារបច្ចេកទេសចម្រុះ (TWGs)។
- ការពិនិត្យមើលឡើងវិញពីទិន្នន័យថ្មីៗ *អង្កេតសេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ២០១៤* និង*ឆ្នាំ២០១៥ អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជានៅឆ្នាំ២០១៤ ទិន្នន័យក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា* និង *ទិន្នន័យមូលដ្ឋានឃុំ-សង្កាត់* ។
- ការពិនិត្យមើលឡើងវិញពីការសិក្សាស្រាវជ្រាវដែលពាក់ព័ន្ធនឹងគោលនយោបាយមួយចំនួន និងឯកសារគោលនយោបាយនានារបស់រាជរដ្ឋាភិបាលកម្ពុជា។

១.១៤- ក្រៅពីការវិភាគលើព័ត៌មានផ្នែកបរិមាណនិងលើចំណុចដៅនានា របាយការណ៍នេះនឹងបង្ហាញផងដែរពីបញ្ហានានា ដែលកើតមាននៅក្នុងការអនុវត្តផែនការនេះ និង ការគាំទ្រទាំងឡាយដែលចាំបាច់ដើម្បីធ្វើឲ្យសម្រេចបាននូវចំណុចដៅនានារបស់ផែនការ។

## ៥- ទម្រង់នៃរបាយការណ៍

១.១៥- របាយការណ៍នេះ ត្រូវបានរៀបចំឡើងជាប្រាំជំពូក ។ ជំពូកទី១ សេចក្ដីផ្ដើម ជំពូកទី២ វិភាគអំពីដំណើរការអនុវត្តម៉ាក្រូសេដ្ឋកិច្ច (កំណើន រចនាសម្ព័ន្ធនៃកំណើន ពាណិជ្ជកម្ម ជញ្ជីងទូទាត់ អតិផរណា និងបញ្ហាផ្សេងៗទៀតរួមជាមួយនឹង ការពិភាក្សាពីភាពក្រីក្រនិងភាពមានការងារធ្វើ)។ ជំពូកទី៣ បង្ហាញពីវឌ្ឍនភាពលើវិស័យសំខាន់ៗមួយចំនួនដូចជា កំណែទម្រង់អភិបាលកិច្ច វិស័យកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ការអភិវឌ្ឍវិស័យឯកជន និងកន្លែងការងារ និង ការអភិវឌ្ឍធនធានមនុស្ស។ ជំពូកទី ៣ ក៏កំណត់នូវបញ្ហាប្រឈមជាសំខាន់ផងដែរតាមវិស័យនានាដែលអាចរារាំងដល់វឌ្ឍនភាព និង /ឬ ធ្វើឲ្យប៉ះពាល់ដល់និរន្តរភាពនៃសមិទ្ធផលសំខាន់ៗ។ ជំពូកទី៤ លើកឡើងពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានា ក្នុងការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្ត ផ.យ.អ.ជ. ក្នុងនោះរួមមាន (១)លទ្ធភាពដែលអាចរកបានទិន្នន័យ និងការគ្រប់គ្រងព័ត៌មាន (២) ការសម្របសម្រួលអន្តរស្ថាប័ន និង(៣)សមត្ថភាពធនធានមនុស្សក្នុងការអនុវត្តការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ជំពូកទី ៤ ក៏មានលើកឡើងពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃ *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ២០១៦-២០៣០*។ ជំពូកទី៥ បង្ហាញដោយសង្ខេបពីសំណើគោលនយោបាយនានា និងផ្ដល់អនុសាសន៍អន្តរវិស័យជាក់លាក់និងវិស័យសម្រាប់មធ្យោបាយឆ្ពោះទៅមុខ ក្នុងនោះរួមមាន រយៈពេល២ឆ្នាំ នៃផែនការបច្ចុប្បន្នដែលនៅសល់ ព្រមទាំងផែនការបន្ទាប់ *ផ.យ.អ.ជ ២០១៩-២០២៣*។

# ជំពូកទី២

# ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ចនៅក្នុងសេដ្ឋកិច្ចកម្ពុជា

## ១- សេចក្តីផ្តើម

២.១- ជំពូកនេះនឹងបរិយាយអំពីទិដ្ឋភាពរួមនៃស្ថានភាពម៉ាក្រូសេដ្ឋកិច្ច ដោយធ្វើការអត្ថាធិប្បាយលើសូចនាករម៉ាក្រូសេដ្ឋកិច្ចសម្រាប់រយៈពេលពាក់កណ្តាលអាណត្តិដំបូងនៃការអនុវត្ត *ផ.យ.អ.ជ. ២០១៤-២០១៨* និងកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាដើម្បីជម្នះឲ្យបាននូវបញ្ហាប្រឈមនានាដែលបណ្តាលមកពីកត្តាខាងក្នុងនិងកត្តាខាងក្រៅ។ ជាក់ស្តែងរាជរដ្ឋាភិបាលកម្ពុជានៅតែបន្តគ្រប់គ្រងបរិស្ថានការអភិវឌ្ឍសេដ្ឋកិច្ចមួយដែលមានស្ថេរភាពតាមរយៈការដោះស្រាយបញ្ហាប្រឈមម៉ាក្រូសេដ្ឋកិច្ច និងហានិភ័យពីកត្តាទាំងពីរខាងក្នុងនិងខាងក្រៅយ៉ាងមានប្រសិទ្ធភាព។ សូចនាករសំខាន់ៗបានបង្ហាញថា ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជាអាចត្រូវបានរក្សាបន្តទៅមុខបានគឺដោយមានភាពបត់បែនគ្រប់គ្រាន់ដើម្បីដោះស្រាយបញ្ហាដែលមិនរំពឹងទុកទាំងក្នុងបរិយាកាសក្នុងស្រុក ក្នុងតំបន់ និងជាសកល។

២.២- បរិយាកាសអំណោយផលនៃសុខសន្តិភាពសង្គម និងការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បានធ្វើឲ្យប្រទេសកម្ពុជានៅតែរក្សាបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងអត្រាប្រមាណ ៧% ក្នុង១ឆ្នាំ សម្រាប់រយៈពេល ៣ឆ្នាំចុងក្រោយ និងកាត់បន្ថយភាពក្រីក្រមកត្រឹម ១៣,៥ % នៅឆ្នាំ២០១៤។ នេះជាលទ្ធផលដែលទទួលបានលើសពីការរំពឹងទុក ដែលបានកំណត់ក្នុង*ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨* ដែលអត្រានៃភាពក្រីក្រនឹងត្រូវកាត់មកត្រឹម១៣,៩% នាឆ្នាំ២០១៧។ សមិទ្ធផលនេះ បានធ្វើឲ្យកម្ពុជាក្លាយទៅជាប្រទេសមួយដែលសម្រេចបាននូវគោលដៅសហស្សវត្សរ៍លឿនមុនគោលដៅកំណត់ក្នុងការកាត់បន្ថយភាពក្រីក្រ និងបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៥ និងត្រូវបានប្រសិទ្ធនាមថាជាខ្លាថ្មីប្រចាំតំបន់អាស៊ី ដោយសារការសម្រេចបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ជាប់គ្នាសម្រាប់រយៈពេលប៉ុន្មានឆ្នាំចុងក្រោយ។ ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ត្រូវបានប៉ាន់ស្មានថានឹងកើនឡើងដល់រង្វង់ ១ ៣០០ ដុល្លារសហរដ្ឋអាមេរិកក្នុងឆ្នាំ២០១៦។ ក្នុងបរិបទនៃភាពរឹងមាំនៃកំណើនសេដ្ឋកិច្ចដែលកម្ពុជាបាននិងកំពុងសម្រេចបាន កម្ពុជានៅតែមានសុទិដ្ឋិនិយមខ្ពស់ក្នុងការបន្តសម្រេចបាននូវគោលដៅកំណើនប្រកបដោយបរិយាប័ន្ន និងការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាព។

## ២- អត្រាកំណើននៃផលិតផលក្នុងស្រុកសរុប( *ផ.ស.ស.*)

### *២.១- អត្រាកំណើននៃ ផ.ស.ស. រួម*

២.៣- ព្រះរាជាណាចក្រកម្ពុជាទទួលបាននូវជោគជ័យគួរឲ្យកត់សម្គាល់ក្នុងវិស័យសេដ្ឋកិច្ច ដែលសម្រេចបានកំណើនរឹងមាំសម្រាប់រយៈពេលពីរទសវត្សរ៍ចុងក្រោយនេះ ជាមួយនឹងអត្រាកំណើនមធ្យមប្រចាំឆ្នាំ ៧,៧%។ នៅក្នុងឆ្នាំ២០១៤ សេដ្ឋកិច្ចកម្ពុជាសម្រេចបានកំណើនតាមការរំពឹងទុក ដែលក្នុងនោះកំណើន ផ.ស.ស. ប្រចាំឆ្នាំស្ថិតក្នុងអត្រា ៧,១% ដោយសារកំណើនខ្ពស់នៃវិស័យសំណង់ ទោះបីមានការថមថយកំណើននៃការនាំចេញ សម្លៀកបំពាក់ និងចំនួនភ្ញៀវទេសចរក្តី។ កំណើន ផ.ស.ស. ដែលសម្រេចបាននេះត្រូវបានជំរុញដោយកំណើននៃវិស័យឧស្សាហកម្ម (១០,១%) ដែលក្នុងនោះវិស័យសំណង់បាននាំមុខជាលើកទីមួយ វិស័យសេវាកម្ម (៨,៧%), និងវិស័យកសិកម្ម (០,៣%)។ សកម្មភាពសេដ្ឋកិច្ចឆ្នាំ ២០១៥ នៅតែបន្តកំណើនខ្ពស់ក្នុងអត្រា ៧% ដែលជំរុញជាសំខាន់ដោយវិស័យឧស្សាហកម្ម (១១,៧%) ជាពិសេសគឺវិស័យកាត់ដេរ។ កំណើនវិស័យសេវាកម្មនៅបន្តរឹងមាំទោះបីថមថយបន្តិចបន្តួច (៧,១%) ខណៈដែលវិស័យកសិកម្មនៅបន្តកំណើនទាប (០,២%)។ សេដ្ឋកិច្ចឆ្នាំ ២០១៦ ត្រូវបានរំពឹងថានៅតែមានសន្ទុះកំណើនខ្ពស់ប្រមាណ ៧% ដែលស្របទៅនឹងការព្យាករទុកនៅដើមឆ្នាំ២០១៦ ក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨*។ សេដ្ឋកិច្ចដែលបន្តកំណើនរឹងមាំនេះ នៅតែបន្តទ្រទ្រង់ជាសំខាន់ដោយ វិស័យកាត់ដេរ ទោះជាកំណើនហាក់ដូចជាថមថយបន្តិចក្តី។ ការរីកចម្រើននៃវិស័យមិនមែនកាត់ដេរ គួបផ្សំនឹងការងើបឡើងវិញនៃវិស័យកសិកម្ម បានជួយប៉ះប៉ូវដល់ការថមថយកំណើនវិស័យសំណង់ និងទេសចរណ៍។ បើធៀបទៅនឹងអត្រាកំណើន ផ.ស.ស. ជាមធ្យមប្រចាំឆ្នាំដែលបានគ្រោងទុកប្រមាណ ៧% អត្រាកំណើននេះសម្រេចបានតាមការដៅទុកសម្រាប់ពាក់កណ្តាលទី ១ នៃ *ផ.យ.អ.ជ. ២០១៤-២០១៨*។ រាជរដ្ឋាភិបាលកម្ពុជាបានព្យាករថាអត្រាកំណើនផលិតផលក្នុងស្រុកសរុបនឹងបន្តនៅជុំវិញ៧,០% ក្នុងមួយឆ្នាំសម្រាប់ពាក់កណ្តាលអាណត្តិបន្ទាប់នៃ *ផ.យ.អ.ជ. ២០១៤-២០១៨*។

២.៤- រាជរដ្ឋាភិបាលកម្ពុជា បានរក្សាការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះការសម្រេចបាននូវកំណើនសេដ្ឋកិច្ចរឹងមាំប្រកបដោយនិរន្តរភាពប្រមាណ៧% ក្នុង១ឆ្នាំ បើទោះជាមូលដ្ឋានសេដ្ឋកិច្ចនៅមានទំហំតូច ពិពិធកម្មសេដ្ឋកិច្ច និងការកែទម្រង់ស្ថាប័ននៅមានកម្រិត និងបន្តជួបប្រទះនូវបញ្ហាប្រឈម និងហានិភ័យខាងក្នុង និងខាងក្រៅក្តី។

រូបភាព ២.១: អត្រាកំណើននៅក្នុងផលិតផលក្នុងស្រុកសរុប, ឆ្នាំបានវាស់វែងប្រចាំឆ្នាំ ២០១០-២០១៨




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មករា ឆ្នាំ២០១៧

## ២.២- ចំណូលក្នុងប្រជាជនម្នាក់

**២.៥-** រូបភាពទី ២.២ ខាងក្រោម បង្ហាញថាផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ (តម្លៃថេរ ឆ្នាំ ២០០០) បានកើនឡើងជាមធ្យម ៧,៧ %ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ។ ចំណូលជាមធ្យមក្នុងប្រជាជនម្នាក់ បានកើនឡើងពី ១ ១៣៨ ដុល្លារអាមេរិក (២០១៤) ទៅ ១ ៣០២ ដុល្លារអាមេរិក (២០១៦) និងកំពុងនៅលើផ្លូវត្រូវដើម្បីឈានទៅសម្រេចគោលដៅនៃ ផ.យ.អ.ជ. ដែលកំណត់ ១ ៥៧៩ ដុល្លារអាមេរិក នៅឆ្នាំ ២០១៨។ ការកើនឡើងនេះធ្វើឲ្យមានការបង្កើនកម្រិតជីវភាពរស់នៅរបស់ប្រជាជន។ ការកើនឡើងផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ បានធ្វើឲ្យកម្ពុជាវិវត្តខ្លួនទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាបនាឆ្នាំ២០១៥។ និន្នាការនេះធ្វើឲ្យកម្ពុជាមាន សុទិដ្ឋិនិយមថានឹងអាចសម្រេចបាននូវគោលដៅរយៈពេលវែងរបស់ខ្លួន ក្នុងការក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់ក្នុងឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់ឆ្នាំ២០៥០។

រូបភាពទី២.២ : ផលិតផលក្នុងស្រុកសរុបក្នុងប្រជាជនម្នាក់ (គិតជាដុល្លារអាមេរិក) ២០១៣-២០១៧




ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ឆ្នាំ២០១៦

## ២.៣- អត្រាកំណើនតាមវិស័យ

២.៦- ជានិន្នាការនៃការអភិវឌ្ឍសេដ្ឋកិច្ច បណ្ដាប្រទេសកំពុងអភិវឌ្ឍស្ទើរតែទាំងអស់មានការវិវត្ត បណ្ដើរៗចេញពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលមានសេដ្ឋកិច្ចផ្អែកលើវិស័យឧស្សាហកម្ម។ មូលហេតុចំបងដែលធ្វើឲ្យមានការផ្លាស់ប្ដូរនេះ គឺដោយសាហេតុផលថាផលិតភាពនៃកម្លាំងពលកម្មនិងចំណូលរបស់ប្រជាជនដែលបំរើការក្នុងវិស័យមិនមែនកសិកម្មដូចជា វិស័យកម្មន្តសាល វិស័យទេសចរណ៍ វិស័យសំណង់ និងវិស័យសេវាកម្មមានកម្រិតខ្ពស់ជាងផលិតភាពនិងចំណូលដែលបានមកពីការបម្រើការងារក្នុងវិស័យកសិកម្ម។ ទោះជាដូចនេះក្ដី ការរៀបរាប់ខាងលើនេះមិនមែនដើម្បីគូសបញ្ជាក់ថា វិស័យកសិកម្មមិនគួរត្រូវបានយកចិត្តទុកដាក់នោះទេ។

២.៧- បន្ទាប់ពីមានការថមថយកំណើនមធ្យមប្រចាំឆ្នាំមកត្រឹម ០,៧% ក្នុងចន្លោះឆ្នាំ ២០១៣-២០១៥ វិស័យកសិកម្ម ចាប់ផ្ដើមងើបឡើងបន្តិចជាមួយនឹងអត្រាកំណើន៣% ក្នុងឆ្នាំ២០១៦ ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុ ពោលគឺទឹកភ្លៀងបានធ្លាក់រាយប៉ាយល្អទូទាំងប្រទេស ដែលធ្វើឲ្យទិន្នផល និងបរិមាណផល ស្រូវមានការកើនឡើង ស្របពេលដែលបរិមាណផលិតកម្ម និងតម្លៃកៅស៊ូកាន់តែមានសន្ទុះឈានឡើង ទោះបីតម្លៃស្រូវមានការធ្លាក់ចុះបន្តិចក្ដី។ យើងសង្កេតឃើញថា អត្រាកំណើនមធ្យមប្រចាំឆ្នាំនៃវិស័យកសិកម្មក្នុងចន្លោះឆ្នាំ ២០១៤-២០១៦ សម្រេចបានត្រឹមតែ ១,២៤% ប៉ុណ្ណោះ ពោលគឺទាបជាងអត្រាកំណើនជាមធ្យមនាឆ្នាំ ២០០៩-២០១៣ ប្រមាណ ៣,៧% និងស្ថិតនៅក្រោមគោលដៅកំណត់ក្នុង ផ.យ.អ.ជ. ដែលបានកំណត់កំណើនប្រចាំឆ្នាំ ៤% ក្នុងអំឡុងអាណត្តិរបស់ខ្លួន។

២.៨- កំណើនយឺតនៃវិស័យកសិកម្ម ត្រូវបានប៉ះប៉ូវមកវិញដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្ម។ រវាងឆ្នាំ ២០១៤-២០១៦ វិស័យឧស្សាហកម្មបានកើនឡើង ១០,៩% ក្នុងមួយឆ្នាំ។ ការរក្សាបាននូវកំណើនដ៏រឹងមាំនៃវិស័យឧស្សាហកម្ម ត្រូវបានរួមចំណែកសំខាន់ភាគច្រើនដោយកំណើនខ្ពស់នៃវិស័យកាត់ដេរ និងសំណង់។ ក្រោយពីវិស័យសំណង់បានក្លាយជាវិស័យជំរុញកំណើនទី១ ជាលើកដំបូងក្នុងឆ្នាំ២០១៤ ក្នុងអត្រាកំណើន ២១,៤% វិស័យ នេះបានថមថយជាបន្តបន្ទាប់មកត្រឹម ១៥,៩% នាឆ្នាំ២០១៦ ដោយសារវដ្តកំណើននៃវិស័យនេះដែលជាធម្មតាតែងមានរយៈពេលមួយខ្លី។ ដោយឡែក វិស័យកាត់ដេរនឹងនៅតែបន្តដើរតួនាទីជាជន្ទល់ទ្រទ្រង់កំណើនដដែល ព្រមទាំងផ្ដល់ការងារជូនប្រជាពលរដ្ឋរាប់សែននាក់ក្នុង១ឆ្នាំ ទោះបីមានការថមថយបន្តិចប៉ុន្តែនៅតែខ្ពស់ជាងឆ្នាំ២០១៥ ក្នុងអត្រា ៨,០% នាឆ្នាំ២០១៦ ដោយសារកំណើនយឺតនៃពាណិជ្ជកម្មជាសកល ការកើនឡើងនៃប្រាក់ដុល្លារអាមេរិក ការដកខ្លួនចេញរបស់ប្រទេសអង់គ្លេសពីសហគមន៍អឺរ៉ុប និងការកើនឡើងជាបន្តបន្ទាប់នៃប្រាក់ឈ្នួលអប្បបរមា។

២.៩- វិស័យសេវាកម្មក្នុងអំឡុងរយៈពេលដូចគ្នា (២០១៤-២០១៦) បានកើនឡើងដោយអត្រាកំណើនប្រចាំឆ្នាំជាមធ្យម ៧,៥% ខ្ពស់ជាងកំណើន ៧,១% នាឆ្នាំ២០១៥ និងគោលដៅ ផ.យ.អ.ជ. ៧,២% សម្រាប់ឆ្នាំ២០១៨ ទោះបីជាមានការថមថយបន្តិចនាឆ្នាំ២០១៦។ វិស័យសេវាកម្មឆ្នាំ២០១៦ មានការ

ថមថយបន្តិចមកត្រឹម ៦,៦% ធៀបនឹងឆ្នាំ២០១៤ និង២០១៥ ដោយសារការបន្តកំណើនយឺតនៃវិស័យទេសចរណ៍ និងការថមថយកំណើននៃវិស័យអចលនទ្រព្យ។ អនុវិស័យផ្សេងទៀតនៃវិស័យសេវាកម្ម រួមមានពាណិជ្ជកម្មក្នុងស្រុកនៅមានកំណើនខ្ពស់នៅឡើយ ដែលមួយផ្នែកគាំទ្រដោយគោលនយោបាយវិត្តរកម្មរបស់រាជរដ្ឋាភិបាលដែលជំរុញដល់ការប្រើប្រាស់ក្នុងស្រុក ខណៈដែលវិស័យគមនាគមន៍មានសន្ទុះកំណើនខ្ពស់ទៅជួយបំពេញដល់ការថមថយនៃវិស័យដឹកជញ្ជូន។

២.១០- បើទោះបីជា *ផ.យ.អ.ជ. ២០១៤-២០១៨* មិនបានកំណត់គោលដៅជាក់លាក់សម្រាប់ចំណែកនៃអនុវិស័យនីមួយៗក្នុង ផ.ស.ស។ ក្នុងអំឡុងពាក់កណ្ដាលដំបូងនៃការអនុវត្ត *ផ.យ.អ.ជ ២០១៤-២០១៨* និន្នាការនៃចំណែកតាមវិស័យ ក្នុង ផ.ស.ស មានការផ្លាស់ប្ដូរគួរឲ្យកត់សម្គាល់ (តារាង ២.១)។ តាមការប៉ាន់ស្មាន ចំណែកនៃវិស័យកសិកម្មបានថយចុះពី ២៨,៩% ក្នុងឆ្នាំ២០១៤ ដល់២៥,៥% ក្នុងឆ្នាំ២០១៦ ដោយសារការថមថយនៃបរិមាណផលិត និងការធ្លាក់ចុះនៃតម្លៃកសិផលក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ ខណៈវិស័យឧស្សាហកម្មមានកំណើនបញ្ច្រាសវិញពី២៥,៦% ទៅ២៩,០%។ នេះឆ្លុះបញ្ចាំងពីការផ្លាស់ប្ដូររចនាសម្ព័ន្ធពីសេដ្ឋកិច្ចដែលពឹងផ្អែក វិស័យកសិកម្មមកពឹងផ្អែកលើឧស្សាហកម្មវិញ ដែលទ្រទ្រង់ដោយកំណើនជាបន្តបន្ទាប់នៃវិស័យកាត់ដេរ សំណង់ ម្ហូបអាហារ ភេសជ្ជៈ ព្រមទាំងគ្រឿងបង្គុំអេឡិចត្រូនិក។ វិស័យសេវាកម្មបានរក្សាចំណែករបស់ខ្លួនក្នុង ផ.ស.ស. ឲ្យនៅដដែលក្នុងរយៈពេល៣ឆ្នាំចុងក្រោយនេះពោលគឺស្ថិតក្នុងរង្វង់ ៣៩,៧% ដោយសារកំណើននៃសកម្មភាពអាជីវកម្មក្នុងស្រុក ដែលបានទៅជួយបំពេញការថមថយនៃតម្លៃបន្ថែមក្នុងវិស័យទេសចរណ៍ និងអចលនទ្រព្យ។

២.១១- ជាសេចក្តីសង្ខេប បីចំណុចសំខាន់អាចត្រូវបានសន្និដ្ឋានពីខាងលើនេះ៖

១. វិស័យកសិកម្មនៅតែបន្តកំណើនយឺត ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ដោយសារបញ្ហាប្រឈមមួយចំនួនដូចជា បញ្ហាផលិតភាពទាប បញ្ហាអាកាសធាតុ និងការធ្លាក់ចុះនៃតម្លៃកសិផល ស្របពេលដែលកម្ពុជាកំពុងផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ចពីប្រទេសដែលពឹងផ្អែកលើវិស័យកសិកម្ម ទៅជាប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែកលើវិស័យឧស្សាហកម្ម។ ក្នុងន័យនេះ វិស័យឧស្សាហកម្មនឹងដើរតួនាទីកាន់តែសំខាន់បន្ថែមទៀតនៅក្នុងសេដ្ឋកិច្ចជាតិ ដែលស្របការកំណត់នៃ *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥*។ ប៉ុន្តែទោះបីជាយ៉ាងនេះក្តី ក៏រាជរដ្ឋាភិបាលកម្ពុជានៅតែបន្តយកចិត្តទុកដាក់ខ្ពស់ក្នុងវិស័យកសិកម្ម ដើម្បីរក្សាបាននូវស្ថិរភាពកំណើនដែលបានដៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨*។ ក្នុងន័យនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ក្នុងការដោះស្រាយបញ្ហាប្រឈមក្នុងវិស័យកសិកម្ម ដោយវិនិយោគបន្ថែមលើប្រព័ន្ធធារាសាស្ត្រ បង្កើនការផលិតពូជសុទ្ធ ស្វែងរកទីផ្សារកសិផល វិនិយោគរួមគ្នាលើបច្ចេកវិទ្យាកសិកម្មជាមួយវិស័យឯកជន និងកែច្នៃកសិផល។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលក៏នឹងផ្តោតការយកចិត្តទុកដាក់លើការធ្វើមច្ឆវប្បកម្ម និងការចិញ្ចឹមសត្វបន្ថែម ដោយផ្សារភ្ជាប់ជាមួយនឹងការគិតគូរទៅដល់តុល្យភាពបរិស្ថាន។

២. វិស័យឧស្សាហកម្ម នៅពឹងផ្អែកខ្លាំងលើវិស័យកម្មន្តសាលសំលៀកបំពាក់។ ការកើនឡើងនូវសមត្ថភាពប្រកួតប្រជែងរបស់ប្រទេសជិតខាងយើងក្នុងតំបន់ ក្នុងខណៈដែលវិស័យកាត់ដេររបស់កម្ពុជានៅមានផលិតភាពទាប ការឡើងថ្លៃប្រាក់ដុល្លារអាមេរិក ការចាកចេញរបស់

អង់គ្លេសពីសហគមន៍អឺរ៉ុប ការកើនឡើងជាបន្តបន្ទាប់នៃប្រាក់ឈ្នួលអប្បបរមា បញ្ហាទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងបញ្ហាសម្របសម្រួលស្ថាប័ន និងនីតិវិធីពាក់ព័ន្ធ ជាឧបសគ្គក្នុងការអភិវឌ្ឍវិស័យនេះនាពេលអនាគត។ ឆ្លើយតបទៅនឹងបញ្ហាប្រឈមទាំងនេះ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់ដល់ការបង្កើនផលិតភាពការងារ ការបន្តធ្វើសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈពិសេសការបង្កើនតម្លៃបន្ថែមរបស់វិស័យកាត់ដេរ និងការកែលម្អនីតិវិធីរដ្ឋបាល ព្រមទាំងការសម្រួលពាណិជ្ជកម្ម។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលនឹងជំរុញការអនុវត្ត *គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា២០១៥-២០២៥* ដើម្បីជំរុញកែប្រែ និងធ្វើទំនើបកម្មរចនាសម្ព័ន្ធឧស្សាហកម្មកម្ពុជា ពីឧស្សាហកម្មអតិពលកម្ម ឈានទៅឧស្សាហកម្មផ្អែកលើជំនាញ។ ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលនឹងបង្កើន ការវិនិយោគសាធារណៈលើវិស័យអប់រំ និង ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ បច្ចេកទេស ឲ្យសមស្របតាមតម្រូវការទីផ្សារ ការផ្គត់ផ្គង់ថាមពលអគ្គិសនីដែលមានតម្លៃសមរម្យជាងមុន, និងការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទឲ្យក្លាយជាប្រព័ន្ធឡូជីស្ទីកមួយដ៏រស់រវើក ដើម្បីធានានូវភាពប្រកួតប្រជែងរបស់កម្ពុជា។

៣. វិស័យសេវាកម្មនៅតែមានសក្តានុពលខ្ពស់ ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ច បើទោះបីវាមានការថមថយបន្តិចបន្តួចក្នុងរយៈពេល៣ឆ្នាំ ចុងក្រោយនេះ។ ការថមថយកំណើនក្នុងវិស័យទេសចរណ៍ វិស័យអចលទ្រព្យ អាចនឹងត្រូវបំពេញដោយកំណើនរឹងមាំនៃសកម្មភាពអាជីវកម្មក្នុងស្រុក ដោយសារគោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការប្រើប្រាស់ក្នុងស្រុក ទោះបីវិស័យដឹកជញ្ជូនក្នុងឆ្នាំ២០១៦ ត្រូវបានមើលឃើញថាមានកំណើនយឺតប្រហាក់ប្រហែលនឹងឆ្នាំ២០១៤។ វានឹងក្លាយជាការចាំបាច់សម្រាប់ប្រទេសកម្ពុជា ក្នុងការលើកកម្ពស់គុណភាពសេវាកម្មទេសចរណ៍របស់ខ្លួន និងការអភិវឌ្ឍផលិតផលទេសចរណ៍គួរឲ្យទាក់ទាញថ្មី។ វិធីសាស្ត្រថ្មីនៃវិស័យទេសចរណ៍គួរត្រូវបានបង្កើតឡើង ដើម្បីផ្តោតលើការទាក់ទាញភ្ញៀវទេសចរដែលចំណាយប្រាក់ច្រើន ពោលគឺមានជាការឃោសនាផ្សព្វផ្សាយទេសចរណ៍បន្ថែមទៀតអំពីទិសដៅទេសចរណ៍របស់ប្រទេសកម្ពុជា និងការរៀបចំកញ្ចប់ទេសចរណ៍ដែលទាក់ទាញភ្ញៀវទេសចរដោយផ្ទាល់ពីបរទេស ដោយបន្ថែមលើលំហូរភ្ញៀវទេសចរដែលហៀរពីប្រទេសជិតខាង។ គោលនយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាលលើការតម្លើងបៀវត្សជូនមន្ត្រីរាជការ ត្រូវបានរំពឹងថានឹងជួយជំរុញកំណើនការប្រើប្រាស់ក្នុងស្រុក និងធ្វើការប៉ះប៉ូវចំពោះកំណើននៃអនុវិស័យសេវាកម្មមួយចំនួន ដើម្បីបន្តរក្សាការរួមចំណែកដ៏សំខាន់នៃវិស័យសេវាកម្មទៅក្នុងសេដ្ឋកិច្ចទាំងមូល។

**តារាង២.១ ចំណែកនិងកំណើននៃវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្មក្នុង *ផ.ស.ស.* (ភាគរយ)**

| | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) |
|---|---|---|---|---|
| **ចំណែកតាមវិស័យ (ថ្លៃបច្ចុប្បន្ន)** | | | | |
| វិស័យកសិកម្ម | ២៨,៩ | ២៦,៦ | ២៥,៥ | ២៤,៤ |
| ដំណាំ | ១៧,២ | ១៥,៨ | ១៥,២ | ១៤,៥ |
| វិស័យឧស្សាហកម្ម | ២៥,៦ | ២៧,៧ | ២៩,០ | ៣០,៣ |
| វាយនភណ្ឌ | ១០,១ | ១០,៦ | ១០,៧ | ១០,៩ |
| សំណង់ | ៨,៥ | ៩,៨ | ១០,៦ | ១១,៣ |
| វិស័យសេវាកម្ម | ៣៩,៧ | ៣៩,៨ | ៣៩,៥ | ៣៩,៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៥,១ | ៤,៩ | ៥,២ | ៥,០ |
| **កំណើនតាមវិស័យ (ថ្លៃពិត)** | | | | |
| វិស័យកសិកម្ម | ០,៣ | ០,២ | ១,៨៥ | ១,៩៦ |
| ដំណាំ | ០,៥ | ០,៣ | ២,២៥ | ២,១ |
| វិស័យឧស្សាហកម្ម | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ |
| វាយនភណ្ឌ | ៦,៦ | ៩,៨ | ៨,០២ | ៨,៤៥ |
| សំណង់ | ២១,៤ | ១៩,២ | ១៥,៩ | ១៤,១ |
| វិស័យសេវាកម្ម | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ៦,១ | ២,៤ | ២,២៣ | ២,៣៤ |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មករា ឆ្នាំ២០១៧*

## ៣- ចំណូលនិងចំណាយថវិការដ្ឋ និងអភិបាលកិច្ច

### *៣.១- គោលនយោបាយសារពើពន្ធ*

២.១២- រាជរដ្ឋាភិបាលកម្ពុជាបានខិតខំប្រឹងប្រែងយ៉ាងខ្លាំងដើម្បីសម្រេចនូវគោលនយោបាយសារពើពន្ធដែលបានកំណត់នៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨* ដើម្បីរក្សាថវិកាប្រកបដោយនិរន្តរភាព ធានាឲ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនិងគោលនយោបាយ និងពង្រឹងសេវាសាធារណៈទៅនិងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ សមិទ្ធផលសំខាន់ៗរួមមាន៖

- ការអភិវឌ្ឍនិងការអនុវត្តនូវយុទ្ធសាស្ត្រការគៀងគរប្រាក់ចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ដើម្បីការកៀរគរប្រាក់ចំណូលក្នុងស្រុក។
- ការអភិវឌ្ឍនិងអនុវត្តនូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដើម្បីការគ្រប់គ្រងឲ្យមាននិរន្តរភាពនៃការគ្រប់គ្រងបំណុលសាធារណៈ។
- ការអភិវឌ្ឍនិងការអនុវត្ត កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី ៣។

- ការរៀបចំនិងការអនុវត្តគោលនយោបាយដើម្បីបង្កើនប្រាក់បៀវត្សរ៍មន្ត្រីរាជការស៊ីវិលជាមូលដ្ឋាន ដើម្បីធានាថានឹងទទួលបានប្រាក់បៀវត្សរ៍អប្បបរមា ១លានរៀលក្នុងឆ្នាំ២០១៨។
- ការអនុវត្តថវិកាកម្មវិធីស្របតាមទិសដៅការផ្សារភ្ជាប់ថវិកាទៅនិងគោលនយោបាយ។

២.១៣- ***ប្រាក់ចំណូល៖*** យុទ្ធសាស្ត្រកៀរគរប្រាក់ចំណូលរយៈពេលមធ្យម ២០១៤-២០១៨ របស់រាជរដ្ឋាភិបាល មានបំណងបង្កើនចំណូលចរន្តបន្ថែម ០,៥ ពិន្ទុភាគរយ នៃ ផ.ស.ស. ជារៀងរាល់ឆ្នាំ។ យុទ្ធសាស្ត្រនេះមានអភិក្រម ប្រមូលឲ្យអស់លទ្ធភាពនូវសក្តានុពលចំណូលដែលមាននាពេលបច្ចុប្បន្ន ដោយមិនបង្កើតប្រភេទពន្ធថ្មី ឬដំឡើងអត្រាពន្ធ និងអាករ លើកលែងតែនៅក្នុងករណីប៉ះប៉ូវដល់ការបាត់ចំណូល ឬ ផលិតផលដែលអាចប៉ះពាល់ដល់បរិស្ថាន និង/ឬសុខភាពសាធារណៈ។ ការកែលម្អកំពុងតែបន្តធ្វើនៅក្នុងការប្រមូលចំណូលគឺមានសារៈសំខាន់ណាស់។ កំណើនចំណូលជាមធ្យមរយៈពេល៣ឆ្នាំចុងក្រោយនេះប្រមាណជាង១ពិន្ទុភាគរយ នៃ ផ.ស.ស. ដែលជាការចូលរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចបាននូវគោលដៅយុទ្ធសាស្ត្របានដាក់ចេញ។ រាជរដ្ឋាភិបាលបានពង្រឹងរដ្ឋបាលសារពើពន្ធនិងមិនមែនសារពើពន្ធដោយអនុវត្តវិធានការនានា ដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨។ ផលធៀបចំណូលចរន្ត នឹងផ.ស.ស. គឺ ១៦,៩% នៅឆ្នាំ២០១៤, ១៧,៨% ក្នុងឆ្នាំ២០១៥ និងប៉ាន់ស្មានប្រមាណ ១៨,៤% ក្នុងឆ្នាំ២០១៦។ ទន្ទឹមនឹងនេះដែរ ច្បាប់និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងពន្ធដារ គយ និងចំណូលមិនមែនសារពើពន្ធត្រូវបានពង្រឹងជាបន្តបន្ទាប់។

២.១៤- ***ចំណាយ៖*** ការចំណាយថវិកាសាធារណៈត្រូវបានពង្រឹងឲ្យកាន់តែមានប្រសិទ្ធភាពនិងល្អប្រសើរជាងមុនដោយផ្តោតជាគោលដៅបន្ថែមទៀតលើវិស័យអាទិភាពដូចជាវិស័យអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈ សុខាភិបាល កសិកម្ម និងហេដ្ឋារចនាសម្ព័ន្ធ។ ការវិនិយោគលើវិស័យសាធារណៈក្នុងវិស័យអាទិភាពទាំងនេះនឹងជួយប្រទេសកម្ពុជាប្រែមុខមាត់ប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ឆ្ពោះទៅរកការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយបរិយាប័ន្ននិងមាននិរន្តរភាព។ ជាក់ស្តែងការបែងចែកថវិកាសាធារណៈសម្រាប់វិស័យអប់រំ បានកើនឡើងជាបន្តបន្ទាប់ពី១,៧% នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៣ ដល់ ២,៦%នៃ ផ.ស.ស. ក្នុងឆ្នាំ២០១៦។

២.១៥- ទន្ទឹមនឹងនោះដែរថវិកាជាតិនេះបានរួមបញ្ចូលការកើនឡើងក្នុងប្រាក់ខែគោលសម្រាប់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធចាប់តាំងពីចុងឆ្នាំ២០១៣ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនិងបង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ។ ឧទាហរណ៍ប្រាក់ខែគោលអប្បបរមារបស់មន្ត្រីរាជការស៊ីវិលបានកើនឡើងពី ៤០០ ០០០ រៀលក្នុងឆ្នាំ២០១៣ ដល់ជាង ៧០០ ០០០រៀលនៅឆ្នាំ២០១៦។

២.១៦- រាជរដ្ឋាភិបាលបានអនុវត្តយ៉ាងពេញលេញនូវថវិកាកម្មវិធីសម្រាប់ក្រសួងទាំង១០ ក្នុងឆ្នាំ២០១៥ ហើយបានផ្តល់អាទិភាពក្រសួង១៥ បន្ថែមទៀតនៅឆ្នាំ២០១៦។ កម្មវិធីថវិកានេះគឺជាផ្នែកមួយនៃការធ្វើកំណែទម្រង់ថវិកា ២០១៣-២០២០ ក្នុងគោលបំណងដើម្បីធានាឲ្យបាននូវប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនិងគោលនយោបាយ ដែលជាគោលដៅក្នុងដំណាក់កាលទី៣ នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល។ លើសពីនេះទៀត រាជរដ្ឋាភិបាលកម្ពុជាបន្តបង្កើនប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងការគ្រប់គ្រង និងការគ្រប់គ្រងការចំណាយរបស់រដ្ឋាភិបាល។

**២.១៧- *បំណុលសាធារណៈ៖*** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ឲ្យអនុវត្តនូវយុទ្ធសាស្ត្រគ្រប់គ្រងបំណុលសាធារណៈ ២០១៥-២០១៨ ដើម្បីធានាថាបំណុលសាធារណៈនឹងមិនកើនលើសកម្រិតអប្បបរមាដែលមានគ្រោះថ្នាក់ក្នុងការគ្រប់គ្រងបំណុលសាធារណៈ។ យុទ្ធសាស្ត្រនេះមានគោលបំណងធានានូវប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព និងគណនេយ្យភាព ក្នុងការគ្រប់គ្រងបំណុលសាធារណៈ ដើម្បីធានារក្សាចីរភាពបំណុលសាធារណៈរយៈពេលវែង និងកម្រិតហានិភ័យបំណុលឲ្យនៅទាប។

**២.១៨-** រាជរដ្ឋាភិបាលបានអនុវត្តនូវកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី១ និងទី២ ទទួលបានជោគជ័យ និងបច្ចុប្បន្នកំពុងអនុវត្តដំណាក់កាលទី៣ ដែលផ្តោតលើការផ្សារភ្ជាប់ "ថវិកាទៅនិងគោលនយោបាយ" មុនពេលអនុវត្តដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម"។ វឌ្ឍនភាពទាំងឡាយដែលទទួលបានពីសមិទ្ធផលទាំងនេះផ្តល់នូវកម្មវិធីមួយរឹងមាំដើម្បីអាចសម្រេចបាននូវចំណុចដៅទាំងឡាយដែលបានកំណត់នៅក្នុង *ផ.យ.អ.ជ. ២០១៤-២០១៨*។

**តារាង២.២ កំណើនផលិតផលក្នុងស្រុកសរុប ពីឆ្នាំ២០១៣-២០១៨**

| សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ (ប៉ាន់ស្មាន) | ២០១៨ (ព្យាករ) |
|---|---|---|---|---|---|---|---|
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | ប៊ីលានរៀល | ៦១ ៣២៧ | ៦៧ ៤៣៧ | ៧៣ ៤២៣ | ៨០ ៥៥៩ | ៨៩ ៤៧៨ | ៩៩ ០២៣ |
| ផ.ស.ស (ថ្លៃបច្ចុប្បន្ន) | លានដុល្លារ | ១៥ ២២៩ | ១៦ ៧៩៦ | ១៨ ០៧៨ | ១៩ ៨៦២ | ២២ ១៦៥ | ២៤ ៥២៩ |
| អត្រាកំណើន ផ.ស.ស.ពិត | % | ៧,៤ | ៧,១ | ៧,០ | ៧,០ | ៧,០ | ៧,០ |
| កសិកម្ម | % | ១,៦ | ០,៣ | ០,២ | ១,៨៥ | ១,៩៦ | ១,៩៩ |
| ឧស្សាហកម្ម | % | ១០,៧ | ១០,១ | ១១,៧ | ១០,៥៥ | ១០,៦៩ | ១០,១១ |
| សេវាកម្ម | % | ៨,៧ | ៨,៧ | ៧,១ | ៦,៦៦ | ៦,៥៣ | ៦,៦៦ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ពាន់រៀល | ៤ ១៩៣ | ៤ ៥៩៧ | ៤ ៩៣៥ | ៥ ២៨០ | ៥ ៧៨៩ | ៦ ៣២៤ |
| ផ.ស.ស.ក្នុងប្រជាជនម្នាក់ | ដុល្លារ | ១ ០៤២ | ១ ១៣៨ | ១ ២១៥ | ១ ៣០២ | ១ ៤៣៤ | ១ ៥៦៧ |
| អតិផរណា (អត្រាកំណើនជាមធ្យមប្រចាំឆ្នាំ) | % | ៣,០ | ៣,៩ | ១,២ | ៣,០ | ៣,៨ | ៣,៥ |
| អត្រាប្តូរប្រាក់ (មធ្យមប្រចាំឆ្នាំ) | រៀល/ដុល្លារ | ៤ ០២៧ | ៤ ០៣៨ | ៤ ០៦០ | ៤ ០៥៣ | ៤ ០៣៧ | ៤ ០៣៧ |
| ទុនបម្រុងបរទេសដុល | នាំចូល ខែ | ៣,៨ | ៤,២ | ៤,៤ | ៥,៥ | ៦,៦ | ៦,០ |
| ទុនបម្រុងបរទេសដុល | លានដុល្លារ | ៣ ៦៤៣ | ៤ ៣៩១ | ៥ ០៩៣ | ៦ ៧៣១ | ៨ ៧៥០ | ១១ ១០០ |

ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ មករា ឆ្នាំ ២០១៧

## ៣.២- គោលនយោបាយរូបិយវត្ថុ

**២.១៩-** *ផ.យ.អ.ជ ២០១៤-២០១៨* កំណត់ចេញជាគោលនយោបាយរូបិយវត្ថុ "ប្រុងប្រយ័ត្ននិងអាចបត់

បែនបាន” សម្រាប់ប្រទេសកម្ពុជា។ វិធានការនានារួមមានការគ្រប់គ្រងនៃលំហូរមូលធនមានភាពប្រសើរឡើង ការបង្កើនទុនបម្រុងអន្តរជាតិ អនុវត្តរបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រងដើម្បីរក្សាស្ថិរភាពប្រាក់រៀលនិងពង្រឹងទំនុកចិត្តរបស់សាធារណជននិងវិនិយោគិនមកលើរូបិយវត្ថុជាតិ *(ឧទាហរណ៍បង្កើនការប្រើប្រាស់ប្រាក់រៀលរបស់ខ្លួន កាត់បន្ថយកម្រិតដុល្លារូបនីយកម្ម)* និងពង្រឹងនិងធានាស្ថិរភាពនៃប្រព័ន្ធធនាគារ។

**២.២០-** ដោយសេដ្ឋកិច្ចកម្ពុជាមានកម្រិតដុល្លាររូបនីយកម្មខ្ពស់ ការរក្សាតម្លៃប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានសារសំខាន់ណាស់ ក្នុងការកសាងជំនឿទុកចិត្តរបស់សាធារណជនមកលើប្រាក់រៀល។ តម្លៃប្រាក់រៀលធៀបនឹងដុល្លារអាមេរិកមានស្ថិរភាព និងមានការប្រែប្រួលបន្តិចបន្តួចតាមកត្តារដូវកាល ដោយអត្រាប្តូរប្រាក់រៀលក្នុងមួយដុល្លារអាមេរិក មានតម្លៃ ៤ ០៦០ ជាមធ្យមក្នុងឆ្នាំ២០១៥ និងបានកើនឡើងដល់ ៤ ០៥៣រៀលក្នុងមួយដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។

**២.២១-** ក្នុងគោលបំណងរក្សាស្ថិរភាពនៃវិស័យធនាគារនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការម៉ាក្រូប្រុងប្រយ័ត្នមួយចំនួន ដើម្បីទប់ស្កាត់នូវកំណើនខ្ពស់នៃឥណទានទៅវិស័យឯកជន ជាពិសេសឥណទានទៅវិស័យសំណង់ និងអចលនទ្រព្យ។ ជាលទ្ធផល អត្រាកំណើនឥណទានមានការថយចុះសន្សឹមៗ ក្នុងកម្រិតមួយសមស្របដែលបន្តគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច ជាពិសេស ការវិនិយោគ។

**២.២២-** ***អតិផរណា៖*** អតិផរណាបានកើនឡើងបន្តិចពី ១,២% ក្នុងឆ្នាំ២០១៥ ដល់ ៣,០% ក្នុងឆ្នាំ២០១៦ ដែលជាលទ្ធផលនៃការកើនឡើងតម្លៃ ដូចជា ប្រេង ម្ហូបអាហារ ភោជនីយដ្ឋាន សេវាសុខភាព និងគ្រឿងសង្ហារឹម។ ទន្ទឹមនឹងនេះដែរ តម្លៃលំនៅដ្ឋាន សម្ភារៈប្រើប្រាស់ និងការដឹកជញ្ជូន ស្ថិតនៅអវិជ្ជមាន។

**២.២៣-**បន្ទាប់ពីការធ្លាក់ចុះនៃតម្លៃប្រេងអន្តរជាតិមកកម្រិតទាបខុសធម្មតាកាលពីឆ្នាំ ២០១៥ ដែលធ្វើឲ្យអត្រាអតិផរណាធ្លាក់ចុះមកត្រឹម ១,២% អតិផរណាបានងើបឡើងវិញក្នុងអត្រា ៣,០% នាឆ្នាំ២០១៦ ដោយសារតម្លៃប្រេងបានបន្តកើនឡើងវិញជាបន្តបន្ទាប់ បន្ទាប់ពីមានការព្រមព្រៀងគ្នាលើការកំណត់ទំហំប្រេងដែលត្រូវផ្គត់ផ្គង់លើទីផ្សាររបស់អង្គការ*OPEC* គួបផ្សំនឹងការងើបឡើងវិញនូវតម្លៃទំនិញមួយចំនួនផ្សេងទៀតលើទីផ្សារអន្តរជាតិ។

## ៤- ភាពបើកចំហនៃសេដ្ឋកិច្ច

**២.២៤-** កម្ពុជាបានក្លាយជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក*(WTO)* ក្នុងឆ្នាំ២០០៤ ហើយត្រូវបានទាមទារឲ្យរក្សាបាននូវសេដ្ឋកិច្ចបើកចំហ។ មានការបង្ហាញជាច្រើនថាប្រទេសកម្ពុជានៅតែបន្តមានការបើកចំហសេដ្ឋកិច្ច និងសេដ្ឋកិច្ចផ្អែកលើការនាំចេញ។ ជាការពិតណាស់ កម្ពុជាអាចនៅបន្តកំណើនសេដ្ឋកិច្ចបានដោយពឹងផ្អែកយ៉ាងខ្លាំងលើការបើកចំហសេដ្ឋកិច្ចនេះ។

**២.២៥-** សូចនាករគន្លឹះពីរត្រូវបានប្រើក្នុងការវាយតម្លៃពីការបើកចំហសេដ្ឋកិច្ច៖

***ទី១*** គឺសារៈសំខាន់នៃពាណិជ្ជកម្មនិងសមាមាត្រនៃការនាំចូលនិងការនាំចេញ (ពាណិជ្ជកម្ម) ដែលធៀបទៅនឹងផលិតផលក្នុងស្រុកសរុប។ ការនាំចេញជាសមាមាត្រនៃផលិតផលក្នុងស្រុកសរុប ដែលទំនងជានឹងមានស្ថិរភាពក្នុងកម្រិត ៤៦,២% ខណៈដែលការនាំចូលធ្លាក់ចុះពី ៦៦,០% នៅឆ្នាំនេះដល់ ៦៣,០% នៅឆ្នាំក្រោយ។

***ទី២*** គឺទំហំនៃលំហូរចូលវិនិយោគពីបរទេស (ឧទាហរណ៍ និន្នាការនៅក្នុងការវិនិយោគបរទេស)។ ទំហំវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងផងដែរក្នុងចំណែកនៃ ផ.ស.ស.។ វិនិយោគផ្ទាល់ពីបរទេសសរុបមានប្រហែល១០% នៃ ផ.ស.ស. នៅឆ្នាំ២០១៤ និងឆ្នាំ២០១៥។ សម្រាប់ឆ្នាំ ២០១៥ ចំនួនទឹកប្រាក់នៃការវិនិយោគផ្ទាល់ពីបរទេសមាន ១,៧៣ពាន់លានដុល្លារ (៩,៦% នៃ ផ.ស.ស.)។ ចំនួននេះទាបជាងគោលដៅក្នុង ផ.យ.អ.ជ. ដែលបានកំណត់ ១៣,១% នៅឆ្នាំ ២០១៥ និង ១៣,២% នៅឆ្នាំ ២០១៨។ រហូតមកដល់ពេលនេះ វិនិយោគផ្ទាល់ពីបរទេសត្រូវបានគេមើលឃើញថា ភាគច្រើនមានចំនួនតូចនៅឡើយនៃការវិនិយោគដែលមានតម្លៃខ្ពស់។ លំហូរវិនិយោគផ្ទាល់ពីបរទេសនៅក្នុងរយៈពេល០៦ខែដំបូងនៃឆ្នាំនេះមានចំនួនប្រហែល ៥១១លានដុល្លារ កើនឡើងពី ៤៨១លានដុល្លារ នៅក្នុងខែដូចគ្នានៃឆ្នាំ២០១៥។ ឃើញថាតិចជាងមួយភាគបួននៃលំហូរវិនិយោគផ្ទាល់ពីបរទេសទាំងនេះបានទៅលើវិស័យធនាគារ ហើយសមាមាត្រខ្ពស់នៃលំហូរទាំងនេះបានចូលទៅក្នុងវិស័យផលិតភាព។

## ៥- ជញ្ជីងទូទាត់កម្ពុជា

**២.២៦-** ជញ្ជីងទូទាត់កម្ពុជា បន្តមានស្ថានភាពល្អប្រសើរ។ ការធ្លាក់ចុះតម្លៃប្រេងបច្ចុប្បន្ន មានឥទ្ធិពលជាវិជ្ជមានលើតុល្យភាពគណនីចរន្ត។ ជាការប្រសើរណាស់សម្រាប់ការធ្លាក់ចុះតម្លៃប្រេង ដែលធ្វើឲ្យការនាំចេញមានភាពប្រសើរឡើង ឱនភាពគណនីចរន្តស្មើនឹង ៧,២% នៃ ផ.ស.ស ក្នុងឆ្នាំ២០១៦។ ឱនភាពគណនីចរន្តត្រូវបានផ្តល់ហិរញ្ញប្បទានដោយលំហូរវិនិយោគផ្ទាល់បរទេសយ៉ាងខ្លាំង ដែលត្រូវបានគេប៉ាន់ប្រមាណថាប្រហែល ១០% នៃ ផ.ស.ស ក្នុងអំឡុងឆ្នាំ ២០១២-២០១៥។ លំហូរវិនិយោគផ្ទាល់បរទេស និងការនាំចេញសម្លៀកបំពាក់ មានភាពប្រសើរឡើង នោះធ្វើឲ្យទុនបម្រុងអន្តរជាតិដុលមានការកើនឡើងរហូតដល់ ៦,៧ពាន់លានដុល្លារ (ឬ ៥,៥ ខែនៃការនាំចូល ស្របនឹងចំណុចដៅ ផ.យ.អ.ជ ដែលកំណត់ ៥,៥ ខែ នៅចុងឆ្នាំ២០១៦ កើនឡើងពី ៥,១ ពាន់លានដុល្លារ នៅឆ្នាំ២០១៥)។

**២.២៧-** ដោយសារតែការថយចុះតិចតួចនៅក្នុងការនាំចូល នោះឱនភាពពាណិជ្ជកម្ម និងឱនភាពគណនីចរន្ត (គិតជាភាគរយនៃ ផ.ស.ស) នឹងមានស្ថានភាពប្រសើរឡើងជាលំដាប់ទាំងឆ្នាំនេះ និងឆ្នាំក្រោយ។ ការនាំចេញជាសមាមាត្រនៃ ផ.ស.ស មានស្ថិរភាពនៅកម្រិត ៤៥,៨% ខណៈដែល ការនាំចូលធ្លាក់ចុះមក ៧៣,០% នៅឆ្នាំនេះពី ៧៥,៩% នៅឆ្នាំមុន។ ដោយជំនួយអភិវឌ្ឍន៍ផ្លូវការមានស្ថេរភាពនោះ ឱនភាពពាណិជ្ជកម្ម និងឱនភាពគណនីចរន្តបានប្រសើរឡើងផងដែរ បន្ទាប់មកទៀតបានថយចុះមក ៨,២% នៃ ផ.ស.ស នៅឆ្នាំនេះពី ៩,៣% នៅឆ្នាំមុន។ ជាមួយនឹងការកែលម្អនៅក្នុងឱនភាពគណនីចរន្ត លំហូរវិនិយោគផ្ទាល់បរទេសមានស្ថេរភាព ធ្វើឲ្យសមតុល្យជញ្ជីងទូទាត់កម្ពុជារក្សាកម្រិតមួយប្រកបដោយនិរន្តរភាព។

## ៦- ភាពក្រីក្រនិងការងារ

### *៦.១- ភាពក្រីក្រនិងវិសមភាព*

២.២៨- ការកាត់បន្ថយភាពក្រីក្រ គឺជាសសរស្ដម្ភសំខាន់របស់គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់រដ្ឋាភិបាល។ កំណើនសេដ្ឋកិច្ចកើនឡើងធ្វើឲ្យមានឥទ្ធិពលយ៉ាងខ្លាំងនិងមានភាពវិជ្ជមានលើការកាត់បន្ថយភាពក្រីក្រ។ សមិទ្ធផលនានារបស់រាជរដ្ឋាភិបាល ជាពិសេសទាក់ទងនឹងការកាត់បន្ថយភាពក្រីក្រគួរឲ្យចាប់អារម្មណ៍៖ ភាពក្រីក្រត្រូវបានកាត់បន្ថយពី ២១,១% ក្នុងឆ្នាំ២០១០ មកនៅ ១៣,៥% នៅឆ្នាំ២០១៤ កម្រិតនៃការធ្លាក់ចុះនេះសម្រេចបានមុនឆ្ងាយពីចំណុចដៅរបស់ *គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា* ដែលបានកំណត់នៅត្រឹម ១៩,៥% និង ១៣,៨% ក្នុង ផ.ស.អ.ជ នៅឆ្នាំ២០១៨។ ទោះបីយ៉ាងណាការកាត់បន្ថយភាពក្រីក្រនៅមានភាពមិនស្មើគ្នាទៅតាមតំបន់នៃប្រទេស តំបន់ខ្លះសម្រេចបាននូវកម្រិតខ្ពស់នៃការកាត់បន្ថយភាពក្រីក្រ ខណៈដែលនៅតំបន់ផ្សេងទៀតដូចជានៅភាគឦសាននៅមានអត្រាខ្ពស់ការកាត់បន្ថយភាពក្រីក្រនៅមានកម្រិតជវភាពតិចតួចនៅឡើយ។ កម្រិតភាពក្រីក្រនៅតែបន្តមានច្រើនតំបន់ជនបទបើធៀបនឹងតំបន់ទីប្រជុំជន។

២.២៩- ភាពក្រីក្រម្ហូបអាហារត្រូវបានកាត់បន្ថយមកនៅសូន្យក្នុងឆ្នាំ២០១៤ កម្រិតនេះសម្រេចបានមុននិងលើសចំណុចដៅក្នុង *គោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា* ដែលបានកំណត់ ១០%។ នេះបង្ហាញថាមានភាពរីកចម្រើនយ៉ាងខ្លាំងផ្នែកសន្តិសុខស្បៀងសម្រាប់ប្រជាជនកម្ពុជា ដែលភាគច្រើនជាអ្នកប្រើប្រាស់ម្ហូបអាហារក្នុងក្រុមបញ្ចភាគទាំងអស់។ ទោះជាយ៉ាងនេះក្ដី ការប្រសើរឡើងនៃសន្តិសុខស្បៀងមិនមានន័យថាបានលើកកម្ពស់អាហារូបត្ថម្ភនោះទេ។ ជាក់ស្ដែងសូចនាករហារូបត្ថម្ភកុមារ ដូចជាកុមារគ្រិននៅមានកម្រិតខ្ពស់គួរឲ្យបារម្ភ។

២.៣០- ប្រជាជនភាគច្រើននៃអ្នកដែលបានចាកចេញពីភាពក្រីក្រ គឺគ្រាន់តែជីវភាពសមល្មមប៉ុណ្ណោះតែនៅមានការលំបាកច្រើន មានមួយភាគធំនៃសមាមាត្រនៃចំនួនប្រជាជនដែលរស់នៅលើខ្សែបន្ទាត់ភាពក្រីក្រ។ ប្រជាជនទាំងនោះគឺជាជនងាយរងគ្រោះ ងាយនឹងធ្លាក់ចុះមកភាពក្រីក្រវិញ ដោយសារតែជួបវិបត្តិដូចជា ជំងឺ និង គ្រោះធម្មជាតិ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់ឬសេដ្ឋកិច្ចសកលធ្លាក់ចុះ (វិបត្តិសេដ្ឋកិច្ច)។ វិធានការដើម្បីជួយជនងាយរងគ្រោះទាំងនោះ រួមមានទាំងការគាំការពារសង្គមត្រូវគិតគូរបន្ថែមទៀត ដើម្បីឲ្យការកាត់បន្ថយភាពក្រីក្រនៅលើគោលជំហរកាន់តែមាននិរន្តរភាព និងបរិយាប័ន្ន ដែលអាចធ្វើឲ្យគ្រួសារដែលងាយរងគ្រោះមានភាពរឹងមាំដើម្បីទប់ទល់នឹងផលប៉ះពាល់នៃវិបត្តិផ្សេងៗ។

២.៣១- ***ភាពក្រីក្រនិងវិសមភាព៖*** មេគុណជីនី គឺវាស់វិសមភាពប្រាក់ចំណូលដែលបានធ្វើឲ្យប្រសើរឡើងពី០,៤១ ក្នុងឆ្នាំ២០០៧ មក ០,២៩ ក្នុងឆ្នាំ២០១៤។ នៅពេលជាមួយគ្នានេះដែរការប្រើប្រាស់ក្នុងចំណោមបញ្ចភាគទាបបំផុតនៃចំនួនប្រជាជនបានកើនឡើងពី ៦,៨៥% ក្នុងឆ្នាំ២០០៧ ទៅ ៨,៤% នៅឆ្នាំ២០១៤ ដោយសារកំណើនយឺតនៅក្នុងវិស័យកសិកម្មដែលប្រជាជនកម្ពុជាភាគច្រើនរស់នៅនិងធ្វើការងារពឹងផ្អែកលើវិស័យនេះ។

### ៦.២- ភាពមានការងារធ្វើ

២.៣២- ភាគលាភប្រជាសាស្ត្ររបស់ប្រទេសកម្ពុជាត្រូវបានជួយជំរុញកំណើនសេដ្ឋកិច្ច និងប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់។ នេះគឺជាលទ្ធផលនៃកម្លាំងពលកម្មកើនឡើងលឿនជាងចំនួនប្រជាជនដែលពឹងផ្អែកក្នុងបន្ទុក ដែលជាធនធានបន្ថែមសម្រាប់ការវិនិយោគ។ ប្រជាជនក្នុងអាយុធ្វើការរបស់កម្ពុជា (១៥-៦៤ឆ្នាំ) បានកើនឡើង៖ ជាមធ្យមប្រជាជនប្រមាណ ១៦២ ០០០ បន្ថែមទៀតក្នុងមួយឆ្នាំក្លាយទៅជាកម្លាំងពលកម្ម។ ចំណែកនៃវិស័យកសិកម្មក្នុងការងារសរុបបានធ្លាក់ចុះពី ៥៧,៦% ក្នុងឆ្នាំ២០០៩ ដល់ ៤៥,៣% នៅឆ្នាំ២០១៤ គឺទាបជាងការព្យាករ ក្នុង ផ.យ.អ.ជ. ៥៧% នៅឆ្នាំ២០១៨។ អំឡុងពេលដូចគ្នានេះដែរចំណែកនៃការងារក្នុងវិស័យឧស្សាហកម្ម និងសេវាកម្មបានកើនឡើង ២៤,៣% និង ៣០,៤%។ ចំណែកវិស័យឧស្សាហកម្មវិញ កើនខ្ពស់ជាងការព្យាករក្នុង ផ.យ.អ.ជ. ដែលកំណត់ ១៣% សម្រាប់ឆ្នាំ ២០១៨។ ចំណែកនៃការងារនៅក្នុងវិស័យសេវាកម្ម គឺស្របតាមការព្យាករក្នុង ផ.យ.អ.ជ សម្រាប់ឆ្នាំ ២០១៨។ ការផ្លាស់ប្ដូរចំណែកនៃវិស័យការងារនេះអាចឆ្លុះបញ្ចាំងពីការកែតម្រូវរចនាសម្ព័ន្ធខាងលើ។ និន្នាការនេះអាចនឹងបន្ត ក្នុងផលិតភាព និងប្រាក់ឈ្នួលខ្ពស់ជាងនៅទីប្រជុំជនដែលជាការទាក់ទាញជនចំណាកស្រុកពីតំបន់ជនបទ។ នៅក្នុងពេលយូរអង្វែង បង្កើនផលិតភាពនៃកម្លាំងពលកម្មគឺអាស្រ័យលើការពង្រឹងសមត្ថភាពរបស់ប្រជាជនកម្ពុជាក្នុងការពង្រឹងការអភិវឌ្ឍធនធានមនុស្សនិងការលើកកម្ពស់ការវិនិយោគលើសេដ្ឋកិច្ចចម្រុះ។

២.៣៣- ***សមាសភាពយេនឌ័រនៅក្នុងកម្លាំងពលកម្ម៖*** នៅឆ្នាំ២០១៥ ការងាររបស់ស្ត្រីក្នុងវិស័យទទួលប្រាក់ឈ្នួល បានឈានដល់ ៤២,៩% ក្នុងវិស័យកសិកម្ម ៤៩%។ សមាមាត្រនៃស្ត្រីធ្វើការនៅក្នុងវិស័យឧស្សាហកម្មក្នុងពេលនេះថយចុះពី ៧៣,៧% ក្នុងឆ្នាំ២០១០ មក ៤៦,១% ក្នុងឆ្នាំ២០១៥។ វិស័យសេវាកម្មមានការកើនឡើងពី ៣៥% ក្នុងឆ្នាំ២០១៣ ទៅ ៣៦% ក្នុងឆ្នាំ២០១៥ គឺនៅទាបជាងចំណុចដៅដែលបានកំណត់ក្នុង ផ.យ.អ.ជ. បានកំណត់ ៥០%។

## ៧- សេចក្ដីសន្និដ្ឋាន

២.៣៤- សូចនាករស្នូលនៃម៉ាក្រូសេដ្ឋកិច្ចបានបង្ហាញថាស្ថានភាពម៉ាក្រូសេដ្ឋកិច្ចនៅបន្តល្អក្នុងអំឡុងពេលពាក់កណ្ដាលដំបូងនៃការអនុវត្ត *ផ.យ.អ.ជ ២០១៤-២០១៨*។ ជាលទ្ធផលប្រទេសមានការរីកចម្រើនជាមួយនឹងកំណើន ផ.ស.ស. និងការកាត់បន្ថយភាពក្រីក្របានយ៉ាងឆាប់រហ័ស។ វាដូចជា បានបញ្ជាក់ប្រាប់ថា ការរៀបចំឡើងវិញនូវរចនាសម្ព័ន្ធសេដ្ឋកិច្ចកំពុងបង្កើនល្បឿនឡើងដែលជាចំណែកនៃ ផ.ស.ស. ក្នុង វិស័យកសិកម្មធ្លាក់ចុះឆាប់រហ័សបើធៀបទៅនឹងវិស័យឧស្សាហកម្ម។

២.៣៥- ដើម្បីឲ្យសមិទ្ធផលទាំងនេះមានចីរភាព គឺត្រូវការនូវកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីជំរុញផលិតភាព បង្កើនការប្រកួតប្រជែង និងការធានាថាផលនៃកំណើននេះគឺប្រកបដោយបរិយាប័ន្ន។ វិស័យអាទិភាពមួយចំនួនទៀតរួមមាន ការកាត់បន្ថយតម្លៃចំណាយលើថាមពល ការលើកកម្ពស់ការតភ្ជាប់ការដឹកជញ្ជូន (ឧទាហរណ៍ "ការតភ្ជាប់") និងការដោះស្រាយគម្លាតនៃជំនាញដោយបង្កើនគុណភាពនៃការអប់រំជាពិសេសសម្រាប់កុមារី និង ការលើកកម្ពស់ការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈស្ត្រីវ័យក្មេងដែលមានអត្រាទាបក្នុងការចូលរួមក្នុងកម្លាំងពលកម្ម។ ទាំងនេះនិងជំហានផ្សេងទៀតត្រូវបានរៀបរាប់នៅ

ក្នុង*គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ២០១៥-២០២៥* ដែលដាក់ឲ្យអនុវត្ត ដោយរាជរដ្ឋាភិបាល កាលពីឆ្នាំ២០១៥។

២.៣៦-មានសារៈសំខាន់ខ្លាំងណាស់ក្នុងការបន្តការដោះស្រាយឧបសគ្គនៃរចនាសម្ព័ន្ធកំណើន និងភាពងាយរងគ្រោះ។ ទាំងនេះរួមបញ្ចូលទាំងមូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត បរិយាកាសពាណិជ្ជកម្មខ្សោយ ដុល្លាររូបនីយកម្មខ្ពស់ និងទីផ្សារហិរញ្ញវត្ថុដែលមិនមានការអភិវឌ្ឍ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតទាមទារឲ្យធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចនៃសេដ្ឋកិច្ច ធ្វើឲ្យប្រសើរឡើងនូវបរិយាកាសអាជីវកម្ម អភិវឌ្ឍន៍ទីផ្សារហិរញ្ញវត្ថុឲ្យកាន់តែស៊ីជម្រៅ ជំរុញការវិនិយោគនិងជួយសម្រួលដល់ប្រសិទ្ធិភាពការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច។

២.៣៧-មានបញ្ហាប្រឈមពីរបន្ថែមទៀតគឺៈ (១) ជំរុញការកាត់បន្ថយភាពក្រីក្រប្រកបដោយចីរភាពនិងបរិយាប័ន្ន ដោយធានាថា គ្រួសាររស់នៅជិតខ្សែបន្ទាត់ភាពក្រីក្រដែលងាយរងគ្រោះមិនអាចធ្លាក់ចុះមកក្នុងភាពក្រីក្រវិញនៅពេលជួបនឹងវិបត្តិផ្សេងៗឡើយ។ អាចសម្រេចទៅបានដោយជំរុញកាលានុវត្តភាពការងារឲ្យបានល្អប្រសើរជាងមុន ធ្វើឲ្យប្រសើរឡើងជាងមុននូវសេវាថែទាំសុខភាព និងវិធានការអន្តរាគមន៍សង្គម ខណៈពេលដែលការពង្រឹងភាពធន់របស់គ្រួសារងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ។ (២) ការសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងចំណោមប្រជាជនក្រីក្រខ្លាំង (គ្មានទ្រព្យសម្បត្តិ ឬអ្នកដែលមានទ្រព្យសម្បត្តិតិចតួច) ដែលត្រូវទទួលបានប្រយោជន៍ពីកំណើនសេដ្ឋកិច្ច។ គ្រួសារក្រីក្រភាគច្រើនមានជំពាក់បំណុលរួចទៅហើយ ដូច្នេះត្រូវជំរុញដល់ប្រជាជនឲ្យប្រើប្រាស់សេវាឥណទានផ្លូវការដែលអាចមានផលប៉ះពាល់តិចតួច។ វិធីសាស្ត្រមួយដែលអាចផ្ដោតទៅលើការបង្កើតទ្រព្យសម្បត្តិតាមរយៈការសន្សំក្នុងសហគមន៍ និងកម្មវិធីផ្ដល់ប្រាក់កម្ចី ព្រមទាំងការផ្ដល់ដីសម្រាប់ផលិតភាព ដោយបំពេញបន្ថែមជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធដើម្បីគាំទ្រសមស្រប (ឧទាហរណ៍ ការផ្សព្វផ្សាយសេវា ផ្ដល់ប្រព័ន្ធធារាសាស្ត្រ)។

# ជំពូកទី៣

# សមិទ្ធផលនិងបញ្ហាប្រឈមចម្បងៗក្នុងអភិបាលកិច្ចនិងវិស័យសំខាន់ៗ

## ១. សេចក្ដីផ្ដើម

៣.១- ជំពូកនេះនឹងបង្ហាញអំពី *វឌ្ឍនភាពពាក់កណ្ដាលអាណត្តិនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨* ដោយផ្ដោតតាមមុំនីមួយៗនៃ *យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣* គឺអភិបាលកិច្ចល្អ កសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ ការអភិវឌ្ឍវិស័យឯកជន និងការអភិវឌ្ឍសមត្ថភាពធនធានមនុស្ស។ ការវាយតម្លៃនេះផ្ដោតលើការកំណត់សមិទ្ធផលសំខាន់ៗ រួមទាំងភាពប្រឈមនានា ដែលជួបប្រទះក្នុងការអនុវត្តរហូតដល់ឆ្នាំ២០១៨។ សូចនាករបរិមាណមួយចំនួនត្រូវបានបង្កើតឡើងសម្រាប់វិស័យមួយចំនួន។ ក្នុងវិស័យមួយចំនួនពុំមានសូចនាករសម្រាប់វាស់វែងគ្រប់គ្រាន់ ប៉ុន្តែសូចនាករគុណភាពនឹងត្រូវយកមកវាស់វែងវឌ្ឍនភាព។

## ២- អភិបាលកិច្ចល្អ: ស្នូលនៃយុទ្ធសាស្ត្រចតុកោណ

### ២.១- ការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ

៣.២- រាជរដ្ឋាភិបាលកម្ពុជា បានផ្ដល់អាទិភាពខ្ពស់ចំពោះការងារប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងបានពង្រីក និងបង្កើនប្រសិទ្ធភាពនៃវិធានការស្នូលទាំង៣ រួមមាន៖ (១) ការពង្រឹងការអប់រំមិនឲ្យប្រព្រឹត្តអំពើពុករលួយ (២) ការបង្ការទប់ស្កាត់កុំឲ្យអាចប្រព្រឹត្តអំពើពុករលួយ និង (៣) ការបង្ក្រាបបទល្មើសបញ្ជូនទៅតុលាការចំពោះជនដែលនៅតែហ៊ានប្រព្រឹត្តអំពើពុករលួយ ***ដែលសម្រេចបានសមិទ្ធផលដូចខាងក្រោម៖***

- បានបន្តជំរុញការងារអប់រំ ផ្សព្វផ្សាយច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយសំដៅបំផុសការចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយពីមន្ត្រីរាជការ សិស្ស-និស្សិត ប្រជាពលរដ្ឋ និងវិស័យឯកជន។
- បានសម្រេចជោគជ័យក្នុងការបញ្ចូលមេរៀនស្ដីពីការប្រឆាំងអំពើពុករលួយទៅក្នុងកម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា ទាំង៣កម្រិតសិក្សា៖ វិទ្យាល័យ អនុវិទ្យាល័យ និង បឋមសិក្សា ចាប់ពីថ្នាក់ទី៤ ដល់ទី១២ ក្នុងឆ្នាំសិក្សា២០១៤ ដល់ ២០១៦។
- ក្រៅពីក្រសួងអប់រំ យុវជន និង កីឡា ដែលនៅរក្សាបានលទ្ធផលដ៏ខ្ពស់នៃការកែទម្រង់ការប្រឡងបាក់ឌុប ក៏នៅមានក្រសួងស្ថាប័នជាច្រើនទៀតដែលបានចាត់ការប្រឡងក្របខណ្ឌក្រោមការសង្កេតការណ៍ផ្ទាល់ពីអង្គភាពប្រឆាំងអំពើពុករលួយ។
- ក្រសួង ស្ថាប័ន បានធ្វើលទ្ធកម្មចំនួន៨៣១លើក នៅលើគម្រោងចំនួន៧២១គម្រោងដោយមានការសង្កេតការណ៍ពីអង្គភាពប្រឆាំងអំពើពុករលួយ។
- បានចុះអនុស្សរណៈនៃការយោគយល់គ្នារវាងក្រុមហ៊ុន សមាគមជាតិ-អន្តរជាតិ គ្រឹះស្ថានឧត្តមសិក្សាបានចំនួន២៥ ដែលក្នុងនោះមានក្រុមហ៊ុនជាង៣០០ និងគ្រឹះស្ថាន

ឧត្តមសិក្សាឯកជនជាង៣០នៅកម្ពុជា។

- បានកសាងសំណុំរឿងបញ្ជូនទៅតុលាការបាន៣៧ករណី បន្ថែមលើការធ្វើលិខិតព្រមាន និងកិច្ចសន្យាបញ្ឈប់កំហុសឆ្គងជាច្រើនករណីទៀត។
- គ្រប់ក្រសួង ស្ថាប័នរបស់រដ្ឋក៏បានពង្រឹងការទទួលពាក្យប្តឹងរបស់ប្រជាជន ហើយអង្គភាពប្រឆាំងអំពើពុករលួយវិញ បានរៀបចំយន្តការទទួលពាក្យបណ្តឹងតាមគ្រប់រូបភាពងាយស្រួល និងអាចចូលរួមបានពីគ្រប់មជ្ឈដ្ឋាន។
- យន្តការដោះស្រាយពាក្យប្តឹងត្រូវបានពង្រឹង និង កែសម្រួលជាបន្តបន្ទាប់ឲ្យកាន់តែប្រសើរឡើងថែមទៀត។
- ក្រៅពីការងារប្រយុទ្ធប្រឆាំងអំពើពុករលួយ ដែលដឹកនាំដោយអង្គភាពប្រឆាំងអំពើពុករលួយដែលជាស្ថាប័នមួយឯករាជ្យពីស្ថាប័នរាជរដ្ឋាភិបាល រាជរដ្ឋាភិបាលកម្ពុជាផ្ទាល់មានសកម្មភាពជាច្រើនក្នុងការចេញលិខិតបទដ្ឋាន ទាំងការកែទម្រង់សំដៅបិទចន្លោះប្រហោងកុំឲ្យមានអំពើពុករលួយអាចកើតបាន ក៏ដូចជាការលុបប្រព័ន្ធចាស់ដោយរៀបចំជាប្រព័ន្ធថ្មីដែលមានភាពស្អាតស្អំ រឹងមាំគួរទុកចិត្តបាន (ឧទាហរណ៍ ការបើកប្រាក់បៀវត្សរ៍តាមម៉ាស៊ីន ATM ការលុបចោលប្រភេទសេវាខ្លះដែលមិនល្អធ្វើឲ្យមនុស្សឆ្លៀតឱកាសបាន)។ បង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្មសម្រាប់ការចុះបញ្ជីពាណិជ្ជកម្ម ការស្នើសុំវិញ្ញាបនបត្រប្រភពដើមទំនិញ ការទូទាត់កម្រៃសេវាសាធារណៈជូនរដ្ឋ តាមប្រព័ន្ធធនាគារពាណិជ្ជកម្ម ជាដើម។

៣.៣- *ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច* បានបន្តប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយតាមរយៈយុទ្ធសាស្ត្រធំៗ ចំនួន០៣ គឺការពង្រឹងផ្នែកផ្សព្វផ្សាយច្បាប់ ការពង្រឹងអធិការកិច្ច និងការពង្រឹងស្ថាប័ននិងអភិវឌ្ឍន៍ធនធានមនុស្ស។

៣.៤- ក្រសួងបានអនុវត្តការងារផ្សព្វផ្សាយច្បាប់អាទិភាពទាំង១១ ដែលរួមមាន៖ ច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ច្បាប់ព្រៃឈើ ច្បាប់ជលផល និងការគ្រប់គ្រងធនធានទឹក ច្បាប់ភូមិបាល ច្បាប់នៃការគ្រប់គ្រងគ្រឿងញៀន ច្បាប់នៃការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងការពារជនរងគ្រោះ ច្បាប់ស្តីពីការបង្ក្រាបល្បែងស៊ីសង ច្បាប់នៃកិច្ចការពារបរិស្ថាននិងគ្រប់គ្រងធម្មជាតិ ច្បាប់ស្តីពីការគ្រប់គ្រងលើវិស័យ ឯកជនក្នុងវិស័យវេជ្ជសាស្ត្រអមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីការទប់ស្កាត់ការរីករាលដាលនៃមេរោគអេដស៍និងជំងឺអេដស៍ ដល់ប្រជាជានទូទាំងរាជធានី ខេត្ត។

៣.៥- **ការពង្រឹងវិស័យអធិការកិច្ច៖** ក្រសួងបានយកចិត្តទុកដាក់អនុវត្តសកម្មភាពការងារអាទិភាពចំនួន៣ គឺ (១)ការងារអធិការកិច្ច (២)ការងារទទួល និងដោះស្រាយពាក្យបណ្តឹង (៣) ការងារតាមដានការអនុវត្តច្បាប់។ ក្រសួងបានតាមដានការអនុវត្តច្បាប់ក្នុងវិស័យមួយចំនួន ដូចជាលទ្ធកម្មសាធារណៈ វិនិយោគ ច្បាប់ព្រៃឈើ ការគ្រប់គ្រងធនធានធម្មជាតិ ទេសចរណ៍ និង

សុខាភិបាល។ ជាលទ្ធផលជាក់ស្តែង ក្រសួងសម្រេចបានការងារ អាទិភាពចម្បងៗទាំង០៣ដូចជា៖ ការងារទទួលនិងដោះស្រាយពាក្យបណ្តឹងក្រសួងបានទទួលពាក្យបណ្តឹងសរុបចំនួន១៧៩ បណ្តឹងដែលភាគច្រើនជារឿងវិវាទដីធ្លី។ ពាក្យបណ្តឹងដែលបានបញ្ជូនទៅសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីដោះស្រាយសរុបចំនួន៤៩បណ្តឹងនិងទទួលបានការឆ្លើយតបវិញចំនួន០៤បណ្តឹង។ ការងារអធិការកិច្ច គឺបានធ្វើអធិការកិច្ចលើការគ្រប់គ្រងរដ្ឋបាល ហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋតាមបណ្តាក្រសួង ស្ថាប័ន និងមន្ទីររាជធានី-ខេត្ត ។ បានចុះតាមដានការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាច្រើនដូចជា៖ ច្បាប់ស្តីពីការវិនិយោគ កិច្ចលទ្ធកម្មសាធារណៈ ការយកភាស៊ី និងការគ្រប់គ្រងសត្តឃាត ច្បាប់ព្រៃឈើ ច្បាប់នៃកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ ទេសចរណ៍ និងបរិស្ថាន ច្បាប់ស្តីពីការគ្រប់គ្រងលើវិស័យឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ច្បាប់ស្តីពីការគ្រប់គ្រងជីកសិកម្ម ច្បាប់ជលផល នៅថ្នាក់ក្រសួងមួយចំនួន និងថ្នាក់រាជធានី-ខេត្ត (២៥រាជធានី-ខេត្ត) ។ បានធ្វើការតាមដាននិងការណែនាំកែតម្រូវលើចំណុចខ្វះខាតមួយចំនួនរបស់មន្ទីរ អង្គភាពពាក់ព័ន្ធ ក្រសួងបានទទួលលទ្ធផលឆ្លើយតបមកវិញគួរឲ្យកត់សំគាល់ ។

៣.៦- **ការពង្រឹងវិស័យអភិវឌ្ឍន៍ស្ថាប័ន និងធនធានមនុស្ស៖** ជាក់ស្តែងក្នុងរយៈពេល២ឆ្នាំកន្លះនេះ ក្រសួងបានរៀបចំការកែលម្អហេដ្ឋារចនាសម្ព័ន្ធដោយបានជួសជុលអាគារ ក្រសួងបន្ថែមសាងសង់អាគាររបស់មន្ទីរខេត្តស្ទឹងត្រែង និងបានចុះសិក្សារកទីតាំងសមស្របសម្រាប់សាងសង់មន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចនៅខេត្តកំពង់ឆ្នាំង។ ក្រសួងបានបង្កើតមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ច ខេត្តត្បូងឃ្មុំ ក្នុងឆ្នាំ ២០១៤។ បានធ្វើប្រកាសស្តីពីការកែសម្រួលតួនាទីនិងភារកិច្ចរបស់ការិយាល័យចំណុះនាយកដ្ឋាន និង មន្ទីររាជធានី-ខេត្ត។ ក្រសួងបានចាត់បញ្ជូនមន្ត្រីសរុបចំនួន៤៦នាក់ ចែកជា០២វគ្គ ដើម្បីទៅរៀនវគ្គបណ្តុះបណ្តាលជំនាញអធិការកិច្ចនៅសាធារណរដ្ឋសង្គមនិយមវៀតណាម។

**បញ្ហាប្រឈម**

៣.៧- លទ្ធផលជាក់ស្តែងឆ្លើយតបតាមផែនការនៅមានកម្រិត៖ ការអនុវត្តន៍ជាក់ស្តែង ក្រសួងមិនទាន់ឆ្លើយតបបានពេញលេញតាមគោលនយោបាយ និងសកម្មភាពអាទិភាពដែលបានកំណត់ក្នុង ផយអជ ឆ្នាំ២០១៤-២០១៨ នៅឡើយ មូលហេតុសមត្ថភាពជំនាញរបស់មន្ត្រីរាជការមួយចំនួននៅមានកម្រិត ហើយកញ្ចប់ថវិកាសម្រាប់បំពេញកាងារក៏នៅមានកម្រិតដែរពុំអាចឆ្លើយតបឲ្យបានគ្រប់គ្រាន់តាមតម្រូវការ ការងារជាក់ស្តែងនៅឡើយ ។

៣.៨- ខ្វះលិខិតបទដ្ឋានគតិយុត្តសម្រាប់បំពេញការងារ៖ ក្រសួងពុំទាន់មានច្បាប់ស្តីពីអធិការកិច្ចដើម្បីបំពេញការងារនៅឡើយ ។ មួយវិញទៀតនិតិវិធីធ្វើអធិការកិច្ច និងនិតិវិធីផ្សព្វផ្សាយច្បាប់ក៏មិនទាន់ត្រូវបានរៀបចំបង្កើតផងដែរ ភាពខ្វះចន្លោះនៃលិខិតបទដ្ឋានគតិយុត្តខាងលើនេះ

បានធ្វើឲ្យក្រសួងពុំមានមូលដ្ឋានគ្រឹះសម្រាប់ជាត្រីវិស័យចង្អុលបង្ហាញផ្លូវក្នុងការបំពេញការងារឲ្យមានប្រសិទ្ធភាពនៅឡើយ ។

## ២.២- កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌

### ការកែទម្រង់រចនាសម្ព័ន្ធ លើប្រព័ន្ធយុត្តិធម៌

៣.៩- ក្នុងគោលបំណងបង្កិតសិទ្ធិទទួលបានយុត្តិធម៌ ឲ្យកាន់តែខិតទៅជិតប្រជាពលរដ្ឋនៅថ្នាក់មូលដ្ឋានតំបន់ខេត្តឆ្ងាយៗ សំដៅចំណេញពេលវេលា ថវិកា មធ្យោបាយធ្វើដំណើរ និងការហូបចុក ស្នាក់នៅរបស់ប្រជាពលរដ្ឋក្នុងការដោះស្រាយរឿងក្ដី ក្រសួងយុត្តិធម៌បានរៀបចំបង្កើតឲ្យមានសាលាដំបូងចំនួន ១ បន្ថែមទៀតគឺៈ សាលាដំបូងខេត្តត្បូងឃ្មុំ។ សាលាដំបូងនេះ ត្រូវបានប្រកាសសុពលភាពដាក់ឲ្យដំណើរការនៅខែកក្កដា ឆ្នាំ២០១៥។ ក្រសួងយុត្តិធម៌ បានរៀបចំតាក់តែងនិងដាក់ឲ្យអនុវត្តនូវច្បាប់មូលដ្ឋានទាំង៣ ពាក់ព័ន្ធនឹងវិស័យយុត្តិធម៌ ដែលរួមមានៈ ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និង ច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ ច្បាប់ទាំង៣នេះ ត្រូវបានអនុវត្តចាប់តាំងពីចុងឆ្នាំ២០១៤ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាពប្រព័ន្ធយុត្តិធម៌ និង ធ្វើឲ្យប្រសើរឡើងនូវគុណភាពសេវាយុត្តិធម៌ ដើម្បីធានាបាននូវឯករាជ្យភាពនៃអំណាចតុលាការ ដោះស្រាយបញ្ហាកកស្ទះសំណុំរឿងនៅតាមតុលាការ ដោយមានបង្កើតឲ្យមានអង្គភាពរដ្ឋបាលតុលាការនៅតាមសាលាជម្រះក្ដីគ្រប់ជាន់ថ្នាក់និងមានបង្កើតឲ្យមានតុលាការជំនាញផ្នែកព្រហ្មទណ្ឌ រដ្ឋប្បវេណី ពាណិជ្ជកម្ម និង ការងារ ព្រមទាំងសាលាឧទ្ធរណ៍តំបន់ផងដែរ។

### ការកសាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា

៣.១០- ក្នុងទិសដៅពង្រឹងនីតិរដ្ឋឲ្យកាន់តែរឹងមាំថែមទៀត ក្រសួងយុត្តិធម៌បានទំនាក់ទំនង និងសហការ ជាមួយអង្គការនានានៃប្រទេសដែលជាដៃគូអភិវឌ្ឍ ធ្វើការតាក់តែង និងកសាងនូវសេចក្ដីព្រាងច្បាប់មូលដ្ឋានសំខាន់ៗជាច្រើន ដែលប្រទេសកម្ពុជាយើងកំពុងត្រូវការជាចាំបាច់បំផុត។ ច្បាប់ជាតិ និងលិខិតបទដ្ឋានគតិយុត្តនានា ដែលបានកសាងរួចនិងបានចូលជាធរមាន មានដូចជាច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា ជាដើម ហើយសេចក្ដីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនទៀតកំពុងត្រូវបានរៀបចំឡើង។

### ការអប់រំនិងផ្សព្វផ្សាយច្បាប់

៣.១១- *ក្រសួងយុត្តិធម៌*បានចុះអនុវត្តការអប់រំ និងផ្សព្វផ្សាយច្បាប់មូលដ្ឋាន និងច្បាប់ពាក់ព័ន្ធនឹងស្ត្រីនិងកុមារ យ៉ាងសកម្មដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និងមន្ត្រីនគរបាលយុត្តិធម៌ ព្រមទាំងមន្ត្រីរាជការនៅតាមរាជធានី-ខេត្តទូទាំងប្រទេស និងបានបោះពុម្ពចែកផ្សាយសៀវភៅច្បាប់ (ដូចជា សៀវភៅក្រមព្រហ្មទណ្ឌ សៀវភៅក្រមនីតិវិធីព្រហ្មទណ្ឌ សៀវភៅក្រមរដ្ឋប្បវេណី

សៀវភៅនីតិវិធីក្រមរដ្ឋប្បវេណី ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្សនិងអំពើធ្វើអាជីវកម្មផ្លូវភេទ) និងផ្សព្វផ្សាយច្បាប់ (ដូចជា ក្រមព្រហ្មទណ្ឌ និងក្រមរដ្ឋប្បវេណី) តាមវិទ្យុនិងទូរទស្សន៍។

### ការអភិវឌ្ឍធនធានមនុស្ស

៣.១២- *ក្រសួងយុត្តិធម៌*បានរៀបចំបណ្តុះបណ្តាលជាច្រើនស្តីពី ច្បាប់ជាតិ-អន្តរជាតិពាក់ព័ន្ធនឹងស្ត្រីៗ ក្រមព្រហ្មទណ្ឌនិងក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណីនិងក្រមនីតិវិធីរដ្ឋប្បវេណី ការចុះបញ្ជីសំណុំរឿងក្តី និងជំនាញផ្សេងៗ ជូនដល់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មន្ត្រីនគរបាលយុត្តិធម៌ និងមន្ត្រីរាជការ នៅតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស។ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ បាននិងកំពុងបន្តអនុវត្តបច្ចេកទេសគរុកោសល្យសិស្សចៅក្រម សិស្សក្រឡាបញ្ជី សិស្សអាជ្ញាសាលា និងសិស្សសារការី។

### សេវាការពារក្តីជូនជនក្រីក្រ

៣.១៣- ក្នុងការអនុវត្តការងារផ្តល់ជំនួយផ្នែកច្បាប់ដល់ជនក្រីក្រ ក្រសួងយុត្តិធម៌បានធ្វើការសហការយ៉ាងជិតស្និទ្ធ ជាមួយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងបានផ្តល់ថវិកាចំនួន ៣០០ លានរៀលក្នុងឆ្នាំ ២០១៥ និងចំនួន ៤០០ លានរៀល ក្នុងឆ្នាំ ២០១៦ សម្រាប់រៀបចំមេធាវីដើម្បីការពារក្តីដល់ជនក្រីក្រទៅតាមសំណើរបស់តុលាការ និងសាមីខ្លួន។

៣.១៤- **បញ្ហាប្រឈម**

- កង្វះខាតថវិកានិងធនធានមនុស្ស ដែលចាំបាច់សម្រាប់គាំទ្រកិច្ចដំណើរការការងារ ក្នុងវិស័យយុត្តិធម៌ នៅពុំទាន់បានសមស្របទាំងបរិមាណ និងគុណភាព។
- ការយល់ដឹង និងការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌របស់មន្ត្រីរាជការ និងសាធារណជន នៅមានកម្រិត
- សាលាដំបូង និងអយ្យការអមសាលាដំបូងរាជធានី ខេត្ត ខ្វះបន្ទប់សម្រាប់ចៅក្រមតំណាងអយ្យការ ក្រឡាបញ្ជី និងផ្នែករដ្ឋបាលសម្រាប់ធ្វើការងារ
- កង្វះខាតកញ្ចប់ថវិកាសម្រាប់ដំណើរការនីតិវិធីតុលាការ
- ដំណើរការចំណាត់ការរឿងក្តីមានការយឺតយ៉ាវ

## ២.៣- កំណែទម្រង់រដ្ឋបាលសាធារណៈ

៣.១៥- *ក្រសួងមុខងារសាធារណៈ* មានតួនាទីដឹកនាំការអនុវត្តកំណែទម្រង់រដ្ឋបាលសាធារណៈ។ ផែនការសកម្មភាពសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុម័តនៅខែមករា ឆ្នាំ២០១៥។ យន្តការសម្របសម្រួលសម្រាប់កំណែទម្រង់រដ្ឋបាលសាធារណៈ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការងារវិមជ្ឈការនិងវិសហមជ្ឈការ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ

២០១៥។ កិច្ចប្រជុំរបស់យន្តការសម្របសម្រួលត្រូវបានរៀបចំឡើងទៀតទាត់រាល់ត្រីមាស ដើម្បីធ្វើសមាហរណកម្មរបៀបវារៈកំណែទម្រង់របស់រាជរដ្ឋាភិបាល។

## ៣.១៦- ការកែលម្អគុណភាពសេវាសាធារណៈ

ក្រសួងមុខងារសាធារណៈ និង គណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈបានសហការជាមួយថ្នាក់ដឹកនាំ និងមន្ត្រីរាជការរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងការត្រួតពិនិត្យនិងកែលម្អបែបបទនិងនីតិវិធីក្នុងការផ្តល់សេវាសាធារណៈ ដើម្បីបង្កើនគុណភាពនិងប្រសិទ្ធភាព រួមទាំងផ្លាស់ប្ដូរផ្នត់គំនិតនិងឥរិយាបទមន្ត្រីរាជការក្នុងការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋឲ្យកាន់តែល្អប្រសើរឡើង។ ក្នុងផ្នែកនេះសមិទ្ធផលសំខាន់ៗសម្រេចបានរួមមាន៖

- បានរៀបចំបង្កើតនិងដាក់ឲ្យដំណើរជាផ្លូវការកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមរយៈទូរស័ព្ទស្មាតហ្វូន។
- បានចងក្រងនិងធ្វើសុក្រិត្យភាពលើបច្ចុប្បន្នកម្មកម្រងព័ត៌មានសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន តាមរយៈកិច្ចប្រជុំអន្តរក្រសួងនិងការជួបជាមួយក្រុមការងារ បានចំនួន ២៦ ក្រសួង ស្ថាប័ន។
- កម្រងព័ត៌មានសេវាសាធារណៈត្រូវបានធ្វើបច្ចុប្បន្នភាព និងដាក់បញ្ចូលក្នុងកម្មវិធីផ្តល់ព័ត៌មានសេវាសាធារណៈតាមទូរស័ព្ទស្មាតហ្វូន ដែលអ្នកប្រើប្រាស់ទូរស័ព្ទស្មាតហ្វូនអាចស្វែងរកព័ត៌មាន ស្តីពីសេវាសាធារណៈគ្រប់សេវាដែលផ្តល់ដោយ ក្រសួងស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បានពង្រីករៀបចំ និងដាក់ឲ្យអនុវត្តយន្តការទីភ្នាក់ងារប្រតិបត្តិការពិសេស នៅក្រសួងសុខាភិបាលចំនួន៤បន្ថែមទៀតរួមមាន៖ មន្ទីរពេទ្យបង្អែកខេត្តកំពត ខេត្តព្រៃវែង ខេត្តក្រចេះ និងខេត្តកំពង់ធំ។
- យន្តការនៃការផ្តល់សេវានិងគុណភាពនៃសេវាសាធារណៈរបស់ក្រសួង ស្ថាប័ន រួមមានក្រសួងពាណិជ្ជកម្ម ក្រសួងយុត្តិធម៌ ក្រសួងសាធារណការនិងដឹកជញ្ជូន និងក្រសួងដែនដីនគរូបនីយកម្ម និងសំណង់ត្រូវបានត្រួតពិនិត្យ និងផ្តល់អនុសាសន៍ឱ្យធ្វើការលម្អដោយលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ។
- បានរៀបចំធ្វើទស្សនកិច្ចសិក្សានៃការផ្តល់សេវាសាធារណៈនៅព្រះរាជាណាចក្រថៃឡង់លើប្រធានបទស្តីពីការផ្តល់សេវាសាធារណៈនៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិមួយចំនួនដូចជា៖ មន្ទីរពេទ្យនគរបាល នាយកដ្ឋានកុងស៊ុលនៃក្រសួងការបរទេស មជ្ឈមណ្ឌលផ្តល់សេវាវិនិយោគ មជ្ឈមណ្ឌល ផ្តល់វិញ្ញាបនបត្រនាំចេញនៃក្រសួងពាណិជ្ជកម្ម នាយកដ្ឋានដឹកជញ្ជូនផ្លូវគោកនៃក្រសួងដឹកជញ្ជូន ការិយាល័យប្រជាពលរដ្ឋ គម្រោងស្រាវជ្រាវនិងអភិវឌ្ឍបរិស្ថានដែលជាគំនិតផ្តួចផ្តើមរបស់ព្រះ

មហាក្សត្រថៃ និងមជ្ឈមណ្ឌលផ្តល់សេវានៅរដ្ឋបាលខេត្តប្រាជប់គីរីខណ្ឌ។

- បាន និងកំពុងរៀបចំសេចក្តីព្រាងច្បាប់ស្តីពីសេវាសាធារណៈ។

## ៣.១៧-ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស

ផ្អែកលើគោលនយោបាយស្តីពីការគ្រប់គ្រងធនធានមនុស្សទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈបានរៀបចំលិខិតបទដ្ឋានគតិយុត្តនិងយុទ្ធសាស្ត្រសំខាន់ៗមួយចំនួនសម្រាប់ពង្រឹងការគ្រប់គ្រងនិងការត្រួតពិនិត្យចំនួនមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យារួមទាំងរចនាសម្ព័ន្ធរបស់ក្រសួងស្ថាប័នទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដើម្បីធ្វើជាមូលដ្ឋានគ្រឹះក្នុងការកែលម្អនីតិវិធីក្នុងការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស តាំងពីការជ្រើសរើសរហូតដល់ការដាក់ឲ្យចូលនិវត្តន៍ ការផ្សារភ្ជាប់ការបណ្តុះបណ្តាលជាប្រព័ន្ធនិងជាកាតព្វកិច្ចទៅនឹងការអភិវឌ្ឍអាជីព ការផ្សារភ្ជាប់ការតែងតាំងនិងការដំឡើងថ្នាក់ទៅនឹងសមិទ្ធកម្មរបស់មន្ត្រីរាជការម្នាក់ៗ ហើយនិងការផ្សារភ្ជាប់ការដំឡើងប្រាក់បៀវត្សរ៍ទៅនឹងគុណផល និងទិន្នផលការងាររបស់អង្គភាពនៅក្នុងក្រសួងស្ថាប័ន ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។ ក្នុងផ្នែកនេះសមិទ្ធផលសំខាន់ៗសម្រេចបានរួមមាន៖

- បានរៀបចំនិងដាក់ឲ្យអនុវត្តព្រះរាជក្រឹត្យ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ និងព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ព្រមទាំងបទដ្ឋានគតិយុត្ត និងឯកសារណែនាំមួយចំនួនទៀតដែលពាក់ព័ន្ធនឹង ការគ្រប់គ្រងចំនួនមន្ត្រីរាជការស៊ីវិល មន្ត្រីជាប់កិច្ចសន្យា ការគ្រប់គ្រងរចនាសម្ព័ន្ធនិងចំនួនមុខតំណែងក្នុងរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័ន ការត្រួតពិនិត្យការគ្រប់គ្រងវត្តមានរបស់មន្ត្រី ការគ្រប់គ្រងនិងការវាយតម្លៃគុណផលរបស់មន្ត្រីរាជការស៊ីវិល។
- បានធ្វើការសិក្សាអំពីតម្រូវការបណ្តុះបណ្តាល និងបានរៀបចំវគ្គបណ្តុះបណ្តាលរយៈពេលខ្លីជូនមន្ត្រីរាជការដូចជា៖ (១) បណ្តុះបណ្តាលមន្ត្រីរាជការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ សរុបចំនួន១ ៩៦៥នាក់ (ស្ត្រីចំនួន៤៩២នាក់) (២) ការជំរុញកំណែទម្រង់អភិបាលកិច្ចល្អសម្រាប់មន្ត្រីរាជការជាន់ខ្ពស់ សម្រាប់ថ្នាក់ដឹកនាំជាអគ្គនាយក អគ្គលេខាធិការ អគ្គាធិការ និងអភិបាលនៃគណៈអភិបាលខេត្ត បានចំនួន៣វគ្គ និង មានសិក្ខាកាមចំនួន ១៦៦នាក់ (ស្ត្រីចំនួន១៦នាក់) និង (៣) បណ្តុះបណ្តាលថ្នាក់ដឹកនាំជាស្ត្រីឋានៈរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការចំនួន១វគ្គ ដែលមានសិក្ខាកាមចូលរួមចំនួន៨៤នាក់។
- បានសិក្សា និងផ្តល់អនុសាសន៍កែលម្អអំពីប្រតិបត្តិការការងារអង្គភាពធនធានមនុស្សរបស់ក្រសួង ស្ថាប័នទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- កែលម្អការរៀបចំផែនការជ្រើសរើសមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា ដើម្បីធានាឲ្យការជ្រើសរើស និងការប្រើប្រាស់ចំគោលដៅ និង មន្ត្រីត្រូវបានគ្រប់គ្រងយ៉ាងហ្មត់ចត់ ដើម្បីកុំឲ្យប៉ះពាល់ដល់កញ្ចប់ថវិកាខ្លាំងពេក។

- បានជួយដល់វិស័យអប់រំ ក្នុងការពង្រឹងការគ្រប់គ្រង និងបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ធនធានមនុស្សរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៣.១៨- ការកែទម្រង់ប្រព័ន្ធបៀវត្ស

ការកែទម្រង់ប្រព័ន្ធបៀវត្ស គឺជាការងារអាទិភាពមួយក្នុងចំណោមការងារអាទិភាពជាច្រើនរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ការកែទម្រង់ប្រព័ន្ធបៀវត្សត្រូវធ្វើឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗរួមមាន៖ (១)ការដំឡើងបៀវត្សត្រូវអនុវត្តសមស្របតាមស្ថានភាពនៃកំណើនសេដ្ឋកិច្ចនិងលទ្ធភាព ទ្រទ្រង់បាននៃថវិកាក្នុងន័យធានាឲ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (២)ការធានាបាននូវសមធម៌ ការបង្កើនផលិតភាពនិងប្រសិទ្ធភាពការងារក្នុងរដ្ឋបាលសាធារណៈ និង(៣)ការធានាសង្គតិភាពរវាងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនិងក្របខណ្ឌ កងកម្លាំងប្រដាប់អាវុធ។ ក្នុងដំណើរការនៃការកែទម្រង់ប្រព័ន្ធបៀវត្ស រាជរដ្ឋាភិបាលបានរៀបចំនូវលិខិតបទដ្ឋានជាច្រើន ដូចជាព្រះរាជក្រឹត្យ អនុក្រឹត្យ និងសារាចរ ដើម្បីពង្រឹងប្រសិទ្ធភាពការងារ ការបង្កើនផលិតភាព និងការបង្កើនបៀវត្សមន្ត្រីរាជការឲ្យបានយ៉ាងតិចមួយលានរៀលនៅឆ្នាំ២០១៨។ គិតមកត្រឹមដំណាច់ឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលបានសម្រេចនូវលទ្ធផលសំខាន់ៗ ដូចមានសង្ខេបខាងក្រោម៖

- បានដាក់ឲ្យអនុវត្តនូវការកំណត់នីតិវិធីសម្រាប់ការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល មន្ត្រីនគរបាលជាតិ យោធិន និងការបើកផ្តល់របបសន្តិសុខសង្គមជូនសិទ្ធិវន្តនិងជូនអតីតយុទ្ធជន និងគ្រួសារអតីតយុទ្ធជនឲ្យបានទាន់ពេលវេលាក្នុងសប្តាហ៍ទី៤នៃខែនីមួយៗ
- បានដាក់ឲ្យអនុវត្តទាំងស្រុងការបើកផ្តល់បៀវត្សជូនមន្ត្រីរាជការស៊ីវិល និងមន្ត្រីនគរបាលជាតិតាមប្រព័ន្ធធនាគារដោយឡែកសម្រាប់យោធិនត្រូវអនុវត្តជាជំហានៗនិងទៅតាមដំណាក់កាល។
- បានដាក់ឲ្យធ្វើនិយ័តកម្មថ្នាក់និងឋានន្តរស័ក្តិជូនមន្ត្រីរាជការស៊ីវិលតាមអតីតភាពការងារចំនួន១៦០ ៤៤០នាក់។
- បានផ្តល់ប្រាក់វិភាជន៍គ្រួសារសម្រាប់កូនមន្ត្រីរាជការរហូតដល់អាយុ២១ឆ្នាំដោយស្វ័យប្រវត្តិ។
- បានកែសម្រួលនីតិវិធីនៃការដាក់មន្ត្រីរាជការស៊ីវិលឲ្យចូលនិវត្តន៍ ដើម្បីធានាការបើកផ្តល់សោធននិវត្តន៍ បានភ្លាមនៅខែបន្ទាប់ពីការដាក់ឲ្យចូលនិវត្តន៍។
- បានដាក់ឲ្យអនុវត្តនូវវិធានការសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល យោធិន នគរបាលជាតិ មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកអណ្តែត។
- បានដាក់ឲ្យអនុវត្តនូវការគ្រប់គ្រង និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យាតាមប្រព័ន្ធព័ត៌មានវិទ្យា និងការបើកផ្តល់ប្រាក់កម្រៃប្រចាំខែតាមប្រព័ន្ធធនាគារ។

- បានកែសម្រួលក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល តាមរយៈព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ។
- បានកែសម្រួលបៀវត្សមូលដ្ឋាន និងការបើកផ្តល់បៀវត្សដល់មន្ត្រីនគរបាលជាតិកម្ពុជា និងយោធិននៃកងយោធពលខេមរភូមិន្ទឲ្យមានសង្គតិភាពនឹងបៀវត្សរបស់មន្ត្រីរាជការស៊ីវិល។
- បានរៀបចំកំណត់និងការបើកផ្តល់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងរបបឧបត្ថម្ភផ្សេងៗជូនមន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ។
- បានរៀបចំប្រាក់បំណាច់ចៅក្រមនិងព្រះរាជអាជ្ញា។
- បានរៀបចំបច្ច័យនិច្ចភត្តប្រចាំខែសម្រាប់មន្ត្រីសង្ឃបំពេញការងារនៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។
- បានរៀបចំប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យានិងមន្ត្រីរាជការដែលបានអនុវត្តភារកិច្ចបន្ថែមនិងភារកិច្ចថ្នាក់គួប។
- បានរៀបចំប្រាក់កម្រៃសម្រាប់គ្រូបង្រៀនជាប់កិច្ចសន្យាអប់រំក្រៅប្រព័ន្ធសម្រាប់កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ កម្មវិធីចូលរៀនឡើងវិញ កម្មវិធីសមមូលបឋមសិក្សា និងកម្មវិធីបង្កើនប្រាក់ចំណូល។
- បានរៀបចំដំឡើងប្រាក់បៀវត្សអប្បបរមាជូនមន្ត្រីរាជការដូចមានតារាងខាងក្រោម៖

### តារាងទី៣.១ : ប្រាក់បៀវត្សអប្បបរមារបស់មន្ត្រីរាជការ

| ល.រ | មុខតំណែងទីប្រឹក្សា ជំនួយការ លេខាធិការ និងមន្ត្រីដែលមានឋានៈស្មើ | ប្រាក់បំណាច់ប្រចាំខែ (រៀល) |
|---|---|---|
| ១ | នាយករដ្ឋមន្ត្រី | ៣ ៦៧៥ ០០០ |
| ២ | ឧបនាយករដ្ឋមន្ត្រី | ២ ៨០០ ០០០ |
| ៣ | ទេសរដ្ឋមន្ត្រី | ២ ៤៥០ ០០០ |
| ៤ | រដ្ឋមន្ត្រី | ២ ១០០ ០០០ |
| ៥ | រដ្ឋលេខាធិការ | ១ ៧៥០ ០០០ |
| ៦ | អនុរដ្ឋលេខាធិការ | ១ ៤០០ ០០០ |
| ៧ | អគ្គនាយក | ៧៣៥ ០០០ |
| ៨ | អគ្គនាយករង | ៦៤៥ ០០០ |
| ៩ | ប្រធាននាយកដ្ឋាន | ៦២០ ០០០ |
| ១០ | អនុប្រធាននាយកដ្ឋាន | ៥៤០ ០០០ |
| ១១ | ប្រធានការិយាល័យ | ៧៨ ១០០ |
| ១២ | អនុប្រធានការិយាល័យ | ៦១ ៤០០ |

### ប្រាក់បំណាច់មុខងារសមាជិករាជរដ្ឋាភិបាល និង អនុរដ្ឋលេខាធិការ

| ល.រ | មុខតំណែង | ប្រាក់បំណាច់មុខងារប្រចាំខែ (រៀល) |
|---|---|---|
| ១ | នាយករដ្ឋមន្ត្រី | ៣ ៦៧៥ ០០០ |

| | | |
|---|---|---|
| ២ | ឧបនាយករដ្ឋមន្ត្រី | ២ ៨០០ ០០០ |
| ៣ | ទេសរដ្ឋមន្ត្រី | ២ ៤៥០ ០០០ |
| ៤ | រដ្ឋមន្ត្រី | ២ ១០០ ០០០ |
| ៥ | រដ្ឋលេខាធិការ | ១ ៧៥០ ០០០ |
| ៦ | អនុរដ្ឋលេខាធិការ | ១ ៤០០ ០០០ |

## ប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និង ប្រាក់ឧបត្ថម្ភប្រចាំខែសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុមប្រឹក្សាក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់និងមន្ត្រីភូមិ

| បរិយាយ | បៀវត្សអប្បបរមាសម្រាប់មន្ត្រីរាជការស៊ីវិលនិងកងកម្លាំងប្រដាប់អាវុធ និង ប្រាក់ឧបត្ថម្ភប្រចាំខែសម្រាប់ក្រុមប្រឹក្សាគ្រប់ប្រភេទ និងមន្ត្រីភូមិ (ជារៀល) | | | | |
|---|---|---|---|---|---|
| | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
| វិស័យរដ្ឋបាលការទូត និងបច្ចេកទេស | ១២៦ ០០០ | ៣៨៤ ០០០ | ៤២៤ ០០០ | ៥៥២ ៨០០ | ៧០០ ៥០០ |
| វិស័យអប់រំ | ១៨៩ ០០០ | ៤០២ ៨០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ |
| វិស័យសុខាភិបាល | ១៨៩ ០០០ | ៣៦០ ០០០ | ៥៥០ ០០០ | ៦៥២ ៨០០ | ៨០០ ៥០០ |
| នគរបាល | | ៣៧៩ ៩៣០ | ៤៦០ ៩៣០ | ៦២៨ ២៧០ | ៧៨៤ ៧៣០ |
| យោធិន | | ៣១៥ ៩៩០ | ៣៩៦ ៩៩០ | ៥៨២ ៤៣០ | ៧៣៣ ៧៣០ |
| ប្រធានក្រុមប្រឹក្សារាជធានី ខេត្ត | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០០០ ០០០ | ១ ០៩០ ០០០ |
| សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត | ៨០០ ០០០ | ៨០០ ០០០ | ៨០០ ០០០ | ៨០០ ០០០ | ៨៧០ ០០០ |
| ប្រធានក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៧០០ ០០០ | ៨១០ ០០០ |
| សមាជិកក្រុមប្រឹក្សាក្រុងស្រុក ខណ្ឌ | ៥០០ ០០០ | ៥០០ ០០០ | ៥០០ ០០០ | ៥០០ ០០០ | ៦៥០ ០០០ |
| ប្រធានក្រុមប្រឹក្សាឃុំ សង្កាត់ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១៥០ ០០០ | ១៥០ ០០០ | ៣០០ ០០០ | ៤០០ ០០០-៥៧០ ០០០ | ៧៥០ ០០០ |
| ជំទប់ទី១ និងទី២ ចៅសង្កាត់រងទី១និងទី២ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១២០ ០០០ | ១២០ ០០០ | ២៤០ ០០០ | ៣៥០ ០០០-៤០០ ០០០ | ៥៥០ ០០០ |
| សមាជិកក្រុមប្រឹក្សាឃុំសង្កាត់ ចាប់ពីខែកក្កដា ឆ្នាំ២០១៥ | ១០០ ០០០ | ១០០ ០០០ | ២០០ ០០០ | ៣០០ ០០០-៣៥០ ០០០ | ៤៨០ ០០០ |
| មេភូមិ | ៦០ ០០០ | ៦០ ០០០ | ១២០ ០០០ | ១៦០ ០០០ | ២០០ ០០០ |
| អនុប្រធានភូមិ | ៥០ ០០០ | ៥០ ០០០ | ១០០ ០០០ | ១៤០ ០០០ | ១៦០ ០០០ |
| សមាជិកភូមិ | ៤០ ០០០ | ៤០ ០០០ | ៨០ ០០០ | ១២០ ០០០ | ១៤០ ០០០ |

## របបសន្តិសុខសង្គមសម្រាប់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន

| បរិយាយ | របបសន្តិសុខសង្គមអប្បបរមាប្រចាំខែ(ជារៀល) | |
|---|---|---|
| | ២០១៥ | ២០១៦ |
| អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន | ៣០០ ០០០ | ៣៦០ ០០០ |

### ៣.១៩- បញ្ហាប្រឈម

- ក្រសួងមុខងារសាធារណៈ និងមន្ទីរមុខងារសាធារណៈរាជធានី ខេត្តទើបត្រូវបានបង្កើតថ្មី ដែលទាមទារ ឲ្យក្រសួងនិងមន្ទីរមានការរៀបចំនិងពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនិងត្រូវធ្វើសមាហរណកម្មថ្នាក់ដឹកនាំ និងមន្ត្រីរាជការពីអង្គភាពដើមមកក្នុងរចនាសម្ព័ន្ធថ្មី របស់ក្រសួងតាមគោលការណ៍នៃការកែទម្រង់ស្ថាប័នរបស់រាជរដ្ឋាភិបាលផងដែរ។
- ការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យាក្នុងរដ្ឋបាលសាធារណៈនៅមានកម្រិតហើយ ការអនុវត្តដាច់ដោយដុំមិនមានលក្ខណៈជាប្រព័ន្ធ។ រំហូរការងារ និងទំនាក់ទំនងផ្ទៃក្នុងនៅតាមក្រសួង ស្ថាប័ន ព្រមទាំងរវាងក្រសួង ស្ថាប័ន និងក្រសួង ស្ថាប័ន នៅមិនទាន់ដំណើរការជាបណ្តាញតភ្ជាប់គ្នាដោយរលូន និងមានប្រសិទ្ធភាព
- យន្តការនិងប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃគុណភាពសេវាសាធារណៈមិនទាន់បានដាក់ឱ្យដំណើរ ការប្រកបដោយប្រសិទ្ធភាព។ ការគ្រប់គ្រង និងការអភិវឌ្ឍអាជីពរបស់មន្ត្រីរាជការមិនទាន់ត្រូវបានរៀបចំជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាព និងមិនទាន់មានរៀបចំការពិពណ៌នាអំពីមុខតំណែងឱ្យបានច្បាស់លាស់។
- សមត្ថភាពធនធានមនុស្ស និងស្ថាប័ននៅមានកម្រិតក្នុងការឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋពិសេសនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- ប្រព័ន្ធបៀវត្សមិនទាន់ឆ្លើយតបនឹងគោលការណ៍សមធម៌ ប្រសិទ្ធភាព និងសង្គតិភាព

## កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ

៣.២០- កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការមានគោលបំណងបង្វិតសេវា ការធ្វើសេចក្តីសម្រេចចិត្ត និងការធ្វើគណនេយ្យភាពឲ្យទៅជិតប្រជាពលរដ្ឋ។ ជាទស្សនវិស័យ រដ្ឋបាលស្រុក រដ្ឋបាលក្រុង និងរដ្ឋបាលរាជធានី គឺជាតួអង្គអ្នកផ្តល់សេវាដែលមានលក្ខណៈសមស្រប និងស្ថិតនៅជិតប្រជាពលរដ្ឋជាងគេនៅកម្ពុជា ហើយក្រសួងស្ថាប័ននៅថ្នាក់ជាតិគឺជាអ្នករៀបចំគោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្តនានា។

៣.២១- ផែនការអនុវត្ត៣ ជំហានទី២ កំពុងត្រូវបានអនុវត្តពីឆ្នាំ២០១៥ដល់ឆ្នាំ២០១៧។ គម្រោងនេះត្រូវបានអនុវត្តដោយស្ថាប័នកណ្ដាលចំនួន៧ ក្រសួងចំនួន១៤ ២៥រាជធានី ខេត្ត និង ១៨៥ក្រុង ស្រុក ខណ្ឌ ដែលផ្ដោតលើការផ្ដល់សេវាសាធារណៈ ជាពិសេសនៅថ្នាក់ក្រុង ស្រុក ខណ្ឌ។ គម្រោងនេះមានគោលបំណង ដូចខាងក្រោម៖

- ផ្ដល់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិនូវ(១)អំណាចក្នុងការសម្រេចចិត្ត ឯករាជ្យ និងស្វ័យភាព (២) ការទទួលខុសត្រូវក្នុងការផ្ដល់សេវាសាធារណៈ និង (៣)អំណាចក្នុងការគ្រប់គ្រងធនធាន រួមទាំងហិរញ្ញវត្ថុនិងបុគ្គលិក។
- លើកកម្ពស់អភិបាលកិច្ចល្អ ការឆ្លើយតប និងគណនេយ្យភាពរបស់រដ្ឋបាលថ្នាក់កម្រោងជាតិចំពោះប្រជាជនទាំងអស់។
- កែលម្អការគ្រប់គ្រងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងអភិវឌ្ឍចំណេះដឹងនិងជំនាញរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីបំពេញភារកិច្ចរបស់ខ្លួន។
- គ្រប់គ្រងនិងសម្របសម្រួលការផ្លាស់ប្ដូរទាំងនេះឲ្យកាន់តែប្រសើរ។

៣.២២- រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក បុគ្គលិក ព្រមទាំងប្រព័ន្ធ និងបែបបទ នីតិវិធីនានាត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត។ រដ្ឋបាលក្រុង ស្រុកមានបែបបទ និងនីតិវិធីសម្រាប់រៀបចំ និងកសាងផែនការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា។ គ្រប់រដ្ឋបាល ក្រុង ស្រុកបានរៀបចំ និងដាក់ឲ្យអនុវត្តនូវវិធានផ្ទៃក្នុងរបស់ខ្លួន ដោយបានកំណត់ និងបែងចែកយ៉ាងច្បាស់រវាងតួនាទីភារកិច្ចរបស់ក្រុមប្រឹក្សា និងតួនាទីភារកិច្ចរបស់គណៈអភិបាល។
- ក្រសួង ស្ថាប័នចំនួន១៤ កំពុងរៀបចំផ្ទេរមុខងារផ្ដល់សេវានានាឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ តាមរយៈអនុក្រឹត្យដែលបានរៀបចំ ក្រសួងបរិស្ថានបានផ្ទេរមុខងារគ្រប់គ្រងសំណល់រឹងទៅឲ្យរដ្ឋបាលក្រុង ស្រុក ហើយក្រសួងអប់រំ យុវជន និងកីឡាបានផ្ទេរមុខងារនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូច ការអប់រំបឋមសិក្សា និងការអប់រំក្រៅប្រព័ន្ធទៅឲ្យរដ្ឋបាលក្រុង ស្រុក។ ជាមួយគ្នានេះ ការអនុវត្តសាកល្បងនូវការផ្ទេរមុខងារមួយចំនួន ដូចជាការធ្វើអនាម័យជនបទ និងការផ្គត់ផ្គង់ទឹកស្អាតជនបទ ជាដើម។
- ការិយាល័យច្រកចេញចូលតែមួយចំនួន ៤០ការិយាល័យ បានផ្ដល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋនៅទីតាំងមួយដែលមានលក្ខណៈល្អប្រសើរ។ នៅក្នុងឆ្នាំ២០១៦ ប្រជាពលរដ្ឋចំនួនជាង ៦០០ ០០០នាក់ បានមកទទួលសេវាពីការិយាល័យច្រកចេញចូលទាំងនេះ។
- រដ្ឋបាលក្រុង ស្រុកទទួលបានប្រភពមូលនិធិច្រើនជាងមុន។ មូលនិធិក្រុង ស្រុក ដែលផ្ដល់មូលនិធិគ្មានភ្ជាប់លក្ខខណ្ឌត្រូវបានបង្កើតឡើង ហើយបានផ្ទេរមូលនិធិទៅឲ្យរដ្ឋបាលក្រុង ស្រុកដែលមានទំហំថវិកាស្មើនឹង១% នៃចំណូលចរន្តថវិកាជាតិនៃឆ្នាំកន្លងទៅ។ ការ

ផ្តល់ហិរញ្ញប្បទានតាមរយៈគម្រោង (SNIF) បានរៀបចំនិងដាក់ឲ្យអនុវត្ត ដែលតាមរយៈយន្តការនេះមូលនិធិចំនួនប្រមាណ២០លានដុល្លារ នឹងត្រូវផ្ទេរទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងរយៈពេលបីឆ្នាំ។ បែបបទ និងនីតិវិធីសម្រាប់អនុវត្តមូលនិធិមានភ្ជាប់លក្ខខណ្ឌត្រូវបានរៀបចំ និងអនុម័តដោយរាជរដ្ឋាភិបាល។

- លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការធ្វើវិមជ្ឈការការគ្រប់គ្រង និងអភិវឌ្ឍធនធានមនុស្សនៅថ្នាក់ក្រោមជាតិដូចជា៖ ព្រះរាជក្រឹត្យ និងសេចក្តីណែនាំនានាត្រូវបានរៀបចំ និងដាក់ឲ្យអនុវត្ត។ លិខិតបទដ្ឋានគតិយុត្តទាំងនេះបានផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការជ្រើសរើស ការតែងតាំង ការលើកទឹកចិត្ត និង ការដាក់ពិន័យនានាដល់បុគ្គលិករបស់ខ្លួន។
- ការអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីគណនេយ្យភាពសង្គម បានជួយឲ្យប្រជាពលរដ្ឋងាយស្រួលក្នុងការទទួលព័ត៌មានអំពីការបំពេញការងារ និងថវិការបស់រដ្ឋបាលឃុំ សង្កាត់ សាលារៀន មណ្ឌលសុខភាព ព្រមទាំងបានសម្របសម្រួលឲ្យមានការចូលរួមពីប្រជាពលរដ្ឋ និងការតាមដានការអនុវត្តនៅក្នុងស្រុកគោលដៅចំនួន៥៤ (ឃុំ សង្កាត់ចំនួន ៤៤៧ សាលាបឋមសិក្សាចំនួន២៤៣ និងមណ្ឌលសុខភាពចំនួន៣៥៧)។ ការរៀបចំវេទិកានៅថ្នាក់ស្រុក ត្រូវបានប្រារព្ធឡើងនៅក្នុងឆ្នាំ២០១៥ ដែលមានប្រជាពលរដ្ឋចូលរួមប្រមាណជាង ១០០ ០០០នាក់។
- សមាគមក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងជាផ្លូវការ។ ការអភិវឌ្ឍសមត្ថភាពបានផ្តល់ដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីអនុវត្តកំណែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ។ ជាក់ស្តែង ក្នុងឆ្នាំ២០១៦ សិក្ខាកាមចំនួនជាង៦០.០០០នាក់ បានទទួលការបណ្តុះបណ្តាល។

### ៣.២៣- បញ្ហាប្រឈម

- ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ទាមទារឲ្យមានទំនាក់ទំនងឲ្យបានទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាពតាមរយៈវិធីសាមញ្ញៗនិងប្រើប្រាស់ភាសាងាយយល់។
- ធនធានរបស់រាជរដ្ឋាភិបាល ពិសេសធនធានពីក្រសួង ស្ថាប័ន ចាំបាច់ត្រូវកៀរគរ ដើម្បីផ្តោតការយកចិត្តទុកដាក់លើការអនុវត្តកំណែទម្រង់ ដោយរួមបញ្ចូលទាំងធនធានសម្រាប់ការអនុវត្តមុខងារដែលបានផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ។
- លិខិតបទដ្ឋានគតិយុត្តនានា ចាំបាច់ត្រូវរៀបចំឲ្យមានលក្ខណៈសាមញ្ញៗជាងមុន។

- ត្រូវពង្រឹងនីតិវិធីដោះស្រាយបណ្តឹង ដើម្បីឲ្យប្រជាពលរដ្ឋអាចចូលរួមកាន់តែសកម្មនៅក្នុងការប្តឹងតវ៉ានៅពេលការផ្តល់សេវានានាមិនបានល្អ ឬមិនឆ្លើយតបទៅនឹងការរំពឹងទុករបស់ប្រជាពលរដ្ឋ។
- ចាំបាច់ត្រូវមានការយកចិត្តទុកដាក់បន្ថែមទៀតលើការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍សមត្ថភាពប្រកបដោយនិរន្តរភាព និងត្រូវធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រ និងប្រសិទ្ធភាពនៃការអភិវឌ្ឍសមត្ថភាព។
- ចាំបាច់ត្រូវបង្កើនចំនួនស្ត្រីនៅក្នុងតួនាទីជាអ្នកធ្វើសេចក្តីសម្រេចចិត្តនៅថ្នាក់ក្រោមជាតិ។
- ក្រសួងស្ថាប័ននានាមួយចំនួននៅមានភាពស្ទាក់ស្ទើរក្នុងការសម្រេចផ្ទេរមុខងារ និងសិទ្ធិអំណាចទៅឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិ។
- នៅពេលដែលមុខងារនានាត្រូវបានផ្ទេរឲ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័ននីមួយៗត្រូវពង្រឹងការរៀបចំលិខិតបទដ្ឋាន និងបែបបទ នីតិវិធីនានា ដោយរួមបញ្ចូលទាំងការកំណត់កម្រិតនិយាម និងកំណត់អំពីដំណើរការនៃការធ្វើអធិការកិច្ច។
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកក្នុងការផ្តល់សេវានានាជាច្រើន ដូច្នេះការផ្តួចផ្តើមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិគឺជាកត្តាសំខាន់ដែលត្រូវយកចិត្តទុកដាក់បន្ថែមទៀត ហើយការអនុវត្តមុខងារជាអាណត្តិទូទៅរបស់ក្រុមប្រឹក្សាក៏ត្រូវពង្រឹងបន្ថែមផងដែរ។
- រដ្ឋបាលក្រុង ស្រុកនៅតែមិនមានធនធានគ្រប់គ្រាន់ ដើម្បីវិភាជន៍សម្រាប់គោលបំណងអភិវឌ្ឍនៅមូលដ្ឋាន។

## ២.៤- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ

៣.២៤- ឆ្លើយតបទៅនឹងការគំរាមកំហែងទាំងឡាយ កងយោធពលខេមរភូមិន្ទបានអនុវត្តសិទ្ធិស្វ័យការពារយ៉ាងប្តូរផ្តាច់ក្នុងការទប់ស្កាត់និងវាយបកទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព រក្សាបាននូវបូរណភាពទឹកដីគ្រប់កាលៈទេសៈនិងរក្សាបាននូវភាពអត់ធ្មត់ខ្ពស់បំផុតដោយគោរពយ៉ាងខ្ជាប់ខ្ជួននូវច្បាប់អន្តរជាតិក៏ដូចជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងផ្នែកការទូតនិងផ្លូវច្បាប់។

៣.២៥- កងយោធពលខេមរភូមិន្ទបាននិងកំពុងអនុវត្តចក្ខុវិស័យប្រែក្លាយអតីតតំបន់ប្រយុទ្ធមកជាតំបន់អភិវឌ្ឍន៍ ពីទីលានសមរភូមិទៅជាទីផ្សារសេដ្ឋកិច្ច ពីតំបន់គ្រោះថ្នាក់ទៅតំបន់ទេសចរណ៍ ពីតំបន់ភ័យខ្លាចទៅជាតំបន់សន្តិភាពមានមនុស្សរស់នៅកុះករ។

៣.២៦- កងយោធពលខេមរភូមិន្ទបាននិងកំពុងបំពេញកិច្ចការពារព្រំដែន សន្តិសុខលំហរសមុទ្រ ការហ្វឹកហ្វឺននិងបណ្តុះបណ្តាល ប្រតិបត្តិការរក្សាសន្តិភាពក្រោមឆត្រអង្គការសហប្រជាជាតិ ការប្រឆាំងភេរវកម្ម ជំនួយមនុស្សធម៌និងការឆ្លើយតបគ្រោះមហន្តរាយ កិច្ចសហប្រតិបត្តិការអន្តរជាតិ និងការគ្រប់គ្រងធនធានការពារជាតិ។

៣.២៧- កងយោធពលខេមរភូមិន្ទបានកសាងមជ្ឈមណ្ឌលយោធិនពិការនានា លំនៅឋានគ្រួសារកងទ័ព និងនិវត្តជន។ បង្កើតបាននូវវិទ្យាស្ថានជាតិគ្រប់គ្រងកម្លាំងរក្សាសន្តិភាព និង កាកសំណល់ជាតិផ្ទុះពីសង្គ្រាម និង បានបង្កើតសមាគមអតីតយុទ្ធជនកម្ពុជាផងដែរ ដើម្បីបម្រើសេវាកម្មសុខុមាលភាពក្នុងសហគមន៍កងទ័ព។ កងយោធពលខេមរភូមិន្ទបានទទួលសិទ្ធិក្នុងការធ្វើធុរៈកិច្ច ដើម្បីស្វែងរកប្រភពចំណូល ពង្រីកកិត្យានុភាពកងទ័ព និងបង្កើនកម្រិតជីវភាពរស់នៅរបស់សហគមន៍កងទ័ព។

### ៣.២៨- បញ្ហាប្រឈម

ទោះជាសម្រេចបាននូវសមិទ្ធផលដូចខាងលើ ក៏កងយុទ្ធពលខេមរភូមិន្ទ នៅជួបបញ្ហាប្រឈមដូចខាងក្រោម៖

- ពុំមានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈសមស្រប ដើម្បីពង្រឹងសមត្ថភាពកងទ័ពលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងវិជ្ជាជីវៈ។
- ការគ្រប់គ្រងនិងប្រើប្រាស់ធនធានរូបវន្តរបស់កងទ័ព នៅពុំទាន់ប្រើប្រាស់ឲ្យអស់សក្តានុពលប្រកបដោយប្រសិទ្ធភាព ដើម្បីទាញយកប្រយោជន៍ឲ្យបានអតិបរមាសម្រាប់បង្កើនកម្រិតជីវភាពរស់នៅនិងការអភិវឌ្ឍអង្គភាព។
- ការបង្កើតដៃគូអភិវឌ្ឍជាយុទ្ធសាស្ត្រ សម្រាប់ធ្វើកិច្ចសហប្រតិបត្តិការនិងការវិនិយោគធុរកិច្ចរយៈពេលវែងនៅពុំទាន់បានឆ្លើយតប។

### សេចក្តីសន្និដ្ឋាន

៣.២៩- ទោះបីមានសូចនាករដែលអាចវាស់វែងបានតិចតួចទាក់ទងនឹងអភិបាលកិច្ចល្អ ដោយផ្អែកលើការវាយតម្លៃផ្នែកគុណភាព ឃើញថាមានវឌ្ឍនភាពល្អលើអភិបាលកិច្ចល្អក្នុងរយៈពេលពាក់កណ្តាលអាណត្តិនៃការអនុវត្តផ.យ.អ.ជ. ជាពិសេសកំណែទម្រង់ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រដ្ឋបាលសាធារណៈ និងវិមជ្ឈការនិងវិសហមជ្ឈការ ព្រមទាំងកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌។ ការវាយតម្លៃផ្នែកគុណភាពលើវឌ្ឍនភាពកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ បានបង្ហាញឲ្យឃើញថា៖ មានភាពជឿនលឿន (៨៧%) គឺសម្រេចបានទាក់ទងធាតុចេញទី១៖ ការរៀបចំនិងការប្រព្រឹត្តទៅរបស់តុលាការ។ មានភាពជឿនលឿនកម្រិតមធ្យម (៥០%) គឺសម្រេចបានទាក់ទងធាតុចេញទី២៖ ការគ្រប់គ្រងសំណុំរឿងត្រូវបានកែលម្អ។ ភាពជឿនលឿនគួរឲ្យកត់សម្គាល់ (២៥%) គឺសម្រេចបានទាក់ទងធាតុចេញទី៣៖ ការដាក់ទោសជំនួស និង វិធានការទាំងឡាយក្រៅពីការឃុំខ្លួនបណ្តោះអាសន្នត្រូវបានអនុវត្ត (ឬត្រូវបានដាក់ជាគម្រោងសាកល្បង)។ សេចក្តីសង្ខេបផ្នែកគុណភាពលើសូចនាករតាមដានរួមក្នុងតារាងទី

៣.២ ខាងក្រោមជួយពន្យល់បន្ថែមដល់ការវាយតម្លៃនេះ។ ទាក់ទងនឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ សូចនាករក៏បានបង្ហាញពីវឌ្ឍនភាពល្អក្នុងផ្នែកអភិបាលកិច្ចផងដែរ។

### តារាងទី ៣.២: វឌ្ឍនភាពនៃស្នូលនៃយុទ្ធសាស្ត្រចតុកោណ៖ អភិបាលកិច្ចល្អ

| ចំណុចដៅ | សកម្មភាពដែលត្រូវអនុវត្ត | វឌ្ឍនភាព |
|---|---|---|
| ១. ការពង្រឹងការទទួលបានសេវាយុត្តិធម៌ | ១. ការផ្សព្វផ្សាយ និងការអនុវត្តច្បាប់សំខាន់ទាំងបីទាក់ទងនឹងប្រព័ន្ធយុត្តិធម៌<br>២. ការកែលម្អការគ្រប់គ្រងករណីបណ្ដឹង<br>៣. មេធាវីសម្រាប់ប្រជាជនក្រីក្រ | ១. មានវឌ្ឍនភាពល្អ<br>២. មានវឌ្ឍនភាពខ្លះ<br>៣. មានវឌ្ឍនភាពខ្លះ |
| ២. សេវាមុខងារសាធារណៈកាន់តែមានតម្លាភាព ប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ | សកម្មភាពសម្រាប់កំណែទម្រង់រដ្ឋបាលត្រូវបានអនុម័តត្រឹមឆ្នាំ២០១៤ (កំណែទម្រងប្រាក់បៀវត្សរ៍ និយាមសេវាសធារណៈ ការគ្រប់គ្រងនិងការអភិវឌ្ឍធនធានមនុស្ស) | កំណែទម្រង់រដ្ឋបាលសាធារណៈត្រូវបានអនុម័ត ផែនការសកម្មភាពត្រូវបានរៀបចំ |
| ៣. ការផ្ដល់សេវាសាធារណៈកាន់តែខិតទៅជិតប្រជាពលរដ្ឋ | ១. ការពង្រឹងក្របខ័ណ្ឌគតិយុត្តនិងសមត្ថភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់ការប្រមូលចំណូលដោយខ្លួនឯង<br>២. ដំណើរការផ្ទេរមុខងារតួនាទីពីថ្នាក់ជាតិទៅរដ្ឋបាលថ្នាក់ក្រោមជាតិ<br>៣. អនុវត្តផែនការយុទ្ធសាស្ត្រគណនេយ្យភាពសង្គម | ១. មិនទាន់សម្រេចបានតាមចំណុចដៅ បានពិនិត្យឡើងវិញការវិភាគគោលនយោបាយ (កំណែទម្រង់ទាំង៣ បាននិងកំពុងរៀបចំ នឹងត្រូវបញ្ចប់នាចុងឆ្នាំ២០១៧)<br>២. កំពុងដំណើរការ មានវឌ្ឍនភាពតិចតួច<br>៣. បានអនុវត្តបិទផ្សាយព័ត៌មានសម្រាប់ប្រជាជនចំនួន ៥៤ស្រុកគោលដៅ |
| ៤. ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកាន់តែមានប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិ | ១. កែលម្អបន្ថែមភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា<br>២. កែលម្អគណនេយ្យភាពហិរញ្ញវត្ថុឬកែលម្អភាពអាចជឿទុកចិត្តបាននិងគណនេយ្យភាពនៃថវិកា<br>៣. កែលម្អបន្ថែមទំនាក់ទំនងគោលនយោបាយថវិកា | ១. សម្រេចបានចំណុចដៅខ្លះ: កំពុងដំណើរការ<br>២. កំពុងដំណើរការ<br>៣. ស្ថិតតាមគន្លង |
| ៥. កម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ដែលមានសង្គតិភាពជាមួយអាទិភាពរបស់រាជរដ្ឋាភិបាល | ១ក. បង្កើនការវិភាជជំនួយអភិវឌ្ឍន៍ផ្លូវការតាមរយៈអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី ១ខ. ប្រើប្រាស់ប្រព័ន្ធលទ្ធកម្ម<br>២ក. បង្កើនការវិភាជជំនួយអភិវឌ្ឍន៍ផ្លូវការដែលឆ្លុះបញ្ចាំងនៅក្នុងផែនការនិងថវិកា ២ខ. ផ្ដល់ហិរញ្ញប្បទានដល់អាទិភាពអភិវឌ្ឍន៍ដោយផ្អែកលើធនធានដែលមាន (ជំនួយអភិវឌ្ឍន៍ផ្លូវការនិងថវិកាជាតិ)<br>៣. បង្កើនភាពស័ក្តិសិទ្ធរបស់ក្រុមការងារបច្ចេកទេសនិងការបន្សុីជាមួយអាទិភាពនៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨ | ១ក. មិនទាន់សម្រេចបាន ១ខ. សម្រេចបានលើសចំណុចដៅ<br>២ក. សម្រេចបានតាមចំណុចដៅ ២ខ. ទិន្នន័យត្រូវបានចែករំលែកជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រុមការងារបច្ចេកទេស |

| | | |
|---|---|---|
| | | ៣. បានពិនិត្យឡើងវិញនូវយន្តការក្រុមការងារបច្ចេកទេស |
| ៦. ផ.យ.អ.ជ. ត្រូវបានអនុម័តដើម្បីសម្រេចបានគោលដៅជាតិនិងត្រូវបានវាយតម្លៃដោយផ្អែកលើទិន្នន័យដែលមានគុណភាព | ១. បញ្ចប់ អនុម័ត និងអនុវត្តផ.យ.អ.ជ. រួមជាមួយកម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល និងពង្រឹងយន្តការផែនការនិងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ<br>២. សាកល្បងសិក្សាអំពីទំនាក់ទំនងរវាងកម្មវិធីវិនិយោគក្នុងវិស័យសុខាភិបាលនិងផ.យ.អ.ជ.<br>៣. យុទ្ធសាស្ត្រជាតិស្ថិតិអភិវឌ្ឍន៍ ២០១៦-២០១៨ និងផែនការមេជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា ២០១៤-២០២០ ត្រូវបានអនុម័តនិងអនុវត្ត | ១. សម្រេចបានចំណុចដៅខ្លះ កំពុងដំណើរការ និងមានវឌ្ឍនភាពល្អ<br>២. បានបញ្ចប់<br>៣. សម្រេចបានចំណុចដៅខ្លះ កំពុងដំណើរការ |
| ៧. ការប្រយុទ្ធនឹងអំពើពុករលួយ | ១. កំណត់វិធានការនិងក្របខ័ណ្ឌគតិយុត្តសម្រាប់ការប្រឆាំងអំពើពុករលួយ<br>២. ផ្តល់ការអប់រំស្តីពីការប្រឆាំងអំពើពុករលួយដល់សិស្សនៅតាមសាលារៀនមធ្យមសិក្សា<br>៣. ពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យឯកជនជាមួយអង្គភាពប្រឆាំងអំពើពុករលួយ | ១. សេចក្តីព្រាងនៃការវាយតម្លៃបានបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី<br>២. កំពុងដំណើរការ មានវឌ្ឍនភាពល្អ<br>៣. ជោគជ័យ កំពុងដំណើរការ |

## ៣- បរិស្ថានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ

### ៣.១- សន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

៣.៣០- សភាពការណ៍ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម នៃព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈល្អប្រសើរ បង្កបរិយាកាសអំណោយផលបន្តទៀតដល់ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ការពង្រឹងលទ្ធិប្រជាធិបតេយ្យ ការគោរពសិទ្ធិមនុស្ស និងនីតិរដ្ឋ។ សន្តិភាពបន្តគ្របដណ្តប់លើផ្ទៃប្រទេស បូរណភាពទឹកដី និងអធិបតេយ្យជាតិ ត្រូវបានការពារយ៉ាងគត់មត់។ តំបន់ព្រំដែនទាំងសងខាងមានសភាពស្ងប់ស្ងាត់ល្អ ទោះបីមានការរំលោភខ្លះៗចំពោះការសន្យារក្សាស្ថានភាពដដែល នៃព្រំដែនដែលមិនទាន់ឯកភាពគ្នា តែយើងបានរួសរាន់ពិគ្រោះដោះស្រាយដោយសន្តិវិធី ទទួលបានលទ្ធផលជាវិជ្ជមាន ពុំមានការប្រឈមដោយអាវុធឡើយ។

**សុវត្ថិភាពសាធារណៈ**

៣.៣១- ព្រឹត្តិការណ៍ជាតិនិងអន្តរជាតិតូចធំ ដែលបានរៀបចំឡើងចំនួន២១ ៩៧២លើក ត្រូវបានការពារប្រកបដោយសុវត្ថិភាពទាំងស្រុង។ សកម្មភាពបាតុកម្ម កូដកម្មចំនួន៥ ៤០០លើក ត្រូវបានការពាររៀបរយសណ្តាប់ធ្នាប់ និងសម្របសម្រួល ដោះស្រាយដោយសន្តិវិធី ប៉ុន្តែមានសកម្មភាព ហឹង្សា ៧លើក បិទផ្លូវ ២៧លើក និងដង្ហែរតាមផ្លូវ ៦៥លើក។

៣.៣២- ឆ្លើយតបចំពោះបញ្ហាសុវត្ថិភាពចរាចរណ៍ផ្លូវគោកក្រសួងមហាផ្ទៃបានយកចិត្តទុកដាក់ចាត់ចែងដឹកនាំអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកថ្មីចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ប្រកបដោយ

ការទទួលខុសត្រូវខ្ពស់និងជាប់ជាប្រចាំ។ ដោយសម្រេចបានលទ្ធផលជាវិជ្ជមាន ធ្វើឲ្យចំនួនគ្រោះថ្នាក់មានការថយចុះ១១% ចំនួនរបួសថយចុះ១៥% ប៉ុន្តែចំនួនមនុស្សស្លាប់កើនឡើង៥%។ ក្រសួងក៏បានយកចិត្តទុកដាក់វិធានការបង្ការ និងពន្លត់អគ្គីភ័យ និងបានបង្កើនសមត្ថភាពនៅតាមអង្គភាព នឹងបំពាក់បន្ថែមរថយន្តអគ្គីភ័យចំនួន១១៣គ្រឿង ដាក់ពង្រាយទៅតាមទីប្រជុំជនសំខាន់ៗ។ ករណីអគ្គីភ័យបានកើនឡើងក្នុងឆ្នាំ២០១៤និង២០១៥ ដែលបណ្តាលមកពីការឆ្លងចរន្តអគ្គិសនី និងការធ្វេសប្រហែសនៃការប្រើប្រាស់អគ្គិសនី។

**សេវាសម្រាប់ប្រជាពលរដ្ឋ**

៣.៣៣- នៅថ្ងៃទី០៩ មិថុនា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តដាក់ឲ្យប្រើប្រាស់ផែនការយុទ្ធសាស្ត្រស្តីពីអត្តសញ្ញាណកម្ម ២០១៧-២០២៦។ គិតចាប់ពីថ្ងៃដំណើរការរហូតមកដល់ថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៦ ប្រជាពលរដ្ឋដែលបានមកចុះបញ្ជីមានចំនួនសរុប ១៥ ០១២ ៩១២នាក់ ហើយបានផ្តល់សៀវភៅស្នាក់នៅចំនួនសរុប ២ ៧៨៩ ៦៥១ក្បាល និងសៀវភៅគ្រួសារចំនួនសរុប ២ ៧០៨ ៦៨៩ក្បាល។ គិតសរុបពីដើមគ្រាឆ្នាំ២០១២ មកដល់ថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មផលិតបានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសរុបចំនួន ៨ ៦១៥ ៧៩៥សន្លឹក លើផែនការ១០ ៩៤៤ ១០១នាក់។ គិតចាប់ពីថ្ងៃទី១៣ ខែតុលា ឆ្នាំ២០១៤ រហូតដល់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៦ បានបោះពុម្ពលិខិតឆ្លងដែនសរុបចំនួន២៣៤ ៦៥៣ក្បាល និងលិខិតធ្វើដំណើរសរុបចំនួន៣៦ ៤៧៨ក្បាល ជូនពលករកម្ពុជាធ្វើការនៅបរទេស។

៣.៣៤- **បញ្ហាប្រឈម**

- ការងារគ្រប់គ្រងអត្តសញ្ញាណកម្មតាមរបៀបចុះ (ដូចជាអត្រានុកូលដ្ឋាន បញ្ជីស្នាក់នៅ) ដោយដៃមិនប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ជាមូលដ្ឋាន ដែលនាំឲ្យមានការលំបាកក្នុងការគ្រប់គ្រង និងធ្វើឲ្យទិន្នន័យមិនដូចគ្នាសម្រាប់ប្រជាពលរដ្ឋម្នាក់ៗ
- សមត្ថភាព និងការយល់ដឹងពីបែបបទនីតិវិធីរបស់មន្ត្រីអត្រានុកូលដ្ឋាននៅថ្នាក់ក្រោមជាតិនៅមានកម្រិត ទាមទារការបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាពបន្ថែមទៀត
- ពាក់ព័ន្ធនឹងការងារផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ មានប្រជាជនចំណាកស្រុកមានចំនួនច្រើន ការចូលរួមរបស់ប្រជាពលរដ្ឋចាប់ពីអាយុ៥៥ឆ្នាំឡើងមានចំនួនតិច និងមួយចំនួនសម្គាល់ថាមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរគំរូចាស់រួចហើយមិនព្រមមកប្តូរថ្មី មានការយឺតយ៉ាវក្នុងការបញ្ជូន ការត្រួតពិនិត្យទិន្នន័យ និងការចែកសន្លឹកអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ និងមានករណីប្រជាពលរដ្ឋបន្លំធ្វើអត្តសញ្ញាណប័ណ្ណលើសពីមួយដង ដែលជាហេតុធ្វើឲ្យមិនអាចបោះពុម្ពអត្តសញ្ញាណប័ណ្ណជូនបាន។

## ការប្រយុទ្ធប្រឆាំងនឹងគ្រឿងញៀន

៣.៣៥- *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* នឹងបន្តដឹកនាំការអនុវត្តឲ្យមានប្រសិទ្ធភាពនូវផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលមានសមិទ្ធផល ដូចខាងក្រោម៖

- បានបន្តយកចិត្តទុកដាក់អនុវត្តយ៉ាងសកម្មការងារអប់រំ ផ្សព្វផ្សាយស្តីពីគ្រឿងញៀន ដោយបានពង្រីកសកម្មភាព ទៅដល់តំបន់គោលដៅជាច្រើនកន្លែង និងគ្របដណ្តប់លើក្រុមជនងាយទទួលរងគ្រោះថ្នាក់ខ្ពស់ជាច្រើននាក់ ទាំងនៅតាមទីប្រជុំជន ក៏ដូចជាទីជនបទនានា។
- ការព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ទាំងនៅតាមមណ្ឌលបណ្តោះអាសន្នរបស់រដ្ឋ ឯកជន ក៏ដូចជាការព្យាបាលដោយផ្អែកលើសហគមន៍នៅតាមមូលដ្ឋានសុខាភិបាល មានការរីកចម្រើនជាងមុន អាស្រ័យដោយគណៈកម្មាធិការទទួលបន្ទុកការងារព្យាបាលនិងស្តារនីតិសម្បទា បានពង្រឹងយន្តការការងាររបស់ខ្លួន។ ជាមួយនេះ អ្នកប្រើគ្រឿងញៀនក៏មានការភ្ញាក់រលឹកទៅទទួលសេវាព្យាបាល ច្រើនជាងមុន។
- មន្ត្រីអនុវត្តន៍ច្បាប់ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិកាន់តែមានសមត្ថភាពខ្ពស់ក្នុងការស្រាវជ្រាវស៊ើបអង្កេតបទល្មើស គួបផ្សំនឹងឆ្លងកាត់បទពិសោធន៍ច្រើន ការយល់ដឹងកាន់តែច្បាស់ពីល្បិចកលរបស់ក្រុមឧក្រិដ្ឋជន រួមជាមួយការប្រើប្រាស់កម្លាំងសរុបនិងកិច្ចសហការក្នុងការផ្តល់ព័ត៌មានរហ័សឲ្យគ្នាទៅវិញទៅមកជាមួយប្រទេសជិតខាង ក្នុងតំបន់និងអន្តរជាតិបានល្អ ធ្វើឲ្យការទប់ស្កាត់និងបង្ក្រាបបទល្មើសគ្រឿងញៀនបានច្រើនករណីធំៗ។

៣.៣៦- ដើម្បីពង្រឹងតម្លៃរបស់គ្រួសារនិងសាសនា ដែលជាមូលដ្ឋានគ្រឹះនៃការរៀបចំសង្គមកម្ពុជា ក្រសួងធម្មការនិងសាសនា បានបន្តជំរុញលើកកម្ពស់យ៉ាងសកម្មនូវតួនាទីរបស់គ្រួសារ និងការផ្សារភ្ជាប់ទៅនឹងតម្លៃជាប្រពៃណីនៃសាសនារបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រសួងសម្រេចបានសមិទ្ធផលជាច្រើនក្នុងវិស័យធម្មការនិងសាសនា ដូចមានបង្ហាញក្នុងតារាងខាងក្រោម៖

**តារាងទី៣.៣: សូចនាករសំខាន់ៗក្នុងវិស័យធម្មការនិងសាសនា**

| សូចនាករ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| **ការពង្រឹងគុណភាព និងពង្រីកវិស័យពុទ្ធិកសិក្សា** | | | | |
| - ចំនួនសាលាធម្មវិន័យ | ចំនួន | ៥២៣ | ៥៨៥ | ៥៨៥ |
| - ចំនួនសមណសិស្សចុះឈ្មោះចូលរៀននៅសាលាធម្មវិន័យ | ចំនួន | ៨ ២២៩ | ៩ ៩៨៩ | ៩ ៩៨៩ |
| - ចំនួនសាលាពុទ្ធិកបឋមសិក្សា | ចំនួន | ៧៤៣ | ៧៤៣ | ៧៤៣ |
| - ចំនួនសមណសិស្សចុះឈ្មោះចូលរៀននៅពុទ្ធិកបឋមសិក្សា | ចំនួន | ១៦ ២២៧ | ១៦ ៧៣៤ | ១៦ ៧៣៤ |
| - ចំនួនសាលាពុទ្ធិកមធ្យមសិក្សាបឋមភូមិ | ចំនួន | ៣៧ | ៣៨ | ៣៨ |
| - ចំនួនសមណសិស្សចុះឈ្មោះចូលរៀននៅពុទ្ធិកមធ្យមសិក្សាបឋមភូមិ | ចំនួន | ៤ ៨១៩ | ៤ ៦៥៣ | ៤ ៦៥៣ |

| | | | | |
|---|---|---|---|---|
| - ចំនួនសាលាពុទ្ធិកមធ្យមសិក្សាទុតិយភូមិ | ចំនួន | ១៥ | ១៥ | ១៥ |
| - ចំនួនសមណសិស្សចុះឈ្មោះចូលរៀននៅពុទ្ធិក មធ្យមសិក្សាទុតិយភូមិ | ចំនួន | ១ ៥២៦ | ១ ៥៩៦ | ១ ៥៩៦ |
| - ចំនួនសាលាពុទ្ធិកសាកលវិទ្យាល័យ | ចំនួន | ៣ | ៣ | ៣ |
| - ចំនួនសមណនិស្សិតចុះឈ្មោះចូលរៀននៅពុទ្ធិក សាកលវិទ្យាល័យ ព្រះសីហនុរាជ | ចំនួន | ១ ៤៩៨ | ១ ២០៣ | ១ ២០៣ |
| - ចំនួនសមណនិស្សិតចុះឈ្មោះចូលរៀននៅពុទ្ធិក សាកលវិទ្យាល័យ ព្រះសីហមុនីរាជា | ចំនួន | ៩៧១ | ៨០៦ | ៨០៦ |
| - ចំនួនសមណនិស្សិតចុះឈ្មោះចូលរៀននៅពុទ្ធិក សាកលវិទ្យាល័យ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន | ចំនួន | ២៧៩ | ២១៧ | ២១៧ |
| - ចំនួនថ្នាក់រៀនពុទ្ធិកក្រោយឧត្តមសិក្សា | ចំនួន | ៤ | ៤ | ៤ |
| - ចំនួនសមណនិស្សិតចុះឈ្មោះចូលរៀននៅពុទ្ធិក ក្រោយឧត្តមសិក្សា | ចំនួន | ២២៧ | ៤៧៥ | ៤៧៥ |

ប្រភព : ក្រសួងធម្មការនិងសាសនា

## ៣.២- បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះនិងចីរភាពបរិស្ថានកំណើនប្រកបដោយចីរភាព

៣.៣៧- បរិស្ថានម៉ាក្រូសេដ្ឋកិច្ច ដូចបានរៀបរាប់នៅក្នុងជំពូកទី២ កំណើនសេដ្ឋកិច្ចកម្ពុជាអាចមានកំណើនក្នុងរង្វង់៧%ក្នុងឆ្នាំ២០១៦និងឆ្នាំ២០១៧។ ជាលទ្ធផល កម្ពុជាស្ថិតលើគន្លងក្នុងការសម្រេចបានចំណុចដៅកំណើនរយៈពេលមធ្យមដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣។ ទោះបីកំណើនក្នុងវិស័យកសិកម្មយឺត ប៉ុន្តែកំណើនក្នុងវិស័យផ្សេងទៀតលឿន ដែលធ្វើឲ្យប្រទេសជៀសផុតពីការធ្លាក់ចុះក្នុងឆ្នាំ២០១៥។ និន្នាការនៃកំណើននៅពាក់កណ្តាលឆ្នាំ២០១៦ បង្ហាញថាវិស័យឧស្សាហកម្មនិងវិស័យសេវាកម្មកំពុងមានកំណើនយឺត ប៉ុន្តែមានកំណើនល្អក្នុងវិស័យកសិកម្មដោយសារអាកាសធាតុអំណោយផល។ បរិស្ថានខាងក្រៅអាចជះឥទ្ធិពលមួយចំនួនដល់កំណើនសេដ្ឋកិច្ចកម្ពុជា ជាពិសេសការនាំចេញ ប៉ុន្តែទស្សនទានសម្រាប់វិស័យទេសចរណ៍និងវិនិយោគផ្ទាល់ពីបរទេសនៅមានកម្រិតទាបនៅឡើយ។ កំណើនវិស័យឧស្សាហកម្មធ្លាក់ចុះបន្តិចពី១១,៧% ក្នុងឆ្នាំ២០១៥ មក ១០,៦% ក្នុងឆ្នាំ២០១៦ ដោយមានកំណើនច្រើនក្នុងវិស័យកម្មន្តសាល ប៉ុន្តែធ្លាក់ចុះវិស័យសំណង់។ វិស័យសេវារំពឹងថានឹងមានកំណើន៦,៧% ក្នុងឆ្នាំ២០១៦ ទាបជាងឆ្នាំ២០១៧

(៧,១%) ដោយសារការថយចុះកំណើននៃការមកដល់របស់ភ្ញៀវទេសចរ។ អតិផរណាប្រចាំឆ្នាំអាចកើនដល់៣,០% ក្នុងឆ្នាំ២០១៦ និង៣,៨% ក្នុងឆ្នាំ២០១៧ ដោយសារការកើនឡើងនៃតម្លៃប្រេងអន្តរជាតិនិងតម្លៃម្ហូបអាហារនៅកម្ពុជា ខ្ពស់ជាងចំណុចដៅ(៣,៥%) ក្នុង ផ.យ.អ.ជ.។ តុល្យភាពចំណាយសរុបរបស់កម្ពុជានៅតែមានលំនឹងល្អ ហើយការបង្រួមថវិកាចូលគ្នាមានវឌ្ឍនភាពល្អ។

### ៣.៣៨- បញ្ហាប្រឈម

**បរិស្ថានខាងក្រៅ៖** ការព្យាករសេដ្ឋកិច្ចសម្រាប់ឆ្នាំនេះនិងឆ្នាំបន្ទាប់អាចខុសប្រសិនបើសេដ្ឋកិច្ចប្រទេសចិនធ្លាក់ចុះខ្លាំងឬប្រសិនបើទីផ្សារហិរញ្ញវត្ថុអន្តរជាតិបន្តមានអស្ថិរភាព និង ភាពមិនប្រាកដប្រជា។

**ការពង្រឹងភាពប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច៖** រាជរដ្ឋាភិបាលត្រូវបន្តខិតខំប្រឹងប្រែងរក្សាភាពប្រកួតប្រជែងខាងក្រៅរបស់ប្រទេស។ វិស័យស្រូវ អង្ករបច្ចុប្បន្នជួបបរិស្ថានពាណិជ្ជកម្មប្រកួតប្រជែងខ្លាំង។ វិស័យកាត់ដេរដំណើរការទៅល្អ ប៉ុន្តែអាចជួបបញ្ហាប្រឈមលើការប្រកួតប្រជែងច្រើន។ វិស័យសេវាកម្មក៏ជួបបញ្ហាប្រឈមច្រើនដែរ ដោយសារមានទិសដៅទេសចរណ៍ច្រើនក្នុងតំបន់។

**កំណើនឥណទាននិងអចលនទ្រព្យ៖** រាជរដ្ឋាភិបាលត្រូវធ្វើឲ្យមានលំនឹងកំណើនឥណទាននៅកម្រិតសមស្របមួយដើម្បីជួយសម្រួលដល់ទីផ្សារអចលនទ្រព្យរបស់កម្ពុជា។
ការពង្រីកលំហថវិកា៖ ភាពជោគជ័យក្នុងការបង្កើនការប្រមូលចំណូលត្រូវបានរក្សាបាននិងពង្រីក ដើម្បីធានាលំហថវិកាសមរម្យសម្រាប់កិច្ចដំណើរការក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។

**ការអនុវត្តថវិកាឆ្នាំ២០១៥** បានជួបបញ្ហាប្រឈមជាច្រើន ដែលបណ្តាលឲ្យមានការពន្យារពេលក្នុងការចំណាយដើមខែដំបូង នៅពេលរាជរដ្ឋាភិបាលបានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញសម្រាប់១០ក្រសួង។

## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៣.៣៩- *ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ* សម្រេចបានវឌ្ឍនភាពល្អក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គោលបំណងនៃកម្មវិធីកំណែទម្រង់នេះ គឺកែលម្អប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាអនុលោមតាមស្តង់ដារអន្តរជាតិ។ សមាសធាតុសំខាន់នៃកម្មវិធីកំណែទម្រង់នេះរួមមានការពង្រឹងជំនឿទុកចិត្តថវិកា ការពង្រឹងការគ្រប់គ្រងនិងការប្រមូលចំណូល ការពង្រឹងគណនេយ្យភាព

ហិរញ្ញវត្ថុតាមរយៈប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ និងការពង្រឹកការអនុវត្តថវិកាកម្មវិធីនិងការកែលម្អការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា។

**សមិទ្ធផល**

៣.៤០- ថវិកាកម្មវិធី មានគោលបំណងកែលម្អការបន្សុីថវិកាទៅនឹងគោលនយោបាយជាតិ និងពង្រឹងការផ្សារភ្ជាប់ការអនុវត្តទៅនឹងគណនេយ្យភាព។ នៅត្រឹមឆ្នាំ២០១៥ ក្រសួងសាកល្បងចំនួន១០បានចាប់ផ្តើមអនុវត្តថវិកាកម្មវិធីពេញលេញ។ ក្នុងឆ្នាំ២០១៦ ក្រសួងចំនួន១៥បន្ថែមទៀតបានរៀបចំថវិកាកម្មវិធីពេញលេញ។ រដ្ឋបាលថ្នាក់ក្រោមជាតិក៏នឹងរៀបចំថវិកាកម្មវិធីពេញលេញផងដែរ។ នៅឆ្នាំ២០១៨ ក្រសួង ស្ថាប័នទាំងអស់នឹងត្រូវអនុវត្តការរៀបចំថវិកាកម្មវិធីពេញលេញ។

**ការកៀរគរចំណូល** យុទ្ធសាស្ត្រកៀរគរចំណូល ២០១៤-២០១៨ បានផ្តល់ក្របខ័ណ្ឌមួយដែលជួយបង្កើនចំណូលក្នុងស្រុកសរុបពី១៥,២% ក្នុងឆ្នាំ២០១៣ និងប៉ាន់ស្មានប្រមាណជា១៨,៦% ក្នុងឆ្នាំ២០១៦។ តាមរយៈតួលេខបណ្តោះអាសន្នក្នុងឆ្នាំ២០១៦ ការប្រមូលចំណូលសារពើពន្ធមានកំណើន១០,៧%ធៀបនឹងឆ្នាំ២០១៥ ប្រមាណជា១៥,៩% នៃផ.ស.ស. ខណៈដែលការប្រមូលចំណូលមិនមែនសារពើពន្ធមានកំណើនប្រមាណ៣៨,៩% ធៀបនឹងឆ្នាំ២០១៥ ប្រមាណជា២,៥% នៃផ.ស.ស។

**ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** គឺមានតួនាទីជាឆ្អឹងខ្នងសម្រាប់ការងារកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងជាប្រព័ន្ធធានានូវប្រសិទ្ធភាព គណនេយ្យភាព និង តម្លាភាពក្នុងការអនុវត្តថវិកា។ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនេះកំពុងដំឡើងនៅតាមនាយកដ្ឋាននានារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រតនាគារជាតិ និងរតនាគាររាជធានី ខេត្ត។

**ការកសាងសមត្ថភាព** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសម្រេចបានវឌ្ឍនភាពល្អក្នុងការពង្រឹងសមត្ថភាពធនធានមនុស្ស និងស្ថាប័នតាមរយៈការជ្រើសរើសមន្ត្រីថ្មីដោយមានវគ្គបណ្តុះបណ្តាលជំនាញក្នុងការគ្រប់គ្រងនិងការរៀបចំផែនការហិរញ្ញវត្ថុ រួមទាំងការវិភាគថវិកា។

**ការផ្ទេរប្រាក់បៀវត្សរ៍ដោយស្វ័យប្រវត្តិ** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងក្រសួងមុខងារសាធារណៈបានសហការគ្នាក្នុងការបង្កើតប្រព័ន្ធអនឡាញសម្រាប់ការផ្ទេរប្រាក់បៀវត្សរ៍ដោយផ្ទាល់ទៅគណនីរបស់មន្ត្រីរាជការនៅតាមធនាគារ។

**ភាពអាចព្យាករនិងតម្លាភាព** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានកែលម្អភាពអាចព្យាករបាននៃថវិកា រួមទាំងតម្លាភាព ដូចជាការបោះពុម្ពផ្សាយថវិកាឆ្នាំ២០១៥សង្ខេប វេទិកាសាធារណៈ

ស្ដីពីក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច និង របាយការណ៍ពិនិត្យនិងវាយតម្លៃម៉ាក្រូសេដ្ឋកិច្ច និង សារពើពន្ធ ជាដើម។

**បញ្ហាប្រឈម**

៣.៤១- សមត្ថភាពមន្ត្រីរាជការនៅក្រសួង ស្ថាប័ននិងរដ្ឋបាលថ្នាក់ក្រោមជាតិនៅមានកម្រិតសម្រាប់ការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការគ្រប់គ្រងធនធានមុខងារសាធារណៈមិនទាន់ត្រូវបានរៀបចំគ្រប់គ្រាន់នៅឡើយ ដែលអាចធ្វើឲ្យមន្ត្រីរាជការមានគណនេយ្យភាពចំពោះការអនុវត្តការងាររបស់ខ្លួន។ ប្រព័ន្ធត្រួតពិនិត្យការអនុវត្តការងារមិនទាន់ត្រូវបានរៀបចំគ្រប់គ្រាន់នៅឡើយ សម្រាប់គាំទ្រប្រព័ន្ធគ្រប់គ្រងដែលផ្ដោតលើការអនុវត្ត។ ពុំទាន់មានប្រព័ន្ធត្រួតពិនិត្យ តាមដាននិងវាយតម្លៃកម្មវិធីជាប្រព័ន្ធ ដែលមានសារៈសំខាន់សម្រាប់ការយល់ដឹងនិងការឆ្លើយតបនឹងការអនុវត្តមិនសម្រេចបានតាមគោលដៅ។

## ចីរភាពបរិស្ថាន

៣.៤២- ការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ រួមទាំងការប្រែប្រួលអាកាសធាតុកំពុងតែជាបញ្ហាសំខាន់ដែលទាក់ទងនឹងចីរភាព និងស្ថេរភាពនៃកំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គមរបស់កម្ពុជា។ បញ្ហាបរិស្ថានជាបញ្ហាអន្តរវិស័យនិងតម្រូវឲ្យមានការសម្របសម្រួលក្នុងរដ្ឋាភិបាលទាំងមូលទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយមានកិច្ចសហការជាមួយគ្រប់អ្នកពាក់ព័ន្ធ។

៣.៤៣- *ក្រសួងបរិស្ថាន* មានតួនាទីដឹកនាំការងារដើម្បីសម្រេចបានចីរភាពបរិស្ថាន។ ក្រសួងសម្រេចបានវឌ្ឍនភាពល្អក្នុងផ្នែកជាច្រើនដូចជា(១)ព័ត៌មាននិងចំណេះដឹងបរិស្ថាន (២)ការគ្រប់គ្រងតំបន់អភិរក្ស (៣)កិច្ចគាំពារបរិស្ថាន និង(៤)ការអភិវឌ្ឍដោយចីរភាព/ការប្រែប្រួលអាកាសធាតុ។

៣.៤៤- គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា គោលដៅទី៧ បានបង្ហាញថាកិច្ចការពារព្រៃឈើ ធនធានទឹក និងបរិស្ថានគឺជាស្នូលនៃការអភិវឌ្ឍន៍ដោយចីរភាព។ ប៉ុន្តែ កិច្ចប្រឹងប្រែងដោយចីរភាពរបស់រដ្ឋាភិបាលមិនទាន់សម្រេចបាននៅឡើយទេ។ ឧទាហរណ៍ គម្របព្រៃឈើមានចំនួន៦១,១៥%ក្នុងឆ្នាំ២០០២ ប៉ុន្តែបានធ្លាក់ចុះមក៤៩,៨%ក្នុងឆ្នាំ២០១៥ ដោយសារសកម្មភាពកាប់បំផ្លាញព្រៃឈើដោយខុសច្បាប់ ដែលស្ថិតនៅក្រោមចំណុចដៅ(៦០%)របស់ផ.យ.អ.ជ.។ ប្រសិនបើមិនការត្រួតពិនិត្យទេ និន្នាការនេះអាចបណ្ដាលឲ្យមានឥទ្ធិពលអេកូឡូស៊ីអវិជ្ជមានទៅគុណភាពដីនិងទឹក ព្រមទាំងការបាត់បង់ជីវៈចម្រុះនិងត្រី។

៣.៤៥- រាជរដ្ឋាភិបាលកំពុងធ្វើការងារជាមួយសហគមន៍ដើម្បីស្ដារការបាត់បង់ផ្ទៃគបរិស្ថានឡើងវិញតាមរយៈការលើកកម្ពស់ការការពារនិងគ្រប់គ្រងធនធានតាមសហគមន៍ដោយចីរភាព។ ឧទាហរណ៍ រាជរដ្ឋាភិបាលបានបង្កើតសហគមន៍ព្រៃឈើចំនួន៤៩៩ ដែលគ្របដណ្ដប់ផ្ទៃដីចំនួន៥១៤លានហិកតា។ ចំនួនសហគមន៍នេសាទបានកើនឡើងពី៤៤០ក្នុងឆ្នាំ២០០៥ ទៅ៥១៦ក្នុងឆ្នាំ២០១៥ ដែលគ្របដណ្ដប់ផ្ទៃដីចំនួន៦៤៧ ០០០ហិកតា ហើយបច្ចុប្បន្នមានតំបន់អភិរក្សនេសាទចំនួន៥៦១ (សហគមន៍ចំនួន៤៦៧កន្លែង)។

៣.៤៦- ទឹកស្អាតនិងអនាម័យ គឺជាចំណុចដៅសំខាន់មួយផ្សេងទៀតក្នុងគោលដៅទី៧នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា។ ការផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនមានចំនួន ៨៨,០១% ក្នុងឆ្នាំ២០១៥ ដែលលើសចំណុចដៅ (>៨០%) ចំណែកការផ្គត់ផ្គង់ទឹកស្អាតជនបទសម្រេចបាន៥០% ដូចចំណុចដៅ។ អនាម័យនៅទីប្រជុំជនសម្រេចបាន ៨៩% ក្នុងឆ្នាំ ២០១៥ លើសចំណុចដៅ( ៧៤%)។

៣.៤៧- ទោះបីការប្រើប្រាស់ធ្យូងសម្រាប់ចម្អិនត្រូវបានកាត់បន្ថយពី៨៤% ក្នុងឆ្នាំ២០០៥ មក៧៤,៨% ក្នុងឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជានឹងមិនអាចសម្រេចបានចំណុចដៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាក្នុងឆ្នាំ២០១៥ទេ។ ការចុះបញ្ជីដីបានកើនឡើងពី ១៥% ក្នុងឆ្នាំ២០០០ ទៅ ២៨% ក្នុងឆ្នាំ២០១១ និង កើនដល់៥៨% ក្នុងឆ្នាំ២០១៥ លើសចំណុចដៅ( ៥៧%)។ រាជរដ្ឋាភិបាលកម្ពុជាត្រូវប្រឹងប្រែងបន្ថែមទៀតដើម្បីសម្រេចបានចំណុចដៅ( ៧០%)ក្នុងឆ្នាំ២០១៨ ក្នុងផ.យ.អ.ជ.។

**បញ្ហាប្រឈម**

៣.៤៨- បញ្ហាប្រឈមសំខាន់គឺការបន្តពង្រឹងសមត្ថភាពសម្រាប់កិច្ចសម្របសម្រួលនិងសហប្រតិបត្តិការអន្តរវិស័យលើបញ្ហាមួយចំនួនដូចជា៖ ទឹក ដីធ្លី ព្រៃឈើ និងគុណភាពខ្យល់នៅតំបន់ទីប្រជុំជននិងជនបទ។ រាជរដ្ឋាភិបាលនឹងត្រូវបង្កើនការដាំកូនឈើឡើងវិញ ដើម្បីស្ដារព្រៃឈើឡើងវិញ។

៣.៤៩- ឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ នគរូបនីយកម្ម និងកំណើនឧស្សាហូបនីយកម្មនឹងដាក់បន្ទុកបន្ថែមលើធនធានធម្មជាតិនិងអេកូឡូស៊ីរបស់កម្ពុជា។

## ៣.៣- ភាពជាដៃគូក្នុងការអភិវឌ្ឍ

៣.៥០- យុទ្ធសាស្ត្រសម្រាប់កិច្ចសហប្រតិបត្តិការអភិវឌ្ឍនិងភាពជាដៃគូ ២០១៤-២០១៨ មានគោលដៅចម្បង គឺលើកកម្ពស់ភាពស័ក្តិសិទ្ធិក្នុងកិច្ចអភិវឌ្ឍន៍។ យុទ្ធសាស្ត្រនេះ បានកំណត់អំពីទិសដៅនិងគោលដៅ ព្រមទាំងឧបករណ៍នានា សម្រាប់គ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍ និង ភាពជាដៃគូក៏ដូចជាកំណត់អភិក្រមសម្រាប់អនុវត្ត និង តាមដានបណ្ដា

សកម្មភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលរួមមានដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងដៃគូក្នុងក្របខណ្ឌនៃកិច្ចសហប្រតិបត្តិការត្បូង-ត្បូង។

## តារាងទី ៣.៤: វឌ្ឍនភាពនៃសូចនាករស្តីពីភាពជាដៃគូក្នុងការអភិវឌ្ឍ

| | ២០១៥ ជាក់ស្តែង | ២០១៨ ចំណុចដៅ | ២០១០ | ២០០៧ |
|---|---|---|---|---|
| ១ ក) ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផល | ៣៧% | ៥០% | --- | --- |
| ១ ខ) ការប្រើប្រាស់អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | ២៨% | ៥០% | ៣៥% | ២៨% |
| ១ គ) ទំហំហិរញ្ញប្បទានឥតភ្ជាប់លក្ខខណ្ឌ | ៥៧% | > ៦០% | ៥៩% | ៥២% |
| ២ ក) ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | ៥៧% | ៥០% | ២១% | ១២% |
| ២ ខ) ការប្រើប្រាស់ប្រព័ន្ធលទ្ធកម្មជាតិ | ២៦% | ៣៥% | ២៤% | ១៦% |
| ៣ ក) ទំហំហិរញ្ញប្បទានកត់ត្រា ក្នុងថវិកាជាតិ<br>ភាពអាចទស្សន៍ទាយនៃហិរញ្ញប្បទានសហប្រតិបត្តិការ | ៧៩%<br>១២១% | ៩០%<br>៩៥% | ១១៤%<br>៩១% | ៨៥%<br>១០៤% |
| ៣ ខ) ការវាយតម្លៃរួមគ្នាលើវឌ្ឍនភាពជាដៃគូ (សូចនាករតាមដានរួមគ្នា) | បានរៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នាឆ្នាំ ២០១៥ | រៀបចំរបាយការណ៍បញ្ចប់ | បានអនុវត្ត | បានអនុវត្ត |

*ប្រភព : គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា*

**សមិទ្ធផល**

៣.៥១- *គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា* បានរៀបចំយុទ្ធសាស្ត្រស្តីពី កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ ២០១៤-២០១៨ ដោយបានកំណត់គោលការណ៍ និង ឧបករណ៍មួយចំនួនសម្រាប់ជាមូលដ្ឋានក្នុងការពង្រឹកភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ ឧបករណ៍ទាំងនោះរួមមាន៖ (១) អភិក្រមគ្រប់គ្រងទូទាំងកម្មវិធី (២) ក្របខណ្ឌលទ្ធផល និង អភិក្រមដែលផ្តោតលើលទ្ធផល (៣) សូចនាករតាមដានរួមគ្នា និង (៤) ការលើកកម្ពស់តម្លាភាព គណនេយ្យភាព និង លទ្ធផលក្នុងការប្រើប្រាស់ធនធាន។

៣.៥២- គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជាបានរៀបចំសូចនាករតាមដានរួមគ្នាតាមវិស័យ នាដើមឆ្នាំ២០១៤ សម្រាប់រយៈពេល៥ឆ្នាំខាងមុខ ស្របតាមអាណត្តិនៃ ផ.យ.អ.ជ. ២០១៤-២០១៨ ។ ប៉ុន្តែ ការពិនិត្យវឌ្ឍនភាពនៃការអនុវត្តសូចនាករតាមដានរួមគ្នា ត្រូវបានប្រព្រឹត្តទៅជារៀងរាល់ឆ្នាំ ហើយវឌ្ឍនភាពនេះ ត្រូវរាយការណ៍ជូនគណៈកម្មាធិការសម្របសម្រួលរវាងរាជរដ្ឋាភិបាល និង ដៃគូអភិវឌ្ឍន៍ ដើម្បីឯកភាពលើសកម្មភាពប្រចាំឆ្នាំដែលត្រូវអនុវត្ត សំដៅធានាសម្រេចឲ្យបាននូវគោលដៅដែលបានកំណត់។ ទន្ទឹមនេះ សូចនាករតាមដានរួមគ្នាទាំងនេះ ក៏ត្រូវរំលេចនៅក្នុងបណ្តាសកម្មភាពអាទិភាពដែលត្រូវត្រួតពិនិត្យក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិផងដែរ។

៣.៥៣- ក្រុមការងារបច្ចេកទេសចម្រុះ ដែលជាមូលដ្ឋានគ្រឹះនៃរចនាសម្ព័ន្ធភាពជាដៃគូ មានតួនាទីសម្របសម្រួលកិច្ចពិភាក្សាបច្ចេកទេសក្នុងកម្រិតវិស័យ និង អន្តរវិស័យ ព្រមទាំងកម្មវិធីកែទម្រង់នានា សម្រាប់គាំទ្រដល់ការអនុវត្តប្រកបដោយប្រសិទ្ធភាព ការតាមដាននិងការដកស្រង់បទពិសោធន៍។ ឆ្នាំ២០១៤ ក្រុមការងារបច្ចេកទេសចម្រុះបានពិនិត្យឡើងវិញនូវរបៀបរបបធ្វើការងាររបស់ខ្លួន រួមទាំងពិនិត្យពីសមាជិកភាពនិងតម្រូវការគាំទ្ររបស់លេខាធិការដ្ឋាន ដើម្បីអនុវត្តអភិក្រមផ្តោតលើលទ្ធផលនិងធានាភាពត្រឹមត្រូវនៃលក្ខខណ្ឌយោងរបស់ក្រុមការងារបច្ចេកទេសចម្រុះនីមួយៗ។ ជាលទ្ធផល ក្រុមការងារបច្ចេកទេសចម្រុះ គឺជាយន្តការពិគ្រោះយោបល់ដែលនៅតែមានប្រសិទ្ធភាពនៅកម្រិតវិស័យ ប៉ុន្តែការអនុវត្តការងាររបស់ក្រុមការងារបច្ចេកទេសចម្រុះទាំង១៩ នៅមានកម្រិត ទាមទារការយកចិត្តទុកដាក់ខ្ពស់លើបញ្ហាអន្តរវិស័យ ដូចជាយេនឌ័រ និង ការប្រែប្រួលអាកាសធាតុ ក៏ដូចជាយន្តការពង្រឹងសមត្ថភាពនិងប្រព័ន្ធជាតិ ដើម្បីធានាសង្គតិភាពជាមួយការដ្ឋានកែទម្រង់វិស័យសាធារណៈរបស់រាជរដ្ឋាភិបាល។

៣.៥៤- ថ្មីៗនេះ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា បានបញ្ចប់ការសិក្សាស្តីពីការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍។ របាយការណ៍នេះបានវិភាគគ្រប់

ផ្អែកជ្រោយនូវសក្ដានុពលហិរញ្ញប្បទាន ដើម្បីឆ្លើយតបនឹងតម្រូវការអភិវឌ្ឍន៍រយៈពេលមធ្យមរបស់កម្ពុជា (មួយទស្សវត្សរ៍ខាងមុខ) ព្រមទាំងលើកឡើងនូវបេកគំហើញ និងអនុសាសន៍សម្រាប់ជាមូលដ្ឋាននៃកិច្ចពិភាក្សានិងការធ្វើសេចក្ដីសម្រេច។ ទន្ទឹមនឹងនេះការវាយតម្លៃនេះបញ្ជាក់អំពីតួនាទីសំខាន់នៃការកៀរគរធនធានក្នុងស្រុក តួនាទីវិស័យឯកជន ក៏ដូចជាតួនាទីនិងការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការនិងភាពជាដៃគូជាមួយដៃគូអភិវឌ្ឍន៍ ។

**បញ្ហាប្រឈម**

៣.៥៥- នៅពេលកម្ពុជាសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប នឹងជះឥទ្ធិពលដល់ទំហំហិរញ្ញប្បទានក្រៅប្រទេស។ តាមបទពិសោធន៍របស់បណ្ដាប្រទេសមួយចំនួនបន្ទាប់ពីសម្រេចបាននូវឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាប ហិរញ្ញប្បទានឥតសំណងអាចនឹងធ្លាក់ចុះ និងត្រូវជំនួសវិញដោយកម្ចីសម្បទាន ហើយហិរញ្ញប្បទានសហប្រតិបត្តិការសុទ្ធអាចធ្លាក់ចុះ ដោយសារការធ្លាក់ចុះនៃការបើកផ្ដល់ហិរញ្ញប្បទានថ្មី ឬកំណើននៃការសងបំណុល។

៣.៥៦- *របៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ២០៣០* រួមទាំង *គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព* បង្កើតបានជាក្របខ័ណ្ឌអភិវឌ្ឍន៍មួយ ដែលចំណាយក្នុងការអនុវត្តក្របខណ្ឌនេះនឹងលើសលទ្ធភាពធនធានសាធារណៈដែលមាន ទោះបីមានប្រភពហិរញ្ញប្បទានថ្មីៗក៏ដោយ។ តួនាទីរបស់វិស័យឯកជននឹងកើនឡើងក្នុងការផ្ដល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តរបៀបវារៈអភិវឌ្ឍន៍ទាំងនេះ។

៣.៥៧- ដោយសារបរិការណ៍អភិវឌ្ឍន៍កម្ពុជាកាន់តែមានភាពស្មុគ្រស្មាញ បញ្ហាអន្តរវិស័យនឹងតម្រូវឲ្យមានការយកចិត្តទុកដាក់ខ្ពស់។ យន្តការប្រសិទ្ធភាពហិរញ្ញប្បទានបច្ចុប្បន្ន ដូចជាក្រុមការងារបច្ចេកទេសចម្រុះ អាចតម្រូវឲ្យមានការកែលម្អបន្ថែម ដើម្បីដោះស្រាយបញ្ហាស្មុគ្រស្មាញទាំងនេះ។

## ៣.៤- សមាហរណកម្មកម្ពុជាកាន់តែស៊ីជម្រៅនៅក្នុងតំបន់និងពិភពលោក

៣.៥៨- ពាណិជ្ជកម្មគឺជាប្រភពនៃកំណើនសេដ្ឋកិច្ចនិងការកាត់បន្ថយភាពក្រីក្រ។ ការនាំចេញ ជាផលធៀបនៃ ផ.ស.ស. អាចនឹងរក្សាបាន៤៦,២% ចំណែកការនាំចូលអាចធ្លាក់ចុះពី៦៦%ក្នុងឆ្នាំ២០១៦ទៅ៦៣%នៅឆ្នាំ២០១៧។ កម្ពុជាគឺជាសេដ្ឋកិច្ចសេរី ដែលពឹងផ្អែកសំខាន់លើពាណិជ្ជកម្ម។

៣.៥៩- លំហូរវិនិយោគផ្ទាល់បរទេសសម្រាប់៦ខែនៃឆ្នាំ២០១៦មានចំនួន៥១១លានដុល្លារអាមេរិក កើនពី៤៨១លានដុល្លារអាមេរិកសម្រាប់រយៈពេលដូចគ្នា។ លំហូរវិនិយោគផ្ទាល់បរទេសតិចជាង១ភាគ៤ត្រូវបានផ្ដល់ទៅវិស័យធនាគារ និងចំណែកផ្សេងទៀតទៅវិស័យផលិតកម្ម។

៣.៦០- កម្ពុជាបន្តអនុវត្តកិច្ចព្រមព្រៀងជាមួយអាស៊ាន ដែលត្រូវធ្វើសមាហរណកម្មចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានក្នុងនាមជាដៃគូស្មើភាពគ្នា។ កម្ពុជាបានចូលរួមក្នុងធនាគារអភិវឌ្ឍន៍វិនិយោគហេដ្ឋារចនាសម្ព័ន្ធក្នុងពេលថ្មីៗនេះ។

៣.៦១- តាមរយៈនៃកិច្ចខិតខំនេះ រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផល ដូចមានខាងក្រោម៖

- បានសហការសម្របសម្រួលជាមួយអង្គការសហប្រជាជាតិក្នុងការស្នើសុំខ្ចីផែនទី UTM ខ្នាត១/១០០ ០០០ ចំនួន១៨ផ្ទាំង ពីអង្គការសហប្រជាជាតិ ដែលជាផែនទីតម្កល់ទុកដោយរាជរដ្ឋាភិបាលកម្ពុជានៅឆ្នាំ១៩៦៤ មកធ្វើការផ្ទៀងផ្ទាត់បង្ហាញឲ្យឃើញភាពត្រឹមត្រូវស្របច្បាប់នៃផែនទី Bonne ខ្នាត១/១០០ ០០០ ចំនួន ២៦ផ្ទាំង។
- បានធ្វើទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អរវាងកម្ពុជា និងចិន ក្នុងការរួមចំណែកដ៏សំខាន់ក្នុងការថែរក្សាសន្តិសុខ និងស្ថេរភាពក្នុងតំបន់ ។ ជាក់ស្តែងកម្ពុជា បានដើរតួនាទីគន្លឹះក្នុងការសម្របសម្រួលរវាងអាស៊ាន-ចិនលើបញ្ហាសមុទ្រចិនខាងត្បូងរហូតសម្រេចបានកុងសង់ស៊ីស (consensus) ក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានលើកទី៤៩ ដែលបានប្រព្រឹត្តិទៅកាលពីខែកក្កដា ឆ្នាំ២០១៦ នៅទីក្រុងវៀងចន្ទន៍ ប្រទេសឡាវ។
- ចំពោះបញ្ហាសន្តិសុខ និងសណ្ដាប់ធ្នាប់សង្គម ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ បានខិតខំការពារផលប្រយោជន៍ និងសិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ពិសេសពលករបម្រើការនៅបរទេស។
- បានចុះកិច្ចព្រមព្រៀងលើកលែងទិដ្ឋាការសម្រាប់អ្នកកាន់លិខិតឆ្លងដែនការទូត និងផ្លូវការជាមួយប្រទេសបេឡារុស តួកគី កូវ៉ែត ទីម័រឡេស្តេ និងសេប៊ី។
- បានបង្កើតមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) តាមរយៈសេចក្តីថ្លែងការណ៍ថ្នាក់ដឹកនាំអាស៊ាន ស្តីពីការបង្កើត ARMAC ដែលបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី២១ កាលពីថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០១២ នៅរាជធានីភ្នំពេញ ។
- បានធ្វើការយ៉ាងសកម្មជាមួយនឹងប្រទេសសមាជិកអាស៊ានទាំងអស់ ដើម្បីសម្រេចបាននូវគោលដៅរបស់អាស៊ានជា សហគមន៍មួយដែលផ្អែកលើវិធានច្បាប់ ដោយយកចិត្តទុកដាក់លើប្រជាជន និងយកប្រជាជនជាស្នូល និងស្របតាម "ទស្សនវិស័យតែមួយ អត្តសញ្ញាណតែមួយ សហគមន៍តែមួយ" ។

- បានចូលរួមចំណែកយ៉ាងសកម្មក្នុងអាស៊ាន តាមរយៈការអនុវត្តនូវកាតព្វកិច្ចនានា ដែលមានចែងនៅក្នុងធម្មនុញ្ញអាស៊ាន ការអនុវត្តកិច្ចព្រមព្រៀង លិខិតូបករណ៍នានា និងសេចក្តីសម្រេចទាំងឡាយរបស់អាស៊ាន ព្រមទាំងចូលរួមរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ាន កិច្ចប្រជុំពាក់ព័ន្ធ និងការរៀបចំសកម្មភាពនានា។
- បានជំរុញ និងលើកកម្ពស់ទំនាក់ទំនងភាពជាដៃគូរបស់អាស៊ានជាមួយបណ្តាប្រទេស និង និងអង្គការតំបន់អន្តរជាតិខាងក្រៅតំបន់ ដោយប្រកាន់ខ្ជាប់នូវគោលការណ៍/អព្យាក្រឹត្យ ការមិនរើសអើង ការបើកចំហ ការសម្លឹងឆ្ពោះទៅខាងក្រៅ និងការដោះស្រាយជម្លោះដោយសន្តិវិធី។
- បានចូលរួមយ៉ាងសកម្មក្នុងការរក្សាតួនាទីស្នូលរបស់អាស៊ានក្នុងការដោះស្រាយបញ្ហាប្រឈមនានា ដែលធ្វើឲ្យប៉ះពាល់ដល់សន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ ដើម្បីធានាថាប្រជាជនអាស៊ាននឹងបន្តរស់នៅក្នុងតំបន់មួយ ដែលប្រកបដោយការឯកភាពគ្នា សុវត្ថិភាព សន្តិភាព ស្ថិរភាព និងភាពស្និតរម្មួតនឹងគ្នា ការទទួលបាននូវកិច្ចការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន ព្រមទាំងការទទួលបាននូវអត្ថប្រយោជន៍ពីការតភ្ជាប់ ឱកាសការងារកាន់តែច្រើន និងវិបុលភាពកាន់តែប្រសើរឡើង ។
- បច្ចុប្បន្នកម្ពុជាមានទំនាក់ទំនងការទូតជាមួយប្រទេសជាមិត្តចំនួន១៥៨ប្រទេស មានស្ថានឯកអគ្គរាជទូត និងមានស្ថានបេសកកម្មអចិន្ត្រៃយ៍ប្រចាំនៅបរទេសសរុបចំនួន៣៨។ ក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាលកម្ពុជាបានបើកស្ថានឯកអគ្គរាជទូតនៅអេហ្ស៊ីប ស្ថានអគ្គកុងស៊ុលនៅខេត្តស៊ីអាន(ប្រទេសចិន) ស្ថានអគ្គកុងស៊ុលនៅខេត្តប៉ាកសេ (ប្រទេសឡាវ) កុងស៊ុលកិត្តិយសនៅទីក្រុងទូលូ(ប្រទេសបារាំង) និងកុងស៊ុលកិត្តិយសនៅទីក្រុងមីឡាន (ប្រទេសអ៊ីតាលី) ។ ក្រៅពីស្ថានទូតបរទេស ក៏មានអង្គការអន្តរជាតិ ទីភ្នាក់ងារអ.ស.ប និងអង្គការមិនមែនរដ្ឋាភិបាលបរទេសជាច្រើនតាំងនៅ និងធ្វើសកម្មភាពសហប្រតិបត្តិការលើគ្រប់វិស័យជាមួយកម្ពុជា។
- បានចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅ ម៉ាលី អាហ្វ្រិកកណ្តាល លីបង់ ស៊ូដង់ ស៊ូដង់ខាងត្បូង និង ស៊ីប។
- បានដាក់បេក្ខភាពកម្ពុជាជាសមាជិកនៃក្រុមប្រឹក្សាសេដ្ឋកិច្ច និងសង្គមរបស់អ.ស.ប (Economic and Social Council) សម្រាប់អាណត្តិ ២០១៩ សំដៅចូលរួមដោះស្រាយបញ្ហាសង្គម និងសេដ្ឋកិច្ចអន្តរជាតិ។
- សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចុះអនុស្សារណៈនៃការយោគយល់ជាមួយលោក Tigran Sargsy ប្រធានក្រុមប្រឹក្សាភិបាលនៃគណៈកម្មការសេដ្ឋកិច្ចអឺរ៉ុប-អាស៊ី ដើម្បីជំរុញការអភិវឌ្ឍនៃទំនាក់ទំនងរវាងកម្ពុជានិងប្រទេសជាសមាជិករបស់ EEC ។

- បានពង្រឹងនិងពង្រីកទំនាក់ទំនងទ្វេភាគីជាមួយប្រទេសជាមិត្ត អង្គការអន្តរជាតិនិងទីភ្នាក់ងារអង្គការសហប្រជាជាតិ ដើម្បីស្វែងរកជំនួយសម្រាប់អភិវឌ្ឍន៍ប្រទេសលើគ្រប់វិស័យ។

៣.៦២- ការដាក់ចេញគោលនយោបាយស្តីពីការលើកកម្ពស់ផលិតកម្មកសិកម្មនិងការនាំចេញស្រូវអង្ករ និង យុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិកម្ពុជា ២០១១-២០២០ បានបង្ហាញសញ្ញាច្បាស់លាស់ថាកម្ពុជាមានបំណងប្រកួតប្រជែងក្នុងទីផ្សារអង្ករនិងកៅស៊ូសកល។

៣.៦៣- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម បានបញ្ជាក់ថាកម្ពុជាមានបំណងធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួននិងបង្កើនផលិតភាព ដើម្បីប្រកួតប្រជែងក្នុងទីផ្សារតំបន់និងសកលប្រកបដោយប្រសិទ្ធភាព។ វឌ្ឍនភាពជាច្រើនសម្រេចបានក្នុងការកែលម្អក្របខ័ណ្ឌគតិយុត្តដើម្បីពង្រឹងបរិស្ថានវិនិយោគនិងពាណិជ្ជកម្ម។

កម្ពុជាកំពុងដើរតួនាទីសំខាន់ជាប្រជាពលរដ្ឋសកលតាមរយៈការចូលរួមក្នុងការរក្សាសន្តិភាពនិងសកម្មភាពបោសសម្អាតគ្រាប់មីនអន្តរជាតិ។

៣.៦៤- គោលនយោបាយបើកចំហរមេឃរបស់កម្ពុជាដើរតួនាទីសំខាន់ក្នុងការទាក់ទាញភ្ញៀវទេសចរ ភាគច្រើនមកពីប្រទេសក្នុងតំបន់។ ការផ្សព្វផ្សាយទេសចរណ៍របស់កម្ពុជាកំពុងកើនឡើងក្នុងកម្រិតសកល។

៣.៦៥- ការសម្តែងរបស់អត្តពលិកអូឡាំពិករបស់កម្ពុជាក្នុងរីយ៉ូនិងផែនការរបស់កម្ពុជាក្នុងការទទួលរៀបចំអាស៊ីហ្គេម២០២៣ បង្ហាញថាកីឡានិងអត្តពលិកគឺជាចំណុចចូលរួមផ្សេងទៀតសម្រាប់សមាហរណកម្មទៅក្នុងកិច្ចការតំបន់និងសកល។

**បញ្ហាប្រឈម**

៣.៦៦- សមាហរណកម្មរបស់កម្ពុជាជាមួយសហគមន៍សេដ្ឋកិច្ចអាស៊ានរួមទាំងទំនាក់ទំនងពាណិជ្ជកម្មសកលនឹងតម្រូវឲ្យមានសហប្រតិបត្តិការនិងកិច្ចសម្របសម្រួលរវាងរដ្ឋាភិបាលនិងតួអង្គអភិវឌ្ឍផ្សេងទៀតក្នុងការពង្រឹងសមត្ថភាពនិងប្រព័ន្ធជាតិ ដើម្បីកែលម្អការផ្តល់សេវានិងពង្រឹងភាពប្រកួតប្រជែងពាណិជ្ជកម្មសេដ្ឋកិច្ច និងបន្តកសាងសមត្ថភាពសម្រាប់ការតាមដាននិន្នាការពាណិជ្ជកម្មនៅគ្រប់វិស័យ។

៣.៦៧- ភាពប្រកួតប្រជែងរបស់កម្ពុជាគឺតម្លៃពលកម្មទាប ដោយសារកម្លាំងពលកម្មអត់ជំនាញ។ ដើម្បីរក្សាបានភាពប្រកួតប្រជែងនេះ ត្រូវបង្កើនជំនាញដល់កម្លាំងពលកម្មដើម្បីពង្រឹងផលិតភាព។

៣.៦៨- រចនាសម្ព័ន្ធក្រសួងនិងធនធានមនុស្ស របៀបត្រិះរិះពិចារណា និងការធ្វើការងាររបស់មន្ត្រីបំពេញការងារក្នុងក្រសួងនិងមន្ត្រីការទូត ជាពិសេស ថវិកាសម្រាប់ដំណើរការជាបញ្ហាប្រឈមដែលតម្រូវឲ្យមានការកែទម្រង់។ ការបំពុលបរិយាកាសនយោបាយទាំងក្នុងប្រទេសនិងនៅក្រៅប្រទេស គួបផ្សំនឹងនិន្នាការជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់កម្ពុជាក្រោមរូបភាព “សិទ្ធិមនុស្ស” និង “លទ្ធិប្រជាធិបតេយ្យ” របស់អង្គការចាត់តាំង និងប្រទេសមួយចំនួន បានបង្កឡើងនូវបញ្ហាប្រឈមសម្រាប់ប្រទេសកម្ពុជា។ រីឯបញ្ហាប្រឈមសំខាន់មួយទៀតរបស់កម្ពុជា គឺបញ្ហាការកំណត់ខ័ណ្ឌសីមាព្រំដែនជាមួយប្រទេសជិតខាងរួមមានៈ កម្ពុជា វៀតណាម កម្ពុជា ថៃ និង កម្ពុជា ឡាវ និង បញ្ហាពលករកម្ពុជាដែលធ្វើការនៅបរទេសទទួលរងការធ្វើបាប និង ធ្វើការហួសកម្លាំងដែលផ្ទុយនឹងគោលការណ៍របស់អង្គការពលកម្មអន្តរជាតិ។

**សន្និដ្ឋាន**

៣.៦៩- ការពិនិត្យមើលសូចនាករស្ទួលបង្ហាញថាស្ថេរភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាផ្តល់បរិយាកាសអំណោយផលសម្រាប់កំណើនដោយប្រកបដោយចីរភាព និង ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចប្រកបដោយបរិយាប័ន្ន។ ដំណើរការកំណែទម្រង់ទាក់ទងនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមានវឌ្ឍនភាពល្អ ជាពិសេសការអនុវត្តថវិកាកម្មវិធី ការគៀរគរចំណូល និងប្រព័ន្ធព័ត៌មានគ្រប់គ្រងហិរញ្ញវត្ថុ។ ស្ថេរភាពបរិស្ថានគឺជាបញ្ហាព្រួយបារម្ភមួយ ជាពិសេសទាក់ទងនឹងការកាប់បំផ្លាញព្រៃឈើនិងការគ្រប់គ្រងធនធានទឹក។ ឧទាហរណ៍ សូចនាករស្តីពីគម្របព្រៃឈើស្ថិតនៅក្រោមចំណុចដៅក្នុងផ.យ.អ.ជ.។ ការពិនិត្យលើសូនាករសំខាន់ៗបង្ហាញថាភាពជាដៃគូសម្រាប់ការអភិវឌ្ឍបន្តមានវឌ្ឍនភាពល្អ ប៉ុន្តែតម្រូវឲ្យមានកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីពង្រឹងតម្លាភាពថវិកាសាធារណៈនិងកែលម្អកិច្ចពិគ្រោះយោបល់ហិរញ្ញវត្ថុអភិវឌ្ឍន៍។ រាជរដ្ឋាភិបាលបន្តពង្រីកការគៀរគរធនធានសម្រាប់ការអភិវឌ្ឍបន្ថែមទៀត។ កម្ពុជាបន្តធ្វើសមាហរណកម្មស៊ីជម្រៅទៅក្នុងសហគមន៍តំបន់និងសកល។ សេដ្ឋកិច្ចកម្ពុជាពឹងផ្អែកច្រើនលើពាណិជ្ជកម្ម ប៉ុន្តែបរិយាកាសពាណិជ្ជកម្មកាន់តែមានភាពក្រគួតប្រជែងច្រើន ដែលតម្រូវឲ្យកម្ពុជាប្រឹងប្រែងបន្ថែមទៀតក្នុងការលើកកម្ពស់ពាណិជ្ជកម្មនិងអភិវឌ្ឍការងារឲ្យកាន់តែមានភាពប្រកួតប្រជែង។

## ៤- ការលើកស្ទួយវិស័យកសិកម្ម

៣.៧០- ប្រជាជនកម្ពុជាច្រើនជាង៧៥% រស់នៅដោយពឹងផ្អែកលើការចិញ្ចឹមជីវិតពីវិស័យកសិកម្ម។ វិស័យកសិកម្មគឺជាប្រភពចំណូលសំខាន់សម្រាប់ប្រជាជនកម្ពុជាប្រមាណ៨៥%។ វិស័យកសិកម្មបានចូលរួមចំណែកប្រហែល២៨,៦% នៃផលិតផលក្នុងស្រុកសរុប (ថ្លៃបច្ចុប្បន្ន) ក្នុងឆ្នាំ ២០១៥។ សម្រាប់វិស័យកសិកម្មទាំងមូល សមាសភាគចូលរួមចំណែកគិតជាភាគរយ នៃផលិតកម្ម

ដំណាំគ្រប់ប្រភេទនាឆ្នាំ២០១៥ មានចំនួនជាងពាក់កណ្ដាលពោលគឺកើនដល់៦០% នៃផលិតផលក្នុងស្រុកសរុបវិស័យកសិកម្ម។ ផលិតកម្មនេសាទបានចូលរួមចំណែកបន្ទាប់ពីដំណាំ គឺមានប្រមាណ ២២% និងអាជីវកម្មព្រៃឈើប្រមាណ៧%។

៣.៧១- គោលបំណងគោលនយោបាយរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ គឺបង្កើនកំណើនវិស័យកសិកម្មឲ្យបាន៥%ក្នុងមួយឆ្នាំតាមរយៈការពង្រឹងផលិតភាពកសិកម្ម ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម និងការគ្រប់គ្រងធនធានជលផលនិងព្រៃឈើប្រកបដោយចីរភាព។

៣.៧២- កំណើនក្នុងវិស័យកសិកម្មត្រូវបានបង្ហាញថាមានការធ្លាក់ចុះ អាស្រ័យដោយកត្តាធម្មជាតិពិសេសផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរពីគ្រោះរាំងស្ងួតក្នុងរយៈពេលបីឆ្នាំចុងក្រោយនេះ។ នៅឆ្នាំ ២០១០ កំណើនកសិកម្មមានក្នុងរង្វង់៤% និងនៅឆ្នាំ២០១១ កំណើននេះបានបន្តធ្លាក់មកត្រឹម ៣,១% ហើយនៅឆ្នាំ២០១២ បានកើនឡើងដល់ប្រមាណ៤,៣%។ ក្នុងចន្លោះឆ្នាំ២០១៣ដល់ ២០១៥ កំណើនកសិកម្មត្រូវបានវាយតម្លៃថាបានធ្លាក់ចុះយ៉ាងគំហុក (១,៥៧% ក្នុងឆ្នាំ២០១៣ និងប្រហែលជិត១% នៅឆ្នាំ២០១៤ និង២០១៥)។ ស្ថានភាពអាក្រក់នៃគ្រោះរាំងស្ងួតនេះបានរាំងខ្លាំងដល់ផលិតកម្មដំណាំ ក៏ដូចជាផលិតកម្មសត្វ (ពិសេសការចិញ្ចឹមគោក្របី) និងមានផលប៉ះពាល់ធ្ងន់ធ្ងរដល់ការនេសាទ ដោយសារកម្រិតកម្ពស់ទឹកទន្លេទាប មិនបានហូរចូលដល់បឹងព្រែកគ្រប់គ្រាន់។

៣.៧៣- ជំរឿនកសិកម្មដំបូងត្រូវបានបញ្ចប់ក្នុងឆ្នាំ២០១៥ តាមរយៈកិច្ចសហប្រតិបត្តិការរវាងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានការគាំទ្រហិរញ្ញវត្ថុពីអង្គការស្បៀងនិងកសិកម្ម។ ជំរឿននេះផ្ដល់ជាទិន្នន័យមូលដ្ឋានដែលអាចប្រើប្រាស់សម្រាប់វាស់វែងសូចនាករសំខាន់ៗ។

## ៤.១- ការលើកកម្ពស់ផលិតភាព ពិពិធភាវូបនីយកម្មកសិកម្ម និងពាណិជ្ជូបនីយកម្ម

### ផលិតកម្មដំណាំស្រូវ

៣.៧៤- គោលនយោបាយស្ដីពីការជំរុញផលិតកម្មស្រូវនិងការនាំចេញអង្ករ ផ្ដល់ជាផែនទីចង្អុលផ្លូវសម្រាប់បង្កើនផលិតកម្មស្រូវនិងការនាំចេញអង្ករ។ ផ្ទៃដីផលិតកម្មដំណាំស្រូវអនុវត្តបានចំនួន ២,៩៦លានហ.ត នាឆ្នាំ២០១១ និងបានកើនដល់ ៣,០៥លានហ.ត. នាឆ្នាំ២០១៥ (ថយចុះប្រមាណ០,១៣%ធៀបនឹងឆ្នាំ២០១៤)។ ផ្ទៃដីប្រមូលផលបានកើនពី២,៧៦លានហ.ត. នាឆ្នាំ ២០១១ ដល់ជាង៣,០២៥លានហ.ត. នាឆ្នាំ២០១៥ និងទិន្នផលជាមធ្យមប្រចាំឆ្នាំទទួលបាន ៣,០៨៥តោន/ហ.ត. កើនលើសឆ្នាំ២០១៤ប្រមាណ 0,១១% (ទិន្នផលស្រូវឆ្នាំ២០១៤ ទទួលបានត្រឹមតែ៣,០៧៩តោន/ហ.ត.)។ ផលិតកម្មដំណាំស្រូវបានទទួលរងដោយគ្រោះធម្មជាតិ ពិសេសគ្រោះរាំងស្ងួតខ្លាំងនៅក្នុងឆ្នាំ២០១៤និង២០១៥កន្លងទៅនេះ។តែទោះជាយ៉ាងនេះក្ដី នាឆ្នាំ២០១៥កន្លងទៅនេះ កម្ពុជាទទួលបានបរិមាណផលស្រូវសរុបប្រមាណជាង៩,៣៣លានតោន កើនលើសឆ្នាំ២០១៤ប្រមាណជា០,១២% (ឆ្នាំ២០១៤ សម្រេចបានត្រឹមតែ៩,៣២លានតោន) និងអាចសល់

សៀ្វងជាអង្ករសរុបចំនួនជាង២,៩៧លានតោន ឬ គិតជាស្រូវនៅសល់ប្រមាណជាង៤,៦៤លានតោន។ ដោយឡែកនៅឆ្នាំ២០១៦ ផ្ទៃដីដាំដុះដំណាំស្រូវសម្រេចបានលើផ្ទៃដី៣,១១លានហ.ត. ទិន្នផលស្រូវគិតជាមធ្យមទាំងប្រាំងនិងវស្សាបានកើនដល់៣,២១១តោន/ហ.ត. និងបរិមាណផលស្រូវបានកើនឡើងដល់ប្រមាណ៩,៩៥លានតោន។

៣.៧៥- ការសម្រេចបានក្នុងការបង្កើនផលិតភាពដំណាំស្រូវបណ្ដាលមកពីកត្តាសំខាន់ៗមួយចំនួនដូចជា ការផ្លាស់ប្ដូរពូជស្រូវដែលមានទិន្នផលខ្ពស់ ដែលជាលទ្ធផលទទួលបានពីការពិសោធស្រាវជ្រាវ ការផ្ទេរបច្ចេកទេសសមស្របដល់កសិករ ពិសេស ការពង្រីកកាន់តែមានប្រសិទ្ធភាព លើការធ្វើស្រែបង្ហាញតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ ការអនុវត្តបច្ចេកទេសគ្រប់គ្រងដី ដើម្បីបង្កើនជីជាតិនិងទិន្នផលដំណាំ និងការបង្កើនការស្រាវជ្រាវនិងអភិវឌ្ឍពូជស្រូវ ដែលស្របនឹងលក្ខណៈដី អាកាសធាតុ ការកំណត់ប្រភេទពូជសំខាន់ៗស្របតាមតម្រូវការទីផ្សារ។ ជាការកត់សម្គាល់បន្ថែមទៀត យន្តូបនីយកម្មកសិកម្មពិតជាបាននិងកំពុងដើរតួសំខាន់ ព្រមទាំងបំពេញនូវកម្លាំងពលកម្មដែលខ្វះខាតក្នុងវិស័យកសិកម្មនាពេលកន្លងមក។

៣.៧៦- ការនាំចេញអង្ករជាផ្លូវការបានកើនពី១០៥ ២៥៩តោន នៅឆ្នាំ២០១០ ដល់២០៥ ៧១៧តោននៅឆ្នាំ២០១២ និងដល់៥៤២ ១៤៤តោន នៅឆ្នាំ២០១៦ ដែលកំណើននេះមានប្រមាណជាប្រាំដងធៀបឆ្នាំ២០១០ និងជាងពីរដងធៀបឆ្នាំ២០១២។ ប្រភេទអង្ករនាំចេញឆ្នាំ២០១៦ គឺអង្ករក្រអូបមានចំនួន៥៦,៦១% អង្ករសគ្រប់ប្រភេទមានចំនួន៣៤,៧៩% និងអង្ករចំហុយមានចំនួន៨,៦% និងបាននាំចេញទៅកាន់ទិសដៅ៦៥ប្រទេស នៅលើសាកលលោក និងមានក្រុមហ៊ុននាំចេញអង្ករចំនួន៨៥ក្រុមហ៊ុន។ ការនាំចេញអង្ករទៅប្រទេសសំខាន់ៗច្រើនជាងគេចំនួន១០រួមមាន ៖ ប្រទេសចិន បារាំង ប៉ូឡូញ ម៉ាឡេស៊ី ហូឡង់ ប៊ែលហ្សិក ឆេក អ៊ីតាលី អង់គ្លេស និង អាឡឺម៉ង់។

**តារាងទី៣.៥: ផលិតកម្មដំណាំស្រូវប្រចាំឆ្នាំ២០១២-ឆ្នាំ២០១៦**

| បរិយាយ | ២០១២ | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ប្រៀបធៀប ២០១៦/ ២០១៥ |
|---|---|---|---|---|---|---|
| ផ្ទៃដីដាំដុះ (ហ.ត.) | ៣ ០០៧ ៥៤៥ | ៣ ០៥២ ៤២០ | ៣ ០៥៥ ៥០៧ | ៣ ០៥១ ៤១២ | ៣ ១១៨ ១៦០ | ២,០៥% |
| ផ្ទៃដីប្រមូលផល (ហ.ត.) | ២ ៩៨០ ២៩៧ | ២ ៩៦៨ ៩៦៧ | ៣ ០២៨ ៨៣៦ | ៣ ០២៥ ៦៣០ | ៣ ០៩៩ ៧៦៩ | ២,៣៤% |
| ទិន្នផល (តោន/ ហ.ត.) | ៣,១១៧ | ៣,១៦៣ | ៣,០៧៩ | ៣,០៨៥ | ៣,២១១ | ៤,២៩% |
| បរិមាណផល (តោន) | ៩ ២៩០ ៩៤០ | ៩ ៣៨៩ ៩៦១ | ៩ ៣២៤ ៤១៦ | ៩ ៣៣៥ ២៨៤ | ៩ ៩៥២ ២៧០ | ៦,៧៣% |
| **បរិមាណអង្ករសល់ (លានតោន)** | ៣ ០៣១ ០១៧ | ៣ ០៩០ ៤៥២ | ៣ ០១៣ ៧៨៣ | ២ ៩៧៥ ៨០៩ | ៣ ២៧៥ ០៨៩ | ៨,៦៧% |
| **គិតជាស្រូវសល់ (លានតោន)** | ៤ ៧៣៥ ៩៦៤ | ៤ ៨២៨ ៨៣២ | ៤ ៧០៩ ០៣៦ | ៤ ៦៤៩ ៧០២ | ៥ ១១៧ ៣២៧ | ៨,៦៧% |

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**រូបភាពទី៣.១: ផលិតកម្មស្រូវនៅរដូវប្រាំងនិងរដូវវស្សា ឆ្នាំ២០១២-ឆ្នាំ២០១៦**




ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

**៣.៧៧-** បច្ចុប្បន្នការប្រើប្រាស់គ្រឿងយន្តនិងឧបករណ៍កសិកម្ម កំពុងមាននិន្នាការកើនឡើងគួរឲ្យកត់សម្គាល់ ដែលជាបច្ច័យមួយបង្ហាញអំពីដំណើរការវិវត្តនៃយន្តូបនីយកម្មក្នុងវិស័យកសិកម្មកម្ពុជា។ ជាក់ស្ដែងក្នុងឆ្នាំ២០១៥នេះ ផ្ទៃដីភ្ជួររាស់សម្រេចបានសរុបប្រមាណ៣,៥២លានហ.ត. ក្នុងនោះ ភ្ជួររាស់ដោយគ្រឿងយន្តកសិកម្មសម្រេចបាន២,៧៤លានហ.ត. ស្មើនឹង៩១%។

៣.៧៨- ការអភិវឌ្ឍសហគមន៍កសិកម្មក៏បាននិងកំពុងទទួលបានការយកចិត្តទុកដាក់ ក្នុងការលើកកម្ពស់សមត្ថភាព ដើម្បីបង្កលក្ខណៈងាយស្រួលដល់ការអភិវឌ្ឍកសិកម្មមានលក្ខណៈប្រមូលផ្ដុំក្នុងភាពជាដៃគូជាមួយផ្នែកឯកជននានា ទទួលបានទាំងបច្ចេកវិទ្យាថ្មីនិងឥណទាន និងធានាស្ថេរភាពនៃការផ្គត់ផ្គង់ផលិតផលទៅកាន់ទីផ្សារក្នុងស្រុក និងអន្តរជាតិ ជាពិសេសជំរុញការអភិវឌ្ឍសហគមន៍កសិកម្មឲ្យក្លាយជាសហគ្រាសកសិកម្មជនបទ សំដៅលើកកម្ពស់សេដ្ឋកិច្ច-សង្គមជនបទ។ ការចងក្រងនិងចុះបញ្ជីសហគមន៍កសិកម្មបានចាប់ផ្ដើមក្នុងឆ្នាំ២០០៣ ហើយមកទល់ចុងឆ្នាំ២០១៥នៅទូទាំងប្រទេសមានសហគមន៍កសិកម្មសរុបចំនួន៧៥០សហគមន៍ និងឆ្នាំ២០១៦កើនដល់៨៥៧សហគមន៍។

## រូបភាពទី៣.២: កំណើនសហគមន៍កសិកម្ម




ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

### ការអភិវឌ្ឍនិងការស្រាវជ្រាវកសិកម្ម

៣.៧៩- ការងារស្រាវជ្រាវនិងអភិវឌ្ឍន៍បច្ចេកវិទ្យាដំណាំកសិកម្ម គឺជាការងារចាំបាច់ក្នុងការអនុវត្តកម្មវិធីបង្កើនផលិតភាព ពិពិធភាវូបនីយកម្ម និងពាណិជ្ជូបនីយកម្មកសិកម្ម។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដោយមានវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (កាឌី) ជាអង្គភាពជំនាញ បានបង្កើតពូជដំណាំកសិកម្មថ្មីៗ ថែរក្សានូវគុណភាពគ្រាប់ពូជនៃពូជដំណាំដែលបានបញ្ចេញ ធ្វើការផ្សព្វផ្សាយពូជទាំងនោះ និងវិធីសាស្ត្រសម្រិតសម្រាំងគ្រាប់ពូជស្រូវបែបកសិករ បច្ចេកវិទ្យាដាំដុះ ថែទាំ និងប្រមូលផល រួមទាំងចងក្រង បោះពុម្ព និងផ្សព្វផ្សាយអត្ថបទវិទ្យាសាស្ត្រ ព្រមទាំងឯកសារបច្ចេកវិទ្យា ជូនដល់កសិករនិងអ្នកពាក់ព័ន្ធទូទាំងប្រទេស។ រាល់ពូជដំណាំដែលក្រសួងបានបញ្ចេញជូនកសិករប្រើប្រាស់ត្រូវបានធានានូវភាពសុទ្ធរបស់វាតាមរយៈការផលិតគ្រាប់ពូជសុទ្ធគ្រើះ ផ្គត់ផ្គង់តាមការបញ្ជាទិញរបស់ក្រុមហ៊ុនឯកជន សហគមន៍កសិកម្ម និងគម្រោងអភិវឌ្ឍន៍នានាដែលអនុវត្តដោយអង្គភាពជំនាញរបស់ក្រសួង និងអង្គការផ្សេងៗ ដើម្បីផលិតនិងផ្គត់ផ្គង់បន្តជូនកសិករ។ ជាក់ស្តែងថ្មីៗនេះ កាឌីបានបញ្ចេញពូជស្រូវថ្មីចំនួន០២បន្ថែមទៀតគឺ (១) ***ពូជស្រូវ ខា១៦*** ដែលជាពូជស្រូវស្រាលមិនប្រកាន់រដូវធន់នឹងកម្តៅខ្ពស់ និងមានប្រភពដើមពីអ៊ីរី (IR10L149) និង (២) ពូជស្រូវ ***ស្នា៨០២*** ដែលជាពូជស្រូវធ្ងន់ប្រកាន់រដូវ សមស្របសម្រាប់ដីជម្រៅខ្លាំងនៃស្រែទំនាបរំពឹងទឹកភ្លៀង។

### ៤.២- ការលើកកម្ពស់ការចិញ្ចឹមសត្វនិងវារីវប្បកម្ម

៣.៨០- ផលិតកម្មសត្វ (គោក្របីជ្រូកមាន់ទា) ជាលក្ខណៈគ្រួសារ ក្នុងរយៈពេល៥ឆ្នាំពីឆ្នាំ២០១២ ដល់ឆ្នាំ២០១៦នេះ មាននិន្នាការកើនឡើង ពោលគឺបានកើនពី២៥,៣៦លានក្បាល ដល់៣៤,១៩ លានក្បាល។ ការចិញ្ចឹមគោមាន ការប្រែប្រួលថយចុះប្រមាណ០,២២% ដោយបានថយចុះពី៣,៤ លានក្បាលនាឆ្នាំ២០១២ មកត្រឹមតែ២,៩លាន ក្បាលនាឆ្នាំ២០១៦។ រីឯក្របីក៏មានការប្រែប្រួល កើនឡើងប្រមាណ ៣,៣៩% គឺពិនិត្យពីរឆ្នាំចុងក្រោយឆ្នាំ២០១៥ មានត្រឹមតែ៥០៦ពាន់ក្បាល កើនប្រមាណជាង ៥២៣ពាន់ក្បាល ក្នុងឆ្នាំ២០១៦។ ការថយចុះចំពោះផលិតកម្មចិញ្ចឹមសត្វគោ ក្របីនេះ គឺជាការថយចុះគោក្របីអូសទាញ មូលហេតុបណ្ដាលមកពីកសិករកាន់តែច្រើនឡើងៗ បោះបង់ការភ្ជួររាស់ដោយគោក្របី មកប្រើប្រាស់សេវាគ្រឿងយន្តកសិកម្ម កង្វះកម្លាំងពលកម្មនៅ ជនបទ (ចំណាកស្រុក) មានការលំបាកក្នុងការស្វែងរកតំបន់មានទឹក និងចំណីគ្រប់គ្រាន់សម្រាប់ ការចិញ្ចឹមសត្វគោក្របី។ ទន្ទឹមនឹងការថយចុះគោអូសទាញនេះ កសិករបានងាកមកចិញ្ចឹមគោមេ និងគោយកសាច់ ហើយជាមួយគ្នានោះ ក៏មានការចាប់ផ្ដើមការវិនិយោគឯកជនចិញ្ចឹមគោសាច់វិញ ផងដែរ។

៣.៨១- មានការកត់សម្គាល់ ការចិញ្ចឹមសត្វជាលក្ខណៈពាណិជ្ជកម្មមានការកើនឡើង ដោយកសិដ្ឋានចិញ្ចឹមសត្វមានចំនួនរហូតដល់២ ៨៥៦កន្លែង និងមានការវិនិយោគបង្កើតរោងចក្រចំណីសត្វ សម្រាប់ផ្គត់ផ្គង់តម្រូវការប្រើប្រាស់ក្នុងស្រុក។ ជាមួយគ្នានេះ ប្រជាកសិករមានការយល់ដឹងខ្ពស់ លើការប្រើប្រាស់ចំណីសត្វនិងចំណីផ្សំស្រេច ប៉ុន្តែចំណីនិងថ្នាំសត្វនៅមានតម្លៃខ្ពស់នៅឡើយ។ ជាការវាយតម្លៃ ប្រជាកសិករមានការយល់ដឹងបណ្ដើរៗនូវបច្ចេកទេសចិញ្ចឹមសត្វ តាមគោលការណ៍ជីវសុវត្ថិភាព និងការយល់ដឹងអំពីវិធានការទប់ស្កាត់ជំងឺឆ្លង។

### វិស័យកសិឧស្សាហកម្ម

៣.៨២- ផ្ទៃដីផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន ១ ០៣៤ ៦៤០ ហ.ត នៅឆ្នាំ២០១៦ លើសឆ្នាំមុនចំនួន៥០ ៥០២ហ.ត និងទទួលបានបរិមាណផលសរុបចំនួន ១៦លានតោន លើសឆ្នាំមុនចំនួន៧៣១ ០៥៧តោន ក្នុងនោះ៖

- ដំណាំរួមផ្សំអនុវត្តបានសរុបចំនួន៩៣៣ ៣៧៣ ហ.ត. (រដូវវស្សា៨៣៥ ៩០៦ ហ.ត. និងរដូវប្រាំង១០៤ ៤៦៨ហ.ត.) និងមានបរិមាណផលចំនួន១៦ ០២២ ៩៥៤ តោន
- ដំណាំឧស្សាហកម្មអនុវត្តបានសរុបចំនួន១០១ ២៦៧ ហ.ត. (រដូវវស្សា៨៦ ៥០៤ ហ.ត. និងប្រាំង១៤ ៧៦៣ហ.ត.) ទទួលបានបរិមាណផលសរុបចំនួន៨៥៦ ៧៨៦តោន។

៣.៨៣- ជាការកត់សម្គាល់ឃើញថា ផ្ទៃដីផលិតកម្មនិងផលិតភាពមានការកើនឡើងព្រមគ្នា ដែលនេះឆ្លុះបញ្ចាំងអំពីការវិវត្តជាវិជ្ជមាន នៅក្នុងប្រព័ន្ធផលិតកម្មដំណាំរួមផ្សំនិងដំណាំឧស្សាហកម្ម តាមរយៈការធ្វើប្រពលវប្បកម្ម ដោយប្រើប្រាស់បច្ចេកទេសសមស្រប និងការផ្ដល់សេវាផ្សព្វផ្សាយកសិកម្មត្រូវបានពង្រីក។

## ការអភិវឌ្ឍអនុវិស័យកៅស៊ូ

៣.៨៤- នៅឆ្នាំ២០១៦នេះ ផ្ទៃដីកៅស៊ូកម្ពុជាសរុបមានចំនួន ៤៣២ ៧៣៥ ហ.ត បើធៀបទៅនឹងឆ្នាំ២០១៥ មានចំនួន ៣៨៨ ៩៥៥ ហ.ត គឺកើនឡើងចំនួន ៤៣ ៧៨០ ហ.ត ស្មើនឹង១១,២៥% ដែលខ្ពស់ជាងចំណុចដៅក្នុង ផ.យ.អ.ជ. (៣៨៤ ៥០០ ហ.ត)។ ផ្ទៃដីកៅស៊ូទាំងនេះ ត្រូវបានបែងចែកជា២ផ្នែកគឺ៖ ក្រុមហ៊ុនកៅស៊ូកសិឧស្សាហកម្ម (អតីតចម្ការកៅស៊ូរដ្ឋ ផ្ទៃដីវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា និងផ្ទៃដីក្រុមហ៊ុនសម្បទានដីសេដ្ឋកិច្ច) សរុបមានចំនួន ២៧៨ ២៨១ ហ.ត ស្មើនឹង៦៤,៣១% និងកៅស៊ូគ្រួសារមានចំនួន ១៥៤ ៤៥៤ ហ.តស្មើនឹង ៣៥,៦៩% នៃផ្ទៃដីកៅស៊ូសរុប។

### តារាងទី៣.៦: ផ្ទៃដីកៅស៊ូ ឆ្នាំ២០១៤និងឆ្នាំ២០១៥

| ផលិតកម្មកៅស៊ូ | ប្រភេទចម្ការកៅស៊ូ | ឯកតា | ២០១៥ | ២០១៦ | ប្រៀបធៀប ២០១៦/២០១៥ |
|---|---|---|---|---|---|
| ផ្ទៃដីដាំកៅស៊ូសរុប | កសិឧស្សាហកម្ម | ពាន់ហត. | ២៣៩,១ | ២៧៨,២ | ១៦,៣ |
| | កៅស៊ូគ្រួសារ | ពាន់ហត. | ១៤៩,៩ | ១៥៤,៥ | ៣,១ |
| | **សរុប** | **ពាន់ហត.** | **៣៨៩,០** | **៤៣២,៧** | **៨,៧** |
| ផ្ទៃដីចៀរជ័រ | កសិឧស្សាហកម្ម | ពាន់ហត. | ៣៤,៧ | ៤០,៧ | ១៧,៣ |
| | កៅស៊ូគ្រួសារ | ពាន់ហត. | ៧៦,៥ | ៨៦,៣ | ១២,៨ |
| | **សរុប** | **ពាន់ហត.** | **១១១,២** | **១២៧,០** | **១៤,២** |
| ផលិតផលកៅស៊ូ | កសិឧស្សាហកម្ម | ពាន់តោន | ៣៩,៣ | ៤៣,៥ | ១០,៧ |
| | កៅស៊ូគ្រួសារ | ពាន់តោន | ៨៧,៦ | ១០១,៦ | ១៦,០ |
| | **សរុប** | **ពាន់តោន** | **១២៦,៩** | **១៤៥,២** | **១៤,៤** |

ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

៣.៨៥- ការនាំចេញកៅស៊ូឆ្នាំ២០១៦ សម្រេចបានចំនួន ១៤៥ ១០០ តោន ស្មើនឹងទឹកប្រាក់ ១៨៧,១៦លានដុល្លារអាមេរិក បើធៀបនឹងឆ្នាំ២០១៥ ដែលការនាំចេញមានចំនួន ១២៨ ០៤៧ តោន ដែលមានទឹកប្រាក់សរុប ១៥៤លានដុល្លារអាមេរិក គឺការនាំចេញកើនឡើងចំនួន ១៧ ០៥៣ តោន ស្មើនឹង១៣,៣២% តែចំណូលកើនឡើងតិចតួច ដោយសារស្ថានភាពថ្លៃកៅស៊ូនៅលើទីផ្សារអន្តរជាតិបានបន្តធ្លាក់ចុះយ៉ាងខ្លាំងនៅបីត្រីមាសដើមឆ្នាំ២០១៦ និងកើនឡើងបន្តិចនៅចុងឆ្នាំ។ កៅស៊ូនាំចេញជាមធ្យម មានតម្លៃ ១ ២៩០ ដុល្លារអាមេរិកក្នុងមួយតោន បើធៀបនឹងឆ្នាំ ២០១៥ ដែលតម្លៃមធ្យមស្មើនឹង ១ ២០៣ ដុល្លារអាមេរិក/តោន ឃើញថាមានការកើនឡើងបន្តិច

គឺ៨៧ដុល្លារអាមេរិកក្នុងមួយតោន ត្រូវនឹង០៧,២៣%។ ចំណូលផុលកៅស៊ូសរុបឆ្នាំ២០១៦ កើនបាន ៣៣,១៦លានដុល្លារអាមេរិក។

រូបភាពទី៣.៣: ផលិតកម្មនិងការនាំចេញកៅស៊ូ




ប្រភព : ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## ៤.៣- កំណែទម្រង់ដីធ្លី និងការបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម

### ៣.៨៦- រដ្ឋបាលដីធ្លី

- **អត្រាប័ណ្ណកម្មសិទ្ធដីធ្លីដែលផ្តល់ជូនប្រជាពលរដ្ឋទូទៅ** បើគិតពីពេលចាប់ផ្តើម រហូតដល់បំណាច់ឆ្នាំ២០១៦ សម្រេចចែកប័ណ្ណ ៤,៤៥១,៨១៧ក្បាលដីស្មើនឹង៦៣,៦% នៃក្បាលដីប៉ាន់ស្មានសរុប៧លានក្បាលដី លទ្ធផលនេះលើសផែនការ១,៦% ។ លទ្ធផលសរុបនេះ បានពីកាងារចុះបញ្ជីដីដូចខាងក្រោម៖
  - ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ សម្រេចបាន ៣,២០២,៩៥៨ប័ណ្ណ។
  - ការចុះបញ្ជីដីធ្លីតាមបទបញ្ជាលេខ ០១បប សម្រេចបាន ៦៣៧,១៣០ប័ណ្ណ។
  - ការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំសម្រេចបាន ៦១០,៤៧០ប័ណ្ណ។
  - ការចុះបញ្ជីដី សហគមន៍ជនជាតិដើមភាគតិច សម្រេចបាន ១៤ សហគមន៍ ស្មើនឹង ៤៥៩ ប័ណ្ណ ទំហំ ១,២៣៥,៧៧៩ហ.ត. ស្មើ១,៤៧៨គ្រួសារ ។
  - ការចុះបញ្ជីដីរដ្ឋ ដែលជាកម្មវត្ថុនៃសម្បទានដីសេដ្ឋកិច្ច និងជួលអចិន្ត្រៃយ៍ សម្រេចបាន ៨០០ប័ណ្ណ ទំហំប្រមាណ ៤០ម៉ឺនហ.ត.។
- **ការងារវិវាទដីធ្លី** បន្តដោះស្រាយវិវាទដីធ្លីដែលនៅសេសសល់ប្រមាណ ១០% ស្មើនឹងជាង៧០០ ករណី ។

## ៣.៨៧- ការរៀបចំដែនដីនិងនគរូបនីយកម្ម

- បានរៀបចំនិងអនុម័តលិខិតបទដ្ឋានគតិយុត្តនានា សម្រាប់ការរៀបចំដែនដី និងនគរូបនីយកម្ម។
- ផែនការប្រើប្រាស់ដីថ្នាក់ ឃុំ សង្កាត់ ចំនួន**៧៦** ទទួលបានការអនុម័ត។
- ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ខណ្ឌ ចំនួន **២៤** បានធ្វើ។
- ប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ចំនួន **៣** ទទួលបានការអនុម័ត។
- ផែនការរៀបចំដែនដីថ្នាក់ខេត្ត បានចំនួន **១**រាជធានីភ្នំពេញ ទទួលបានការអនុម័ត។

## ៣.៨៨- ការបែងចែកដី

- បានបែងចែកដីសម្បទានសង្គមកិច្ចជូនអតីតកងកម្លាំងប្រដាប់អាវុធនិងគ្រួសារបានចំនួន៣ ៣០៤គ្រួសារមានផ្ទៃដីសរុប ៤ ៥៤៥.៨៨ហ.ត. ក្នុងនោះដីលំនៅឋាន ៤០៦,៨៨ហ.ត. និងដីកសិកម្ម ៤ ១៣៩ហ.ត.។
- បានផ្តល់ដីសម្បទានសង្គមកិច្ចជូនប្រជាពលរដ្ឋក្រីក្រស៊ីវិលទូទៅទំហំ ៧៥ ៦៧៨,៧៤ ហ.ត. ក្នុងនោះគម្រោង LASED ផ្តល់ដីទំហំ ១៧ ០៤២ ស្មើនឹង ៥ ១៤១គ្រួសារ។
- បានផ្តល់ដីសម្បទានសង្គមកិច្ចទំហំ ១២ ២៧៥ហ.ត. និងបានចុះបញ្ជីដីនិងផ្តល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុស្មើនឹង ៣ ៣៩៧ក្បាលដី ត្រូវនឹង ៣ ១៣៦ គ្រួសារលើផ្ទៃដីទំហំ ១ ៣៧៧,៥៦ហ.ត.។
- ដីបម្រុងទុកសម្រាប់គោលដៅសម្បទានសង្គមកិច្ចមានទំហំ ២៧ ៦៦៧ហ.ត. ដែលកំពុងធ្វើបច្ចុប្បន្នភាព ។

## ៣.៨៩- ការគ្រប់គ្រង និងការអភិវឌ្ឍវិស័យសំណង់

- កិច្ចសហប្រតិបត្តិការជាមួយថ្នាក់ជាតិ និងអន្តរជាតិ ក្នុងកិច្ចការរៀបចំឯកសារគតិយុត្តផ្លាស់ប្តូរបទពិសោធន៍ និងបណ្តុះបណ្តាលធនធានមនុស្ស ដូចជាវគ្គបណ្តុះបណ្តាលអំពីសំណង់អគារបៃតង ការគ្រប់គ្រងសំណង់កម្ពុជា និងការរៀបចំបទប្បញ្ញត្តិបច្ចេកទេសសំណង់ ការរៀបចំពិធីតាំងពិព័រណ៍ឧស្សាហកម្មសំណង់ ការរៀបចំឯកសារគតិយុត្តនិងបទប្បញ្ញត្តិបច្ចេកទេសសំណង់ និងការផ្លាស់ប្តូរបទពិសោធន៍លើការងារសំណង់។
- បាននិងកំពុងរៀបចំសេចក្តីព្រាងច្បាប់សំណង់ ស្តង់ដារសំណង់ ស្តង់ដារស្ថាបត្យកម្ម នីតិវិធីនៃការជួសជុលបេតុង និងប្រកាសស្តីពីការរុះរើសំណង់អគារ។
- បានផ្សព្វផ្សាយឯកសារគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងការងារសំណង់ដល់មន្ត្រីជំនាញ និងអាជ្ញាធរពាក់ព័ន្ធតាមបណ្តារាជធានី ខេត្តទូទាំងប្រទេស។

- ការចេញលិខិតអនុញ្ញាតសាងសង់ លិខិតបើកការដ្ឋាន លិខិតបិទការដ្ឋាន ដែលគិតជាតម្លៃប៉ាន់ស្មានទុនវិនិយោគសរុប ២ ៥០៧លានដុល្លារអាមេរិក ឆ្នាំ២០១៤ និង ៣ ៣៣៨ លានដុល្លារអាមេរិក ឆ្នាំ២០១៥ កើនឡើង៣៤% ។ ក្នុងឆ្នាំ២០១៦ តម្លៃប៉ាន់ស្មានទុនវិនិយោគសរុប ៥ ៥៨០លានដុល្លារអាមេរិក កើនឡើង ៦៧% ធៀបនឹងឆ្នាំ២០១៥។

### ការបោសសម្អាតមីន

៣.៩០- ចាប់ពីឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០១៦ ផ្ទៃដីទំហំ៤៩ ៩៧២ហ.ត.ត្រូវបានបោសសម្អាត។ ទោះបីយ៉ាងណាក្តី ប្រទេសកម្ពុជានៅមានផ្ទៃដីដែលមានការគម្រាមកំហែងដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម ចំនួន១៩៦ ៧៧៩ហ.ត.ទៀត ដែលនៅមិនទាន់បានបោសសម្អាត។

### តារាងទី៣.៧ : សូចនាករស្តីពីគ្រាប់មីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម

| សូចនាករសំខាន់ៗ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| ជនរងគ្រោះដោយសារមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ១៥១ | ១៣៦ | ១២២ |
| | លទ្ធផល | ១៥៤ | ១១១ | ៨៣ |
| ចំនួនជនរងគ្រោះដោយសារការលេង និងច្នៃគ្រាប់មីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ (ស្លាប់/របួស) | នាក់ | ៩៩ | ៨៦ | ៧៣ |
| | លទ្ធផល | ៧៧ | ៧៣ | ៣៧ |
| ផ្ទៃដីសរុបបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម (ផ្អែកលើលទ្ធផលពីការស្រាវជ្រាវមូលដ្ឋាន) | ហត. | ៩ ១៤៣ | ៩ ៦០០ | ១០ ០៨០ |
| | លទ្ធផល | ១៨.២១៣ | ១៨.៥៣១ | ១៣ ២២៨ |
| សមាមាត្រនៃផ្ទៃដីបានបោសសម្អាតមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម | % | ៤,៧ | ៥ | ៥,២៦ |
| | លទ្ធផល % | ១០៤,១៨ | ១,៧៤ | -២៨,៨០ |

ប្រភព : អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីននិងសង្គ្រោះជនពិការដោយសារមីន

### ៣.៩១- បញ្ហាប្រឈម

- ការស្រាវជ្រាវពីទំហំផ្ទៃដីសរុបដែលមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាម នៅមិនទាន់បានបញ្ចប់នៅឡើយ ដោយសារកង្វះខាតថវិកា។

- ទោះបីជាមានកិច្ចខិតខំប្រឹងប្រែងយ៉ាងសកម្មពីប្រតិបត្តិករ និងភាគីពាក់ព័ន្ធ ក៏អត្រាគ្រោះថ្នាក់ដោយសារមីន/ស.ផ.ស. នៅតែកើតមានឡើង។
- ការធ្លាក់ចុះថវិកាពីដៃគូអភិវឌ្ឍនិងភាគីពាក់ព័ន្ធ នៅតែជាបញ្ហាប្រឈមក្នុងការបោសសម្អាតផ្ទៃដីដែលមានមីន និងសំណល់ជាតិផ្ទុះពីសង្គ្រាមសម្រាប់សកម្មភាពសេដ្ឋកិច្ច ដូចជាការធ្វើកសិកម្ម ការចិញ្ចឹមសត្វ ជាដើម និងការសង់លំនៅដ្ឋានរបស់ប្រជាជនប្រកបដោយសុវត្ថិភាព។

## ៤.៤- ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព

### កំណែទម្រង់ព្រៃឈើ

៣.៩២- *ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ* បានធ្វើការវាយតម្លៃអំពីការប្រែប្រួលធនធានគម្របព្រៃឈើថ្នាក់ជាតិជាបន្តបន្ទាប់ចាប់ពីឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០១៤ ដោយគិតជាមធ្យមរយៈពេល៤ឆ្នាំធ្វើការវាយតម្លៃម្តង។ តាមលទ្ធផលវាយតម្លៃនេះឃើញថា ធនធានគម្របព្រៃឈើបានធ្លាក់ចុះជាបន្តបន្ទាប់ ពិសេសក្នុងអំឡុងពេលចុងក្រោយនេះ (ចុងឆ្នាំ២០១០-២០១៤)។ នៅឆ្នាំ២០០៥ គម្របព្រៃឈើមានប្រមាណ៥៩,០៩% ឆ្នាំ២០១០មានប្រហែល៥៧,០៧% និងនៅឆ្នាំ២០១៤បានធ្លាក់ចុះនៅត្រឹមតែ៤៩,៤៨%។

៣.៩៣- រាជរដ្ឋាភិបាលកម្ពុជាបានផ្តោតការយកចិត្តទុកដាក់ លើកម្មវិធីកំណែទម្រង់វិស័យព្រៃឈើ និងបានខិតខំបង្កើនសមត្ថភាពបច្ចេកទេស សំដៅជំរុញការងារគ្រប់គ្រងឲ្យមានប្រសិទ្ធភាពខ្ពស់ ព្រមទាំងព្រៃសហគមន៍ ដើម្បីទប់ស្កាត់និងបង្ក្រាបបទល្មើសព្រៃឈើ។ គណៈកម្មាធិការជាតិត្រូវបានបង្កើតឡើង សំដៅទប់ស្កាត់និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ឈើ ការនាំចេញឈើខុសច្បាប់ និងបទល្មើសនានានៅភាគឦសាន្តនៃប្រទេស។ ក្នុងឆ្នាំ២០១៥ ចំនួនសហគមន៍ព្រៃឈើសរុបកើនដល់៤៩៩ ប្រៀបធៀបនឹងឆ្នាំ២០១៤ មានចំនួន៤៨៥។

៣.៩៤- ក្រសួងបានបណ្តុះនិងចែកចាយកូនឈើជូនប្រជាជនសរុបចំនួន២ ០៥២ ៣៨១ដើម និងបានដាំដើមឈើសរុបចំនួន ៤ ៦៩០ហ.ត. ក្នុងឆ្នាំ២០១៥។

៣.៩៥- ក្រសួងក៏បានបន្តបង្ក្រាបរាល់បទល្មើសសត្វព្រៃនិងបទល្មើសព្រៃឈើ ព្រមទាំងករណីកាប់ព្រៃឈើទន្ទ្រានយកដី។ ក្នុងសកម្មភាពបង្ក្រាបនេះ ក្រសួងប្រមូលបានភស្តុតាងជាច្រើនសម្រាប់សកម្មភាពល្មើសច្បាប់ទាំងនេះ ដូចជា ឈើ សត្វព្រៃ និង រណាយន្តជាដើម។

### វិស័យជលផល

៣.៩៦- រហូតមកដល់ឆ្នាំ២០១៥នេះ សហគមន៍នេសាទមានចំនួន៥១៦ត្រូវបានបង្កើត ក្នុងនោះសហគមន៍នេសាទទឹកសាបចំនួន៤៧៧ និងសហគមន៍នេសាទសមុទ្រចំនួន៣៩។ ក្រោយការកែ

ទម្រង់ស៊ីជម្រៅផ្នែកជលផល ដោយរំសាយឡូត៍នេសាទទាំងអស់នៅទូទាំងប្រទេស មានកន្លែងអភិរក្សជលផលថ្មីចំនួន៥៨កន្លែង សរុបទូទាំងប្រទេសមានចំនួន៥៦១កន្លែង (សហគមន៍៤៦៧កន្លែង)។ ក្នុងឆ្នាំ២០១៥នេះ បង្កាលបេតុងមានចំនួន៤៦ដើម ត្រូវបានបានបោះ ស្នាក់ការបណ្តែតទឹកចំនួន៤ និងស្នាក់ការបេតុងចំនួន៣ទៀតត្រូវបានសាងសង់ ព្រមទាំងបានដាក់កម្លាំងយាមល្បាតជាប្រចាំ។

៣.៩៧- នៅក្នុងឆ្នាំ២០១៥ បទល្មើសចំនួន៣ ៩៧៤ករណីត្រូវបានបង្ក្រាប និងការផ្សព្វផ្សាយច្បាប់ លិខិតបទដ្ឋានគតិយុត្ត នៅតាមមូលដ្ឋានបានអនុវត្តចំនួន២៨០វគ្គ។

### វិស័យរ៉ែនិងប្រេងកាត

៣.៩៨- គិតចាប់តាំងពីឆ្នាំ២០១៤ មកដល់ចុងឆ្នាំ២០១៦នេះ ក្រសួងរ៉ែនិងថាមពល បានបញ្ចប់អាជ្ញាបណ្ណពាក់ព័ន្ធនឹងវិស័យរ៉ែចំនួន១៨៣អាជ្ញាបណ្ណ ក្នុងនោះមានអាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន១អាជ្ញាបណ្ណ រ៉ែសំណង់ចំនួន៩០ និងអាជ្ញាប័ណ្ណស្វែងរុករកចំនួន៩២អាជ្ញាបណ្ណ។ ក្រសួងបានចាត់វិធានការតាមផ្លូវច្បាប់ចំពោះក្រុមហ៊ុនចំនួន០៣ ដោយដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីអនុវត្តការជាកពិន័យ និងផ្តន្ទាទោសជនល្មើសឲ្យទទួលខុសត្រូវតាមច្បាប់ជាធរមាន។ ក្នុងអំឡុងពេលដដែលនេះដែរ ក្រសួងបានចេញអាជ្ញាបណ្ណពាក់ព័ន្ធវិស័យធនធានរ៉ែសរុបចំនួន១៩៧អាជ្ញាបណ្ណ ដែលក្នុងនោះមានអាជ្ញាបណ្ណរ៉ែសំណង់ចំនួន១៨៩ អាជ្ញាបណ្ណស្វែងរុករកចំនួន០៥ អាជ្ញាបណ្ណឧស្សាហកម្មអាជីវកម្មធនធានរ៉ែចំនួន០៣។

៣.៩៩- តាមរយៈការអនុវត្តកម្មវិធីការងារអធិការកិច្ចលើវិស័យរ៉ែនិងយន្តការទទួលពាក្យបណ្តឹងបានធ្វើឲ្យក្រសួងអាចកាត់បន្ថយនូវសកម្មភាពអាជីវកម្មរ៉ែអាណាធិបតេយ្យបានយ៉ាងច្រើន ជាពិសេសពាក់ព័ន្ធទៅនឹងការលុបបំបាត់អាជីវកម្មបូមខ្សាច់អាណាធិបតេយ្យតាមដងទន្លេមេគង្គ និងនៅតំបន់ផ្សេងៗទៀត។ ក្រុមការងារអធិការកិច្ចក៏បានសហការជាមួយនឹងអាជ្ញាធរមូលដ្ឋាន និងស្ថាប័នពាក់ព័ន្ធក្នុងការអប់រំ និងលើកកម្ពស់ការទទួលខុសត្រូវក្នុងការចូលរួមកាត់បន្ថយផលប៉ះពាល់បរិស្ថានក្នុងការដឹកជញ្ជូនផលិតផលរ៉ែ ជាពិសេសការដឹកជញ្ជូនអាចម៍ដីនិងខ្សាច់។ មកទល់ដំណាច់ឆ្នាំ២០១៦នេះ ក្រសួងបានរៀបចំវេទិកាសាធារណៈចំនួន៩លើក ហើយមានប្រជាពលរដ្ឋចូលរួមសរុបចំនួន៤ ៥០០នាក់។ ក្រសួងក៏បានរៀបចំកម្មវិធីផ្សព្វផ្សាយពីសកម្មភាពការងាររបស់ក្រសួងជូនដល់សិស្ស និស្សិត ឲ្យបានយល់ពីកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួង ក៏ដូចជារាជរដ្ឋាភិបាល ជៀសវាងការជឿតាមព័ត៌មានមិនច្បាស់ការធ្វើឲ្យមានការភាន់ច្រឡំនិងធ្វើឲ្យរាំងស្ទះដល់ការអភិវឌ្ឍលើវិស័យរ៉ែនិងថាមពល។

៣.១០០- ក្នុងវិស័យប្រេងកាត រាជរដ្ឋាភិបាលបានពង្រឹងការអនុវត្តកាតព្វកិច្ចក្នុងកិច្ចព្រមព្រៀងប្រេងកាត ដែលជាលទ្ធផលបានបញ្ចប់កិច្ចព្រមព្រៀងប្រេងកាតចំនួន០៣ប្លុក ក្នុងដែនសមុទ្រ។ បានចរចាបញ្ចប់កញ្ចប់ឯកសារគម្រោងអភិវឌ្ឍន៍ប្រេងកាតប្លុកA ដើម្បីឈានទៅធ្វើផលិត

កម្ម។ បានអនុញ្ញាតឲ្យក្រុមហ៊ុន HiRex នៃប្រទេសម៉ាឡេស៊ីចរចាកិច្ចព្រមព្រៀងស្វែងរុករកប្រេងកាតប្លុកC។ ផ្តល់កិច្ចព្រមព្រៀងអាជ្ញាបណ្ណនិងកំពុងជំរុញការអនុវត្តគម្រោងសាងសង់រោងចក្រចម្រាញ់ប្រេងកាតរបស់ក្រុមហ៊ុន Cambodian Petrochemical Co.Ltd. នៅខេត្តព្រះសីហនុ។ អនុញ្ញាតឲ្យក្រុមហ៊ុន Petrochemicals (Cambodia) Refinery Ltd. សិក្សាសមិទ្ធិលទ្ធភាពគម្រោងសាងសង់បំពង់បង្ហូរប្រេង និងឧស្ម័ន ពីបណ្ដាគម្រោងក្នុងដែនសមុទ្រកម្ពុជា មកដែនគោកខេត្តព្រះសីហនុ និងគម្រោងសាងសង់បំពង់បង្ហូរប្រេងនិងឧស្ម័ន ពីខេត្តព្រះសីហនុមកភ្នំពេញ និងបណ្ដាខេត្តសំខាន់ៗមួយចំនួន។ អនុញ្ញាតឲ្យក្រុមហ៊ុន PV Oil(Cambodia)ធ្វើការសិក្សាសមិទ្ធិលទ្ធភាពរោងចក្រលាយប្រេង ដោយប្រើវត្ថុធាតុដើម Condensate។ ចំពោះវិស័យដោនស្ទ្រីម (downstream) ក្រសួងបានចេញវិញ្ញាបនបត្រនិងលិខិតបញ្ជាក់បច្ចេកទេសសុវត្ថិភាពស្ថានីយ៍ប្រេងឥន្ធនៈចំនួន១០៦ថែមទៀតផង។

៣.១០១- ការជំរុញកំណើនលំហូរចំណូលជាតិពីវិស័យធនធានរ៉ែ និងប្រេងកាត៖ មកដល់ពាក់កណ្តាលអាណត្តិទី៥នេះ ក្រសួងរ៉ែនិងថាមពលបានខិតខំអនុវត្តគោលនយោបាយគៀរគរចំណូលមិនមែនសារពើពន្ធរបស់រាជរដ្ឋាភិបាល ដោយរៀបចំកំណត់អត្រាសួយសាររ៉ែថ្មីឲ្យស្របតាមការ វិវឌ្ឍរបស់ទីផ្សារផលិតផលរ៉ែនាពេលបច្ចុប្បន្ន កែសម្រួលនីតិវិធីប្រមូលនិងបង់កម្រៃសួយសាររ៉ែ កម្រៃសេវាសាធារណៈឲ្យមានភាពងាយស្រួលដល់អ្នកជាប់កាតព្វកិច្ចក្នុងការធ្វើការបង់កាតព្វកិច្ចហិរញ្ញវត្ថុជូនរដ្ឋ និងធានាមិនឲ្យមានបំណុលកើតមានឡើងបាន ការរឹតបន្តឹងការទារបំណុលដោយអនុវត្តតាមកាតព្វកិច្ចហិរញ្ញវត្ថុក្នុងកិច្ចព្រមព្រៀងរ៉ែនិងប្រេងកាតនិងតាមលិខិតបទដ្ឋានគិតិយុត្តជាធរមាន និងការជម្រះបំណុលរ៉ាំរ៉ៃដែលកើតមានឡើងកន្លងមក។

**បញ្ហាប្រឈម**

៣.១០២- បញ្ហាប្រឈមចំពោះមុខនៅក្នុងការអនុវត្តផែនការសម្រាប់ការអភិវឌ្ឍវិស័យកសិកម្មរួមមាន៖

- ភាពងាយរងគ្រោះនៃប្រព័ន្ធដាំដុះ ដោយសារកត្តាប្រែប្រួលអាកាសធាតុ និងកង្វះខាតប្រព័ន្ធស្រោចស្រពគឺជាបញ្ហាមួយដែលបានជួបប្រទះជារៀងរាល់ឆ្នាំ។ ការស្រាវជ្រាវ អភិវឌ្ឍន៍ ផលិត និងផ្សព្វផ្សាយពូជដំណាំដែលមានគុណភាពនៅមានកម្រិត។ ម៉្យាងទៀតលទ្ធភាពទទួលបានសេវាផ្សព្វផ្សាយកសិកម្មក៏នៅមានកម្រិតដែរ។ សមត្ថភាពស្រូបយកចំណេះដឹងបច្ចេកទេសដាំដុះ និងការប្រើប្រាស់ធាតុចូលកសិកម្មឲ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស ក៏ដូចជាក្នុងការកែច្នៃផលិតផលក្នុងចំណោមប្រជាកសិករនៅមានកម្រិត។
- ការបង្កើតសហគមន៍កសិកម្ម ក្នុងគោលបំណងដើម្បីបង្កើនអំណាចតថ្លៃ ការទទួលបាននូវសេវាបច្ចេកទេសនិងឥណទាន និងការប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធាន គឺត្រូវបានអនុវត្ត ប៉ុន្តែក៏បានទទួលស្គាល់ថានៅមិនទាន់គ្រប់គ្រាន់ ដែលត្រូវបន្តពង្រឹងឲ្យបាន

ប្រសើរជាងនេះ។ សហគមន៍កសិករដាំកៅស៊ូនៅមិនទាន់ត្រូវបានពង្រឹកនៅឡើយ ដែលទាមទារឲ្យមានការយកចិត្តខ្ពស់លើកិច្ចការនេះ។

- ការចូលក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានក្រោយ២០១៥៖ លំហូរដោយសេរីនៃការនាំចូល នាំចេញកសិផលបានកើតមាន ដូចនេះ ការត្រៀមលក្ខណៈក្នុងការពិនិត្យការនាំចូល (អនាម័យនិងភូតគាមអនាម័យ) ជាចំណុចគន្លឹះត្រូវយកចិត្តទុកដាក់ ពិសេសសមត្ថភាពពិសោធន៍ និងការឈរជើងត្រួតពិនិត្យតាមគោលដៅ។
- ផលិតកម្មសត្វគោក្របីមិនសូវមានការរីកចម្រើនខ្លាំងក្លានៅឡើយ។ ផលិតកម្មគោក្របីមានការថយចុះដោយសារខ្វះកម្លាំងពលកម្ម ចំណាកស្រុក ការថយចុះវាលស្មៅចិញ្ចឹមសត្វ ខ្វះប្រភពទឹក ស្របជាមួយកំណើនគ្រឿងយន្តកសិកម្ម។ អត្រាឈឺ ស្លាប់សត្វ និងជំងឺឆ្លងសត្វនៅតែជាការគំរាមកំហែងដល់ផលិតកម្មសត្វធ្វើឲ្យផលិតភាពសត្វថយចុះ ថ្នាំការពារព្យាបាលសត្វនិងឧបករណ៍សម្ភារបរិក្ខាបសុពេទ្យត្រូវបង្កើនបន្ថែម។ នៅមានបទល្មើសដឹកជញ្ជូនសត្វ និងផលិតផលសត្វ ការគ្រប់គ្រងសត្តឃាតដ្ឋាន និងការត្រួតពិនិត្យអនាម័យសត្វ នៅអនុវត្តមិនទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ។ ការស្រាវជ្រាវផ្នែកផលិតកម្មនិងបសុព្យាបាល ការផ្សព្វផ្សាយបច្ចេកទេសផលិតកម្មបសុព្យាបាល អនុវត្តនៅមិនទាន់បានទូលាយ អាស្រ័យដោយធនធាននិងមធ្យោបាយមានកម្រិត។
- ការទន្ទ្រានដីក្នុងនាទីព្រៃលិចទឹកនិងដែននេសាទ ជាបញ្ហាប្រឈម ដែលត្រូវតែមានវិធានការជាបន្ទាន់បំផុត។ ការអនុវត្តវិធានការការពារកន្លែងអភិរក្សទាំងទឹកសាបនិងសមុទ្រ ការបោះបង្គោលព្រំប្រទល់ព្រៃលិចទឹក និងការលុបបំបាត់បទល្មើសជលផលនៅជួបការលំបាក។ សមត្ថភាពរបស់គណៈកម្មការសហគមន៍នេសាទក៏នៅមានកម្រិតដែរ ដោយសហគមន៍ភាគច្រើនពុំមានការជួយឧបត្ថម្ភគាំទ្រគ្រប់គ្រាន់។ បទល្មើសនេសាទដោយប្រើឧបករណ៍ឆក់ ស្បៃមុង ការកាប់បំផ្លាញព្រៃលិចទឹកក្នុងដែនអភិរក្សនៅតែបន្តកើតមាន។
- បទល្មើសព្រៃឈើនិងសត្វព្រៃ នៅបន្តកើនមានគួរឱ្យកត់សម្គាល់ ការហ៊ុមព័ទ្ធដីព្រៃ ការឈូសឆាយដីព្រៃធ្វើជាកម្មសិទ្ធិនៅតែជាបញ្ហាប្រឈម។ មធ្យោបាយសម្រាប់ដំណើរការការងារនៅតំបន់ដាច់ស្រយាលនៅមានកម្រិត ដែលអាចប៉ះពាល់ដល់ប្រសិទ្ធភាពការងារ។ កិច្ចសហការនិងការចូលរួមរបស់អ្នកពាក់ព័ន្ធនៅមានកម្រិត ជាពិសេសក្នុងការត្រួតពិនិត្យបង្ក្រាបបទល្មើសព្រៃឈើ និងការកំណត់ព្រំប្រទល់ដែនដីព្រៃឈើ តែងជួបប្រទះការលំបាក និងមានវិវាទ។
- សកម្មភាពរ៉ែអាណាធិបតេយ្យនៅតែបន្តកើតមានឡើង ក្នុងតំបន់មួយចំនួន។
- កង្វះទិន្នន័យស្តីពីសក្តានុពលនៃជម្រករ៉ែរបស់កម្ពុជា និង ទិន្នន័យស្តីពីការវិភាគសេដ្ឋកិច្ចរបស់វិស័យរ៉ែក្នុងសេដ្ឋកិច្ចជាតិ។
- ច្បាប់ និងបទប្បញ្ញត្តិ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យអាជីវកម្មរ៉ែនៅមិនទាន់គ្រប់គ្រាន់។
- ការគៀរគរចំណូលជាតិ ជាពិសេសចំណូលមិនមែនសារពើពន្ធនៅមិនទាន់បានគ្រប់ជ្រុងជ្រោយឲ្យអស់ពីលទ្ធភាព។
- ការប្រើប្រាស់សេវាកម្មក្នុងស្រុកឲ្យបានជាអតិបរមាដើម្បីបម្រើប្រតិបត្តិការរ៉ែគ្រប់ដំណាក់កាលនៅមិនទាន់អាចធ្វើទៅបាន។

- តម្លៃប្រេងនៅក្នុងទីផ្សារអន្តរជាតិបានធ្លាក់ចុះ និងបន្តនៅកម្រិតទាបនៅឡើយ ដែលនេះជាកត្តាប្រឈមមួយខ្លាំងសម្រាប់ការអភិវឌ្ឍវិស័យប្រេងកាតនៅកម្ពុជា ដើម្បីធ្វើឲ្យកម្ពុជាមានលទ្ធភាពឆ្ពោះទៅរកដំណាក់ប្រេងទីមួយ ក្នុងពេលអនាគតដ៏ខ្លីខាងមុខ។
- ក្របខណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាទាក់ទងនឹងវិស័យប្រេងកាតនៅមិនទាន់បានបំពេញគ្រប់គ្រាន់ ធ្វើឲ្យការគ្រប់គ្រងវិស័យប្រេងកាតនៅមិនទាន់បានពេញលេញទាំងផ្នែកអាប់ស្ទ្រីម ( Upstream ) និងដោនស្ទ្រីម (Downstream)។

## កិច្ចគាំពារបរិស្ថាន និងការអភិរក្សជីវៈចម្រុះ

### ៣.១០៣- ការងារអប់រំនិងព័ត៌មានបរិស្ថាន

- បានអនុវត្តការងារអប់រំបរិស្ថានក្នុងប្រព័ន្ធ ដោយបានបញ្ចូលការអប់រំបរិស្ថានទៅក្នុងកម្មវិធីគ្រប់ភូមិសិក្សា ជំរុញការអនុវត្ត "កម្មវិធីសាលាមេត្រីបរិស្ថាន" កសាងសមត្ថភាពគ្រូនៅកម្រិតបឋម សិក្សា និងមធ្យមសិក្សា បណ្តុះបណ្តាលក្រុមអ្នកនិពន្ធសៀវភៅសិក្សាគោល និងបញ្ជ្រាបការ អប់រំបរិស្ថានដើម្បីការអភិវឌ្ឍដោយចីរភាពទៅក្នុងកម្មវិធីបង្រៀនរបស់វិទ្យាស្ថានជាតិអប់រំ។
- បានអនុវត្តការងារអប់រំបរិស្ថានក្រៅប្រព័ន្ធ ដោយបានរៀបចំយុទ្ធនាការបរិស្ថានពង្រឹងនិងពង្រីក ការផ្សព្វផ្សាយព័ត៌មានបរិស្ថានតាមគ្រប់មធ្យោបាយ និងគ្រប់រូបភាព ដូចជា វិទ្យុ ទូរទស្សន៍ បណ្តាញទំនាក់ទំនងសង្គម គេហទំព័រ www.moe.gov.kh យូធូប បណ្ណាល័យអេឡិចត្រូនិក។
- បានធ្វើប្រតិភូកម្មមុខងារអប់រំនិងផ្សព្វផ្សាយព័ត៌មានបរិស្ថានទៅឲ្យរដ្ឋបាលរាជធានីខេត្តទាំង ២៥។
- បានធ្វើបច្ចុប្បន្នភាពផែនទីតំបន់ការពារធម្មជាតិទូទាំងប្រទេស ដែលក្នុងនោះបានបញ្ចូលផែនទី តំបន់ការពារធនធានធម្មជាតិថ្មីចំនួន៨តំបន់ និងរៀបចំឡើងវិញនូវផែនទីតំបន់ការពារធម្មជាតិចំនួន១៣តំបន់ ដែលបានផ្ទេរពីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងកសាងផែនទីរបៀងអភិរក្ស ជីវៈចម្រុះ ។

### ៣.១០៤- ការគ្រប់គ្រងធនធានធម្មជាតិ

- បានត្រួតពិនិត្យវាយតម្លៃគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ច ដោយបាននិរាករណ៍គម្រោងវិនិយោគអភិវឌ្ឍន៍ចំនួន២៧ បានកាត់បន្ថយរយៈពេលជួលពី៩៩ឆ្នាំ ឬ ៧០ឆ្នាំ មកនៅត្រឹម៥០ឆ្នាំ។
- បានផ្ទេរគម្រោងវិនិយោគអភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចដំណាំកសិឧស្សាហកម្មចំនួន ៧៣កន្លែង ទៅឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីគ្រប់គ្រងបន្ត ចំណែក

តំបន់ព្រៃការពារ តំបន់អភិរក្សព្រៃឈើ និងព្រៃផ្តល់ផលចំនួន១៨កន្លែង ត្រូវបានផ្ទេរមកក្រសួងបរិស្ថានគ្រប់គ្រងវិញ។

- បានបង្កើនផ្ទៃដីតំបន់ការពារធម្មជាតិបន្ថែមលើតំបន់ដែលមានស្រាប់ទាំង៤៥កន្លែង ដោយបានបង្កើតរបៀងអភិរក្សជីវៈចម្រុះ ដែលក្នុងនោះផ្ទៃដីសរុបនឹងកើនដល់ប្រមាណជាង៧,៣ លានហ.ត.។
- បានកំណត់ព្រំ និងបោះបង្គោលព្រំប្រទល់តំបន់ការពារធម្មជាតិចំនួន១ ៧០៤ បង្គោល និង បានរៀបចំផែនការ និងកំណត់តំបន់គ្រប់គ្រងបានចំនួន០៤តំបន់។
- បានបញ្ចូលមន្ត្រីជាប់កិច្ចសន្យាជាឧទ្យានុរក្សចំនួន៩៥៧នាក់ ជាមន្ត្រីក្របខណ្ឌសាធារណៈ សម្រាប់ឆ្នាំ២០១៦។
- បានបង្ក្រាប ទប់ស្កាត់ និងបញ្ឈប់ទាំងស្រុងនូវបទល្មើសព្រៃឈើទ្រង់ទ្រាយធំក្នុងតំបន់ការពារធម្មជាតិ។
- បានបង្កើតសហគមន៍តំបន់ការពារធម្មជាតិសរុបចំនួន១៣៣សហគមន៍ ដែលមានប្រជាពលរដ្ឋសរុបចំនួន ៣២ ០២៨គ្រួសារ រស់នៅក្នុងភូមិ២៤៣ភូមិ លើផ្ទៃដី១៩៣ពាន់ហិកតា និងបានលើកកម្ពស់ជីវភាពសហគមន៍តាមរយៈការបង្កើតជម្រើសមុខរបរថ្មីក្នុងវិស័យកសិកម្ម និង ចិញ្ចឹមសត្វ ការកែច្នៃផលនិងអនុផលព្រៃឈើ ជំនួសឲ្យការពឹងអាស្រ័យទាំងស្រុងលើធនធានធម្មជាតិ។
- បានចុះបញ្ជីដីរដ្ឋសម្រាប់គម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិចំនួន៦ និង គម្រោងចំនួន៩ ទៀត កំពុងដំណើរការ។

## ៣.១០៥- កិច្ចគាំពារបរិស្ថាន

- បានរៀបចំអនុក្រឹត្យមួយចំនួន ស្តីពីការបង្កើតមូលនិធិបរិស្ថាននិងសង្គម ការគ្រប់គ្រងសំរាម សំណល់រឹង រាវ ទីប្រជុំជន ការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនីនិងអេឡិចត្រូនិក ការកម្រិតនិយាមសារធាតុបំពុលនិងគ្រោះថ្នាក់ ការត្រួតពិនិត្យនិយាមគុណភាពខ្យល់ និងសម្លេង និង ការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថានលើរាល់គម្រោងវិនិយោគសាធារណៈ និង ឯកជន។
- បានផ្ទេរមុខងារ និងវិភាជន៍ថវិកា ទៅឲ្យរដ្ឋបាលក្រុងគោលដៅទាំង២៦ សម្រាប់អនុវត្តមុខងារគ្រប់គ្រងសំណល់រឹង រាវ នៅតាមទីប្រជុំជនទូទាំងព្រះរាជាណាចក្រកម្ពុជា។
- បានពង្រឹងប្រសិទ្ធភាពការតាមដាន និងត្រួតពិនិត្យគុណភាពបរិស្ថាន (ទឹក ដី និងខ្យល់) ដើម្បីជាមូលដ្ឋានក្នុងការវាយតម្លៃពីស្ថានភាពបំពុលបរិស្ថាន និងដាក់ចេញនូវវិធានបង្ការជាមុន ក្នុងគោលដៅធានាសុវត្ថិភាពសុខភាពសាធារណៈ និងគុណភាពបរិស្ថាន។

- បានតម្រូវឲ្យគ្រប់គម្រោងអភិវឌ្ឍន៍ទាំងឯកជន និងសាធារណៈរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម និងពន្លឿនការពិនិត្យផ្តល់យោបល់លើរបាយការណ៍។

៣.១០៦- **ការអភិវឌ្ឍន៍ដោយចីរភាព/ការប្រែប្រួលអាកាសធាតុ**

- បានបង្កើតក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងអគ្គលេខាធិការដ្ឋាន ដើម្បីលើកកម្ពស់ការអភិវឌ្ឍដោយចីរភាព សំដៅធានានូវតុល្យភាពរវាងសេដ្ឋកិច្ច បរិស្ថាន សង្គម និងវប្បធម៌នៅក្នុង ព្រះរាជាណាចក្រកម្ពុជា។
- បានរៀបចំផែនការយុទ្ធសាស្ត្រ ផែនការសកម្មភាព គោលការណ៍ណែនាំ របាយការណ៍ជាតិ និងយន្តការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានជីវៈចម្រុះ និងជីវសុវត្ថិភាព ការអភិវឌ្ឍបៃតង និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាទំនើប។
- បានរៀបចំគោលនយោបាយ និងជំហររបស់កម្ពុជាសម្រាប់ចរចា និងអនុវត្តអនុសញ្ញា UNFCCC និង UNCBD ព្រមទាំងកិច្ចព្រមព្រៀងពហុភាគី និងទ្វេភាគីនានា នៅថ្នាក់ជាតិ តំបន់ និងអន្តរជាតិ។
- បានសិក្សាស្រាវជ្រាវវាយតម្លៃគុណតម្លៃជីវៈចម្រុះ និងសេវាកម្មប្រព័ន្ធអេកូឡូស៊ី និងប្រភេទរុក្ខជាតិ សត្វកម្រ ងាយរងគ្រោះ និងជិតផុតពូជ ព្រមទាំងសិក្សាលទ្ធភាពក្នុងការបង្កើតរុក្ខឧទ្យាន និង តិណាល័យថ្នាក់ជាតិ។
- បានសហការជាមួយដៃគូអភិវឌ្ឍ ក្នុងការរៀបចំគម្រោងស្នើសុំសម្រាប់កៀរគរថវិកាអនុវត្តកម្មវិធីការប្រែប្រួលអាកាសធាតុ ការគ្រប់គ្រងធនធានជីវៈចម្រុះ និងជីវសុវត្ថិភាព ទីក្រុងនិរន្តភាព ថាមពលនិរន្តភាព និងការសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបៃតង។
- បានសម្របសម្រួលសហការរៀបចំ និងអនុវត្តកម្មវិធីការប្រើប្រាស់ថាមពលនុយក្លេអ៊ែរបម្រើឲ្យគោលបំណងសន្តិភាព ថាមពលកកើតឡើងវិញ ថាមពលស្អាត ជីវៈម៉ាស ប្រសិទ្ធភាពថាមពល និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។
- បានជួបពិភាក្សាជាប្រចាំជាមួយដៃគូអភិវឌ្ឍ រួមមាន អង្គការជាតិ និង អន្តរជាតិ វិស័យឯកជន និង សហគមន៍មូលដ្ឋាន ដើម្បីកៀរគរការគាំទ្រ និង ការចូលរួមក្នុងកិច្ចគាំពារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ ការអភិរក្សជីវៈចម្រុះ និង ការរស់នៅប្រកបដោយចីរភាព ជាពិសេស ការធ្វើកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យបរិស្ថាន និងធនធានធម្មជាតិ។

៣.១០៧- **ក្របខ័ណ្ឌហិរញ្ញប្បទានប្រែប្រួលអាកាសធាតុកម្ពុជា** បានបញ្ចប់នៅឆ្នាំ២០១៤ ហើយការពិនិត្យឡើងវិញជាទៀងទាត់នូវការចំណាយសាធារណៈ លើកិច្ចការអាកាសធាតុ បង្ហាញពីកំណើនការចំណាយលើការប្រែប្រួលអាកាសធាតុ ធៀបនឹងផ.ស.ស ពី១%នៅឆ្នាំ២០១៣ ដល់ ១,៣%នៅឆ្នាំ២០១៤។ លើសពីនេះ គ្រឹះស្ថានមួយចំនួនកំពុងពង្រឹងប្រព័ន្ធ និងប្រតិបត្តិការរបស់

ខ្លួន ដើម្បីមានលទ្ធភាពប្រើប្រាស់មូលនិធិអាកាសធាតុដោយផ្ទាល់ ដូចជា មូលនិធិបន្សាំ ឬ មូលនិធិអាកាសធាតុបៃតង ក្នុងនោះយ៉ាងហោចណាស់មានស្ថាប័នចំនួនពីរ (ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដែលបង្ហាញពីវឌ្ឍនភាពជាច្រើនក្នុងដំណើរការនៃការស្វែងរកការទទួលស្គាល់ជាផ្លូវការនេះ។

៣.១០៨- **ក្របខ័ណ្ឌជាតិតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការប្រែប្រួលអាកាសធាតុ** ត្រូវបានប្រកាសដាក់ឲ្យប្រើប្រាស់នៅខែមេសា ឆ្នាំ២០១៦។ ការចាត់ចែងស្ថាប័ននិងប្រព័ន្ធគ្រប់គ្រងទិន្នន័យសម្រាប់តាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានសម្រាប់ការអភិវឌ្ឍដោយចីរភាពនិងនៅតាមវិស័យកំពុងត្រូវបានពង្រឹងជាបណ្ដើរៗ។

៣.១០៩- **ជំនួយឥតសំណងសម្រាប់ស្រាវជ្រាវអំពីការប្រែប្រួលអាកាសធាតុ** ត្រូវបានដាក់ឲ្យប្រើប្រាស់ ដើម្បីលើកកំពស់ការស្រាវជ្រាវអំពីបញ្ហាសំខាន់ៗ ដែលទាក់ទងនឹងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការបង្កើតក្របខ័ណ្ឌជាតិគ្រប់គ្រងចំណេះដឹងសម្រាប់ការប្រែប្រួលអាកាសធាតុ និងផែនការសកម្មភាព ដែលឥឡូវនេះកំពុងចាប់ផ្ដើមប្រតិបត្តិការ។

៣.១១០- **បញ្ហាប្រឈម**

- កង្វះខាតធនធានហិរញ្ញវត្ថុនិងមនុស្ស ព្រមទាំងមធ្យោបាយនានាទៀតដែលគាំទ្រដល់ដំណើរការប្រចាំថ្ងៃក្នុងការងារអប់រំ ស្រាវជ្រាវ និងផ្សព្វផ្សាយបរិស្ថាន។
- ការគ្រប់គ្រងតំបន់ការពារធម្មជាតិជួបប្រទះបញ្ហាប្រឈមមួយចំនួន ដូចជា (១)លំហូរចូលនៃជនចំណាកស្រុក ទៅក្នុងតំបន់ការពារធម្មជាតិ រួមទាំងការប្រើប្រាស់ប្រជាពលរដ្ឋក្រីក្រជាខែល សម្រាប់ធ្វើការកាប់ទន្ទ្រានរានដីព្រៃយកធ្វើជាកម្មសិទ្ធិ និងកេងចំណេញផ្នែកនយោបាយ (២) កង្វះខាតធនធានមនុស្សនិងហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ និង (៣) កិច្ចសហប្រតិបត្តិការអន្តរក្រសួង ស្ថាប័ន ដើម្បីសម្របសម្រួលការអនុវត្ត ការផ្ដល់ហិរញ្ញប្បទាន ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការគ្រប់គ្រងតំបន់ការពារធម្មជាតិ។
- កង្វះខាតធនធានមនុស្ស ឧបករណ៍និងថវិកាសម្រាប់ដំណើរការនិងការកសាង សមត្ថភាពដើម្បីកំណត់ប្រសិទ្ធភាពនៃតំបន់ការពារធម្មជាតិ។ ចំណេះដឹងរបស់ មន្ត្រីនៅមានកម្រិត ជាពិសេសទាក់ទងនឹងជំនាញការវិភាគសេដ្ឋកិច្ច និងការខូចខាតបរិស្ថាន ជំនាញជលវិទ្យា ជំនាញភូគព្ភសាស្ត្រ ជំនាញGIS និងជំនាញវិភាគហានិភ័យបរិស្ថាន។ បទពិសោធន៍លើការអនុវត្តកំណែទម្រង់ថវិការតាមកម្មវិធីនៅមានកម្រិតបានធ្វើឲ្យមាន ការរាំងស្ទះដល់ការអនុវត្តជ.យ.អ.ជ. និងមិនឆ្លើយតបសូចនាករបានគ្រប់ជ្រុងជ្រោយ

- សមត្ថភាពពុំទាន់គ្រប់គ្រាន់ក្នុងការទទួលបានហិរញ្ញប្បទានអាកាសធាតុ (ស្ថាប័នរដ្ឋាភិបាល និងភ្នាក់ងារមិនមែនរដ្ឋាភិបាល) ដែលរួមទាំងភាពយឺតយ៉ាវនៃវឌ្ឍនភាពដំណើរការទទួលស្គាល់ជាផ្លូវការដែលកំពុងប្រព្រឹត្តទៅសម្រាប់ស្ថាប័នជាតិ ដើម្បីទទួលមូលនិធិអន្តរជាតិ (ដូចជាមូលនិធិបន្សាំ មូលនិធិអាកាសធាតុបៃតង) និងតម្រូវឲ្យមានយន្តការសម្របសម្រួលនិងគ្រប់គ្រងការទទួលបានហិរញ្ញប្បទានដោយផ្ទាល់ពីហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុសកល។ សមត្ថភាពស្ថាប័ននៅទន់ខ្សោយ សម្រាប់គ្រប់គ្រងព័ត៌មាន និងចំណេះដឹង និងសម្រាប់ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការប្រែប្រួលអាកាសធាតុ។ កង្វះការបង្កើនការយល់ដឹង និងការប្រាស្រ័យទាក់ទងឲ្យបានគ្រប់គ្រាន់ដល់ស្រទាប់មហាជនពីតួនាទីសំខាន់ៗរបស់ពួកគេ ក្នុងការឆ្លើយតបនឹងការប្រឈមនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

### ការគ្រប់គ្រងគ្រោះមហន្តរាយ

៣.១១១- ផែនការសកម្មភាពជាតិសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ២០១៤-២០១៨ បានរៀបចំឡើងផ្អែកលើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ កំណត់ទិសដៅយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ របស់ប្រទេសកម្ពុជា សំដៅការពារការអភិវឌ្ឍ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ។ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានខិតខំយកចិត្តទុកដាក់ក្នុងការពង្រឹងសមត្ថភាពនៅថ្នាក់ជាតិថ្នាក់ក្រោមជាតិនិងមូលដ្ឋានសហគមន៍ លើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយផ្សារភ្ជាប់ជាមួយការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ដើម្បីកាត់បន្ថយការបាត់បង់អាយុជីវិត ទ្រព្យសម្បត្តិ សម្ភារដោយសារគ្រោះមហន្តរាយ ក្នុងគោលដៅកសាងភាពធន់របស់ប្រជាជន និងសហគមន៍ទៅនឹងគ្រោះមហន្តរាយ។

៣.១១២- *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* សម្រេចបានសមិទ្ធផលមួយចំនួន ដូចជា(១) បានរៀបចំក្របខ័ណ្ឌគតិយុត្តនិងស្ថាប័នសម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយ (២)បានបញ្ជ្រាបការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងការរៀបចំផែនការវិស័យ ដូចជាវិស័យអប់រំ សុខាភិបាល ជាដើម (៣) បានផ្សារភ្ជាប់ការគ្រប់គ្រងគ្រោះមហន្តរាយជាមួយការប្រែប្រួលអាកាសធាតុ និង(៤) បានបង្កើតប្រព័ន្ធព័ត៌មានការបាត់បង់និងខូចខាតដោយគ្រោះមហន្តរាយនៅកម្ពុជា។ ឆ្លើយតបនឹងការគ្រប់គ្រងគ្រោះមហន្តរាយ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានធានាឲ្យមានប្រព័ន្ធស្បៀងបម្រុងជាតិ។

**បញ្ហាប្រឈម**

៣.១១៣- *គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ* ស្ថិតនៅក្នុងដំណាក់កាលដំបូងក្នុងការបង្កើតគោលការណ៍រួមមួយសម្រាប់គ្រប់គ្រងគ្រោះមហន្តរាយ។ ក្រៅពីប្រព័ន្ធស្បៀងបម្រុងជាតិ

គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ បានអនុវត្តសកម្មភាពចំពោះកិច្ចជាច្រើន ដែលពុំទាន់បង្កើតបានជាប្រព័ន្ធមួយនៅថ្នាក់ជាតិ។ បញ្ហាប្រឈមសំខាន់គឺកង្វះខាតធនធានហិរញ្ញវត្ថុ ពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ កង្វះខាតសមត្ថភាពបច្ចេកទេស និងយន្តការសម្របសម្រួលអន្តរវិស័យ។ ដោយសារការប្រែប្រួលអាកាសធាតុនិងការធ្លាក់ចុះហិរញ្ញប្បទានឥតសំណង រាជរដ្ឋាភិបាលត្រូវរៀបចំយុទ្ធសាស្ត្រគៀរគរហិរញ្ញប្បទាន ដែលកំណត់ឲ្យបានច្បាស់លាស់ពីអាទិភាព ដោយផ្តោតលើការសម្របសម្រួលការឆ្លើយតបនិងការទប់ស្កាត់គ្រោះមហន្តរាយ។

### ការអភិវឌ្ឍជនបទ

៣.១១៤- *ផ.យ.អ.ជ. ២០១៤-២០១៨* បានបញ្ជាក់ថា ការអភិវឌ្ឍជនបទ គឺមានសារៈសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ ដោយហេតុថាប្រជា ជនក្រីក្រច្រើនជាង៧៥% រស់នៅតំបន់ជនបទ។ រាជរដ្ឋាភិបាល នឹងបន្តជំរុញការអនុវត្តកម្មវិធីអភិវឌ្ឍន៍ជនបទចម្រុះ ដែលផ្តោតការយកចិត្តទុកដាក់ជាសំខាន់ទៅលើកត្តាដែលមានផលប៉ះពាល់ជាវិជ្ជមានទៅលើប្រជាពលរដ្ឋក្រីក្រនៅតំបន់ជនបទ ដូចជាការផ្គត់ផ្គង់ទឹកនៅជនបទនិងការងារអនាម័យជនបទ ការកសាងផ្លូវជនបទ និងការពង្រឹងសមត្ថភាពស្ថាប័ន និងការអភិវឌ្ឍធនធានមនុស្ស។ តារាងទី៨ ខាងក្រោមបង្ហាញអំពីវឌ្ឍនភាពលើសូចនាករសំខាន់ៗមួយចំនួនទាក់ទងនឹងការអភិវឌ្ឍជនបទ។

**សមិទ្ធផល**

៣.១១៥- *ក្រសួងអភិវឌ្ឍន៍ជនបទ* សម្រេចបានក្នុងការលើកកម្ពស់ការផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យនៅតំបន់ជនបទ ដែលបង្ហាញពីវឌ្ឍនភាពល្អក្នុងការសម្រេចបានចំណុចដៅក្នុងផ.យ.អ.ជ.។ សមិទ្ធផលនេះបានចូលរួមចំណែកដល់ការលើកកម្ពស់សុខាភាពនិងអាហារូបត្ថម្ភសម្រាប់ប្រជាជនរស់នៅតំបន់ជនបទ។

៣.១១៦- ក្រសួងអភិវឌ្ឍន៍ជនបទសម្រេចបានការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទតាមរយៈការសម្រេចបានតាមផែនការប្រចាំឆ្នាំរបស់ខ្លួន ក្នុងការស្តារផ្លូវជនបទឡើងវិញទៅជាផ្លូវក្រាលបេតុង ឬក្រាលកៅស៊ូប្រភេទDBST។

៣.១១៧- ក្រសួងអភិវឌ្ឍន៍ជនបទបានរៀបចំវគ្គបណ្តុះបណ្តាលដល់មន្ត្រីចំនួន១ ៤៣៨នាក់នៅថ្នាក់ក្រោមជាតិស្តីពី PRF Reform Program បានរៀបចំបោះឆ្នោតឡើងវិញដល់គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ដែលផុតអាណត្តិបានចំនួន១៤ ១៤៧ ភូមិ បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមបង្ការ និងការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយក្នុងសហគមន៍ចំនួន១២វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន៤២០នាក់ នៅខេត្តបាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ និងបានចេញលិខិតទទួលស្គាល់អត្តសញ្ញាណ បានចំនួន០៥សហគមន៍។

## តារាងទី៣.៨ : សូចនាករសំខាន់ៗ របស់ក្រសួងអភិវឌ្ឍន៍ជនបទ

| សូចនាករ | ឯកតា | ឆ្នាំ២០១៤ | | ឆ្នាំ ២០១៥ | | ឆ្នាំ២០១៦ | |
|---|---|---|---|---|---|---|---|
| | | ផែនការ | ការអនុវត្ត | ផែនការ | ការអនុវត្ត | ផែនការ | ការអនុវត្ត |
| ការស្តារនិងផ្លូវជនបទ លើប្រវែងសរុប ៤០០០០គ.ម. | គម. | ២៨ ៦០០ | ២៧ ៨៣៥ | ២៩ ៤៥០ | ២៨ ៣៦៧ | ៣២ ០០០ | ២៨ ៥៧៥ |
| ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ ឬបេតុង | គម. | ៤៦,៧០ | ៦ ៥៣០ | ៥០ | ៥៩ ៦៨៨ | ៦០ | ១១ ៣១០ |
| ប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹកដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៤៦,៧ | ៤៦,៧០ | ៥០,៥០ | ៥០ | ៥៣ | ៥ ១៥០ |
| ប្រជាជនទទួលបានសេវាអនាម័យដែលមានការកែលម្អប្រកបដោយនិរន្តរភាព | % | ៤២ | ៤៦ | ៤៦ | ៥១ | ៥០ | ៥៦ |
| ចំនួនសហគមន៍ជនជាតិភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | សហគមន៍ | ១៣០ | ១០០ | ១៦០ | ១០៨ | ១៩០ | ១១៥ |
| ចំនួនភូមិដែលបានបណ្តុះបណ្តាលពីការអភិវឌ្ឍភូមិ | ភូមិ | ១ ៨០០ | ១ ៥៦១ | ២ ០០០ | ១ ៥២២ | ២ ២០០ | ១ ៥២៦ |
| សិក្សានិងសាងសង់សាកល្បងផ្លូវជនបទ ក្រាលកៅស៊ូ ៤៥០គ.ម. ដែលអាចធន់នឹងការប្រែប្រួលអាកាសធាតុ | គ.ម. | ៦៧,៥ | | ៩០ | | ១១២,៥ | |
| កសាងសមត្ថភាព គ.អ.ភ. ស្តីពីជម្រើសនៃការបន្សាំ និង កាត់បន្ថយការប្រែប្រួលអាកាសធាតុ និងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | ១ ៨៥៤ | ១ ៥៦១ | ២ ៤៧២ | ១ ៥២២ | ៣ ០៩១ | ១ ៥២៦ |

ប្រភព : ក្រសួងអភិវឌ្ឍន៍ជនបទ

### បញ្ហាប្រឈម

៣.១១៨- ការប្រែប្រួលអាកាសធាតុដែលធ្វើឲ្យប៉ះពាល់ដល់ចីរភាពរបស់គម្រោងហេដ្ឋារចនាសម្ព័ន្ធផ្លូវជនបទហើយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋជនបទបានធ្វើឲ្យមានការខ្វះកម្លាំងពលកម្មនៅតំបន់ជនបទ។

៣.១១៩- កំណើនយានយន្ត ការដឹកលើសទម្ងន់កំណត់ និងបើកលើសល្បឿនកំណត់ធ្វើឲ្យផ្លូវជនបទឆាប់ខូច និងមានគ្រោះថ្នាក់ចរាចរណ៍កើនឡើងជាញឹកញាប់ និងមិនទាន់មានការចូលរួមថែទាំផ្លូវជនបទពីថ្នាក់សហគមន៍និងអ្នកប្រើប្រាស់ផ្លូវឲ្យបានពេញលេញ។

ការយល់ដឹងពីអនាម័យនៅតាមជនបទនៅមានកម្រិត និងការចូលរួមថែទាំអណ្តូងទឹក ស្រះទឹកពីសហគមន៍នៅមានកម្រិត

### ភូមិមួយ ផលិតផលមួយ

៣.១២០- ក្នុងនិតិកាលទី៥នៃរដ្ឋសភាព ចលនាភូមិមួយ ផលិតផលមួយ ដែលដឹកនាំដោយគណៈកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ ត្រូវបានធ្វើសមាហរណកម្មចូលមកក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ (ក.ក.ជ) និងសម្រេចបានសមិទ្ធផលដូចខាងក្រោម៖

- បានរៀបចំឯកសារគតិយុត្តនានាក្នុងការពង្រឹងកិច្ចដំណើរការ ការងារជំរុញចលនាភូមិមួយផលិតផលមួយ
- បានរៀបចំគោលនយោបាយជាតិស្ដីពីការជំរុញចលនាភូមិមួយផលិតផលមួយ ដែលត្រូវបានរាជរដ្ឋាភិ-បាលអនុម័តកាលពីថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៦ ។
- បានជួយសម្របសម្រួលជាមួយនឹងអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ដើម្បីអនុញ្ញាតឲ្យអាជីវករ និងសិប្បករ ខ្មែរបាននាំផលិតផលខ្មែរទៅចូលរួមតាំងពិព័រណ៍នៅប្រទេសថៃ ម៉ាឡេស៊ី ប្រុយណេ និងចិន សរុបទាំងអស់បានចំនួន១៣ដង។
- បានជួយសម្របសម្រួលឲ្យអាជីវករខ្មែរ រៀបចំពិព័រណ៍តាំងលក់ផលិតផលខ្មែរតាមបណ្តារាជធានី -ខេត្ត នានាចំនួន២១ដង ដោយសហការជាមួយនឹងគណៈកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយ រាជធានី -ខេត្ត។

### បញ្ហាប្រឈម

៣.១២១- ថ្វីតែមានការខិតខំជំរុញការងារជំរុញចលនាភូមិមួយផលិតផលមួយ ឲ្យទទួលបានជោគជ័យយ៉ាងណាក៏ដោយ ក៏ការងារនេះបានជួបនូវបញ្ហាប្រឈមជាច្រើនដែលទាមទារឲ្យមានការដោះស្រាយប្រទាក់ក្រឡាគ្នា មិនមែនតែនៅក្នុងសមាគម សហគមន៍ ឬក្រុមខ័ណ្ឌផលិតផលប៉ុណ្ណោះទេ តែក៏មាននៅក្នុងរចនាសម្ព័ន្ធធ្វើការទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិផងដែរ ក្នុងនោះរួមទាំងធនធានមនុស្សនៅក្នុងអគ្គលេខាធិការដ្ឋានភូមិមួយផលិតផលមួយ ការអនុវត្តតួនាទីនិងភារកិច្ចរបស់នាយកដ្ឋាននីមួយៗ ការពង្រឹងតួនាទីនិងភារកិច្ចរបស់គណកម្មាធិការជំរុញចលនាភូមិមួយផលិតផលមួយ រាជធានី ខេត្តទាំង២៥ ការពង្រឹងកិច្ចសហការនិងការសម្របសម្រួលរវាងអគ្គលេខាធិការដ្ឋាន និងក្រសួងពាក់ព័ន្ធ និងជាមួយគណៈកម្មាធិការរាជធានី ខេត្ត ដំណើរការតួនាទី-ភារកិច្ចរបស់គណកម្មាធិការជាតិជំរុញចលនាភូមិមួយផលិតផលមួយ។

### សេចក្ដីសន្និដ្ឋាន

៣.១២២- តារាងខាងក្រោមបង្ហាញពីវឌ្ឍនភាពទាក់ទងនឹងសូចនាករតាមដានរួមគ្នាសម្រាប់មុំទី១នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ការពិនិត្យមើលសូចនាករតាមដានរួមគ្នា និងសូចនាករតាមដាន ព្រមទាំងការវាយតម្លៃផ្នែកគុណភាពបង្ហាញថាមានវឌ្ឍនភាពល្អ ដែលនឹងអាចសម្រេចបានចំណុចដៅផ.យ.អ.ជ.ក្នុងឆ្នាំ២០១៨។ ផលប៉ះពាល់នៃការប្រែ

ប្រែប្រួលអាកាសធាតុលើកសិកម្មនិងអភិវឌ្ឍន៍ជនបទកាន់តែធ្ងន់ធ្ងរដោយសារគុណភាពសេវាគាំទ្រនិងហេដ្ឋារចនាសម្ព័ន្ធមិនល្អ ចំណាយផលិតកម្មខ្ពស់ និងការពឹងផ្អែកលើផលិតកម្មស្រូវ។ ការវាយតម្លៃនេះបង្ហាញពីសារៈសំខាន់នៃការលើកកម្ពស់ផលិតភាពនិងពិពិធកម្មផលិតផលកសិកម្ម ដើម្បីបង្កើនផលចំណេញដល់កសិករ និងបញ្ជាក់ពីតួនាទីសំខាន់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសការកាប់បំផ្លាញព្រៃឈើនិងការគ្រប់គ្រងធនធានទឹក។ រាជរដ្ឋាភិបាលនឹងត្រូវផ្តល់ធនធានហិរញ្ញវត្ថុកាន់តែច្រើនសម្រាប់កិច្ចការនេះនិងត្រូវពង្រឹងប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃការវិនិយោគ តាមរយៈកិច្ចសម្របសម្រួលនិងសហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន និងការពង្រឹងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃលើការប្រែប្រួលអាកាសធាតុនិងការគ្រប់គ្រងគ្រោះមហន្តរាយ។ ការងារបច្ចុប្បន្នទាក់ទឹងនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្តល់ជាកាលានុវត្តភាពសម្រាប់ដោះស្រាយបញ្ហាទាំងនេះ។

## តារាងទី៣.៩ : វឌ្ឍនភាពរបស់មុំទី១នៃយុទ្ធសាស្រ្តចតុកោណ៖ ការលើកកម្ពស់វិស័យកសិកម្ម

| ចំណុចដៅ | សកម្មភាពដែលត្រូវអនុវត្ត | វឌ្ឍនភាព |
|---|---|---|
| លើកកម្ពស់ផលិតភាពនិងពិពិធកម្មកសិកម្ម និងការគ្រប់គ្រងធនធានទឹក | ១. ទិន្នផលស្រូវជាមធ្យមសម្រេចបាន៣,១៨តោន/ហ.ត.<br>២. សន្ទស្សន៍ពិពិធកម្មដំណាំសម្រេចបាន៣៥%នៃផ្ទៃដីដាំដុះសរុប<br>៣. ផ្ទៃដីស្រោចស្រពសម្រាប់ដំណាំស្រូវសម្រេចបាន១ ៥៤៥លានហ.ត.<br>៤. ឯកសារ SPFL បានដាក់ជូនរាជរដ្ឋាភិបាលស្នើសុំហត្ថលេខា | ១. សម្រេចបានចំណុចដៅខ្លះ<br>២. សម្រេចលើសចំណុចដៅ<br>៣. សម្រេចលើសចំណុចដៅ<br>៤. ដាក់ស្នើសុំការអនុម័ត |
| ការគ្រប់គ្រងនិងអភិរក្សព្រៃឈើដោយចីរភាព | ១. ពង្រឹងនិងបង្កើនសហគមន៍ព្រៃឈើ<br>២. ការដាំកូនឈើឡើងវិញ<br>៣. ការបង្កើតតំបន់អភិរក្សព្រៃឈើនិងសត្វព្រៃ<br>៤. កម្មវិធីហិរញ្ញប្បទានព្រៃឈើដោយចីរភាពតាមរយៈ one signed ERPA | ១. កំពុងដំណើរការ<br>២. កំពុងដំណើរការ<br>៣. សម្រេចបានចំណុចដៅខ្លះ៖ កំពុងដំណើរការ<br>៤. បានបញ្ចប់ |
| ការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍការនេសាទដោយចីរភាព | ១. ផលិតកម្មត្រីទឹកសាបនិងទឹកប្រៃនៅតែមានស្ថេរភាព<br>២. ការបង្កើនផលិតកម្មវារីវប្បកម្មត្រីទឹកសាបនិងទឹកប្រៃ<br>៣. ការកែលម្អការគាំទ្រសម្រាប់គុណភាពនិងសុវត្ថិភាពផលិតផលត្រីដល់អ្នកនេសាទ អ្នកកែច្នៃ និងអ្នកនាំចេញ | ១. សម្រេចបានចំណុចដៅខ្លះ៖ កំពុងដំណើរការមានវឌ្ឍនភាពល្អ<br>២. សម្រេចបានតាមចំណុចដៅ<br>៣. បញ្ចប់សេចក្តីព្រាងនិងកំពុងរងចាំការអនុម័ត |

| | | |
|---|---|---|
| រដ្ឋបាល ការគ្រប់គ្រង និងការបែងចែកដីធ្លី | ១. ការបញ្ចប់ក្របខ័ណ្ឌគតិយុត្តនិងគោលនយោបាយស្ដីពីការគ្រប់គ្រងដែនដីនិងនគររូបនីយកម្ម<br>២. ការពង្រឹងដំណើរការចុះបញ្ជីដីធ្លី<br>៣. ការបង្កើនការអនុវត្តកម្មវិធីបែងចែកដីសម្បទានសង្គមកិច្ចទូទាំងប្រទេស | ១. សម្រេចបានចំណុចដៅខ្លះនិងកំពុងបន្តកិច្ចពិភាក្សា<br>២. មានវឌ្ឍនភាពល្អ<br>៣. កំពុងពិនិត្យមើលសារពើភ័ណ្ឌដីកម្មសិទ្ធិរបស់រដ្ឋ |
| ការបោសម្អាតគ្រាប់មីន | ១. ដីដែលបោសម្អាតរួចត្រូវបានប្រើប្រាស់ដោយអ្នកទទួលផលប្រយោជន៍សម្រាប់គោលបំណងអភិវឌ្ឍន៍<br>២. ការកាត់បន្ថយចំនួនជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ<br>៣. ជនរងគ្រោះដោយសារគ្រាប់មីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះបានដឹងសិទ្ធិនិងទទួលបានការគាំទ្រដោយប្រសិទ្ធភាព | ១. សម្រេចបានចំណុចដៅខ្លះ កំពុងដំណើរការ<br>២. មិនសម្រេចបានតាមចំណុចដៅ<br>៣. មិនសម្រេចបានតាមចំណុចដៅ កំពុងដំណើរការ |

## ៥- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

៣.១២៣- ផ.យ.អ.ជ. បានបញ្ជាក់អំពីជំហានក្នុងការលើកកម្ពស់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនគ្រប់ប្រភេទ រួមទាំងហេដ្ឋារចនាសម្ព័ន្ធទីប្រជុំជនដោយមានប្រព័ន្ធភស្តុភារដែលមានប្រសិទ្ធភាព និងសុវត្ថិភាពចូលរួមចំណែកក្នុងការលើកកម្ពស់ភាពប្រកួតប្រជែងជាតិនិងសុខាមាលភាពរបស់ប្រជាជន។ រាជរដ្ឋាភិបាលបានកំពុងយកចិត្តទុកដាក់លើការបង្កើតភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន ដែលជាយន្តការមួយសម្រាប់កៀរគរធនធានសម្រាប់គាំទ្រដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។

## ៥.១- ការអភិវឌ្ឍវិស័យហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

### ១. ការងារផ្លូវថ្នល់

៣.១២៤- ផ្លូវជាតិ និងផ្លូវខេត្ត ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងសាធារណការ និងដឹកជញ្ជូន មកទល់នឹងបច្ចុប្បន្ននេះ នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមាន៖ ផ្លូវជាតិកម្រិត១ មានចំនួន ០៩ខ្សែ ប្រវែងសរុប ២ ២៥៤ គ.ម. ផ្លូវជាតិកម្រិត២ មាន ៦៦ខ្សែ ប្រវែងសរុប ៥ ០០៧ គ.ម. ដូចនេះជាសរុបយើងមានផ្លូវជាតិ មានប្រវែង ៧ ២៦១ គ.ម. ដែលក្នុងនោះចាក់កៅស៊ូ និងបេតុងបាន ៥ ២៦២ គ.ម. ត្រូវនឹង ៧២,៤៦% នៃប្រវែងផ្លូវជាតិសរុប។ ដោយឡែកផ្លូវខេត្ត មានចំនួន៥២៨ ខ្សែ ប្រវែងសរុប ៨ ១១៥ គ.ម. ត្រូវបានចាក់កៅស៊ូ និងបេតុង ប្រវែង ១ ៦៣៩ គ.ម. ស្មើនឹង ២០,១% នៃប្រវែងផ្លូវខេត្តសរុប។ ជារួមទាំងផ្លូវជាតិ និងផ្លូវខេត្ត មកទល់នឹងបច្ចុប្បន្ននេះ មានប្រវែងសរុប ១៥ ៣៧៦ គ.ម. ដែលចាក់កៅស៊ូ និងបេតុងហើយ មានប្រវែង ៦ ៩០១ គ.ម. (កើនឡើងបានប្រវែង ៥៣៨,៤៦គ.ម.) ត្រូវនឹង ៤៤,៨៨% នៃប្រវែងផ្លូវសរុប។

**តារាងទី៣.១០ : ចំណាត់ថ្នាក់ផ្លូវ**

| ចំណាត់ថ្នាក់ផ្លូវ | ប្រវែង | ចំនួនខ្សែផ្លូវ |
|---|---|---|
| ផ្លូវជាតិកម្រិត១ | ២ ២៥៤ គ.ម. | ៩ |
| ផ្លូវជាតិកម្រិត២ | ៥ ០០៧ គ.ម. | ៦៦ |
| ផ្លូវខេត្ត | ៨ ១១៥ គ.ម. | ៥២៨ |

ប្រភព : ក្រសួងសាធារណការនិងដឹកជញ្ជូន

### ២. ការងារដឹកជញ្ជូនផ្លូវគោក

៣.១២៥- ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៦ ការចុះបញ្ជីយានយន្តមានចំនួនច្រើនជាង១ ២៦៨ ៥១៥ គ្រឿង កើនឡើង ៥៩% សម្រាប់ម៉ូតូ និង៤៦% សម្រាប់រថយន្តគ្រប់ប្រភេទ ធៀបនឹងរយៈពេល ៣ ឆ្នាំមុន ២០១១-២០១៣)។

៣.១២៦- ការចេញប័ណ្ណបើកបរចំនួន ៣១៤ ៧០៣ប័ណ្ណ (ម៉ូតូ ១៥ ៦០៩ប័ណ្ណ ថយចុះ ៤៦% និងរថយន្ត ២៩៩ ០៩៤ប័ណ្ណ កើនឡើង ៥៧% ធៀបនឹងរយៈពេល៣ឆ្នាំមុន ២០១១-២០១៣)។ ដំណើរការប្រតិភូកម្មមុខងារចុះបញ្ជីទោចក្រយានយន្ត ទៅការិយាល័យច្រកចេញ-ចូលតែមួយថ្នាក់ក្រោមជាតិបានចំនួន៤០ការិយាល័យ ក្រុងស្រុកខណ្ឌ។ បានបង្កើតប្រព័ន្ធស្វ័យប្រវត្តិកម្ម ដើម្បីផ្តល់សេវាសាធារណៈលើការចុះបញ្ជីប័ណ្ណបើកបរ ការចុះបញ្ជីយានយន្តការត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត ការផ្តល់លិខិតអនុញ្ញាតឲ្យយានយន្តធ្វើអាជីវកម្ម ដឹកជញ្ជូន និងការចុះបញ្ជីក្រុមហ៊ុនដឹកជញ្ជូនឲ្យបានលឿន មានប្រសិទ្ធភាពខ្ពស់ និងតម្លាភាព។ បានពង្រីកការផ្តល់សេវាត្រួតពិនិត្យលក្ខណៈបច្ចេកទេសយានយន្ត រថយន្តចល័តបំពាក់ដោយបច្ចេកវិទ្យាទំនើបចំនួន០២គ្រឿង ដើម្បីបង្ខិតសេវាត្រួតពិនិត្យយានយន្តឲ្យជិតប្រជាពលរដ្ឋជាពិសេស សម្រាប់ម្ចាស់រថយន្តនៅតាមបណ្តាខេត្ត។

### ៣. ការងារផ្លូវទឹក ដឹកជញ្ជូនផ្លូវទឹក និងដឹកជញ្ជូនតាមនាវាសមុទ្រ

#### ការងារផ្លូវទឹក

៣.១២៧- ប្រវែងផ្លូវទឹកសរុបនៅកម្ពុជា មានប្រមាណ ១ ៧៥០ គ.ម. ចំណែកប្រវែង ៨៥០ គ.ម. ទៀតអាចធ្វើនាវាចរបានតែរដូវប្រាំងប៉ុណ្ណោះ។ ក្រសួងបានបញ្ចប់ការផលិតផែនទីទន្លេមេគង្គលើ ចាប់ពីភ្នំពេញដល់ទីរួមខេត្តកំពង់ចាម និង សិក្សាពីការប្រែប្រួលលក្ខណៈជលសាស្ត្រសាងខាងកាត់ទន្លេប្រវែង១ ០០០ម៉ែត្រ រួមមាន៖ ស្ពានព្រែកតាមាក់ ស្ពានគីហ្សូណា និង ចុះសិក្សាវាស់ស្ទង់ជម្រៅទឹកតំបន់ច្រាំងទន្លេបាសាក់ ស្ថិតក្នុងខេត្តកណ្តាល និង កំពង់ចាម។

#### ដឹកជញ្ជូនផ្លូវទឹក

៣.១២៨- ផ្ទេរកម្មសិទ្ធិជលយានចំនួន ៣១គ្រឿង ផ្តល់ប័ណ្ណសម្គាល់ជលយានចំនួន ៧៩គ្រឿង ប្តូរប័ណ្ណ សម្គាល់ជលយានចំនួន ២០គ្រឿង ផ្តល់ប័ណ្ណបើកបរជលយានចំនួន ១៧០ប័ណ្ណ ផ្តល់ប័ណ្ណ

យន្តការីចំនួន ២៦ប័ណ្ណ ត្រួតពិនិត្យលក្ខណៈបច្ចេកទេសជលយានចំនួន៤៩៩គ្រឿង និងផ្តល់ច្បាប់អាជីវកម្មដឹកជញ្ជូនចំនួន៥៧៧គ្រឿង។

### ដឹកជញ្ជូនតាមនាវាសមុទ្រ

៣.១២៩- ផ្តល់ប័ណ្ណសម្គាល់នាវាចំនួន១៩គ្រឿង ត្រួតពិនិត្យលក្ខណៈបច្ចេកទេសនាវា (ថ្មី និងបន្ត) ចំនួន៨៧គ្រឿង លិខិតអនុញ្ញាតធ្វើអាជីវកម្មចំនួន១២៣ច្បាប់ ផ្តល់វិញ្ញាបនប័ត្រសមត្ថភាពជំនាញចំនួន៣២ច្បាប់ ផ្តល់សៀវភៅវិជ្ជាជីវៈនាវិក និងពន្យារពេលចំនួន១២៨ច្បាប់។

### ៤. ការងារផ្លូវដែក

៣.១៣០- រាជរដ្ឋាភិបាលបានប្រឹងប្រែងក្នុងការសាងសង់និងជួសជុលប្រព័ន្ធផ្លូវដែកឡើងវិញ ដើម្បីពង្រឹងការដឹកជញ្ជូននិងកាត់បន្ថយចំណាយដែលពាក់ព័ន្ធនឹងការដឹកជញ្ជូន។ ការងារផ្លូវដែកទិសខាងត្បូងនិងទិសខាងជើងទទួលបានថវិកា៤៣,២៥លានដុល្លារអាមេរិកពីថវិកាជាតិក្នុងឆ្នាំ២០១៥និងឆ្នាំ២០១៦។ ដែលក្នុងនោះបានធ្វើការជួសជុលឡើងវិញកំណាត់ផ្លូវដែក ទិសខាងត្បូងដោយបានជួសជុលស្ពានធំៗចំនួន៥ ពីភ្នំពេញរហូតដល់ស្ថានីយ៍ព្រះសីហនុ។ បានដាក់ឲ្យដំណើរការខ្សែរថភ្លើងដឹកអ្នកដំណើរពីភ្នំពេញទៅក្រុងព្រះសីហនុ។ ផ្លូវទិសខាងជើង បានសាងសង់បញ្ចប់ស្ពានផ្លូវដែកមិត្តភាព កម្ពុជា-ថៃ (ថវិកាជំនួយឥតសំណងរបស់ថៃ)។ កំណាត់ផ្លូវដែកពីប៉ោយប៉ែតមកដល់មង្គលបុរី បានភ្ជាប់គ្នារួចរាល់ ដោយសាងសង់ក្នុងកម្រិត ២០ តោនក្នុងអ័ក្ស។ ម៉្យាងទៀតកំណាត់ផ្លូវដែក មង្គលបុរី-បាត់ដំបង ក៏ត្រូវបានធ្វើការជួសជុលផងដែរទាំងនេះបានបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការបញ្ចប់ការងារផ្លូវដែកដែលនៅសល់។

### ៥. សុវត្ថិភាពចរាចរណ៍ផ្លូវគោក

៣.១៣១- គ្រោះថ្នាក់ចរាចរណ៍មាន ១២ ៧៥៩ករណី (ស្លាប់ ៦ ០៣៥នាក់ របួសធ្ងន់ ១១ ២៦២ នាក់ និងរបួសស្រាល ១០ ០៥៦នាក់) ថយចុះ៦,៦៣% ធៀបនឹងឆ្នាំ២០១១-២០១៣ ដែលមាន ១៣ ៦៦៥ករណី (ស្លាប់ ៥ ៨២១នាក់ របួសធ្ងន់ ១៣ ៧០៣នាក់ និងរបួសស្រាល ១៦ ០៩៨ នាក់)។ ចំនួនគ្រោះថ្នាក់ចរាចរណ៍ ថយចុះ៦,៦% ចំណែកចំនួនអ្នកស្លាប់បានកើនឡើង៣,៦៨%។ គ្រោះថ្នាក់ចរាចរណ៍ដែលបានកើតឡើងគិតជាមធ្យមក្នុងមួយថ្ងៃមានជនរងគ្រោះស្លាប់លើសពី ៥ នាក់ និងរងរបួសជាង១០នាក់។

#### សមាគ្រាសសាធារណៈ

៣.១៣២- បរិមាណទំនិញ កើនឡើង៣៧,០៧% បរិមាណកុងតឺន័រ កើនឡើង៤៤,២៦% និងនាវាឆ្លងកាត់ បានកើនឡើង៣១,៦៨% ធៀបនឹងឆ្នាំ២០១១-២០១៣ នៅកំពង់ផែស្វយ័តក្រុងព្រះសីហនុ។ នៅកំពង់ផែស្វយ័តភ្នំពេញ បរិមាណទំនិញបានកើនឡើង៣៦,០៤% បរិមាណកុងតឺន័រកើនឡើង៤៩,០៥% និង ចំនួននាវាឆ្លងកាត់កើនឡើង ៣,៣០% ធៀបនឹងឆ្នាំ២០១១-២០១៣។

#### ការដឹកជញ្ជូនឆ្លងកាត់ព្រំដែន

៣.១៣៣- កម្ពុជាបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយប្រទេសឡាវ ថៃ និងវៀតណាម ក្នុងការពិនិត្យចំនួនកូតាសម្រាប់ការដឹកជញ្ជូនអ្នកដំណើរនិងទំនិញឆ្លងកាត់ព្រំដែន។ ការត្រួតពិនិ

ត្យនេះមានសារៈសំខាន់សម្រាប់កម្ពុជា ដោយសារទីតាំងភូមិសាស្ត្ររបស់ប្រទេសកម្ពុជា សម្រាប់កំណើននៃការដឹកជញ្ជូនអ្នកដំណើរនិងទំនិញឆ្លងកាត់ ពីកំណើនទេសចរណ៍ក្នុងតំបន់និងសមាហរណកម្មអាស៊ាន។ ជាមួយប្រទេសឡាវអនុវត្តកូតា ៤០គ្រឿង។ ជាមួយប្រទេសវៀតណាមបានដំឡើងកូតា ៥០០គ្រឿង។ ជាមួយប្រទេសថៃ អនុវត្តកូតា ៤០គ្រឿង។ សម្រាប់ប្រតិបត្តិការ កម្ពុជា-ឡាវ-វៀតណាម អនុវត្តកូតា ១៥០គ្រឿង។

**ការវិនិយោគផ្នែកឯកជន**

៣.១៣៤- ក្នុងនាមសហប្រធានក្រុមការងារថាមពល និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ក្រសួងបានរៀបចំកិច្ចប្រជុំជាទៀងទាត់ ដើម្បីសម្រួលដល់កិច្ចពិភាក្សារវាងរដ្ឋនិងវិស័យឯកជន អំពីតម្រូវការរបស់វិស័យដឹកជញ្ជូននៅកម្ពុជា។ ក្រសួងក៏បានទាក់ទាញការវិនិយោគពីវិស័យឯកជន លើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផងដែរ រួមមាន ផ្លូវ ស្ពាន និងកំពង់ផែ។ ក្រសួងបាននឹងកំពុងទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍនានា ដើម្បីជួយជាជំនួយបច្ចេកទេសក្នុងការរៀបចំជានីតិវិធី បទដ្ឋាននានា ដែលទាក់ទងដល់ការងារវិនិយោគ គម្រោងសាងសង់ផ្លូវស្ពាន។

៣.១៣៥- **បញ្ហាប្រឈម**

- បញ្ហាប្រឈមចម្បងរបស់វិស័យដឹកជញ្ជូនគឺការកែលម្អឡូជីស្ទិកនៃការតភ្ជាប់តាមរយៈការកែលម្អប្រសិទ្ធភាពនិងកាត់បន្ថយចំណាយសម្រាប់ការដឹកជញ្ជូន។
- ល្បឿននៃនគរូបនីយកម្មនៅកម្ពុជាជាពិសេសនៅរាជធានីភ្នំពេញកំពុងតម្រូវឲ្យមានការពង្រីកនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធ រួមទាំងការដឹកជញ្ជូន ទឹកស្អាត អនាម័យ ប្រព័ន្ធលូ និងថាមពល។
- ការសាងសង់និងការជួសជុលហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ (ទីប្រជុំជននិងតំបន់ជនបទ) កាន់តែមានសារៈសំខាន់ ទោះបីមានចំណាយខ្ពស់ក៏ដោយ។
- ការអភិវឌ្ឍនិងការគ្រប់គ្រងភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជនតម្រូវឲ្យសមត្ថភាពធនធានមនុស្សនិងស្ថាប័នខ្ពស់ទាក់ទងនឹងផ្នែកបច្ចេកទេសនិងរដ្ឋបាល។
- ប្រសិទ្ធភាពនិងសមត្ថភាពនៃការដឹកជញ្ជូនតាមផ្លូវទឹកនិងប្រព័ន្ធកំពង់ផែត្រូវពង្រឹងបន្ថែមតាមរយៈការអភិវឌ្ឍកំពង់ផែថ្មីៗ ពង្រឹងការគ្រប់គ្រងច្បាប់ និងបទដ្ឋានគតិយុត្តនានា និងការពង្រឹងធនធានមនុស្ស។

## អាកាសចរស៊ីវិល

៣.១៣៦- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលទទួលខុសត្រូវសម្រាប់ការគ្រប់គ្រងវិស័យអាកាសចរស៊ីវិលនៅកម្ពុជា។

**ហេដ្ឋារចនាសម្ព័ន្ធអាកាសយានដ្ឋាន**

៣.១៣៧- អាកាសយានដ្ឋានអន្តរជាតិទាំងបីត្រូវបានពង្រីកស្ថានីយ៍អ្នកដំណើរ ចំណតអាកាសយាន(អាកាសយានដ្ឋានអន្តរជាតិសៀមរាបបានចំនួន៥ចំណត និងអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានចំនួន៦ចំណត) និងបានពង្រីកទំហំផ្លូវរត់ និងពង្រឹងតំបន់សុវត្ថិភាពចុងផ្លូវរត់០៥ (អាកាសយានដ្ឋានអន្តរជាតិសៀមរាប) បំពាក់ឧបករណ៍លើដីថ្មី បំពាក់ឧបករណ៍ស្ថានីយ៍អ្នកដំណើរថ្មីៗ និងទំនិញ ដើម្បីឲ្យស្របតាមស្តង់ដារបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងសមត្ថភាពប្រកួតប្រជែង។ សមត្ថភាពរបស់អាកាសយានដ្ឋានអន្តរជាតិទាំងបី នាពេលបច្ចុប្បន្នអាចទទួលអ្នកដំណើរបានចំនួន១០,៥លាននាក់ក្នុងមួយឆ្នាំ និងអាចទទួលយន្តហោះប្រភេទ B767 B757 B737 A330 A300 A320 A321 A319 ATR72 MA60 និង B747។

## ប្រព័ន្ធគ្រប់គ្រងចរាចរណ៍ផ្លូវអាកាស និងគមនាគមន៍អាកាសចរណ៍

៣.១៣៨- ក្រុមហ៊ុនសេវាកម្មនាំផ្លូវអាកាសកម្ពុជា ជាប្រតិបត្តិករ ទទួលខុសត្រូវលើដំណើរការប្រចាំថ្ងៃក្នុងការគ្រប់គ្រងចរាចរណ៍និងនាំផ្លូវអាកាសនៅកម្ពុជា។ រដ្ឋាភិបាលជប៉ុនបានផ្តល់គម្រោងជំនួយឥតសំណង សម្រាប់ពង្រឹងសមត្ថភាពធនធានមនុស្សដើម្បីមានសមត្ថភាពឈានទៅអនុវត្តប្រព័ន្ធនាំផ្លូវអាកាសថ្មី តាមផ្កាយរណប (New CNS/ATM System) ដែលមានរយៈពេល៥ឆ្នាំ ចាប់អនុវត្តពីឆ្នាំ២០១១ដល់ឆ្នាំ២០១៥។ បន្ទាប់ពីគម្រោងការត្រូវបានបញ្ចប់ជាស្ថាពរ ប្រទេសកម្ពុជាបានអនុវត្តបទដ្ឋានហោះហើរថ្មី ដោយប្រើប្រាស់ប្រព័ន្ធផ្កាយរណប ដោយកាត់បន្ថយបាននៅពេលវេលារយៈចំងាយ និងការចំណាយហោះហើរ។

## ការចូលរួមពីវិស័យឯកជន និងការធ្វើឯកជនភាវូនីយកម្ម

៣.១៣៩- ការចូលរួមពីវិស័យឯកជនបានក្លាយទៅជាយុទ្ធសាស្ត្រមូលដ្ឋានក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មអាកាសចរស៊ីវិលតាំងពីឆ្នាំ១៩៩៥។ ក្រុមហ៊ុនអាកាសចរណ៍ជាតិកម្ពុជាអង្គរ ត្រូវបានបង្កើតឡើងរវាងក្រុមហ៊ុនអាកាសចរវៀតណាម(៤៩%) រាជរដ្ឋាភិបាលកម្ពុជា (២៦%) និងវិនិយោគិនក្នុងស្រុក (២៥%)។ ក្រុមហ៊ុន អាកាសចរណ៍ឯកជនក្នុងស្រុកចំនួន៦ និងក្រុមហ៊ុនបរទេសចំនួន៣០ កំពុងប្រតិបត្តិការហោះហើរដឹកជញ្ជូនអ្នកដំណើរ និងទំនិញព្រមទាំងមានក្រុមហ៊ុនឯកជនមួយចំនួនកំពុងស្នើសុំវិញ្ញាបនប័ត្រប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាសពីរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល សម្រាប់ប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរ និងទំនិញ តាមដំណាក់ផ្លូវហោះហើរក្នុងស្រុក និងអន្តរជាតិ។

## ការកសាងធនធានមនុស្ស

៣.១៤០- តាមរយៈកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងសាធារណរដ្ឋកូរ៉េនិងរាជរដ្ឋាភិបាលកម្ពុជា រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិលបានទទួលជំនួយឥតសំណង សម្រាប់គម្រោងការសាងសង់មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិលនៅកម្ពុជា រយៈពេលអនុវត្ត៤ឆ្នាំ ចាប់អនុវត្តពីឆ្នាំ២០១៤-

២០១៧។ គម្រោងនេះបានផ្តល់កម្ពុជានូវមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ដោយមានបំពាក់គ្រឿងបរិក្ខារសម្រាប់បណ្តុះបណ្តាល និងសិក្សា ហើយភាគីកូរ៉េជួយបណ្តុះបណ្តាលធនធានគ្រូបង្គោល និងអ្នកគ្រប់គ្រងដំណើរការប្រព្រឹត្តិទៅរបស់មជ្ឈមណ្ឌល។ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានពង្រឹងសមត្ថភាពមន្ត្រី តាមរយៈការបណ្តុះបណ្តាលមន្ត្រីរាជការទៅតាមផែនការឆ្នាំដែលបានគ្រោងទុកជាបន្តបន្ទាប់។ ជាក់ស្តែងក្នុងឆ្នាំ២០១៦ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល បានអនុវត្តតាមផែនការបណ្តុះបណ្តាលរយៈដែលផ្តោតជាសំខាន់លើ៣ជំនាញគឺ៖ ការត្រួតពិនិត្យសុវត្ថិភាព ការត្រួតពិនិត្យសន្តិសុខអាកាសចរណ៍ និងជំនាញទូទៅ ដល់មន្ត្រីត្រួតពិនិត្យសុវត្ថិភាព សន្តិសុខ និងមន្ត្រីរៀបចំចងក្រងបទប្បញ្ញត្តិ ព្រមទាំងមន្ត្រីផ្តល់សេវាសាធារណៈលើវិស័យអាកាសចរស៊ីវិលផងដែរ ដែលត្រូវបានបែងចែកតាមលក្ខណៈបច្ចេកទេសជា៣កម្រិតគឺ៖ វគ្គជំនាញបឋម វគ្គរក្សានិរន្តរភាពជំនាញ និង វគ្គបង្កើនសមត្ថភាពជំនាញ។ ជាលទ្ធផលទទួលបានគឺ៖ ការបណ្តុះបណ្តាលក្នុងប្រទេសបានចំនួន៨៣នាក់ និង ក្រៅប្រទេសបានចំនួន៨៦នាក់។

**សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស**

៣.១៤១- បរិមាណនៃការដឹកជញ្ជូនតាមផ្លូវអាកាស រួមមានអ្នកធ្វើដំណើរនិងទំនិញ បាននឹងកំពុងកើនឡើង។ អាកាសយានដ្ឋានអន្តរជាតិទាំងបី ទទួលបានអ្នកដំណើរជាតិនិងអន្តរជាតិចំនួនប្រមាណ ៦លាននាក់ កើនឡើង១១% ធៀបនឹងឆ្នាំ២០១៤ ដោយឡែកក្នុងឆ្នាំ២០១៦ អ្នកដំណើរមានចំនួនចំនួន៧ លាននាក់ កើន១០% ធៀបនឹងឆ្នាំ២០១៥។ រូបភាពខាងក្រោមបង្ហាញអំពីកំណើនជើងហោះហើរអន្តរជាតិ និងចំនួនជើងហោះហើរក្នុងស្រុកក្នុងឆ្នាំ២០១៤និងឆ្នាំ២០១៥។ ការដឹកជញ្ជូនតាមផ្លូវអាកាសនឹងបន្តកើនឡើងដោយសារសមាហរណកម្មអាស៊ាន កំណើនទេសចរណ៍ និងកំណើនពាណិជ្ជកម្ម។

**រូបភាពទី៣.៤ : ស្ថានភាពជើងហោះហើរក្នុងស្រុក និងអន្តរជាតិ ឆ្នាំ២០១៥**




ប្រភព : **រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល**

៣.១៤២- បញ្ហាប្រឈម

- ការពង្រឹង និងរក្សាសុវត្ថិភាព សន្តិសុខ សម្រាប់ប្រតិបត្តិការដឹកជញ្ជូនតាមផ្លូវអាកាស ស្របតាមស្តង់ដាររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងឆ្លើយតបទៅនឹងកំណើនចរាចរណ៍ផ្លូវអាកាស។
- កង្វះខាតធនធានសម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឲ្យស្របតាមស្តង់ដាររបស់អង្គការអាកាសចរស៊ីវិលអន្តរជាតិ និងការប្រកួតប្រជែងទីផ្សារ។
- កង្វះខាតធនធានមនុស្សក្នុងស័យអាកាសចរស៊ីវិល រួមទាំងកង្វះខាតគោលនយោបាយ និងបទបញ្ញត្តិសេដ្ឋកិច្ចលើវិស័យអាកាសចរស៊ីវិល ដែលត្រូវការជំនាញការបរទេសមកជួយរៀបចំគោលនយោបាយ និងបទបញ្ញត្តិទាំងនេះ។

## ៥.២- ការគ្រប់គ្រងធនធានទឹកនិងប្រព័ន្ធធារាសាស្ត្រ

### ១. ការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក

### ការស្តារនិងការសាងសង់ប្រព័ន្ធធារាសាស្ត្រ

៣.១៤៣- ក្រសួងធនធានទឹកនិងឧតុនិយម បានជួសជុល-ស្តារឡើងវិញ និងសាងសង់ប្រព័ន្ធ ធារាសាស្ត្រ និងកិច្ចដំណើរការថែទាំ ទាំងតូចទាំងធំនៅទូទាំងប្រទេសក្នុងឆ្នាំ ២០១៤-២០១៦ សម្រេចបាន៤២៣គម្រោង ដែលពង្រីកលទ្ធភាពស្រោចស្រពលើផ្ទៃដីដំណាំស្រូវ សរុបចំនួន ២៥៧ ៩២៦ហ.ត. ក្នុងនោះរួមមាន (ស្រូវរដូវវស្សា ចំនួន ១៨៣ ៣៨៤ហ.ត. និងស្រូវរដូវប្រាំង ចំនួន ៧៤ ៥៤២ហ.ត. និងស្រោចស្រពដំណាំរួមផ្សំបាន ៣ ៣៩៨ហ.ត.។

**តារាងទី៣.១១: លទ្ធភាពស្រោចស្រពប្រចាំឆ្នាំ**

| ឆ្នាំ | ចំនួនគម្រោង | លទ្ធភាពស្រោចស្រព (ហ.ត.) | | | ដំណាំ |
|---|---|---|---|---|---|
| | | វស្សា | ប្រាំង | សរុប | ហ.ត. |
| ២០១៤ | ៧១ | ៨០ ២៤៥ | ៤១ ០១៣ | ១២១ ២៥៨ | ១ ២២៨ |
| ២០១៥ | ១៥២ | ៦២ ២៨៩ | ១៩ ១៦៦ | ៨១ ៤៥៥ | ១ ៥៥៨ |
| ២០១៦ | ២០០ | ៤០ ៨៥០ | ១៤ ៣៦៣ | ៥៥ ២១៣ | ៦១២ |
| សរុប | ៤២៣ | ១៨៣ ៣៨៤ | ៧៤ ៥៤២ | ២៥៧ ៩២៦ | ៣ ៣៩៨ |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

### ការជួសជុល-ថែទាំសំណង់សិល្បការ

៣.១៤៤- ក្រសួងនិងមន្ទីរធនធានទឹកនិងឧតុនិយម រាជធានី-ខេត្ត បានធ្វើការជួសជុល ថែទាំសំណង់សិល្បការតាមបណ្តាប្រព័ន្ធធារាសាស្ត្រនៅតាមខេត្ត ហើយសម្រេចបានរួមមានសំណង់

ទ្វារទឹក សរុបចំនួន៩៤កន្លែង សំណង់លូទឹក សរុបចំនួន ១៨៥កន្លែង សំណង់ស្ពាក់ទឹក សរុបចំនួន ៣៤កន្លែង និងសំណង់បង្ហៀរទឹក សរុបចំនួន១៣កន្លែង។

**តារាងទី៣.១២ : ការជួសជុល-ថែទាំសំណង់សិល្បការតាមឆ្នាំ**

| ឆ្នាំ | ទ្វារទឹក (កន្លែង) | លូទឹក (កន្លែង) | ស្ពាក់ទឹក (កន្លែង) | បង្ហៀរ (កន្លែង) |
|---|---|---|---|---|
| ២០១៤ | ៤០ | ១០៥ | ៣០ | ៥ |
| ២០១៥ | ២០ | ៧៣ | ៤ | ២ |
| ២០១៦ | ៣៣ | ៧ | | ៦ |
| **សរុប** | **៩៤** | **១៨៥** | **៣៤** | **១៣** |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

**ការរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក**

៣.១៤៥- ក្រសួងបានរៀបចំសហគមន៍កសិករប្រើប្រាស់ទឹក នៅតាមប្រព័ន្ធធារាសាស្ត្រ ក្នុងឆ្នាំ ២០១៤-២០១៦ សម្រេចបានសរុបចំនួន ៤៦សហគមន៍ ដែលមានផ្ទៃដីស្រូវសរុប ៦៨ ៨៧៨ហ.ត. ក្នុងនោះផ្ទៃដីស្រូវវស្សា ៥៨ ២០៥ហ.ត. ស្រូវប្រាំងចំនួន១០ ៦៧៣ហ.ត. និងមាន១៨ ៨១១ គ្រួសារ។

**តារាងទី៣.១៣ : ចំនួនសហគមន៍កសិករប្រើប្រាស់ទឹកតាមឆ្នាំ**

| ឆ្នាំ | ចំនួនសហគមន៍ | ផ្ទៃដីដំណាំស្រូវ | | | ចំនួនគ្រួសារ |
|---|---|---|---|---|---|
| | | ស្រូវវស្សា ហ.ត. | ស្រូវប្រាំង ហ.ត. | សរុប ហ.ត. | |
| ២០១៤ | ១៨ | ១៦ ៤០០ | ៥ ៤២៦ | ២១ ៨២៦ | ៩ ២៦៩ |
| ២០១៥ | ៩ | ៧ ២២៦ | ៦៨០ | ៧ ៩០៦ | ៣ ៥៦៣ |
| ២០១៦ | ១៩ | ៣៤ ៥៧៩ | ៤ ៥៦៧ | ៣៩ ១៤៦ | ៥ ៩៧៩ |
| **សរុប** | **៤៦** | **៥៨ ២០៥** | **១០ ៦៧៣** | **៦៨ ៨៧៨** | **១៨ ៨១១** |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

## ២. ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់-ទឹកប្រៃ និងអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

**ការគ្រប់គ្រង និងកាត់បន្ថយគ្រោះទឹកជំនន់-ទឹកប្រៃ**

៣.១៤៦- ទឹកជំនន់ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ បានបណ្ដាលឲ្យខូចខាតដល់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសេដ្ឋកិច្ចសង្គមជាច្រើន ដោយសារការប្រែប្រួលអាកាសធាតុ។ ក្រសួងធនធានទឹកនិងឧតុនិយមបានធ្វើការជួសជុលទំនប់ទប់ស្កាត់**ទឹកជំនន់និងទឹកប្រៃ** ដូចមានខាងក្រោម៖

- **ការទប់ស្កាត់ទឹកជំនន់៖** បានធ្វើការជួសជុលទំនប់ការពារទប់ស្កាត់ទឹកជំនន់ បានចំនួន ១០ គម្រោង ដែលមានលទ្ធភាពការពារលំនៅដ្ឋានប្រជាពលរដ្ឋ បានចំនួន៥២៦ហត.. រក្សានិរន្តរភាពការពារផ្ទៃដីស្រូវនិងដំណាំ ព្រមទាំងការពារច្រាំងទន្លេនៅក្រុងកំពង់ចាមបាន៣៩០ម។

**តារាងទី៣.១៤ : ការទប់ស្កាត់ទឹកជំនន់តាមឆ្នាំ**

| ឆ្នាំ | ចំនួនគម្រោង | លទ្ធភាពការពារ ហ.ត. | | | |
|---|---|---|---|---|---|
| | | លំនៅដ្ឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៤ | ៣ | ១៥០ | | | ១៥០ |
| ២០១៥ | ៤ | ១០០ | | | ១០០ |
| ២០១៦ | ៣ | ២៧៦ | | | ២៧៦ |
| **សរុប** | **១០** | **៥២៦** | | | **៥២៦** |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

- **ការទប់ស្កាត់ទឹកប្រៃ៖** បានធ្វើការជួសជុល និងថែទាំជាប្រចាំទំនប់ការពារទប់ស្កាត់ទឹកប្រៃ បានចំនួន ២៦**គម្រោង** ហើយការពារទប់ស្កាត់ទឹកប្រៃ កុំឲ្យប៉ះពាល់ផ្ទៃដី សរុបចំនួន ៩៤០ ហ.ត.។

**តារាងទី១៥ : ការទប់ស្កាត់ទឹកប្រៃតាមឆ្នាំ**

| ឆ្នាំ | ចំនួនគម្រោង | លទ្ធភាពការពារ ហ.ត. | | | |
|---|---|---|---|---|---|
| | | លំនៅដ្ឋាន | ស្រូវ | ដំណាំ | សរុប |
| ២០១៤ | ១ | | | | |
| ២០១៥ | ១២ | | ៧៥០ | ១៥ | ៧៦៥ |
| ២០១៦ | ១៣ | | ១៦៥ | ១០ | ១៧៥ |
| **សរុប** | **២៦** | | **៩១៥** | **២៥** | **៩៤០** |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

**ការគ្រប់គ្រងនិងការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត**

៣.១៤៧- គ្រោះរាំងស្ងួតតែងកើតមានឡើង ដោយការប្រែប្រួលអាកាសធាតុ និងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ផលិតផលកសិកម្ម ដែលជាហេតុបណ្តាលឲ្យទិន្នផលស្រូវធ្លាក់ចុះធ្វើឲ្យប្រជាកសិករមានចំណូលទាប។ ក្នុងន័យនេះ ការអន្តរាគមន៍ដោយម៉ាស៊ីនបូមទឹក ដែលជួយដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើរតួយ៉ាងសំខាន់ក្នុងការសង្គ្រោះ បន្ធូរបន្ថយ និងកែលម្អដំណាំកសិកម្មដែលរងផលប៉ះពាល់ពីគ្រោះរាំងស្ងួត។

### ការអន្តរាគមន៍សង្គ្រោះស្រូវពេលមានគ្រោះរាំងស្ងួត

៣.១៤៨- ក្រសួងធនធានទឹកនិងឧតុនិយម បានប្រមូលផ្តុំនូវម៉ាស៊ីនបូមទឹក និងមធ្យោបាយចាំបាច់នានា ក្នុងការអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវ ដែលប៉ះពាល់ពីគ្រោះរាំងស្ងួតក្នុងឆ្នាំ ២០១៤-២០១៦។

**តារាងទី៣.១៦ : ផ្ទៃដីស្រូវសង្គ្រោះបានតាមឆ្នាំ**

| ឆ្នាំ | ផ្ទៃដីស្រូវសង្គ្រោះបាន | | |
|---|---|---|---|
| | ប្រាំង(ហ.ត.) | វស្សា(ហ.ត.) | សរុប |
| ២០១៤ | ២៣ ៥២៦ | ៣០ ៦២៣ | ៥៤ ១៤៩ |
| ២០១៥ | ២២ ១៦៤ | ៣៧ ៨៥១ | ៦០ ០១៥ |
| ២០១៦ | ៦៣ ៥៨៦ | ២៩ ៣២១ | ៩២ ៩០៧ |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

៣.១៤៩- ក្រៅពីការងារអន្តរាគមន៍សង្គ្រោះស្រូវ ដោយម៉ាស៊ីនបូមទឹកក៏មាន ការងារសង្គ្រោះស្រូវដោយប្រព័ន្ធធារាសាស្ត្រ (បង្ហូរ) មានដូចបណ្តាឆ្នាំខាងក្រោម៖

**តារាងទី៣.១៧ : ផ្ទៃដីស្រូវដែលបង្ហូរសង្គ្រោះតាមឆ្នាំ**

| ឆ្នាំ | លទ្ធផលបង្ហូរសង្គ្រោះ | | |
|---|---|---|---|
| | ប្រាំង(ហ.ត.) | វស្សា(ហ.ត.) | សរុប |
| ២០១៤ | ៣ ៧៦៩ | ២ ៨៣៥ | ៦ ៦០៤ |
| ២០១៥ | ២ ៧៨២ | ៣ ២៨៧ | ៦ ០៦៩ |
| ២០១៦ | ៣៨១ | ៦៨១ | ១ ០៦២ |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

### ការជំទើ្បង-ជួសជុល ស្ថានីយបូមទឹក និងម៉ាស៊ីនបូមទឹក

៣.១៥០- ដើម្បីឲ្យការងារអន្តរាគមន៍បូមទឹកសង្គ្រោះស្រូវបានសម្រេច ក្រសួងបានសាងសង់-ដំឡើងស្ថានីយបូមទឹក ១កន្លែង ជួសជុលស្ថានីយបូមទឹក ១៩កន្លែង និងជួសជុលម៉ាស៊ីនបូមទឹកចំនួន ៦៤គ្រឿង។

**តារាងទី៣.១៨ : ចំនួនស្ថានីយបូមទឹកនិងម៉ាស៊ីនបូមទឹកដែលបានសាងសង់និងជួសជុល**

| ឆ្នាំ | សាងសង់ស្ថានីយ (កន្លែង) | ជួសជុលស្ថានីយ (កន្លែង) | ជួសជុលម៉ាស៊ីន (កន្លែង) |
|---|---|---|---|
| ២០១៤ | ១ | ៧ | ៣២ |
| ២០១៥ | | ៩ | ១១ |
| ២០១៦ | | ៣ | ២១ |
| **សរុប** | **១** | **១៩** | **៦៤** |

ប្រភព : ក្រសួងធនធានទឹកនិងឧតុនិយម

### ៣. ការរៀបចំក្របខ័ណ្ឌច្បាប់-បញ្ញត្តិ សម្រាប់និរន្តរភាពនៃទឹក

៣.១៥១- ក្រសួងសម្រេចបាននូវសមិទ្ធផល ក្នុងការរៀបចំអនុក្រឹត្យសារជាថ្មី បានចំនួន២ ដើម្បីអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងធនធានទឹក នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានដូចខាងក្រោម៖

- អនុក្រឹត្យស្ដីពីនីតិវិធីនៃការបង្កើត ការរំសាយចោល និងការកំណត់តួនាទី និងភារកិច្ចនៃសហគមន៍កសិករប្រើប្រាស់ទឹក ដែលគណៈរដ្ឋមន្ត្រីប្រជុំពេញអង្គ អនុម័តជាផ្លូវការនៅថ្ងៃទី ១២ ខែមីនា ឆ្នាំ ២០១៥។
- អនុក្រឹត្យស្ដីពីការគ្រប់គ្រងអាងទន្លេ ដែលគណៈរដ្ឋមន្ត្រីប្រជុំពេញអង្គ អនុម័តជាផ្លូវការនៅថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០១៥។

### ៤.ការគ្រប់គ្រងព័ត៌មានជលសាស្ត្រនិងឧតុនិយម

៣.១៥២- ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ ការប្រែប្រួលអាកាសធាតុបានបណ្ដាលឲ្យកើតមានឡើងនូវគ្រោះរាំងស្ងួតនិងទឹកជំនន់ ដែលជាគ្រោះធម្មជាតិដ៏ធំ បានធ្វើឲ្យបាត់បង់ដល់អាយុជីវិតមនុស្ស សត្វ ខូចខាតទ្រព្យសម្បត្តិសាធារណៈ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន។ ដើម្បីទប់ទល់ និងកាត់បន្ថយនូវគ្រោះមហន្តរាយធម្មជាតិនេះ ទាមទារឲ្យមានការដំឡើងស្ថានីយឧតុនិយមនិងស្ថានីយជលសាស្ត្រ នៅតាមទន្លេ ដងទន្លេ និងស្ទឹងសំខាន់ៗ ដើម្បីទទួលបាននូវទិន្នន័យធាតុអាកាសជាក់លាក់ និងកម្រិតកម្ពស់ទឹក ទិន្នន័យធារទឹក សម្រាប់ធ្វើការព្យាករស្ថានភាពឧតុនិយម និងស្ថានភាពជលសាស្ត្រឲ្យបានទៀងទាត់ សុក្រឹត និងផ្សព្វផ្សាយជូនដំណឹងទាន់ពេលជូនដល់សាធារណជន ឲ្យបានមុនពេលគ្រោះមហន្តរាយពីធម្មជាតិកើតឡើង ដូចជាភាពរាំងស្ងួត ខ្យល់ព្យុះ រន្ទះនិងទឹកជំនន់។ សមិទ្ធផលការងារខាងលើក្រសួងសម្រេចបានដូចខាងក្រោម៖

- ដំឡើងស្ថានីយជលសាស្ត្រ ២៤កន្លែង និងជួសជុល ១កន្លែង នៅតាមបណ្ដាលខេត្ត។
- ដំឡើងក្ដារវាស់កម្ពស់ទឹកចំនួន ៤២កន្លែង និងជួសជុល ៦កន្លែង នៅតាមចំណុចត្រួតពិនិត្យតាមបណ្ដោយទន្លេ និងស្ទឹង។
- ដំឡើងស្ថា នីយឧតុនិយមបានចំនួន ៤៤កន្លែង និងជួសជុលកែលម្អស្ថានីយឧតុនិយមបានចំនួន ៤កន្លែង និងដំឡើងប៉ុស្ដិ៍តម្រងទឹកភ្លៀងចំនួន ៣០កន្លែង និងជួសជុលប៉ុស្ដិ៍តម្រងទឹកភ្លៀងបានចំនួន ១៣កន្លែង បំពាក់ឧបករណ៍ស្វ័យប្រវត្តិតាមស្ថានីយសរុបបានចំនួន ២**កន្លែង**។

៣.១៥៣- **បញ្ហាប្រឈម**

- តម្រូវការក្នុងការអនុវត្តបច្ចេកវិទ្យាដែលធន់នឹងអាកាសធាតុទៅក្នុងគម្រោងធារាសាស្ត្រ និងហេដ្ឋារចនាសម្ព័ន្ធជនបទផ្សេងទៀត។
- ការគ្រប់គ្រងធនធានទឹកចម្រុះអន្តរវិស័យ រួមទាំងការគ្រប់គ្រងអាងទន្លេត្រូវពង្រឹងបន្ថែមទៀត ដោយសារកំណើនសម្ពាធលើធនធានទឹក ដែលបណ្តាលមកពីការអភិវឌ្ឍ កំណើនវិស័យកសិកម្ម នគរូបនីយកម្មនិងឧស្សាហូបនីយកម្ម និងការផលិតថាមពល។
- ថវិកាលើការងារជួសជុល និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមានកម្រិតទាប។ ការផ្តល់ ថវិកាលើការងារ ជួសជុល ស្តារ និងសាងសង់ប្រព័ន្ធធារាសាស្ត្រមានការយឺតយ៉ាវនឹងពុំចំរដូវកាលសាងសង់ ព្រមទាំងនៅមានកម្រិតដែលពុំអាចឆ្លើយតមតាមតម្រូវការជាក់ ស្តែង។ ការចូលរួមរបស់កសិករលើការងារប្រើប្រាស់ និងថែទាំប្រព័ន្ធធារាសាស្ត្រនៅមាន កម្រិតទាប។

### ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន

- បានផលិតទឹកស្អាតនៅទូទាំងប្រទេស ពីឆ្នាំ២០១២ ដល់ដើមឆ្នាំ២០១៧ បាន ៩៩៧ ៤១៣ ៣០៤ ម៉ែត្រគ្រីគុណ
- បានចេញប្រកាសស្តីពី នីតិវិធីនៃការកំណត់ថ្លៃទឹក និងប្រកាសពាក់ព័ន្ធការធ្វើអាជីវកម្មផ្សេងទៀត ដែលបានចូលជាធរមាន កាលពីថ្ងៃទី០៤ ខែមីនា ឆ្នាំ២០១៦
- បានដាក់ឲ្យដំណើរការរោងចក្រលិតទឹកស្អាតថ្មីនៅខេត្តមណ្ឌលគិរី បាត់ដំបង និងកំពង់ចាម
- បានបើកការដ្ឋានឲ្យដំណើរការសាងសង់រោងចក្រផលិតទឹកស្អាតថ្មីនៅខេត្តកំពត គ្រោងបញ្ចប់នៅក្នុង ឆ្នាំ២០១៨
- បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីការគ្រប់គ្រងសេវាកម្មទឹកស្អាត
- បានចេញប្រកាសស្តង់ដារគុណភាពទឹកស្អាតថ្នាក់ជាតិ
- អភិវឌ្ឍប្រព័ន្ធត្រួតពិនិត្យគុណភាពទឹកឲ្យមានប្រសិទ្ធភាព និងបានបង្កើតប្រព័ន្ធត្រួតពិនិត្យប្រតិបត្តិការ ទឹកស្អាតឯកជន និងសាធារណៈនៅកម្ពុជា (Monitoring System) តាមរយៈការបញ្ចូលទិន្នន័យ
- បានចេញប្រកាសអនុញ្ញាតឲ្យធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជនកើនឡើងចំនួន១១៩ កន្លែង អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតឯកជន ដែលមានការសម្បទានដោយរដ្ឋាភិបាល ចំនួន ១១កន្លែង និង អាជីវកម្មផ្គត់ផ្គង់ទឹកស្អាតរដ្ឋសរុប១៣ កន្លែង ក្នុងនោះមានរដ្ឋាករទឹកស្វយ័តពីរ ផងដែរ
- បានប្រើប្រាស់ធនធានរបស់រាជរដ្ឋាភិបាល ធនធានរបស់អង្គភាព និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នានា ដើម្បីអភិវឌ្ឍប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- បានបង្កើត"សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា"

- បាននឹងកំពុងបន្តការងារបណ្តុះបណ្តាល និងអនុវត្តគម្រោងពង្រីកហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត ដើម្បី ឈានទៅ ស្វយ័តភាពជាសហគ្រាសមានលក្ខណៈសេដ្ឋកិច្ច
- បានផ្ទេរភារកិច្ចចំនួន០៦ មុខងារ ដល់ថ្នាក់ក្រោមជាតិ

បញ្ហាប្រឈម

- ខ្វះច្បាប់ បទដ្ឋានគតិយុត្ត ឯកសារផ្លូវច្បាប់នានា សម្រាប់ការងារគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត
- ថវិកាបដិភាគពីរដ្ឋាភិបាលមានកម្រិតតិចតួចសម្រាប់ការអភិវឌ្ឍន៍វិស័យទឹកស្អាត
- ធនធានមនុស្សមានកម្រិតនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ មានតម្រូវការក្នុងការបង្កើតមជ្ឈមណ្ឌល បណ្តុះបណ្តាលជំនាញបច្ចេកទេសទឹកស្អាតនៅពេលអនាគត
- ទិន្នន័យដែលផ្តល់ដោយសេវាករផ្គត់ផ្គង់ទឹកស្អាតពុំមានភាពជាក់លាក់
- សមត្ថភាពម្ចាស់ការគ្រប់គ្រងដោយខ្លួនឯងរបស់ រដ្ឋាករទឹកសាធារណៈមួយចំនួននៅមានកម្រិត
- ពុំមានការសិក្សាផលប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ពីផ្នែកឯកជន។

## ៥.៣- ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី

### ប្រភពផ្គត់ផ្គង់អគ្គិសនី

៣.១៥៤- នៅក្នុងឆ្នាំ២០១៦ បរិមាណប្រភពថាមពលអគ្គិសនីដែលបានផលិតនិងនាំចូលទូទាំងប្រទេសមានចំនួន៧ ១៩៤,៥៤លានគីឡូវ៉ាត់ម៉ោង បើប្រៀបធៀបទៅនឹងឆ្នាំ២០១៥ ដែលមានត្រឹមតែ៥ ៩៨៩,៥៦ លានគីឡូវ៉ាត់ម៉ោង គឺមានការកើនឡើង២០,១២%។ សេចក្តីត្រូវការអតិបរមានៅទូទាំងប្រទេសក្នុងប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី មានប្រមាណ១១០០ មេហ្គាវ៉ាត់ ដែលនៅរដូវវស្សាតម្រូវការប្រមាណក្រោម១ ០០០មេហ្គាវ៉ាត់ ក្នុងនោះនៅតំបន់រាជធានីភ្នំពេញកំពង់ចាម ប្រមាណ៧២០មេហ្គាវ៉ាត់ បណ្តាខេត្តភាគខាងត្បូង ប្រមាណ១១០មេហ្គាវ៉ាត់ និងភាគខាងលិច១៩០មេហ្គាវ៉ាត់។ នៅរដូវវស្សាបានបន្ថយជាអតិបរមានូវការផលិតថាមពលចេញពីប្រភពដែលប្រើប្រេងឥន្ធនៈ ហើយជំនួសមកវិញដោយវារីអគ្គិសនី និងបានកាត់បន្ថយជាអតិបរមានូវការនាំចូលថាមពលតាមរយៈបណ្តាញតង់ស្យុងខ្ពស់ពីបណ្តាប្រទេសជិតខាង គឺការនាំចូលពីប្រទេសថៃបានកាត់បន្ថយរហូតដល់សូន្យមេហ្គាវ៉ាត់ និងពីប្រទេសវៀតណាមកាត់បន្ថយជាអតិបរមាមកនៅត្រឹម៥០មេហ្គាវ៉ាត់។

## តារាងទី៣.១៩ : ទិន្នន័យនៃប្រភពអគ្គិសនីផ្សេងៗដែលផ្គត់ផ្គង់តម្រូវការអគ្គិសនីនៅកម្ពុជា

| ប្រភពអគ្គិសនី | ២០១៤ | | | ២០១៥ | | | ២០១៦ | | |
|---|---|---|---|---|---|---|---|---|---|
| | MW | លាន kWh | % | MW | លាន kWh | % | MW | លាន kWh | % |
| ១-ប្រភពអគ្គិសនីក្នុងស្រុក | | | | | | | | | |
| ប្រភពដុតធ្យូងថ្ម | 110.00 | 840.33 | 17.83 | 368.00 | 2,210.14 | 36.90 | 368.00 | 2,589.89 | 36.00 |
| ប្រភពវារីអគ្គិសនី | 682.10 | 1,829.78 | 38.82 | 927.00 | 1,988.38 | 33.20 | 927.00 | 2,620.67 | 36.43 |
| ប្រភពដុតប្រេង | 176.98 | 159.90 | 3.39 | 218.00 | 117.69 | 1.96 | 218.00 | 207.17 | 2.88 |
| ប្រភពថាមពលកកើតឡើងវិញ | 16.57 | 2.90 | 0.06 | 16.57 | 38.04 | 0.64 | 28.00 | 29.15 | 0.41 |
| ប្រភពផ្ទាល់របស់ឧស្សាហកម្ម និងអ្នកចែកចាយ | 39.54 | 85.92 | 1.83 | 39.54 | 94.00 | 1.57 | 23.16 | 75.29 | 1.05 |
| **សរុបប្រភពអគ្គិសនីក្នុងស្រុក** | 1,025.19 | 2,918.83 | 61.93 | 1,569.11 | 4,448.25 | 74.27 | 12.00 | 12.00 | 0.17 |
| ២-ប្រភពអគ្គិសនីនាំចូល | | | | | | | | | |
| ប្រភពនាំចូលពីថៃសរុប | 135.50 | 524.20 | 11.12 | 135.50 | 243.88 | 4.07 | 135.50 | 343.05 | 4.77 |
| ប្រភពនាំចូលពីវៀតណាមសរុប | 196.25 | 1,256.23 | 26.65 | 277.00 | 1,280.06 | 21.37 | 277.00 | 1,281.39 | 17.81 |
| ប្រភពនាំចូលពីឡាវសរុប | 2.00 | 13.77 | 0.29 | 4.00 | 17.37 | 0.29 | 4.00 | 35.95 | 0.50 |
| **សរុបប្រភពអគ្គិសនីនាំចូល** | 333.75 | 1,794.20 | 38.07 | 416.50 | 1,541.31 | 25.73 | 416.50 | 1,660.39 | 23.08 |
| ៣-សរុបប្រភពអគ្គិសនីទាំងអស់ | 1,358.94 | 4,713.03 | 100.0 | 1,985.61 | 5,989.56 | 100.0 | 1,992.66 | 7,194.56 | 100.0 |

ប្រភព : ក្រសួងរ៉ែនិងថាមពល

៣.១៥៥- ក្រសួងក៏បានយកចិត្តទុកដាក់ជំរុញការចូលរួមអភិវឌ្ឍន៍ប្រភពអគ្គិសនីស្អាតផងដែរ។ ក្នុងនោះមានគម្រោងមួយចំនួនបានដាក់ឲ្យដំណើរការរួចហើយ និង គ្រោងដាក់ឲ្យដំណើរការ៖

- បានដាក់ឲ្យដំណើរការរោងចក្រអគ្គិសនីដុតកាកអំពៅ អានុភាពសរុប៥៧,៥មេហ្គាវ៉ាត់។
- បានដាក់ឲ្យដំណើរការគម្រោងថាមពលជីវម៉ាស់ដុតអង្កាមអានុភាពសរុប៣មេហ្គាវ៉ាត់។
- គម្រោងចង្ក្រានប្រសិទ្ធភាព ឬចង្ក្រានប្រណិតបានផលិតចង្ក្រានចំនួន៣.០៩៣.១៦៧ ចង្ក្រាន ដោយរួមមានចង្ក្រាននាងកង្រីនិងចង្ក្រានឡូវថ្មី ដែលកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់បានចំនួន៧៦៧ ៦៩៩តោនឧស្ម័នកាបូនិច។
- អនុញ្ញាតឲ្យសិក្សាគម្រោងផលិតថាមពលអគ្គិសនីដើរដោយពន្លឺព្រះអាទិត្យ ថាមពលខ្យល់ និងកាកសំណល់សំរាមទីក្រុងចំនួន៥ គម្រោង។
- រោងចក្រអគ្គិសនីដើរដោយថាមពលព្រះអាទិត្យ អានុភាព១០មេហ្គាវ៉ាត់ ទីក្រុងបាវិត ខេត្តស្វាយរៀង គ្រោងនឹងដាក់ឲ្យដំណើរការនៅចុងឆ្នាំ២០១៧។
- ស្ថានីយ៍វារីអគ្គិសនីសេសានក្រោម២ (វារីអគ្គិសនីធំជាងគេបង្អស់នៅប្រទេសកម្ពុជា) មេហ្គាវ៉ាត់ នឹងដាក់៤០០ភាពសរុបដែលមានអានុឲ្យដំណើរការម៉ាស៊ីនទី១ ដែលមានអានុភាព៥០មេហ្គាវ៉ាត់នៅចុងឆ្នាំ២០១៧។

### ប្រព័ន្ធបញ្ជូនអគ្គិសនីនិងការចែកចាយអគ្គិសនី

៣.១៥៦- ការអភិវឌ្ឍបណ្ដាញបញ្ជូន និងអនុស្ថានីយ៍ ដែលជាឆ្អឹងខ្នងនៃការផ្គត់ផ្គង់អគ្គិសនីនៅកម្ពុជា បានបន្តការសាងសង់ និងដាក់ឲ្យដំណើរការបណ្ដាញបញ្ជូន និងអនុស្ថានីយ៍ជាបន្តបន្ទាប់ធ្វើឲ្យបណ្ដាញតង់ស្យុងខ្ពស់ចំនួន១.៥២៥គ.ម. និងមានអនុស្ថានីយ៍ចំនួន២៥ គ្របដណ្ដប់ផ្ទាល់លើខេត្តចំនួន១៤ និងមិនផ្ទាល់ចំនួន៤ខេត្តទៀត ដែលធ្វើការប៉ាន់ស្មានតាមអត្រាតម្លៃមធ្យម មានទំហំវិនិយោគលើខ្សែបណ្ដាញតង់ស្យុងខ្ពស់ និងអនុស្ថានីយ៍មានចំនួន ៨៣៤ លានដុល្លាអាមេរិក។ ដើម្បីបញ្ជូនប្រភពអគ្គិសនីពីអនុស្ថានីយ៍បណ្ដាញជាតិទៅកាន់តំបន់ជនបទនានា ចាំបាច់ត្រូវការខ្សែបណ្ដាញតង់ស្យុងមធ្យមដែលបច្ចុប្បន្នមានប្រវែង២៨.៨៩២ ៤៤គ.ម. ត្រង់ស្វូម៉ាទ័រចែកចាយមានចំនួន១២.៦០៥គ្រឿង ខ្សែបណ្ដាញចែកចាយតង់ស្យុងទាបមានចំនួន ២៦ ៦៧៩ គ.ម និងការភ្ជាប់ចរន្តជូនអ្នកប្រើប្រាស់ចំនួន២ ១៥៩ ៣២៤កន្លែង ហើយតាមការប៉ាន់ស្មានអត្រាថ្លៃមធ្យម ទំហំវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនេះមានចំនួនសរុប ១.១៧២លានដុល្លាអាមេរិក ដែលក្នុងនោះវិនិយោគដោយអគ្គិសនីកម្ពុជាចំនួន៣៩៦លានដុល្លារអាមេរិក និងវិនិយោគដោយសេវាករឯកជនចំនួន៧៧៦លានដុល្លារអាមេរិក។ បន្ថែមពីលើនេះ អគ្គិសនីកម្ពុជាកំពុងតែធ្វើការពង្រីកបណ្ដាញបញ្ជូនរងចេញពីអនុស្ថានីយ៍ទៅកាន់តំបន់ជនបទនានា ក្នុងក្របខណ្ឌនៃឥណទានពីប្រទេសចិននិងឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីបញ្ជូនប្រភពអគ្គិសនីរបស់បណ្ដាញជាតិទៅឲ្យតំបន់នានាដែលមិនទាន់ទទួលបានប្រភពអគ្គិសនីពីបណ្ដាញជាតិ ដែលគម្រោងវិនិយោគនេះមានទឹកប្រាក់៣៥២,៩៨លានដុល្លាអាមេរិក។

- ការអភិវឌ្ឍបណ្ដាញចែកចាយ៖ អ្នកកាន់អាជ្ញាបណ្ណបានអភិវឌ្ឍបណ្ដាញចែកចាយគ្របដណ្ដប់លើភូមិចំនួន១០ ៥៨៩ភូមិ ដែលត្រូវជា៧៤,៧៤% នៃចំនួនភូមិទូទាំងប្រទេស
- ការភ្ជាប់ចរន្តពីបណ្ដាញជូនអ្នកប្រើប្រាស់មានចំនួនប្រមាណ ២ ១៥៩ ៣២៤ខ្នងផ្ទះ ត្រូវជា៦៥,៨៣% ធៀបនឹងចំនួនខ្នងផ្ទះសរុបប្រមាណ ៣ ២៨០ ០០០ខ្នងផ្ទះ។

**តារាងទី៣.២០ : ហេដ្ឋារចនាសម្ព័ន្ធបញ្ជូនរង និងប្រព័ន្ធចែកចាយអគ្គិសនី**

| ប្រភេទហេដ្ឋារចនាសម្ព័ន្ធ | ឯកតា | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| បណ្ដាញតង់ស្យុងមធ្យម | គ.ម. | 17,456 | 20,907.60 | 31,117.00 |
| ត្រង់ស្វូម៉ាទ័រ | គ្រឿង | 8,559 | 10,703.00 | 13,378.75 |
| បណ្ដាញតង់ស្យុងទាប | គ.ម. | 17,452 | 19,588.00 | 23,526.25 |
| លំនៅដ្ឋានភ្ជាប់ចរន្ត | ចំនួនភ្ជាប់ | 1,350,000 | 1,759,797.00 | 2,159,324.00 |

ប្រភព : ក្រសួងរ៉ែនិងថាមពល

## ៣.១៥៧- បញ្ហាប្រឈម

- កង្វះទិន្នន័យអភិវឌ្ឍន៍និងផែនការវិនិយោគតំបន់ឧស្សាហកម្ម តំបន់សេដ្ឋកិច្ចពិសេស ទីក្រុងរណប បូរី និងអគារពាណិជ្ជកម្មធំៗពីស្ថាប័នពាក់ព័ន្ធផ្សេងៗ ដើម្បីផ្គត់ផ្គង់និងចែក

ចាយអគ្គិសនីដល់តំបន់ទាំងនោះឲ្យស្របតាមសេចក្តីត្រូវការ នៃការប្រើប្រាស់អគ្គិសនីបានទាន់ពេលវេលា

- ភាពខុសគ្នានៃការប្រើប្រាស់ថាមពលអគ្គិសនីនៅពេលបន្ទុកអតិបរមានិងបន្ទុកអប្បបរមា
- អតុល្យភាពនៃការផ្គត់ផ្គង់ថាមពលនៅរដូវវស្សានិងរដូវប្រាំង
- ការបញ្ជូនអគ្គិសនីនៅក្នុងប្រព័ន្ធបណ្ដាញជាតិបញ្ជូនអគ្គិសនីមិនទាន់មានស្ថិរភាព
- ការពង្រីកបណ្ដាញចែកចាយឲ្យដល់ជនបទនៅមានកម្រិត
- ថ្លៃលក់អគ្គិសនីរវាងទីក្រុងនិងជនបទនៅមានគម្លាតគ្នានៅឡើយ
- ការគ្រប់គ្រងនិងសវនកម្មថាមពលក្នុងអគារ រោងចក្រ និងសហគ្រាស
- ការដោះស្រាយផលប៉ះពាល់បរិស្ថាននិងសង្គមរបស់គម្រោងផលិតកម្មនិងខ្សែបណ្ដាញបញ្ជូន និង
- កង្វះធនធានមនុស្សដែលមានជំនាញ ចំណេះដឹង និងបទពិសោធន៍ ដើម្បីឆ្លើយតបនឹងតម្រូវការទីផ្សារការងារពាក់ព័ន្ធនឹងវិស័យថាមពល។

## ៥.៤- ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន

### ៣.១៥៨- វិស័យប្រៃសណីយ៍

- លើកកម្ពស់គុណភាពសេវា ភាពជឿទុកចិត្ត ផ្ដល់ចំណេះដឹងខាងបច្ចេកទេស ផ្ដល់ការគាំទ្រដល់បណ្ដាសេវាដែលមានស្រាប់ និងប្រសិទ្ធភាពនៃបណ្ដាញប្រៃសណីយ៍។
- បង្កើនសុចរិតភាព និងសុវត្ថិភាពនៃសេវាប្រៃសណីយ៍។
- ដាក់ឲ្យប្រើប្រាស់ប្រព័ន្ធ IFS នៃសហភាពប្រៃសណីយ៍សកល សម្រាប់សេវាផ្ញើរប្រាក់អន្តរជាតិ តាមប្រព័ន្ធអេឡិចត្រូនិច (IEMO) របស់ប្រៃសណីយ៍កម្ពុជា។
- ពង្រឹងសមត្ថភាពក្នុងការអនុវត្ត និងគ្រប់គ្រងសេវាសកល។

**តារាងទី៣.២១ : សូចនាករស្តីពីអត្រាអ្នកប្រើប្រាស់**

| លរ. | បរិយាយ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| ១ | អត្រាអ្នកប្រើសេវា នាក់/ឆ្នាំ | ០,០៩២៦ | ០,០៩០៣ | ០,១០០៧ |
| ២ | អាត្រាបម្រើសេវា០១ការិយាល័យ/ផ្ទៃដីគម² | ៣ ៣៥២ | ៣ ៣៥២ | ៣ ៣៥២ |
| ៣ | ចំនួនអាជ្ញាប័ណ្ណបញ្ញើធាប់រហ័សអន្តរជាតិ | ១៧ | ២៥ | ២៩ |

ប្រភព : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## វិស័យទូរគមនាគមន៍

៣.១៥៩- គិតត្រឹមឆ្នាំ២០១៦ ចំនួនទូរស័ព្ទសរុប គឺ២០ ១៤២ ៧៦៤ ក្នុងនោះទូរស័ព្ទអចល័តមានចំនួន២២៧ ២៦១ ឯទូរស័ព្ទចល័តមានចំនួន ១៩ ៩១៥ ៥០៣។ ក្នុងចំណោមប្រជាជន១០០នាក់ អត្រាអ្នកប្រើទូរស័ព្ទអចល័តមានចំនួន១,៤៥នាក់ និងទូរស័ព្ទចល័តមានចំនួន១២៧,៤៥នាក់ ក្នុងពេលដែលគុណភាពនៃបណ្តាញនិងសេវាទូរគមនាគមន៍ត្រូវបានពង្រឹងឥតឈប់ឈរ។ ទន្ទឹមគ្នានេះប្រភេទទូរស័ព្ទអចល័តមានការអភិវឌ្ឍ និងពង្រីកសេវាប្រើប្រាស់ ជាពិសេសនៅរាជធានីភ្នំពេញព្រមទាំងខេត្តមួយចំនួនដែលមានបណ្តាញខ្សែកាប្លិ៍អុបទិកឆ្លងកាត់។ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ បានបន្តសហការជាមួយអង្គការ JICA ដើម្បីស្ថាបនាហេដ្ឋារចនាសម្ព័ន្ធបណ្តាញទូរគមនាគមន៍ប្រវែង៤៨០គ.ម. នៅក្នុងខេត្តមួយចំនួន។

### តារាងទី៣.២២ : ទិន្នន័យស្តីពីការប្រើប្រាស់សេវាទូរគមនាគមន៍

| ល.រ | វាយមុខសញ្ញា | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|
| 1 | **ចំនួនទូរស័ព្ទសរុប** | **២០ ៨១៣ ០៣៨** | **២១ ០៩៤ ៦៥៣** | **២០ ១៤២ ៧៦៤** |
| | -ទូរស័ព្ទអចល័ត | ៣៦១ ០៥៦ | ២៦៥ ៣៨៧ | ២២៧ ២៦១ |
| | -ទូរស័ព្ទចល័ត | ២០ ៤៥១ ៩៨២ | ២០ ៨៥០ ៥៤៣ | ១៩ ៩១៥ ៥០៣ |
| 2 | **ចំនួនអ៊ិនធឺណិតសរុប** | **៥ ០២៥ ៩៤៥** | **៦ ៧៩៦ ០០៨** | **៨ ០៩៩ ១៣២** |
| | - អ៊ិនធឺណិតអចល័ត | ៦៨ ៤៩៦ | ៨៥ ៣៨៤ | ៩៨ ២៩៨ |
| | - អ៊ិនធឺណិតចល័ត | ៤ ៩៥៧ ៤៤៩ | ៦ ៧១០ ៦២៤ | ៨ ០០០ ៨៣៤ |

ប្រភព : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

### តារាងទី៣.២៣ : អត្រាអ្នកប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធឺណិត

| ល.រ | វាយមុខសញ្ញា | ឯកតា | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ១ | **អត្រាអ្នកប្រើប្រាស់ទូរស័ព្ទសរុប** | ក្នុង១០០នាក់ | **១៣៧,០៧** | **១៣៧,០១** | **១២៨,៩០** |
| | ទូរស័ព្ទអចល័ត | ក្នុង១០០នាក់ | ២,៣៨ | ១, ៦៦ | ១,៤៥ |
| | ទូរស័ព្ទចល័ត | ក្នុង១០០នាក់ | ១៣៤,៦៩ | ១៣៥,៣៥ | ១២៧,៤៥ |
| ២ | **អត្រាអ្នកប្រើប្រាស់អ៊ិនធឺណិតសរុប** | ក្នុង១០០នាក់ | **៣៣,១០** | **៤៤,១២** | **៥១,៨៣** |
| | អ៊ិនធឺណិតអចល័ត | ក្នុង១០០នាក់ | ០,៤៥ | ០,៥៥ | ០,៦៣ |
| | អ៊ិនធឺណិតចល័ត | ក្នុង១០០នាក់ | ៣២,៦៥ | ៤៣,៥៦ | ៥១,២០ |

ប្រភព : ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

## ប្រព័ន្ធផ្សព្វផ្សាយ

៣.១៦០- ប្រជាជនប្រមាណ៨៨%នៃប្រជាជនសរុបទូទាំងប្រទេសអាចទទួលបានព័ត៌មាន កម្មវិធីអប់រំ និងកម្មវិធីកំសាន្ត ជាដើម ដែលផ្សាយវិទ្យុនិងទូរទស្សន៍ និងបណ្តាញព័ត៌មានសង្គម។

**តារាងទី៣.២៤ : ការទទួលបានព័ត៌មានសាធារណៈ**

| សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|
| ១. ចំនួនអ្នកស្តាប់វិទ្យុ មើលទូរទស្សន៍ | % | ៨៥ | ៨៦ | ៨៧ | ៨៨ |
| ២. ទស្សនាវដ្តី ព្រឹត្តិប័ត្រ និង កាសែត | % | ៤២ | ៤៦ | ៥០ | ៥២ |

ប្រភព : ក្រសួងព័ត៌មាន

៣.១៦១- ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១៥ ដែលមានអគ្គលេខាធិការដ្ឋាននៅក្រសួងផែនការ។ លេខាធិការដ្ឋាននេះនឹងគាំទ្រដល់ការផ្លាស់ប្តូរទៅជាសេដ្ឋកិច្ចដែលមានលក្ខណៈពិពិធកម្មជាងមុនតាមរយៈការជំរុញនវានុវត្តន៍វិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅតាមក្រសួង ស្ថាប័ននិងក្នុងវិស័យឯកជន។ លេខាធិការដ្ឋានបានរៀបចំផែនការមេជាតិស្តីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា សម្រាប់ទម្រង់ទិសការងារនេះទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

**ការកសាងសមត្ថភាពក្នុងវិស័យប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន**

- បានបង្កើតវិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន នៅឆ្នាំ ២០១៤។
- និស្សិតចំនួន៣០០នាក់(ស្រី៧៦នាក់)កំពុងសិក្សាលើ៣មុខវិជ្ជាៈទូរគមនាគមន៍ វិទ្យាសាស្ត្រកុំព្យូទ័រ និងពាណិជ្ជកម្មអេឡិចត្រូនិក។
- បានបណ្តុះបណ្តាលមន្ត្រីរាជការលើជំនាញមូលដ្ឋានគ្រឹះកុំព្យូទ័រ និងទូរស័ព្ទឆ្លាតវៃចំនួន ១០០០នាក់ មកពីគ្រប់ក្រសួងស្ថាប័ន និងមន្ត្រីសាលាខេត្ត២៤ខេត្តក្រុង។
- បានរៀបចំពានរង្វាន់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន )ICT Award( ថ្នាក់ជាតិបានពីរលើក។

៣.១៦២- **បញ្ហាប្រឈម**

- ខ្វះខាតក្របខណ្ឌបច្ចេកទេស និងយន្តការបច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានរួម។
- ខ្វះខាតធនធានហិរញ្ញវត្ថុ និង សម្ភារៈបច្ចេកទេស និង អ្នកជំនាញ។
- គុណភាពនៃសូហ្វវែរកម្មវិធីនៅមានកម្រិតបង្កើតជាន់គ្នានិងមិនមានលក្ខណៈរួមបញ្ចូល។

- ការលើកកម្ពស់វិទ្យាសាស្ត្រនិងបច្ចេកវិទ្យានៅតែជាបញ្ហាប្រឈម ជាពិសេសការកៀរគរធនធានសម្រាប់អភិវឌ្ឍវិទ្យាសាស្ត្រនិងបច្ចេកវិទ្យារួមទាំងការសម្របសម្រួលអន្តរវិស័យ។

**សេចក្ដីសន្និដ្ឋាន**

៣.១៦៣- ការត្រួតពិនិត្យមើលសូចនាករស្នូលបង្ហាញថាមានវឌ្ឍនភាពល្អក្នុងការអភិវឌ្ឍផ្នែកសំខាន់នៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសការដឹកជញ្ជូន រួមមានផ្លូវថ្នល់និងស្ពាន ផ្លូវដែក និងផ្លូវអាកាស ហើយក៏បានបង្ហាញផងដែរថាត្រូវបង្កើនវឌ្ឍនភាពល្អនេះបន្ថែមទៀតដើម្បីត្រូវគ្នាជាមួយកំណើនតម្រូវការ។ ឧទាហរណ៍ ចំនួននៃការចុះបញ្ជីយានយន្តនិងចំនួនអ្នកដំណើរមានការកើនឡើង ដែលអាចបណ្ដាលឲ្យមានសម្ពាធដល់ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន។ នៅមានគម្លាតព័ត៌មានទាក់ទងនឹងនគរូបនីយកម្មនិងកំណើនតម្រូវការសម្រាប់ពង្រឹងហេដ្ឋារចនាសម្ព័ន្ធទីប្រជុំជន។ រាជរដ្ឋាភិបាលនឹងត្រូវយកចិត្តទុកដាក់បន្ថែមនៅពេលរៀបចំផ.យ.អ.ជ.២០១៩-២០២៣ ដោយត្រូវបន្ថែមសូចនាករតាមដានឲ្យបានច្រើន។ សូចនាករទាក់ទងនឹងការគ្រប់គ្រងធារាសាស្ត្រនិងធនធានបង្ហាញពីវឌ្ឍនភាពល្អ ក្នុងវិស័យនេះ ប៉ុន្តែមិនបានបង្ហាញពីទំនាក់ទំនងជាគុចេញទៅនឹងលទ្ធផលតាមគោលបំណងគោលនយោបាយ ដែលតម្រូវឲ្យមានការសម្របសម្រួលរវាងក្រសួង ស្ថាប័នពាក់ព័ន្ធដូចជាក្រសួងធនធានទឹកនិងឧតុនិយមនិងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ទាក់ទងនឹងការរៀបចំផែនការ ការអនុវត្ត និងការតាមដាន។ ការអភិវឌ្ឍបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មានមានវឌ្ឍនភាពល្អទាក់ទងនឹងការប្រើប្រាស់ទូរស័ព្ទនិងអ៊ិនធឺណិត។ ផែនការមេជាតិស្ដីពីវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាតម្រូវឲ្យមានការគាំទ្រហិរញ្ញវត្ថុនៅគ្រប់វិស័យពាក់ព័ន្ធទាំងអស់។ ដោយសារវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាជាផ្នែកមួយសំខាន់នៃគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដូចនេះត្រូវកែលម្អការសម្របសម្រួលអន្តរវិស័យសម្រាប់ការរៀបចំផែនការ ថវិកា ការអនុវត្ត និងការតាមដាន សម្រាប់ផ.យ.អ.ជ.២០១៩-២០២៣។

## ៦- ការអភិវឌ្ឍវិស័យឯកជននិងការងារ

៣.១៦៤- រាជរដ្ឋាភិបាកម្ពុជា បានកំណត់ថាវិស័យឯកជន គឺជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច។ វិស័យឯកជនមានតួនាទីគន្លឹះក្នុងការជំរុញកំណើន និងការអភិវឌ្ឍសង្គមកិច្ច សេដ្ឋកិច្ច ជាពិសេស ការធ្វើឲ្យសម្រេចនូវគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការធ្វើពិពិធកម្មមូលដ្ឋានផលិតកម្ម ការបញ្ចូលបច្ចេកវិទ្យាទំនើប និងគំនិតច្នៃប្រឌិតសំដៅបង្កើនប្រសិទ្ធភាព និងពង្រឹងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចជាតិ ព្រមទាំងការបង្កើតការងារ។

### ៦.១- ការពង្រឹងវិស័យឯកជននិងការជំរុញការវិនិយោគ និងធុរកិច្ច

៣.១៦៥- ចាប់ពីឆ្នាំ២០១៤ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមរបៀបវារៈកំណែទម្រង់ស៊ីជម្រៅ ដើម្បីកែលម្អបរិយាកាសធុរកិច្ចនិងវិនិយោគ ជាពិសេស ពន្លឿនការផ្តល់សេវាពាណិជ្ជកម្ម និងការចរចាបើកទីផ្សារថ្មីៗ បន្ថែមទៀតសម្រាប់ផលិតផលទំនិញរបស់កម្ពុជា។

៣.១៦៦- តាមរយៈកំណែទម្រង់ស៊ីជម្រៅនេះ សម្រេចបាននូវវឌ្ឍនភាពដូចខាងក្រោម៖

**ការងារកំណែទម្រង់ក្នុងវិស័យពាណិជ្ជកម្ម**

- បានបង្កើតឲ្យមានប្រព័ន្ធស្វ័យប្រវត្តិកម្ម ក្នុងការផ្តល់សេវាចេញវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ សេវាចុះបញ្ជីពាណិជ្ជកម្ម សេវាចុះបញ្ជីម៉ាក (សេវាស្វ័យប្រវត្តិកម្ម) ។ ក្រសួងពាណិជ្ជកម្ម បានយកចិត្តទុកដាក់ក្នុងការពង្រឹងពង្រីកធនធានមនុស្ស និងរចនាសម្ព័ន្ធការគ្រប់គ្រងហិរញ្ញវត្ថុ និងវិមជ្ឈការនិងវិសហមជ្ឈការ សេវានាំចេញ-នាំចូល និងសេវាពាក់ព័ន្ធនឹងការជំរុញពាណិជ្ជកម្ម ដើម្បីធានាបាននូវប្រសិទ្ធភាពការងារប្រសើរ និងរហ័សទាន់ចិត្តជូនសាធារណជន និងតម្រូវការចាំបាច់ ស្របតាមស្ថានភាពនៃការអភិវឌ្ឍក្នុងតំបន់ និងសកលលោក។

**ការងារសហប្រតិបត្តិការ សមាហរណកម្ម និងជំរុញពាណិជ្ជកម្ម**

- លើការងារអភិវឌ្ឍន៍ទីផ្សារ បានបើកមជ្ឈមណ្ឌលពាណិជ្ជកម្មកម្ពុជាចំនួន៥ទីតាំងនៅក្នុងប្រទេសចិន (ទីក្រុងប៉េកាំង សៀងហៃ ហាយនឹង ក្វាងចូវ និងនៅខេត្តស៊ីអាន)។ បានបញ្ចប់ការចរចាជាមួយភាគីវៀតណាមក្នុងការចុះអនុស្សរណៈយោគយល់រវាងក្រសួងពាណិជ្ជកម្មកម្ពុជា និងក្រសួងឧស្សាហកម្ម និង ពាណិជ្ជកម្មវៀតណាម ស្តីពីការកសាងផ្សារព្រំដែនកម្ពុជានៅស្រុកមេមត់ ខេត្តត្បូងឃ្មុំ និង កិច្ចសម្របសម្រួលពាណិជ្ជកម្មរវាងក្រសួងទាំងពីរ ក្នុងការផ្តល់ភាពអនុគ្រោះជូនគ្នាទៅវិញទៅមក។
- ក្រសួងពាណិជ្ជកម្មបានពង្រឹងដៃគូពាណិជ្ជកម្ម និងស្វែងរកទីផ្សារនៅក្រៅប្រទេសជាច្រើនលើក ដើម្បីទាក់ទាញវិនិយោគិនបរទេស និងការធ្វើពាណិជ្ជកម្មនៅកម្ពុជា។
- បានសហការជាមួយមជ្ឈមណ្ឌលអាស៊ាន-ជប៉ុន មជ្ឈមណ្ឌលអាស៊ានចិន មជ្ឈមណ្ឌលអាស៊ាន-កូរ៉េ មជ្ឈមណ្ឌលអាស៊ាននៅឥណ្ឌូនេស៊ី មជ្ឈមណ្ឌល អាស៊ាន-អាមេរិក អាស៊ាន-រុស្ស៊ី អាស៊ាន-ហុងកុង ដើម្បីពង្រឹងភាពជាដៃគូពាណិជ្ជកម្ម-វិនិយោគ និងការលើកកម្ពស់ផលិតផលកម្ពុជានៅក្នុងទីផ្សារបរទេស។
- បានលើកកម្ពស់ផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដើម្បីធ្វើឲ្យផលិតផលកម្ពុជាប្រើប្រាស់ជំនួសការនាំចូល និងឈានទៅការនាំចេញទៅលក់នៅលើកទីផ្សារបរទេស។
- បានធ្វើយុទ្ធនាការទិញផលិតផលខ្មែរ ក្នុងក្របខ័ណ្ឌទូទាំងប្រទេស ដោយបានរៀបចំនៅបណ្តាខេត្តទាំងអស់នៅកម្ពុជា និងចូលរួមពិព័រណ៍អន្តរជាតិ ក្នុងក្របខ័ណ្ឌទ្វេភាគី តំបន់ និងពិភពលោកជារៀងរាល់ឆ្នាំ។

- ចាប់ពីចុងឆ្នាំ២០១៥ អាស៊ានបានប្រែក្លាយជាសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) និងបានធ្វើឲ្យមានវឌ្ឍនភាពលើការធ្វើសេរីភាវូបនីកម្មពន្ធគយអាស៊ាន ការសម្រួលពាណិជ្ជកម្មតាមរយៈការចេញវិញ្ញាបនបត្រដោយអ្នកនាំចេញ (SC) ការចេញវិញ្ញាបនបត្រតាមប្រព័ន្ធអេឡិចត្រូនិក Form D និហិដ្ឋានព័ត៌មានពាណិជ្ជកម្មអាស៊ាន (ATR) ដំណោះស្រាយអាស៊ានសម្រាប់វិនិយោគ សេវាកម្ម និងពាណិជ្ជកម្ម (ASSIST), ច្រកចេញ-ចូលតែមួយអាស៊ាន (ASW) និងស្តង់ដារ និង ភាពអនុលោម និងសម្រេចបាននូវសេចក្តីប្រកាសស្តីពីអាស៊ានមួយ សេចក្តីប្រកាសទីក្រុងវៀងច័ន្ទស្តីពីការអនុម័តលើផែនការការងារគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន (IAI) សេចក្តីប្រកាសទីក្រុងវៀងច័ន្ទស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និង កំពុងចរចាបន្តលើការធ្វើសមាហរណកម្មទ្វេភាគី និងក្នុងតំបន់។ សម្រាប់ក្របខ័ណ្ឌភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយក្នុងតំបន់ (RCEP) ក្រសួងកំពុងចូលរួមចរចាយ៉ាងសកម្ម ដែលរំពឹងថា នៅដំណាច់ឆ្នាំ២០១៧នេះ RCEP នឹងអាចសម្រេចបានតាមផែនការរបស់ដៃគូទាំង១៦ប្រទេស។
- បាននិងកំពុងធ្វើកិច្ចសហការជាមួយបណ្តាប្រទេសនៅអឺរ៉ុប មជ្ឈឹមបូព៌ា អាហ្វ្រិក ទីម័រឡេសតេ និងបណ្តាប្រទេសនៅទ្វីបអាមេរិក ដើម្បីពង្រីកទីផ្សារផលិតផលកម្ពុជា។
- បាននិងកំពុងប្រមូល ឯកសារ របាយការណ៍ ព័ត៌មាន ទិន្នន័យ ច្បាប់ និងបទដ្ឋាននានាពីក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីរៀបចំសរសេររបាយការណ៍ត្រួតពិនិត្យឡើងវិញគោលនយោបាយពាណិជ្ជកម្មកម្ពុជាលើកទី២ ដែលនឹងត្រូវធ្វើរបាយការណ៍ជូនអង្គការពាណិជ្ជកម្មពិភពលោក នៅចុងឆ្នាំ២០១៧។
- អនុវត្តកម្មវិធីគាំទ្រការអភិវឌ្ឍពាណិជ្ជកម្ម (TDSP) ដែលរួមចំណែកក្នុងការកសាងគោលនយោបាយអភិវឌ្ឍន៍ និងកំណែទម្រង់ស៊ីជម្រៅក្នុងវិស័យពាណិជ្ជកម្ម ដោយផ្តោតទៅលើកំណែទម្រង់កិច្ចសម្រួលពាណិជ្ជកម្ម ធ្វើឲ្យមានកំណើនវិនិយោគទុនដោយផ្ទាល់ (FDI) និងការធ្វើឲ្យមានកំណើនប្រាក់ចំណូលពីការបង់ពន្ធគយ ។
- អនុវត្តកម្មវិធីពង្រឹងក្របខ័ណ្ឌសមាហរណកម្មជំហានទី១ (EIF Tier 1) និងគម្រោងពិពិធកម្ម និងពង្រីកការនាំចេញកម្ពុជាជំហានទី១ (CEDEP 1) ដែលធ្វើឲ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការគ្រប់គ្រងនិងអនុវត្តកម្មវិធីជំនួយសម្រាប់ពាណិជ្ជកម្ម រៀបចំយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (DTIS) បញ្ជ្រាបវិស័យពាណិជ្ជកម្ម រៀបចំគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រពាណិជ្ជកម្មនានា ពង្រឹងការទទួលស្គាល់គុណភាពផលិតកម្មក្នុងវិស័យស្រូវអង្ករ លើកកម្ពស់ការចូលរួមរបស់ស្ត្រីក្នុងវិស័យពាណិជ្ជកម្ម និងបានជំរុញផលិតផលសូត្រនិងបង្កើតការងារក្នុងវិស័យនេះ ។

- បានដំណើរការត្រួតពិនិត្យទំនិញនាំចេញ-នាំចូលនៅតាមគ្រប់ច្រកទ្វារព្រំដែន និងឃ្លាំងពិនិត្យទីផ្សារក្នុងស្រុក ដើម្បីទប់ស្កាត់ការនាំចូល-នាំចេញ និងការចរាចរទំនិញពុំសមស្របតាមបញ្ញត្តិបច្ចេកទេស។
- បានសហការក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី លើការងារពង្រឹងគុណភាព និងសុវត្ថិភាពផលិតផល និង គោលនយោបាយពាណិជ្ជកម្ម ក្នុងទិសដៅបម្រើអ្នកប្រើប្រាស់ និងការពារកេរ្តិ៍ឈ្មោះផលិតផលកម្ពុជានៅលើទីផ្សារអន្តរជាតិ។
- បានការអនុម័តពីរាជរដ្ឋាភិបាលលើអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការត្រួតពិនិត្យផលិតផលហាឡាលកម្ពុជា និង បានរៀបចំគោលនយោបាយអភិវឌ្ឍន៍ផលិតផលម្រេច នយោបាយអភិវឌ្ឍន៍កសិ-ពាណិជ្ជកម្មកម្ពុជា និង ចូលរួមរៀបចំគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មកម្ពុជា២០១៥-២០២៥ និង ការអភិវឌ្ឍបរិយាកាសធុរកិច្ចនិងវិនិយោគ។
- បានខិតខំពង្រីកនិងថែរក្សាស្តុកយុទ្ធសាស្ត្រស្បៀងត្រៀមបម្រុង សម្រាប់ចូលរួមអន្តរាគមន៍សង្គ្រោះដល់ជនរងគ្រោះ និង ស្វែងរកទីផ្សារអង្ករ។
- បានសម្រួលពាណិជ្ជកម្មលើកសិផលកម្ពុជា ដើម្បីឲ្យការនាំចេញមានភាពរលូន រហ័សជាមួយនឹងការបន្ថយសោហ៊ុយនាំចេញ។

## តារាងទី៣.២៥ : សូចនាករសំខាន់ៗក្នុងវិស័យពាណិជ្ជកម្ម

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ |
|---|---|---|---|---|---|---|
| ១ | តម្លៃនៃការនាំចូល | ពាន់លានរៀល | ៣៧១៧២ | ៧៦ ៨១៨ | ៤៣ ៣១៦ | ៥០ ១៧៥ |
| | | លានដុល្លារ | ៩ ២៣១ | ១៩ ០២៤ | ១០ ៦៦៩ | ១២ ៣៧១ |
| ២ | តម្លៃនៃការនាំចេញ | ពាន់លានរៀល | ៣៧ ២៤៣ | ៤៣ ១៤០ | ៣៤ ៦៨២ | ៤០ ៨៥៥ |
| ៣ | តម្លៃនៃការនាំចេញ | លានដុល្លារ | ៩ ២៤៨ | ១០ ៦៨៣ | ៨ ៥៤២ | ១០ ០៧៣ |
| ៤ | សម្លៀកបំពាក់ | ពាន់លានរៀល | ១៩ ៧២០ | ២១ ៥៧៦ | ២៣ ១៤៧ | ២៦ ៨៧៩ |
| ៥ | សម្លៀកបំពាក់ | លានដុល្លារ | ៤ ៨៩៧ | ៥ ៣៤៣ | ៥ ៧០១ | ៦ ៦២៧ |
| **៦** | **ចំនួនក្រុមហ៊ុនចុះបញ្ជីពាណិជ្ជកម្ម** | **ចំនួន** | ៣ ៩១៦ | ៥ ២៤៥ | ៦ ៤១៧ | ៤ ៥៧៥ |
| | - ក្រុមហ៊ុន | | ២ ៩៦២ | ៣ ៧៨៤ | ៤ ៣៧០ | ៣ ២២៤ |
| | - ក្រុមហ៊ុនឯកបុគ្គល | | ៦២៤ | ៨៧១ | ១ ៤២៤ | ៨៦៦ |

| | | | | | | |
|---|---|---|---|---|---|---|
| | - សាខាក្នុងស្រុក | | ២៥៧ | ៥៣៤ | ៥៥០ | ៤០៩ |
| | - សាខាក្រៅស្រុក | | ៤៣ | ៣៧ | ៤៧ | ៤៦ |
| | - ការិយាល័យតំណាងក្រុមហ៊ុនបរទេស | | ៣០ | ១៨ | ២៦ | ៣០ |
| ៧ | ចំនួនចុះបញ្ជីម៉ាក | ចំនួន | ៥ ១៣៨ | ៤ ២៨០ | ៥ ៣៧០ | ៤ ៦៨១ |
| ៨ | ចំនួនរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | ចំនួន | ៩២០ | ១ ០៧៧ | ១ ១៨២ | ១ ៣២២ |
| ៩ | ចំនួនកម្មករ (ប្រុស និងស្រី) បំពេញការងារក្នុងរោងចក្រចុះបញ្ជីនាំចេញតាមប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម | នាក់ | ៦៦៦៣៥៧ | ៧៩៣ ៧៤៥ | ៨៧១ ៦៦៨ | ៩៨២ ៥៧០ |
| ១០ | ប្រាក់បៀវត្សសរុប | លានដុល្លារ | ៩១៦ | ១ ១៩២ | ១ ៤១២ | ១ ៦៧០ |

ប្រភព : ក្រសួងពាណិជ្ជកម្ម

**៣.១៦៧-** ចំនួនមកដល់របស់ភ្ញៀវទេសចរបានកើនឡើងពី៣,៦លាននាក់ក្នុងឆ្នាំ២០១២ មក ៤,៨លាននាក់ក្នុងឆ្នាំ២០១៥ ទោះបីមានកំណើនបែបនេះ ប៉ុន្តែនៅតែទាបជាងចំណុចដៅ (៥,១៩លាននាក់) ក្នុងផ.យ.អ.ជ. ២០១៤-២០១៨។ អត្រាកំណើនមកដល់របស់ភ្ញៀវទេសចរអន្តរជាតិមានធ្លាក់ចុះ៥%នៅឆ្នាំ២០១៦ ធៀបឆ្នាំ២០១៥ (៦,១%)។ ដើម្បីជំរុញឧស្សាហកម្មទេសចរណ៍ ក្រសួងទេសចរណ៍បានដាក់ចេញគោលនយោបាយ China Readdy ដែលមានគោលបំណងទាក់ទាញភ្ញៀវទេសចរចិនប្រមាណ២លាននាក់ត្រឹមឆ្នាំ២០២០។ លើសពីនេះទៀត ទិដ្ឋាការសម្រាប់ភ្ញៀវទេសចរនិងធុរកិច្ច ដែលអាចចេញចូលច្រើនដងនិងមានរយៈពេល៣ឆ្នាំនឹងដាក់ឲ្យអនុវត្តក្នុងពេលឆាប់ៗនេះ ដើម្បីជំរុញទេចរណ៍។

**៣.១៦៨-** *ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ* ដែលសម្រេចបានការងារតាមផែនការយុទ្ធសាស្ត្រទាំង ៥ ដូចមានចែងក្នុង ផ.យ.អ.ជ. ២០១៤-២០១៨ មានដូចខាងក្រោម៖

- បានបន្តលើកកម្ពស់ការរៀបចំព្រឹត្តិការណ៍វប្បធម៌ប្រចាំឆ្នាំមានដូចជា មហោស្រពខ្លែងខ្មែរ ម្ហូបអាហារខ្មែរ និងសម្លៀកបំពាក់ខ្មែរ មហោស្រពសិល្បៈសូនរូប និងសិប្បកម្ម មហោស្រពកំណាព្យ និងចម្រៀងខ្មែរជាសកល មហោស្រពសិល្បៈយុវជនទូទាំងប្រទេស និងទិវាវប្បធម៌ជាតិ ៣មីនា ជាដើម និងមានការទៅចូលរួមសម្តែងសិល្បៈនានានៅក្រៅប្រទេស និងការអនុញ្ញាតឲ្យខ្ចីបុរាណវត្ថុខ្មែរទៅតាំងនៅបរទេសដើម្បីផ្សព្វផ្សាយពីវប្បធម៌ជាតិ។

- បានបង្កើនការគាំទ្រ និងលើកទឹកចិត្តដល់ការច្នៃប្រឌិតបង្កើតថ្មីលើគ្រប់ផ្នែកក្នុងវិស័យវប្បធម៌ ដែលជាផ្នែកមួយជួយឲ្យមានការទទួលស្គាល់នូវឧស្សាហកម្មច្នៃប្រឌិត ដូចជារៀបចំរបាំសហសម័យមានចំណងជើងថា "គ្រុឌ" និងរបាំបុរាណទំនើបកម្មមួយមានចំណងជើង ថា "ព្រះនាងរាជទេវី"។ល។
- បានរៀបចំវេទិកាសិល្បៈនិងសិក្ខាសាលា ដោយមានការចូលរួមសហការពីក្រសួងស្ថាប័ន អង្គការ សមាគម និងដៃគូអភិវឌ្ឍនានាដើម្បីជួយពង្រឹកកិច្ចអភិរក្សនិងអភិវឌ្ឍវិស័យវប្បធម៌ ដូចជាវេទិកាសិល្បៈស្តីពី "ការជំរុញឧស្សាហកម្មច្នៃប្រឌិតនៅកម្ពុជា" សិក្ខាសាលាផ្តោតលើការពង្រឹងសមត្ថភាពក្នុងការចុះបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៅតាមសហគមន៍ "យុវជន និងការអភិវឌ្ឍវប្បធម៌ (ការអភិរក្ស ទំនើបកម្ម និងការបង្កើតថ្មី)" និងសិក្ខាសាលាទាក់ទងនឹងសិទ្ធិអ្នកនិពន្ធ និងសិទ្ធិប្រហាក់ប្រហែល។
- បានចុះ "ចាប៉ីដងវែង" ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនិងបានរួមគ្នាជាមួយប្រទេសកូរ៉េខាងត្បូង ហ្វីលីពីន និងវៀតណាមចុះ "ល្បែង និងពិធីនៃប្រពៃណីទាញព្រ័ត្រ" ជាពហុជាតិសាសន៍ក្នុងបញ្ជីបេតិកភណ្ឌវប្បធម៌អរូបីនៃមនុស្សជាតិនៃអង្គការ UNESCO ។
- បានលើកកម្ពស់ការទាក់ទាញក្រុមហ៊ុនថតភាពយន្តបរទេស ឲ្យមកថតភាពយន្តនៅកម្ពុជាតាមរយៈកិច្ចសហប្រតិបត្តិការជាមួយភាគីអន្តរជាតិមានបារាំងនិងអាមេរិកជាដើម។
- បានរៀបចំចងក្រងនិងទទួលបានការឯកភាពជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា លើ "**គោលនយោបាយជាតិស្តីពីវិស័យវប្បធម៌**" ។
- បានអប់រំបណ្តុះបណ្តាលស្តីពីក្បួនខ្នាតក្បាច់ចម្លាក់ខ្មែរ ដល់បណ្តាសិប្បករ អាជីវករ ដែលប្រកបអាជីវកម្មលើផលិតផលសិល្បៈសូនរូបនិងសិល្បៈសិប្បកម្ម ដោយឈរលើគោលការណ៍អប់រំដើម្បីវប្បធម៌ វប្បធម៌ដើម្បីអប់រំ។
- បានបណ្តុះបណ្តាលនិស្សិតថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ដោយមានការសហការជាមួយវិទ្យាស្ថាន INALCO របស់ប្រទេសបារាំង។
- បានជួសជុលប្រាសាទ និងសំណង់ចាស់បុរាណនានាដែលកំពុងស្ថិតនៅក្នុងស្ថានភាពហានិភ័យដូចជាប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយទ័ព ប្រាសាទភ្នំជីសូរ្យ ប្រាសាទបាណន់ ប្រាសាទឯកភ្នំស្ពានទ័ព និងវត្តមហាលាភ។ល។
- បានសហការជាមួយបណ្តាប្រទេសជាមិត្តនានាជាអាទិ៍មានបារាំង អាមេរិក និងថៃដើម្បីទាមទារនិងស្នើសុំយកបុរាណវត្ថុដែលបាននាំចេញពីកម្ពុជាដោយខុសច្បាប់។
- បន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍនានា ដើម្បីស្វែងរកមូលនិធិទ្រទ្រង់ដល់ការការពារ ជួសជុលនូវវត្ថុបុរាណនិងស្ថានីយបុរាណ។

- បន្តកិច្ចសហប្រតិបត្តិការស្រាវជ្រាវ តាមបែបបុរាណវិទ្យា ជាតិពិន្ទុវិទ្យា និងប្រវត្តិសាស្ត្រ ជាមួយស្ថាប័នអន្តរជាតិនានាដើម្បីស្វែងយល់អំពីតម្លៃមរតកបុរាណរបស់ជាតិ និង ផ្សព្វផ្សាយអំពីតម្លៃទាំងនោះឲ្យបានទូលំទូលាយ។

**បញ្ហាប្រឈម**

៣.១៦៩- **ការប្រកួតប្រជែងក្នុងតំបន់និងសកលៈ** បរិយាកាសសម្រាប់ពាណិជ្ជកម្មក្នុងតំបន់និងសកលកាន់តែមានភាពប្រកួតប្រជែងច្រើន ដូចនេះរាជរដ្ឋាភិបាលនឹងត្រូវពង្រឹងការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និងពង្រឹងជំនាញរបស់កម្លាំងពលករ សម្រាប់ជំរុញវិស័យកាត់ដេរ និងវិស័យផ្សេងៗទៀត ដើម្បីលើកកម្ពស់ផលិតភាព និងបង្កើនកម្រិតជំនាញ។ ការសម្របសម្រួលពាណិជ្ជកម្ម ចំណាយតិចក្នុងការធ្វើធុរកិច្ច និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធទាំងផ្នែកទន់និងរឹង ក៏អាចជួយពង្រឹងភាពប្រកួតប្រជែងរបស់កម្ពុជាទាំងមូល។

៣.១៧០- វិស័យទេសចរណ៍ ក៏ជួបប្រទះបញ្ហាប្រឈមជាច្រើនដែរ ដូចជាមានទិសដៅទេសចរណ៍ច្រើនក្នុងតំបន់ (ឧទាហរណ៍ ភូមា)។ បន្ទាប់ពីវិធានការទាក់ទងនឹងទិដ្ឋាការ កម្ពុជានឹងបន្តពិចារណាពីវិធីសាស្ត្រផ្សេងៗទៀត ដើម្បីជំរុញកំណើនវិស័យទេសចរណ៍ រួមទាំងវិធានការគោលនយោបាយ សម្រាប់កែលម្អហេដ្ឋារចនាសម្ព័ន្ធនិងសេវាគាំទ្រទាក់ទងនឹងទេសចរណ៍។ **បេតិកភណ្ឌវប្បធម៌និងការអភិរក្សបរិស្ថានៈ** ឧស្សាហកម្មទេសចរណ៍ជាច្រើនរបស់កម្ពុជាត្រូវបានធ្វើប្រតិបត្តិការនៅជុំវិញតំបន់បេតិកភណ្ឌពិភពលោករបស់ខ្លួន (ឧទាហរណ៍ តំបន់អង្គរ) និងបរិស្ថានធម្មជាតិ។ ភាពលំបាកក្នុងការរក្សាតុល្យភាពរវាងបេតិកភណ្ឌវប្បធម៌ ការអភិរក្សបរិស្ថាន និងការអភិវឌ្ឍសេដ្ឋកិច្ច។

៣.១៧១- លំហូរវិនិយោគផ្ទាល់បរទេសៈ វិនិយោគផ្ទាល់បរទេសនៅមានចំនួនច្រើននៅឡើយ ប៉ុន្តែអាចនឹងធ្លាក់ចុះជាយថាហេតុ។ បន្ទាប់ពីរក្សាកំណើន៧,៦%ក្នុងឆ្នាំ២០១៤-២០១៥ សន្ទស្សន៍វិនិយោគផ្ទាល់បរទេសអាចធ្លាក់មកត្រឹម៧,១% ក្នុងឆ្នាំ២០១៦ និង៦,៩%ក្នុងឆ្នាំ២០១៧។ វិនិយោគផ្ទាល់បរទេសពឹងផ្អែកច្រើនលើវិនិយោគផ្ទាល់បរទេសរបស់ចិន ដែលមានប្រមាណ១ភាគ៣នៃចំនួនសរុប។ ការកែសម្រួលសេដ្ឋកិច្ចរបស់ចិនអាចធ្វើឲ្យអ្នកវិនិយោគដកការវិនិយោគបរទេសចេញ ប៉ុន្តែដោយសារកំណើនសេដ្ឋកិច្ចក្នុងប្រទេសចិនភាគច្រើនពឹងផ្អែកលើវិនិយោគក្នុងស្រុក ដូចនេះនៅតែអាចមានកំណើនវិនិយោគផ្ទាល់បរទេសរបស់ចិនមកប្រទេសតូចៗ ដូចជាកម្ពុជាជាដើម។

## ៦.២- ការអភិវឌ្ឍឧស្សាហកម្ម និងសហគ្រាសធុនតូចនិងមធ្យម

៣.១៧២- គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ផ្ដល់នូវក្របខ័ណ្ឌសម្រាប់ពង្រឹងភាពប្រកួតប្រជែងខាងក្រៅរបស់កម្ពុជា ដោយផ្ដោតលើការកែលម្អបរិយាកាសអំណោយផលចំពោះធុរកិច្ច ការសម្របសម្រួលពាណិជ្ជកម្ម និងការលើកកម្ពស់កម្លាំងពលកម្មដែលមានផលិតភាពខ្ពស់។ គោលនយោបាយនេះក៏បានកំណត់ពីការអភិវឌ្ឍធុរកិច្ចលើវិស័យកសិកម្មជាសមាភាគសំខាន់នៃការអភិវឌ្ឍវិស័យឯកជន។

៣.១៧៣- *ក្រសួងឧស្សាហកម្មនិងសិប្បកម្ម* សម្រេចបានសមិទ្ធផល ដូចខាងក្រោម៖

***ផ្នែកឧស្សាហកម្ម***

- រោងចក្រសរុបមានចំនួន ១ ៥៧៩ រោងចក្រ រួមមានផ្នែកអាហារ ភេសជ្ជៈ បារី ផ្នែកឧស្សាហកម្មតម្បាញ និងកាត់ដេរសម្លៀកបំពាក់ សរុបកំលាំងពលកម្មចំនួន ៩២១ ៨៥៨ នាក់ ក្នុងនោះ ផ្នែកកាត់ដេរ និងស្បែកជើង មាន ៧៩៨ ៨១៥នាក់។
- បានបន្តអនុវត្ត បង្កើតស្តង់ដារជាតិ និងស្តង់ដារតែមួយអាស៊ាន។
- បានសម្របសម្រួលការងារផ្ទេរបច្ចេកវិទ្យារវាងចិន និងគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការ អាស៊ាន ផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា។
- បានលើកកម្ពស់សុក្រឹត្យភាពនៃប្រព័ន្ធមាត្រាសាស្ត្រជាតិ ការពារដល់អ្នកផ្គត់ផ្គង់ និងអ្នកប្រើប្រាស់
- បានរៀបចំធ្វើប្រតិភូកម្មអំណាចជូនដល់គណៈអភិបាលរាជធានីខេត្ត នូវមុខងារមួយចំនួន។
- បានរៀបចំឲ្យមានយន្តការធ្វើអធិការកិច្ចតាមបណ្ដារោងចក្រដោយក្រុមអធិការកិច្ចចម្រុះរបស់ក្រសួងតែមួយក្នុងការពង្រឹងការអនុវត្តច្បាប់ស្ដីពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម និង បទដ្ឋានគតិយុត្តពាក់ព័ន្ធនានា។
- បានរៀបចំឲ្យមានការប្រកួតប្រជែងយកពានរង្វាន់«ស៥» ប្រចាំឆ្នាំដើម្បីលើកកម្ពស់ផលិតភាពរបស់ក្រុមហ៊ុន សហគ្រាស រោងចក្រ និង សិប្បកម្ម។
- បានជម្រុញឲ្យមានការលើកកម្ពស់ការ ការពារកម្មសិទ្ធិឧស្សាហកម្ម តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការទ្វេភាគី ជាមួយអង្គភាពវិញ្ញាបនបត្រតក្កកម្មអ៊ឺរ៉ុប(EPO) អង្គភាពវិញ្ញាបនបត្រតក្កកម្មជប៉ុន (JEPO) និង អង្គភាពកម្មសិទ្ធិបញ្ញាសឹង្ហបូរី (IPOS)បន្ថែមទៀតក្រៅពីយន្តការកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន និងអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO) ព្រមទាំងកំពុងដាក់ឲ្យដំណើរការ ការចុះបញ្ជីតាមប្រព័ន្ធទំនើបកម្មសិទ្ធឧស្សាហកម្ម (Industrial Property Automation System-IPAS)។
- បានដំណើរការក្រុមប្រឹក្សាជាតិវាយតម្លៃទទួលស្គាល់ជាតិ Cambodia Accreditation National Council (CANC) ចាប់តាំងពីដំណើរការក្រុមប្រឹក្សានេះមក ក្នុងឆ្នាំ២០១៤ បានធ្វើការវាយតម្លៃ

ទទួលស្គាល់ដល់មន្ទីរពិសោធន៍ តាមស្តង់ដារអន្តរជាតិ ISO/IEC 17025 ដល់ក្រុមហ៊ុនឯកជនចំនួន០២ និងស្ថាប័នរដ្ឋចំនួន០១។

***ផ្នែកសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម***

- បានផ្តល់ជំនួយបច្ចេកទេសនិងសម្របសម្រួលសកម្មភាពទទួលបានហិរញ្ញវត្ថុដល់សហគ្រាសធុនតូច និងមធ្យម ផលិតនិងកែឆ្នៃម្ហូបអាហារចំនួន១៣ ដើម្បីធ្វើការផ្លាស់ប្តូរបច្ចេកវិទ្យាថ្មី។
- បានបញ្ចប់សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធុនតូច និងមធ្យម កម្ពុជាបានបញ្ចប់សេចក្តីព្រាងគោលនយោបាយលើកទឹកចិត្ត សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ចែកចេញ ជាបីផ្នែក៖ ផ្នែកបច្ចេកទេស ផ្នែកហិរញ្ញវត្ថុ និងផ្នែកទីផ្សារ។
- បានបណ្តុះបណ្តាលធនធានមនុស្សលើជំនាញផ្នែកទន់ និងផ្នែករឹង ដល់ម្ចាស់ បុគ្គលិក កម្មករ និងមន្ត្រីជំនាញពាក់ព័ន្ធ សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម តាមរយៈវគ្គខ្លីៗ នៅនឹងកន្លែងក្នុង និង ក្រៅប្រទេសសរុប ១៨វគ្គ ស្មើនឹង ៩០០សិក្ខាកាម។
- ការសាកល្បងបង្កើតសួនអេកូ សហគ្រាសធុនតូច និងមធ្យម នៅខេត្តកណ្តាល និងពីរកន្លែងទៀតនៅខេត្ត កំពង់ចាម និងកំពង់ឆ្នាំង ក្រោមប្រធានបទ«ខេត្តមួយសួន សហគ្រាសធុនតូច និងមធ្យម និងសិប្បកម្មមួយ» តាមរយៈកិច្ចសហប្រតិបត្តិការមេគង្គ-ឡាងឆាង។
- បានរៀបចំអនុក្រឹត្យស្តីពីយន្តការសម្របសម្រួលការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសេវាកម្មនានា ក្រោមដំបូលតែមួយសម្រួលដល់ការចុះបញ្ជីសហគ្រាសធុនតូច និងមធ្យម និងសិប្បកម្ម ឲ្យកាន់តែមានភាពងាយស្រួល និងសាមញ្ញ តាមរយៈការចុះបញ្ជីតាម Online Registration)។
- បានរៀបចំបញ្ជីវិភាគមុខងាររួចហើយសម្រាប់ការធ្វើប្រតិភូកម្មអំណាចក្នុងការចុះបញ្ជីសហគ្រាស សិប្បកម្មដែលមានដើមទុនក្រោម៥ម៉ឺនដុល្លារអាមេរិក និង គ្មានហានីភ័យជូនរដ្ឋបាលថ្នាក់ ខេត្ត ក្រុងស្រុកខ័ណ្ឌ និងឃុំ-សង្កាត់ រង់ចាំការសម្រេចដោយថ្នាក់ដឹកនាំក្រសួង។
- បានចងក្រងទិន្នន័យមូលដ្ឋានផលិតកម្មរវាងសហគ្រាសធុនតូច និងមធ្យម និងសហគ្រាសធុនធំ។

**៣.១៧៤- បញ្ហាប្រឈម**

- ការត្រួតពិនិត្យនិងរៀបចំឡើងវិញនូវគម្រោងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុដែលផ្តល់ការលើកទឹកចិត្តដល់ការវិនិយោគនៅតាមវិស័យនានាដែលមានចែងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

- ការយល់ដឹងអំពីនីតិវិធីនិងបែបបទស្នើសុំបង្កើតនិងវិញ្ញាបនបត្រដំណើរការរោងចក្រ សិប្បកម្ម នៅមានកម្រិត
- កង្វះធនធានមនុស្ស ហិរញ្ញវត្ថុ និងបរិក្ខារក្នុងដំណើរការចុះបញ្ជីសហគ្រាស។

## ៦.៣- ការអភិវឌ្ឍទីផ្សារការងារ

៣.១៧៥- *គោលនយោបាយជាតិមុខរបរ ឆ្នាំ២០១៥-២០២៥* ផ្តោតលើបញ្ហានានាទាក់ទងនឹងភាពអត់ការងារធ្វើ តាមរយៈស្វែងរកនិងផ្តល់ឱកាសការងារសមរម្យ បង្កើនផលិតភាពពលកម្ម អភិវឌ្ឍជំនាញនិងធនធានមនុស្ស ព្រមទាំងពង្រឹងអភិបាលកិច្ចទីផ្សារពលកម្ម ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច។ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈមានយុទ្ធសាស្ត្រសំខាន់ៗចំនួន៥ គឺ(១) ការអភិវឌ្ឍនិងលើកកម្ពស់លក្ខខណ្ឌការងារ (២) ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ(៣) ការអភិវឌ្ឍមុខរបនិងការងារ (៤) ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្តីពីការងារ និង(៥) ការពង្រឹងអភិបាលកិច្ចល្អ។។

### លក្ខខណ្ឌការងារនិងទំនាក់ទំនងឧស្សាហកម្ម

៣.១៧៦- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ បន្តយកចិត្តទុកដាក់លើការដោះស្រាយវិវាទ រួមទាំងការងារសម្របសម្រួលរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល ព្រមទាំងការទប់ស្កាត់កូដកម្មនិងបាតុកម្មខុសច្បាប់។ ក្រសួងបានបង្កើនសកម្មភាពអធិការកិច្ច ដើម្បីលើកកម្ពស់សិទ្ធិនិងផលប្រយោជន៍របស់កម្មករ/និយោជិក រួមទាំងកិច្ចសហប្រតិបត្តិការជាមួយ*កម្មវិធីរោងចក្រប្រសើរជាងមុន* របស់អង្គការពលកម្មអន្តរជាតិ។ ក្រសួងបន្តកិច្ចប្រឹងប្រែងកាត់បន្ថយនិងទប់ស្កាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅក្នុងរោងចក្រកាត់ដេរសម្លៀកបំពាក់និងស្បែកជើងនិងកសិឧស្សាហកម្ម។ ក្នុងឆ្នាំ២០១៤ ប្រាក់ឈ្នួលអប្បបរមាបានកើនឡើងពី៨០ដុល្លារអាមេរិកទៅ១០០ដុល្លារអាមេរិកក្នុង១ខែ ហើយកើនពី១០០ដុល្លារអាមេរិកទៅ១២៨ដុល្លារអាមេរិកក្នុង១ខែក្នុងឆ្នាំ ២០១៥ និងបានកើនឡើងពី១២៨ដុល្លារអាមេរិកទៅ១៤០ដុល្លារអាមេរិកក្នុង១ខែក្នុងឆ្នាំ២០១៦ ។

### ការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ

៣.១៧៧- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានចុះបញ្ជីគ្រឹះស្ថានក្រោមឱវាទក្រសួងសរុប ចំនួន១០៦ ក្នុងនោះ គ្រឹះស្ថានសាធារណៈចំនួន៣៩ ធៀបនឹងឆ្នាំ២០១៤ ដែលមានចំនួន៩១។ ក្រសួងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីជំនាញឧស្សាហកម្ម បច្ចេកទេស សិប្បកម្ម សេវាកម្ម ទេសចរណ៍ និងកសិកម្ម ដោយមានសិក្ខាកាមចូលរៀនចំនួន៤៣ ១៩៥នាក់។ ក្រសួងបាន និងកំពុងរៀបចំគោលនយោបាយជាតិស្តីពីការបណ្តុះបណ្តាលនិងអប់រំវិជ្ជាជីវៈនិងបច្ចេកទេស។

### ការអភិវឌ្ឍមុខរបរនិងការងារ

៣.១៧៨- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈបានផ្ដល់សេវាការងារនិងមុខរបរដល់ប្រជាជនចំនួន៩៩ ៧០៨នាក់ ក្នុងនោះស្រី៦៦ ៥០៨នាក់។ បច្ចុប្បន្ន កម្ពុជាមានពលករចំនួន៦១៩ ៣៥៩នាក់ កំពុងធ្វើការនៅក្រៅប្រទេសគឺថៃ(៥៣៣ ៧០៧នាក់) ម៉ាឡេស៊ី(៣៨ ៦៣៣នាក់) កូរ៉េខាងត្បូង(៤៤ ៣៣០នាក់) ជប៉ុន(២ ២៨៨នាក់) និងសឹង្ហបូរី(៤០១នាក់)។ ក្រសួងបានចងក្រងនិងផ្សព្វផ្សាយព័ត៌មានការងារទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។ ក្នុងឆ្នាំ២០១៥ ក្រសួងបានផ្ដល់ប័ណ្ណនិងសៀវភៅការងារដល់កម្មករចំនួន២០០ ៩៧៤នាក់ កើនឡើង២១% ធៀបនឹងឆ្នាំ២០១៤ និងផ្ដល់សេវាដូចគ្នាដល់កម្មករបរទេសចំនួន៣៥ ៩១២នាក់ កើនឡើង១១២% ធៀបនឹងឆ្នាំ២០១៤។

### ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទបញ្ញត្តិនៃច្បាប់ស្ដីពីការងារ

៣.១៧៩- បច្ចុប្បន្ន កម្មករនិងនិយោជិតដែលស្ថិតក្រោមច្បាប់ការងារនឹងទទួលបានគម្រោងគ្រោះថ្នាក់ការងារ ដែលផ្ដល់ការធានារ៉ាប់រងដល់ពលករនិងនិយោជិតដែលរងគ្រោះថ្នាក់និងជំងឺក្នុងរយៈពេលបំពេញការងារ។ គិតត្រឹមចុងឆ្នាំ២០១៥ បេឡាជាតិរបបសន្តិសុខសង្គមបានពង្រីកវិសាលភាពនៅទូទាំង២៥រាជធានី ខេត្ត ដោយមានសហគ្រាស គ្រឹះស្ថានចុះបញ្ជីកាចំនួន ៧ ៧៩៦ និងមានកម្មករនិយោជិតចំនួន ១ ០៧៧ ០៧៩ នាក់។ អនុក្រឹត្យលេខ០១ ចុះខែមករា ឆ្នាំ២០១៦ បង្កើតគម្រោងធានារ៉ាប់រងសុខភាព ដែលបំពេញបន្ថែមលើគម្រោងគ្រោះការងារ។ គម្រោងនេះផ្ដល់ដល់កម្មករនិងនិយោជិតនូវការថែទាំនិងព្យាបាលសុខភាព ផលប្រយោជន៍ពេលលំហែរមាតុភាព និងប្រាក់ឈ្នួលប្រចាំថ្ងៃនៅពេលអវត្តមានពីការងារដោយសារជំងឺ។

### ពង្រឹងអភិបាលកិច្ចល្អ

៣.១៨០- ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កំពុងអនុវត្តកម្មវិធីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងថវិកាកម្មវិធី ដែលបន្ស៊ីថវិកាក្រសួងទៅនឹងអាទិភាពគោលនយោបាយទាំង៥របស់ខ្លួនខាងលើ។ កម្ពុជាគឺជាសមាជិកនៃក្រុមប្រឹក្សាពលកម្មអន្តរជាតិ ពីឆ្នាំ២០១៤ដល់ឆ្នាំ២០១៧។

### បញ្ហាប្រឈម

### ការបណ្ដុះបណ្ដាលវិជ្ជាជីវៈនិងបច្ចេកទេស

៣.១៨១- គោលនយោបាយជាតិស្ដីពីការអប់រំនិងការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ គឺជាដំណាក់កាលចាប់ផ្ដើមដំបូង ដែលក្រសួងអាចបំពេញបន្ថែមតាមរយៈផែនការសកម្មភាពយុទ្ធសាស្ត្រដែលកំណត់ពីគោលបំណង អាទិភាព និងហិរញ្ញប្បទាន។ ភាពប្រឈមសំខាន់គឺការកំណត់តួនាទីឲ្យបានច្បាស់លាស់របស់រាជរដ្ឋាភិបាលនិងវិស័យឯកជនទាក់ទងនឹងការបណ្ដុះប

ណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ។ រាជរដ្ឋាភិបាលត្រូវធានាថាស្ត្រីនិងជនពិការទទួលបានការបណ្ដុះបណ្ដាលបច្ចេកទេសនិងវិជ្ជាជីវៈ សេវាការងារនិងមុខរបរ និងប្រាក់ឈ្នួលស្មើគ្នា។

**ធានារ៉ាប់រងលើភាពអត់ការងារធ្វើ**

៣.១៨២- គោលនយោបាយជាតិមុខរបរ បានកំណត់តម្រូវការធ្វើការសិក្សាលទ្ធភាពស្ដីពីការអភិវឌ្ឍគម្រោងភាពអត់ការងារធ្វើ។ រហូតមកដល់ពេលនេះ ធានារ៉ាប់រងភាពអត់ការងារធ្វើមិនទាន់មាននៅកម្ពុជាទេ ដូចនេះកង្វះខាតសមត្ថភាពនិងជំនាញ។

**ពលកម្មកុមារ**

៣.១៨៣- ការកាត់បន្ថយនិងការទប់ស្កាត់ពលកម្មកុមារ ជាពិសេសទម្រង់ធ្ងន់ធ្ងរ នៅតែជាបញ្ហាប្រឈមក្នុងបរិបទនៃភាពក្រីក្រនិងវិសមភាព។

**ការដោះស្រាយវិវាទពលកម្ម**

៣.១៨៤- រាជរដ្ឋាភិបាល នឹងបន្តធ្វើការជាមួយនិយោជកនិងតំណាងកម្មករ ដើម្បីធានាថាវិវាទពលកម្មត្រូវបានដោះស្រាយតាមសន្តិវិធីនិងយុត្តិធម៌សម្រាប់គ្រប់អ្នកពាក់ព័ន្ធ។

**សុវត្ថិភាពរបស់កម្មករ**

៣.១៨៥- សុវត្ថិភាពកន្លែងធ្វើការនិងលក្ខខណ្ឌការងារ រួមទាំងការដឹកជញ្ជូនកម្មករដោយសុវត្ថិភាព។ សុវត្ថិភាពកម្មករក៏ត្រូវគិតគូរផងដែរចំពោះកម្មករធ្វើការក្រៅប្រទេស។

## ៦.៤- ការអភិវឌ្ឍវិស័យធនាគារ និងហិរញ្ញវត្ថុ

៣.១៨៦- នៅខែមីនា ឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានកំណត់អត្រាប្រាក់បម្រុងកាតព្វកិច្ច ១២,៥% លើកម្ចីពីបរទេសរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ ដើម្បីកាត់បន្ថយការពឹងផ្អែកលើកម្ចីបរទេសនិងកំណើនឥណទាន ក៏ដូចជារួមចំណែកកាត់បន្ថយហានិភ័យនៃលំហូរមូលធន។ នៅចុងឆ្នាំ២០១៥ ធនាគារជាតិនៃកម្ពុជាបានចេញប្រកាសស្ដីពីអនុបាតគ្របខណ្ឌសន្ទនីយភាព (Liquidity Coverage Ratio: LCR) និងតម្រូវឲ្យអនុវត្តចាប់ពីខែមករា ឆ្នាំ២០១៦។ គោលបំណងសំខាន់នៃប្រកាសនេះ គឺបង្កើនភាពធន់រយៈពេលខ្លីនៃហានិភ័យ សន្ទនីយភាពរបស់ស្ថាប័ននីមួយៗ និងធានាថាស្ថាប័ននីមួយៗមានទ្រព្យសកម្មគ្រប់គ្រាន់ដែលអាចប្ដូរទៅជាសាច់ប្រាក់ដោយមិនខាតបង់ ឬខាតបង់តិចតួចពីតម្លៃទីផ្សារដើម្បីបំពេញ តម្រូវការសន្ទនីយភាពក្នុងស្ថេរស្ត្រេសតេស្តសេណារីយ៉ូ សម្រាប់រយៈពេល៣០ថ្ងៃ។

៣.១៨៧- ទិន្នន័យបង្ហាញថាកំណើនឥណទានធនាគារបានផ្ដល់ទៅកសិកម្ម កម្មន្តសាល និងការដឹកជញ្ជូន ពាណិជ្ជកម្មលក់ដុំនិងលក់រាយ សណ្ឋាគារ និងភោជនីយដ្ឋាន។ ឥណទានរបស់គ្រឹះស្ថានធនាគារប្រមាណ ៦០% នៃឥណទានសរុបត្រូវបានបែងចែកទៅកាន់វិស័យ កសិកម្ម

កម្មន្តសាល ការដឹកជញ្ជូន ពាណិជ្ជកម្មលក់ដុំនិងរាយ និងសណ្ឋាគារនិងភោជនីយដ្ឋាន។ ទន្ទឹមនេះ ឥណទានចំពោះវិស័យអចលនទ្រព្យបានកើនឡើងយ៉ាងឆាប់រហ័ស ដែលបញ្ហានេះអាចបង្កឲ្យមានហានិភ័យដល់ស្ថិរភាពហិរញ្ញវត្ថុ។

៣.១៨៨- ទោះបីជាអត្រាកំណើនឥណទានបានថមថយខ្លះក៏ដោយ ឥណទានរបស់គ្រឹះស្ថានធនាគារនៅចុងឆ្នាំ២០១៦ មានកំណើន ២២%។ គិតត្រឹមចុងឆ្នាំ២០១៦នេះ ផលធៀបរវាងឥណទាននិងប្រាក់បញ្ញើរបស់គ្រឹះស្ថានធនាគារជាមធ្យមមានកម្រិតប្រមាណ ៩៩%។ តួលេខនេះបង្ហាញថា គ្រឹះស្ថានធនាគារពឹងផ្អែកលើប្រភពទុនពីខាងក្រៅក្រោមរូបភាពជាកម្ចីបរទេស ដើម្បីផ្តល់ឥណទានរបស់ខ្លួន។ ប៉ុន្តែ កម្ចីនេះគឺមានឥណប្រតិទានវែង ដែលមានសមាមាត្រ ប្រមាណ ៨៥%នៃកម្ចីបរទេសសរុប ហើយត្រូវបានខ្ចីពីធនាគារមេរបស់ខ្លួន ដែលកត្តានេះអាចកំណត់បានពី ស្ថិរភាពនៃប្រភពទុនរបស់គ្រឹះស្ថាន។

**បញ្ហាប្រឈម**

៣.១៨៩- បច្ចុប្បន្ន គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើមួយចំនួនមានទំហំធំជាងធនាគារពាណិជ្ជខ្នាតមធ្យម ប៉ុន្តែបទបញ្ញត្តរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនៅមានចំណុចខ្វះខាតមួយចំនួន និងមិនទាន់បានធ្វើបច្ចុប្បន្នកម្មឲ្យស្របតាមទំហំនិងការអភិវឌ្ឍរបស់វិស័យមីក្រូហិរញ្ញវត្ថុ។ ដើម្បីពង្រឹងភាពធន់នៃវិស័យធនាគារ ធនាគារជាតិនៃកម្ពុជាបាននិងកំពុងធ្វើបច្ចុប្បន្នកម្មលើបទបញ្ញត្តដែលមានស្រាប់ ព្រមទាំងសិក្សានិងរៀបចំបទបញ្ញត្តថ្មីៗបន្ថែមទៀតសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ។

**សេចក្តីសន្និដ្ឋាន**

៣.១៩០- មានវឌ្ឍនភាពល្អក្នុងការពង្រឹងវិស័យឯកជន និងលើកកម្ពស់វិនិយោគនិងធុរកិច្ច ជាពិសេសវឌ្ឍនភាពក្នុងបរិស្ថានអំណោយផលសម្រាប់ធុរកិច្ច និងការសម្របសម្រួលពាណិជ្ជកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជាក្នុងពាណិជ្ជកម្មតំបន់ និងសកលលោក។ នេះអនុវត្តលើអនុវិស័យសេវាកម្ម ដូចជាទេសចរណ៍ដែលប្រឈមនឹងភាពប្រកួតប្រជែងច្រើនក្នុងតំបន់។ ការអភិវឌ្ឍទីផ្សារការងារ គឺជាស្នូលនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម និង ជាផ្នែកមួយនៃសសរស្តម្ភសម្រាប់កំណើនប្រកបដោយចីរភាពនិងបរិយាប័ន្ន ដែលនឹងបន្តមាននៅក្នុង ផ.យ.អ.ជ. ២០១៩-២០២៣។ រាជរដ្ឋាភិបាលនឹងបន្តយកចិត្តទុកដាក់លើទំនាក់ទំនងឧស្សាហកម្ម ការអប់រំនិងបណ្តុះបណ្តាលវិជ្ជាជីវៈនិងបច្ចេកទេស និងសន្តិសុខសង្គម។ សូចនាករតាមដានបន្ថែមនឹងត្រូវបង្កើតឡើងដើម្បីតាមដានវឌ្ឍនភាពគោលបំណងតាមវិស័យ។ សូចនាករទាក់ទងនឹងការអភិវឌ្ឍវិស័យធនាគារនិងហិរញ្ញវត្ថុ បង្ហាញថាវិស័យនេះ បានបន្តរីកចម្រើនយ៉ាងឆាប់

រហ័ស និងរួមចំណែកគាំទ្រដល់ការរីកចម្រើននៃវិស័យសេដ្ឋកិច្ច។ ទន្ទឹមនេះ ធនាគារជាតិនៃកម្ពុជាបានដាក់ចេញនូវវិធានការម៉ាក្រូប្រុងប្រយ័ត្នដើម្បីពង្រឹងស្ថិរភាពហិរញ្ញវត្ថុ។ ទោះយ៉ាងណាហានិភ័យនៃការកើនឡើងថ្លៃខ្ពស់នៃវិស័យអចលនទ្រព្យ គឺជាការព្រួយបារម្ភនៅពេលខាងមុខ។

## ៧- ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

### ៧.១- ការពង្រឹងនិងការលើកកម្ពស់វិស័យអប់រំ វិទ្យាសាស្ត្រ បច្ចេកវិទ្យា ព្រមទាំងការបណ្ដុះបណ្ដាលបច្ចេកទេស

៣.១៩១- រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលល្អនៅក្នុងគ.អ.សក.ទី២ សម្រេចឲ្យបានសកលកម្មអក្ខរកម្មនិងការអប់រំបឋមសិក្សា។ នៅកម្រិតជាតិ អត្រាអក្ខរកម្មសម្រាប់ប្រជាជនអាយុ១៥-២៤ឆ្នាំ បានកើនឡើងពី៨០,៤%ក្នុងឆ្នាំ២០០៤ទៅ៩៣%ក្នុងឆ្នាំ២០១៤ ដែលបង្ហាញពីការសម្រេចបាន៩៤,៥%ដូចបានកំណត់នៅក្នុងគ.អ.ស.ក.។ គម្លាតយេនឌ័រត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័ស ប៉ុន្តែនៅមានគម្លាតអក្ខរកម្មក្នុងបណ្ដាប្រជាជនក្រីក្រ ប្រជាជននៅទីប្រជុំជន និងជនជាតិភាគតិច។

៣.១៩២- លើសពីនេះទៀត ក្រសួងអប់រំ យុវជន និងកីឡាបានសម្រេចបានសមិទ្ធផលក្នុងឆ្នាំសិក្សា២០១៣-២០១៤និង២០១៤-២០១៥ ដែលបានឆ្លុះបញ្ចាំងពីវឌ្ឍនភាពនៃកំណែទម្រង់សំខាន់ៗរបស់ខ្លួន ដូចខាងក្រោម ៖

៣.១៩៣- **ការអប់រំកុមារតូច ៖** កុមារអាយុពី ០ ទៅ ក្រោម ៦ឆ្នាំ ទទួលសេវាអប់រំគ្រប់រូបភាព មាន ២០,១៧ ភាគរយ នៃចំនួនប្រជាជនអាយុពី ០ទៅក្រោម ៦ឆ្នាំ។ កុមារអាយុ៥ឆ្នាំ ទទួលបានសេវាអប់រំគ្រប់រូបភាព សម្រេចបាន ៦៤,១ ភាគរយ នៃចំនួនកុមារអាយុ៥ឆ្នាំ ។

៣.១៩៤- **ការអប់រំបឋមសិក្សា ៖** អត្រាពិតនៃការសិក្សានៅបឋមសិក្សាសម្រេចបាន ៩៨,៤%ក្នុងឆ្នាំ២០១៦។ វិសមភាពយេនឌ័រនៅបឋមសិក្សាត្រូវបានកែលម្អ។ អត្រាពិតនៃការសិក្សារបស់សិស្សស្រីខ្ពស់ជាងសិស្សប្រុស។ សន្ទស្សន៍យុគភាពយេនឌ័រនៃអត្រាពិតចូលរៀនថ្មីនិងអត្រាពិតនៃការសិក្សានៅបឋមសិក្សាក្នុងរយៈពេល៤ឆ្នាំចុងក្រោយស្មើ១។

៣.១៩៥- **ការអប់រំមធ្យមសិក្សា ៖** អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិសម្រេចបាន ៤៥,៨%ក្នុងឆ្នាំ២០០៥ កើនដល់៥៨,១%ក្នុងឆ្នាំ២០១០ និងធ្លាក់ចុះមក ៥៣,៨% នៅឆ្នាំសិក្សា ២០១៦ ទាបជាងចំណុចដៅ (៧៣,៨%)។

៣.១៩៦- អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សានិងនៅធម្យមសិក្សាមិនទាន់សម្រេចបានតាមចំណុចដៅទេ។ អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សាបានកើនពី៨៣,២%ក្នុងឆ្នាំ២០១០មក ៨៤,១%ក្នុង២០១៥។ អត្រាបញ្ចប់ការសិក្សានៅធម្យមសិក្សាបឋមភូមិបានធ្លាក់ចុះពី៤៨,៧% ក្នុងឆ្នាំ២០១០មក៤០,៣%ក្នុងឆ្នាំ២០១៥។ កត្តាសេដ្ឋកិច្ចបានជំរុញឲ្យគ្រួសារបញ្ជូនកូនទៅក្នុងកម្លាំងពលកម្មនៅវ័យក្មេង និងកំណើននៃការធ្វើចំណាកស្រុករកការងារធ្វើរបស់គ្រួសារ។

៣.១៩៧- ការទទួលបានទឹកស្អាតប្រើប្រាស់នៅតាមសាលារៀនបឋមសិក្សាកំពុងកើនឡើង ទោះបីនៅតាមខេត្តមួយចំនួនសម្រេចបានតិចជាង៦០%ក៏ដោយ និងនៅធម្យមសិក្សាសម្រេចបានលើស៦០% ។

៣.១៩៨- *ក្រសួងអប់រំ យុវជន និងកីឡា*បានផ្តោតលើការអនុវត្តកំណែទម្រង់សំខាន់ៗក្នុងវិស័យអប់រំ ដូចជា៖ (១)ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន (២)ការកែលម្អកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងបរិស្ថានសិក្សា (៣)ការអនុវត្តការងារអធិការកិច្ច (៤) ការពង្រឹងការវាយតម្លៃការសិក្សា និង (៥) កំណែទម្រង់ឧត្តមសិក្សា។

៣.១៩៩- ក្រសួងអប់រំ យុវជន និងកីឡាមានកិច្ចសហការល្អជាមួយដៃគូអភិវឌ្ឍនិងសង្គមស៊ីវិល និងមានការប្តេជ្ញាចិត្តក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំរួមគ្នា ដែលបានចែងច្បាស់លាស់ពីគោលបំណងនិងអាទិភាពនានាក្នុងវិស័យអប់រំ។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំបានគាំទ្រដោយប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំដែលអាចឲ្យដៃគូអភិវឌ្ឍទាំងអស់តាមដានរួមគ្នាលើវឌ្ឍនភាពរបស់សូចនាករទាំងអស់ក្នុងវិស័យអប់រំ។

**តារាងទី៣.២៦ : សូចនាករនិងចំណុចដៅជ្រើសរើសសំខាន់ៗ ក្នុងវិស័យអប់រំ យុវជន និងកីឡា**

| សូចនាករសំខាន់ៗ ក្នុងវិស័យអប់រំ | | ឯកតា | ២០១២-២០១៣ | ២០១៣-២០១៤ | ២០១៤-២០១៥ | ២០១៥-២០១៦ | ២០១៦-២០១៧ | ២០១៧-២០១៨ |
|---|---|---|---|---|---|---|---|---|
| | | | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ជាក់ស្តែង | ព្យាករណ៍ |
| ១ | ភាគរយកុមារអាយុ៥ឆ្នាំក្នុងការអប់រំកុមារតូចនៅគ្រប់រូបភាព | % | ៥៦,៥ | ៥៩,៩៣ | ៦១,៤ | ៦៤,១ | ៦៦,៣ | ៦៨ |
| ២ | សាលាបឋមសិក្សា (១-៦) | ចំនួន | ៦ ៩១០ | ៦ ៩៩៣ | ៧ ០៥១ | ៧ ០៨៥ | ៧ ១៤៤ | ៧ ៦០៦ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៣ | សរុប | % | ៩៧ | ៩៨,២ | ៩៨ | ៩៨,៤ | ៩៧,៧ | ១០០ |
| ៤ | ប្រុស | % | ៩៧ | ៩៥,៤ | ៩៤,១ | ៩៧,៧ | ៩៧,៤ | ១០០ |
| ៥ | ស្រី | % | ៩៧ | ៩៨,៥ | ៩៨,០ | ៩៩,៣ | ៩៨,២ | ១០០ |
| ៦ | ទីប្រជុំជន | % | ៨៩,៨ | ៨៣,៦ | ៨២,៩ | ៨៣,៣ | ៨៤ | ១០០ |
| ៧ | ជនបទ | % | ៩៨,៦ | ៩៨,៤ | ៩៧,២ | ៩៦,៥ | ៩៦,៥ | ១០០ |
| អត្រារួមនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៨ | សរុប | % | ១២១,១ | ១១៩,២ | ១១១,២ | ១០៧ | ១១៣,២ | ១០៣ |
| ៩ | ប្រុស | % | ១២៣,១ | ១១៧,៨ | ១១២,១ | ១០៨ | ១១៣,៩ | ១០៣ |
| ១០ | ស្រី | % | ១១៩ | ១១៧,៥ | ១១០,២ | ១០៧ | ១១៣,៣ | ១០៣ |
| អត្រាបញ្ចប់ការសិក្សានៅបឋមសិក្សា | | | | | | | | |
| ១១ | សរុប | % | ៩១,៥ | ៨៨,៩៤ | ៨៤,១ | ៨០,៦ | ៧៩,៩ | ៨៣ |
| ១២ | ប្រុស | % | ៩១,៩ | ៨៧,៧ | ៨១,៨ | ៨២,៥ | ៧៦,៧ | ៨៤,២ |
| ១៣ | ស្រី | % | ៩១ | ៩០,១៩ | ៨៦,៦ | ៨៣,៩ | ៨៣,២ | ៨៤,៥ |
| ១៤ | ចំនួនសាលាមធ្យមសិក្សាបឋមភូមិ | ចំនួន | ១ ៦២២ | ១៦៥៩ | ១៦៧៤ | ១៦៨៤ | ១ ៦៩៨ | ១ ៦៧២ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ១៥ | សរុប | % | ៥៦,៥ | ៥៣,៣ | ៥៣,៣ | ៥៣,៨ | ៥៧,៦ | ៥៤,៩ |
| ១៦ | ប្រុស | % | ៥៦,២ | ៥២,១ | ៥១,៥ | ៥១,៤ | ៥៣,៩ | ៥០,៩ |
| ១៧ | ស្រី | % | ៥៦,៧ | ៥៤,៥ | ៥៥,៣ | ៥៦,៧ | ៦១,៥ | ៥៤,៩ |
| ១៨ | ទីប្រជុំជន | % | ៧៨,៤ | ៦០,០ | ៥៨,៣ | ៥៩,២ | ៥៥,៨ | ៥៥,៥ |
| ១៩ | ជនបទ | % | ៥២,៦ | ៥១,៧ | ៥២,១ | ៥២ | ៥១,៦ | ៥៤,៨ |
| អត្រាបញ្ចប់ការសិក្សាមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ២០ | សរុប | % | ៤២,២ | ៣៩,០៩ | ៤០,៣ | ៣៩,២ | ៤២,៦ | ៤៤,៦ |
| ២១ | ប្រុស | % | ៤២ | ៣៨,២៣ | ៣៨,៩ | ៣៧,៣ | ៣៩,៣ | ៤១,១ |
| ២២ | ស្រី | % | ២៥,៥ | ៤០,០២ | ៤១,៨ | ៤១,២ | ៤៦ | ៤៤,៦ |
| ២៣ | ចំនួនសាលាមធ្យមសិក្សាទុតិយភូមិ | ចំនួន | ៤៣៣ | ៤៤៤ | ៤៥៥ | ៤៦៣ | ៤៨៦ | ៦៦៨ |
| អត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ | | | | | | | | |
| ២៤ | សរុប | % | ២៩,៨ | ២៦,០ | ២៥,៣ | ២៤,៣ | ២៦,៥ | ២៧,៧ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ២៥ | ប្រុស | % | ៣១,៩ | ២៥,២ | ២៣,៨ | ២៤,១ | ៣៩,៤ | ២៧,៥ |
| ២៦ | ស្រី | % | ២៧,៦ | ២៥,៧ | ២៦,៩ | ២៥,២ | ២៨,១ | ២៧,៧ |
| ២៧ | ចំនួនវិទ្យាល័យអប់រំបច្ចេកទេស | ចំនួន | ២ | ៣ | ៣ | ៤ | ៧ | ៨ |
| ២៨ | ចំនួនសិស្សនៅមធ្យមសិក្សាអប់រំបច្ចេកទេស | ចំនួន | ៨៩៧ | ៦៥៣ | ៨៦៨ | ១០៦៦ | ១ ១៤៨ | ១៤៩២ |
| ២៩ | អត្រាអក្ខកម្មជនពេញវ័យ អាយុ១៥ឆ្នាំឡើង (១៥-៤៥ ឆ្នាំ) | % | ៨០,០ (២០១៣) | ៨៧,០ (២០១៤) | ៧៨,១ (២០១៥) | ៧៨,១ | ៧៩,៨ | ៨១,៤ |

ប្រភព : ក្រសួងអប់រំ យុវជន និងកីឡា

**បញ្ហាប្រឈម**

៣.២០០- ទន្ទឹមនឹងសមិទ្ធផលគួរឲ្យកត់សម្គាល់ខាងលើ បញ្ហាប្រឈមមួយចំនួនចាំបាច់ត្រូវមានកិច្ចខិតខំប្រឹងប្រែងដោះស្រាយ មានដូចខាងក្រោម៖

- មានវឌ្ឍនភាពល្អសម្រាប់អត្រារួមនៃការសិក្សានៅបឋមសិក្សា ប៉ុន្តែអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សានៅតែជាបញ្ហាប្រឈម។
- ធានាកុមារមកពីគ្រួសារក្រីក្រ និងងាយរងគ្រោះ សហគមន៍ជនជាតិភាគតិច ទទួលបានឱកាសអប់រំស្មើគ្នា។ បញ្ហានេះអាចដោះស្រាយបានតាមរយៈការសាងសង់សាលារៀនឲ្យបានច្រើននៅក្នុងតំបន់ដាច់ស្រយាល់និងការបង្កើនការផ្ដល់អាហារូបករណ៍សម្រាប់សិស្សក្រីក្រ។
- ការពង្រឹងគុណភាពរបស់គ្រូបង្រៀននិងនិរន្តរភាពនៃការប្ដេជ្ញាចិត្តនិងធនធានហិរញ្ញវត្ថុ។
- ការបណ្ដុះបណ្ដាលគ្រូបង្រៀនលើមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅតែជាបញ្ហាប្រឈម និងតម្រូវឲ្យមានកម្មវិធីសិក្សាស្ដីពី វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យានៅកម្រិតឧត្ដមសិក្សា និងលើកទឹកចិត្តសិស្ស និស្សិតឲ្យផ្ដោតលើការអប់រំបច្ចេកទេស ទាក់ទងនឹងមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា។
- ការកែលម្អកម្មវិធីសិក្សានៅមធ្យមសិក្សា ដោយដាក់បញ្ចូលការអប់រំបច្ចេកទេស។
- ការពង្រឹងស្ថាប័ននិងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ការអប់រំកាយ (រួមមានការអប់រំសុខភាព និងអាហារូបត្ថម្ភ) កីឡា និងអត្តពលកិក។
- បញ្ហាប្រឈមទាំងនេះបង្ហាញអំពីកំណើនតម្រូវការហិរញ្ញប្បទាន ដែលភាពប្រឈមសំខាន់ជាងគេ។

## ៧.២- ការលើកកម្ពស់សុខភាពនិងអាហារូបត្ថម្ភ

៣.២០១- *ផ.យ.អ.ជ.២០១៤-២០១៨* បានកំណត់ថាសុខភាពគឺជាធាតុផ្សំសំខាន់ក្នុងការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្សសម្រាប់កំណើនសេដ្ឋកិច្ច និងបង្ហាញថាគោលដៅនិងអាទិភាពនៅក្នុងផែនការយុទ្ធសាស្រ្តសុខាភិបាលជាមធ្យោបាយក្នុងការលើកកម្ពស់ការអភិវឌ្ឍប្រកបដោយចីរភាពក្នុងវិស័យសុខាភិបាល។ ផ.យ.អ.ជ.បានកំណត់អាទិភាពក្នុងវិស័យសុខាភិបាលចំនួន០៤ គឺ(១)លើកកម្ពស់សុខភាពផ្លូវភេទ សុខភាពបន្តពូជ សុខភាពស្ត្រី និងសុខភាពកុមារ (២)កាត់បន្ថយមរណភាពដោយដោយសារជំងឺឆ្លង (៣)កាត់បន្ថយមរណភាពដោយជំងឺមិនឆ្លង និង(៤)ធានាការទទួលបានសេវាសុខភាពដោយសមធម៌។ ថវិកាជាតិសម្រាប់វិស័យសុខាភិបាលបានកើនឡើង២២%ពីឆ្នាំ២០១២ដល់ឆ្នាំ២០១៥។

៣.២០២- រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលច្រើនក្នុងវិស័យសុខាភិបាល ជាពិសេសសម្រេចបានចំណុចដៅរបស់គ.អ.ស.ក.ដែលទាក់ទងនឹងសុខភាព និងមានវឌ្ឍនភាពល្អក្នុងការកាត់បន្ថយមរណភាពមាតានិងកុមារ ការកាត់បន្ថយការរីករាលដាល់ជំងឺឆ្លង និងការពង្រីកមូលនិធិសមធម៌សុខភាពសម្រាប់ប្រជាជនក្រីក្រ។

៣.២០៣- ចំណុចដៅនៅក្នុងគ.អ.ស.ក.ទី៤ ការកាត់បន្ថយមរណភាពកុមារសម្រេចបានទាំងអស់។ ចំណុចដៅនៅក្នុងគ.អ.ស.ក.ទី៥ ការលើកកម្ពស់សុខភាពមាតាសម្រេចបានសូចនាករភាពច្រើន។ ចំណុចដៅនៅក្នុងគ.អ.ស.ក.ទី៦ ការប្រយុទ្ធប្រឆាំងមេរោគអេដស៍ ជំងឺអេដស៍ ជំងឺគ្រុនចាញ់ និងជំងឺផ្សេងៗទៀតក៏សម្រេចបានផងដែរ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងសុខាភិបាលបានសហការគ្នាលើកកម្ពស់ប្រសិទ្ធភាពថវិកាដែលវិភាជសម្រាប់វិស័យសុខាភិបាល។ មានកំណើនការវិភាជថវិកាសម្រាប់វិស័យសុខាភិបាល រួមមានបដិភាគរបស់រដ្ឋាភិបាលដល់មូលនិធិសមធម៌សុខភាពនិងមន្ទីរពេទ្យគុន្ធបុប្ផា។

៣.២០៤- ការពង្រឹងការប្រមូលទិន្នន័យសុខាភិបាលអន្តរវិស័យបានផ្តល់មូលដ្ឋានសម្រាប់ការចាប់ផ្តើមការស្រាវជ្រាវវិស័យសុខាភិបាលជាមធ្យោបាយសម្រាប់ផ្តល់ព័ត៌មាន និងភស្តុតាងសម្រាប់ការរៀបចំគោលនយោបាយ ផែនការ និងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ។

៣.២០៥- **សុខភាពបន្តពូជនិងសុខភាពផ្លូវភេទ (ការលើកកម្ពស់សុខភាពមាតា)៖** ចំណុចដៅសំខាន់ៗដែលបានកំណត់នៅក្នុងគ.អ.ស.ក.ទី៥ មាន (១)អត្រាមរណៈភាពមាតា (១០០ ០០០ក្នុងកំណើតរស់) ចំណុចដៅឆ្នាំ២០១៥ គឺ២៥០ (២)សមាមាត្រស្ត្រីសម្រាលកូនដោយបុគ្គលិកសុខា

ភិបាលជំនាញ ចំណុចដៅឆ្នាំ២០១៥គឺ៨៧% (៣)អត្រាផ្តល់កំណើតសរុប ចំណុចដៅឆ្នាំ២០១៥ គឺ៣នាក់ (៤) សមាមាត្រស្ត្រីដែលបានរៀបការ និងបានប្រើប្រាស់វិធីពន្យារកំណើតចំណុចដៅឆ្នាំ២០១៥ គឺ៦០% (៥)សមាមាត្រស្ត្រីមានផ្ទៃពោះដែលទទួលបានការពិនិត្យផ្ទៃពោះ២ដង ឬច្រើនជាង ដោយបុគ្គលិកសុខាភិបាលជំនាញ ចំណុចដៅឆ្នាំ២០១៥ គឺ៩០% និង (៦)សមាមាត្រស្ត្រីមានផ្ទៃពោះដែលសម្រាលកូនដោយធ្វើការវះកាត់ ចំណុចដៅឆ្នាំ២០១៥ គឺ៤។

៣.២០៦- ការកាត់បន្ថយអត្រាមរណៈភាពមាតាបានថយចុះយ៉ាងលឿនពី ៤៧២ក្នុងទារកកើតរស់ ១០០ ០០០នាក់ នៅឆ្នាំ២០០៥ មកត្រឹម១៧០ ក្នុង១០០ ០០០កំណើតរស់ នៅឆ្នាំ២០១៤។ ប៉ុន្តែតួលេខនេះ នៅតែខ្ពស់នៅឡើយ។ ការសម្រាលដោយអ្នកផ្តល់សេវាមានជំនាញ(វេជ្ជបណ្ឌិត/ឆ្មប/គិលានុបដ្ឋាក/យិកា)បានកើនឡើងយ៉ាងខ្លាំងពី ៤៤% នៅឆ្នាំ២០០៥ ដល់ ៨៥,០២% នៅឆ្នាំ២០១៦។ រីឯការសម្រាលនៅមូលដ្ឋានសុខាភិបាលបានកើនពី ២២% នៅឆ្នាំ២០០៥ ដល់ ៨០,៥២% នៅឆ្នាំ២០១៦។ អត្រាផ្តល់កំណើតសរុបបានធ្លាក់ចុះពី៤នាក់ក្នុងឆ្នាំ២០០០ មក ២,៧ នាក់ក្នុងឆ្នាំ២០១៤ ។ អត្រាផ្តល់កំណើតសរុបរបស់ស្ត្រីតាមតំបន់ជនបទមាន២,៩ក្នុងអាយុបន្តពូជពី១៥ឆ្នាំដល់៤៩ឆ្នាំ ហើយស្ត្រីនៅទីប្រជុំជនមាន២,១។

៣.២០៧- ស្ត្រីមានស្វាមីក្នុងវ័យបន្តពូជដែលបានរៀបអាពាហ៍ពិពាហ៍អាយុពី១៥-៤៩ឆ្នាំ ប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើបណាមួយបានកើនឡើងពី១៩% ក្នុងឆ្នាំ២០០០ ដល់ ២៤,៨២% ក្នុងឆ្នាំ២០០៨ និង៣២,៦៥% ក្នុងឆ្នាំ២០១៦។ ទោះបីការប្រើប្រាស់វិធីពន្យារកំណើតបានកើនឡើងសម្រាប់ស្ត្រីមានស្វាមី ប៉ុន្តែការមានផ្ទៃពោះក្នុងចំណោមស្ត្រីអាយុ១៥ដល់១៩ឆ្នាំចាប់ផ្តើមមានចំនួន១២% ក្នុងនោះ៧% បានក្លាយជាមាតា និង ៥% ទៀតកំពុងមានគភ៌លើកទី១ (ឆ្នាំ២០១៤)។

៣.២០៨- ស្ត្រីមានគភ៌បានមកពិនិត្យថៃទាំគភ៌មុនសម្រាលជាមួយបុគ្គលិកសុខាភិបាលលើកទី២ បានកើនឡើងពី២៥,៤%ក្នុងឆ្នាំ២០០០ ដល់៩៦,៦% នៃស្ត្រីមានគភ៌រំពឹងទុកក្នុងឆ្នាំ២០១៦។ ចំណែកការពិនិត្យថៃទាំគភ៌មុនសម្រាលលើកទី៤ មានចំនួន៧២,២៣% នៃស្ត្រីមានគភ៌រំពឹងទុកក្នុងឆ្នាំ២០១៦។ អត្រានៃការសម្រាលកូនដោយវិធីវះកាត់(គិតជាភាគរយនៃចំនួនសម្រាលសរុប) មានកំណើនប្រចាំឆ្នាំជាមធ្យម ក្នុងរង្វង់១% រវាងឆ្នាំ២០០៨(១,០៤%) និងឆ្នាំ២០១៦ (៥,៤០%) ដោយសារការពង្រីកសេវាសង្គ្រោះបន្ទាន់ផ្នែកសម្ភពនិងថៃទាំទារកកាន់តែច្រើន និងបង្កើនការស្រាវជ្រាវរកស្ត្រីមានគភ៌ប្រឈមនឹងហានិភ័យខ្ពស់។ មរណភាពកុមារនិងសុខភាពកុមារ៖ ចំណុចដៅសំខាន់ៗដែលបានកំណត់នៅក្នុងគ.អ.ស.ក. មាន (១)កាត់បន្ថយអត្រាមរណៈភាពកុមារអាយុក្រោម១ឆ្នាំឲ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៨និងឆ្នាំ២០១៥ (២)កាត់បន្ថយអត្រាមរណៈភាពកុមារអាយុក្រោម៥ឆ្នាំឲ្យបានពាក់កណ្តាលរវាងឆ្នាំ១៩៩៨និងឆ្នាំ២០១៥ (៣)

បង្កើនការផ្តល់វ៉ាក់សាំងដល់កុមារឲ្យបាន៩០% និង(៤)បង្កើនការបំបៅដោះម្តាយដល់កុមាររហូតអាយុ៦ខែឲ្យបាន៧០%។

៣.២០៩- សូចនាករសំខាន់ៗរបស់សុខភាពទារក និងកុមារមានការជឿនលឿនគួរឲ្យកត់សំគាល់។ អត្រាមរណៈភាពកុមារអាយុក្រោម១ឆ្នាំបានធ្លាក់ចុះពី៩៥នាក់ ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០០០ មក២៨នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០១៤ និងអត្រាមរណៈភាពកុមារអាយុក្រោម៥ឆ្នាំ ធ្លាក់ចុះពី១២៤នាក់ក្នុង១០០០កំណើតរស់ ក្នុងឆ្នាំ២០០០ មក៣៥នាក់ក្នុង១០០០កំណើតរស់ក្នុងឆ្នាំ២០១៤ ។

៣.២១០- អត្រាគ្របដណ្តប់នៃ ការផ្តល់វ៉ាក់សាំងបង្ការជំងឺខាន់ស្លាក់-ក្អកមាន់-តេតាណូស៣លើក មានការកើនឡើងដោយក្នុងឆ្នាំ២០០៣មានអត្រាត្រឹមតែ៧៣% និងបានឡើងដល់៩៦,៨៥% នាឆ្នាំ២០១៦។ វឌ្ឍនភាពគួរឲ្យកត់សម្គាល់គឺ «សូន្យករណី» នៃជំងឺកញ្ជ្រឹលដែលមានចាប់ពីឆ្នាំ២០១២មក។

៣.២១១- ការបំបៅកូនដោយទឹកដោះម្តាយដល់កុមាររហូតដល់អាយុ៦ខែ បានទទួលស្គាល់ដោយមាតានិងពលរដ្ឋជាច្រើនក្នុងសង្គមកម្ពុជា។ កុមារទទួលការបំបៅដោះពីម្តាយមានប្រមាណ៦០%ក្នុងឆ្នាំ២០០៥ និងកើនដល់៧៤%ក្នុងឆ្នាំ២០១០។ ក្នុងឆ្នាំ២០១៤ អត្រានៃការបំបៅកូនដោយទឹកដោះម្តាយលើកុមារអាយុ០ទៅ៥ខែមានដល់ទៅ៩៣%។

៣.២១២- **ជំងឺឆ្លង៖** ចំណុចដៅសំខាន់ៗដែលបានកំណត់នៅក្នុងគ.អ.ស.ក.ទី៦ មាន(១) កាត់បន្ថយអត្រាផ្ទុកមេរោគអេដស៍/ជំងឺអេដស៍មកនៅត្រឹម០,៦%ក្នុងចំណោមប្រជាជនសរុប (២) កាត់បន្ថយប្រេវ៉ាឡង់ជំងឺគ្រុនចាញ់និងជំងឺគ្រុនឈាមមកនៅ០,៨% និង(៣) កាត់បន្ថយប្រេវ៉ាឡង់ជំងឺរបេងមកនៅ៦៥៣ក្នុងចំណោមប្រជាជន១០០ ០០០នាក់។

៣.២១៣- *មេរោគអេដស៍/ជំងឺអេដស៍៖* អត្រាផ្ទុកមេរោគអេដស៍ ក្នុងចំណោមប្រជាជនទូទៅដែលមានអាយុ ១៥-៤៩ឆ្នាំ បានធ្លាក់ចុះពី ១,៧០មក ២០០០ក្នុងឆ្នាំ %,៨% នៅឆ្នាំ២០១០ និងបន្តធ្លាក់ចុះមកត្រឹម០,៦.។ ដូច្នេះកម្ពុជាអាចឈានទៅសម្រេចបាននូវចំណុចដៅ ៨២០១៥នៅឆ្នាំ% ០ ជ.អ.ឃ,៥។ ក្នុងរយៈកាលប្រាំឆ្នាំចុងក្រោយ ចំនួននៃករណីឆ្លងមេរោគអេដ២០១៥ក្នុងឆ្នាំ % ស៍ថ្មីក្នុងមួយឆ្នាំ ក៏មានការថយចុះគួឲ្យកត់សម្គាល់ផងដែរ ដោយបានធ្លាក់ចុះពីប្រមាណ ១ ៦៦២ នៅឆ្នាំ២០១០ មក ៦៤៥ នាក់នៅឆ្នាំ២០១៦ រីឯអត្រាគ្របដណ្តប់ដោយឱសថប្រឆាំងមេរោគអេដស៍ ក៏បានកើនឡើងជាលំដាប់រហូតដល់ ៧៤,៥ក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍ទាំងអស់ %

។ អត្រានៃអ្នកជំងឺអេដស៍ដែលនៅរស់២០១៥ ដែលត្រូវការ ឱសថប្រឆាំងមេរោគអេដស៍ក្នុងឆ្នាំ ទទួលឱសថានមានជីវិតក្រោយពីថប្រឆាំងមេរោគអេដស៍ អស់យៈពេល ១២ខែ មាន៨៤,៥នៅ % ៧៥និង ២០១៤ឆ្នាំ,៩។ លើសពីនេះទៅទៀត អត្រាឆ្លងមេរោគអេដស៍ ពីម្តាយ២០១៥នៅឆ្នាំ % ៨ ទៅទារកបានកាត់បន្ថយពី,១៣៦ មក ២០១៣នៅឆ្នាំ %,២។ ប្រទេសកម្ពុជា២០១៥នៅឆ្នាំ % ដោយក ២០២៥បានប្តេជ្ញាចិត្ត ក្នុងការបញ្ចប់ការឆ្លងមេរោគអេដស៍នៅឆ្នាំ ារអនុវត្តនូវផែនការ យុទ្ធសាស្ត្រជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបមេរោគអេដស៍ និងជំងឺអេដស៍លើកទី៤ ២០១៥)-២០២០របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍។ (

៣.២១៤- *ជំងឺគ្រុនចាញ់និងគ្រុនឈាម៖* នៅត្រឹមឆ្នាំ២០១៤ កម្ពុជាបានសម្រេចចំណុចដៅរបស់ គ.អ.ស.ក.ឆ្នាំ២០១៥ដែលអត្រាស្លាប់ដោយជំងឺគ្រុនចាញ់0,៧៨ក្នុងប្រជាជន១00 000នាក់។ អត្រាស្លាប់ដោយជំងឺគ្រុនចាញ់បានធ្លាក់ចុះពី៥,៣ ក្នុងប្រជាជន១00 000នាក់ ក្នុងឆ្នាំ២000 មក0,0១% ក្នុងប្រជាជន១00 000នាក់នៅឆ្នាំ២0១៦។ អត្រាអ្នកស្លាប់ដោយជំងឺគ្រុនឈាម មានការប្រែទៅតាមឆ្នាំ និងតាមសភាពធ្ងន់ធ្ងរនៃជំងឺ។ អត្រាស្លាប់នៃជម្ងឺគ្រុនឈាមប្រែប្រួលពី ១,២៣%នៅឆ្នាំ២០១២ ទៅ0,១% នៅឆ្នាំ២០១៦។

៣.២១៥- *ជំងឺរបេង៖* ជំងឺរបេងគឺជាប្រភេទជំងឺម៉្យាងដែលជាប់ទាក់ទងជាមួយភាពក្រីក្រនិងកង្វះ អាហារូបត្ថម្ភ ដែលត្រូវបានកាត់បន្ថយ។ អត្រាប្រេវ៉ាឡង់ជំងឺរបេងបានធ្លាក់ចុះពី១ ២៣0ករណី នៅឆ្នាំ២00៥ មកត្រឹម៦៩៤ករណី ក្នុងប្រជាជន១00 000នាក់ ក្នុងឆ្នាំ២0១៤។ ការគ្រប ដណ្តប់នៃវិធីសាស្ត្រព្យាបាលដោយត្រួតពិនិត្យផ្ទាល់កម្រិតមូលដ្ឋាននៃជំងឺរបេង(ដូតស៍ DOTS) រក្សាបាន១00 %នៃមណ្ឌលសុខភាពទូទាំងប្រទេស។

៣.២១៦- *ជំងឺមិនឆ្លងនិងជំងឺរ៉ាំរ៉ៃនិងបញ្ហាសុខភាពផ្សេងទៀត៖* ការប្រែប្រួលសុខភាពនិងប្រជា សាស្ត្រនៅកម្ពុជាត្រូវបានកើនមកជាមួយការកើនឡើងនូវនៃជំងឺមិនឆ្លង ជាពិសេសជំងឺទឹកនោម ផ្អែម ជំងឺលើសឈាម និងជំងឺមហារីក។ អត្រាមរណភាពដោយជំងឺមិនឆ្លងកំពុងកើនឡើង ហើយ ប្រេវ៉ាឡង់នៃកត្តាហានិភ័យក៏កំពុងកើនឡើងដែរ។ បច្ចុប្បន្ន ជំងឺមិនឆ្លងមានប្រមាណពាក់កណ្តា លនៃជំងឺទាំងអស់។ កត្តាហានិភ័យសំខាន់ៗសម្រាប់ជំងឺមិនឆ្លងគឺអាចការពារបាន ដែលមានដូច ជារបបអាហារមិនល្អ សកម្មភាពផ្នែករាងកាយ ការប្រើប្រាស់ថ្នាំជក់ និងការប្រើប្រាស់ជាតិអាល់ កុល។ រាជរដ្ឋាភិបាលបានបង្ហាញពីការប្តេជ្ញាចិត្តក្នុងការដោះស្រាយបញ្ហាជំងឺមិនឆ្លងនៅក្នុង ផែនការសកម្មភាពសម្រាប់ទប់ស្កាត់និងគ្រប់គ្រងជំងឺមិនឆ្លង(២០១៤-២០២០)។ ប៉ុន្តែ ការផ្តល់ សេវាសម្រាប់ជំងឺមិនឆ្លងនៅទាបនៅឡើយ។

**បញ្ហាប្រឈម**

៣.២១៧- មរណភាពមាតានិងកុមារ ជាពិសេសទារកស្លាប់នៅខ្ពស់ បើប្រៀបធៀបជាមួយបណ្តាប្រទេសក្នុងតំបន់។ លទ្ធផលសុខភាពក្នុងចំណោមប្រជាជនដែលមានលក្ខខណ្ឌសង្គមនិងសេដ្ឋកិច្ចខុសៗគ្នា នៅមិនទាន់មានសមធម៌។

៣.២១៨- កង្វះអាហារូបត្ថម្ភ (ស្រួចស្រាវនិងរ៉ាំរ៉ៃ) ក្នុងចំណោមស្ត្រីនិងកុមារតូចនៅខ្ពស់ ធ្វើឲ្យប៉ះពាល់ធ្ងន់ធ្ងរដល់ការអភិវឌ្ឍសុខភាពនិងស្មារតីរបស់កុមារ នៅដំណាក់ក្រោយៗនៃជីវិតរស់នៅ។

៣.២១៩- ឧប្បត្តិហេតុនៃកំណើនមានគភ៌ក្នុងវ័យជំទង់អាយុពី១៥-១៩ឆ្នាំ រួមជាមួយនឹងការសម្រាលកូនដោយស្ត្រីក្រីក្រនៅមូលដ្ឋានសុខាភិបាលនៅមានកម្រិតទាបនៅឡើយ ទោះបីជាបានកើនឡើងក្តី អាចធ្វើឲ្យយឺតយ៉ាវដល់ការកាត់បន្ថយមរណភាពមាតានិងទារក។

៣.២២០- ការចម្លងនៃមេរោគអេដស៍នៅតែគួរឲ្យព្រួយបារម្ភ ក្នុងក្រុមប្រជាជនមួយចំនួន ដូចជាស្ត្រីបម្រើការកន្លែងកំសាន្ត បុរសរួមភេទជាមួយបុរស អ្នកកែភេទ និងអ្នកចាក់គ្រឿងញៀន។ ថវិកាសរុបពីដៃគូអភិវឌ្ឍ សម្រាប់ការឆ្លើយតបមេរោគអេដស៍ មានការថយចុះ ដោយសារកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប ដែលបណ្តាលឲ្យយើងជាប្រទេសមិនសូវមានលក្ខណសម្បត្តិសមស្របសម្រាប់ទទួលបានការឧត្ថម្ភពីខាងក្រៅ។ ក្នុងដំណាក់កាលនេះ និន្នាការសកលលោកកំពុងវិវឌ្ឍន៍ដែលដៃគូអភិវឌ្ឍកំពុងជំរុញឲ្យមានការវិភាជថវិកាក្នុងស្រុកច្រើនជាងមុន។

៣.២២១- អត្រាស្រាវជ្រាវករណីថ្មីនៃជំងឺរបេងទាប រីឯករណីថ្មីនិងអត្រាស្លាប់នៃជំងឺរបេងនៅខ្ពស់ ហើយភាពស៊ាំនឹងឱសថព្យាបាលច្រើនមុខ នៅតែជាបញ្ហាប្រឈម ទោះបីជាសម្រេចបានអត្រាព្យាបាលជាសះស្បើយខ្ពស់ក្តី។

៣.២២២- ភាពស៊ាំរបស់មេរោគគ្រុនចាញ់ហ្វាល់ស៊ីប៉ារ៉ូម (falciparum malaria parasites) ជាមួយឱសថព្យាបាលអាតេមីស៊ីនិន (Artemisinin) នៅតែជាបញ្ហាចំបងដែលត្រូវយកចិត្តទុកដាក់នៅក្នុងប្រទេសកម្ពុជា ក៏ដូចជានៅក្នុងសកលលោក។

៣.២២៣- កំណើនប្រេវ៉ាឡង់នៃជំងឺមិនឆ្លង រួមជាមួយអាយុកាលរស់នៅវែងរបស់ប្រជាជន ព្រមទាំងនគរូបនីយកម្ម ជាបញ្ហាប្រឈមដល់រចនាសម្ព័ន្ធ និងវិធីសាស្ត្រនៃការផ្តល់សេវាសុខភាព។ បន្ទុកនៃជំងឺវិបល្លាសផ្លូវចិត្ត (mental health disorders) ជាសម្ពាធនៅក្នុងស្ថានភាពដែលប្រព័ន្ធសុខាភិបាលកំពុងតែអភិវឌ្ឍសមត្ថភាពឲ្យបានគ្រប់គ្រាន់ ដើម្បីឆ្លើយតបទៅនឹងតម្រូវការសេវា។

៣.២២៤- បញ្ហាប្រឈមចម្បងៗមួយចំនួនទៀត៖

- ជំងឺឆ្លងលេចឡើងថ្មីឬលេចឡើងសារជាថ្មីម្តងទៀត នៅតែជាបញ្ហាប្រឈមដល់ប្រពន្ធ័សុខាភិបាល និងបន្តគម្រាមកំហែងដល់សន្តិសុខសុខភាពអន្តរជាតិ ។ ហានិភ័យជាសក្តានុពលលើសុខភាពមនុស្ស ដែលបណ្តាលមកពីហានិភ័យសុខភាពបរិស្ថាន និងបំរែបំរួលអាកាសធាតុ ជាបញ្ហាប្រឈមនៃការឆ្លើយតបពហុវិស័យ។
- តម្រូវការសេវាសុខភាពមានគុណភាពបានកើនឡើង ដោយសារប្រជាពលរដ្ឋយល់ឃើញថាគុណភាពសេវាជាទូទៅដែលផ្តល់ដោយផ្នែកសាធារណៈនិងឯកជន នៅមិនទាន់គ្រប់គ្រាន់។ ការផ្តល់សេវាសុខភាពមានគុណភាពជួបឧបសគ្គ ដោយសារធនធានមិនគ្រប់គ្រាន់ ពិសេសធនធានមនុស្ស សមត្ថភាពធ្វើរោគវិនិច្ឆ័យ និងឱសថបរិក្ខារនៅខ្វះខាតដោយអន្លើ ។
- សមត្ថភាពសេវាសុខាភិបាលសាធារណៈ មិនទាន់ដោះស្រាយបានពេញលេញទៅនឹងបញ្ហាជំងឺឬបញ្ហាសុខភាពបណ្តាលមកពីជំងឺឆ្លង ជំងឺមិនឆ្លង-រ៉ាំរ៉ៃ ជំងឺផ្លូវចិត្ត និងការឆ្លើយតបបន្ទាន់បញ្ហាសុខភាពសាធារណៈ ដូចជាការផ្ទុះជំងឺឆ្លងលេចឡើងឬលេចឡើងជាថ្មី ការត្រៀមរៀបចំនិងឆ្លើយតបនឹងគ្រោះមហន្តរាយ។
- ចំណាយប្រាក់ហោប៉ៅលើសុខភាពខ្ពស់ រីឯការប្រមូលផ្តុំហានិភ័យមានកម្រិតទាប ដោយសារមានតែមូលនិធិសមធម៌សុខភាពសម្រាប់ប្រជាជនក្រីក្រ ចំណែកឯប្រព័ន្ធធានារ៉ាប់រងសុខភាពសង្គមសម្រាប់ប្រជាជននៃសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធ កំពុងស្ថិតនៅក្នុងដំណាក់កាលអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយ។
- ការរីកដុះដាលយ៉ាងលឿននៃសេវាសុខាភិបាលឯកជន នាំមកនូវបញ្ហាប្រឈមដល់មុខងារដឹកនាំ និងគ្រប់គ្រងរបស់ក្រសួងសុខាភិបាល និងសមត្ថភាពនិយ័តកម្មនៅក្នុងប្រពន្ធ័សុខាភិបាល។
- ប្រតិភូកម្មឬការប្រគល់មុខងារទៅរដ្ឋបាលថ្នាក់ក្រោមជាតិ តម្រូវឲ្យមានការកែសម្រួលមុខងារ និងរចនាសម្ព័ន្ធស្ថាប័នរបស់ក្រសួងសុខាភិបាល និងអង្គភាពសុខាភិបាលគ្រប់ថ្នាក់។

**តារាងទី៣.២៧ : សូចនាករសំខាន់ក្នុងវិស័យសុខាភិបាល**

| សូចនាករស្នូល | ទិន្នន័យដើមគ្រា | លទ្ធផលសម្រេចបាន | | គោលដៅចំណុច | | |
|---|---|---|---|---|---|---|
| | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ |
| ១. កម្មវិធីសុខភាពផ្លូវភេទ សុខភាពបន្តពូជ មាតា ទារក និងកុមារ និង អាហារូបត្ថម្ភ | | | | | | |
| ១. អត្រាមរណភាពមាតា (១០០ ០០០ទារកកើតរស់) | ២០៦ | ១៧០ | ១៧០ | | | ១៣០ |

| | | | | | | |
|---|---|---|---|---|---|---|
| ២. អត្រាមរណភាពទារក (១000ទារកកើតរស់) | ២៧ | ១៨ | ១៨ | | | ២០ |
| ៣. អត្រាមរណភាពកុមារក្រោម១ឆ្នាំ (១ 000ទារកកើតរស់) | ៤៥ | ២៨ | ២៨ | | | ៣២ |
| ៤. អត្រាមរណភាពកុមារក្រោម៥ឆ្នាំ (១ 000ទារកកើតរស់) | ៥៤ | ៣៥ | ៣៥ | | | ៤២ |
| ៥. %នៃស្ត្រីមិនចង់មានគភ៌ ដែលពុំបានទទួលសេវាពន្យារកំណើត | ១៦,៦ | ១៣ | ១៣ | | | ៨ |
| ៦. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់វិធីសាស្ត្រពន្យារកំណើតទំនើបមួយក្នុងចំណោមស្ត្រីបានរៀបការអាយុ ១៥-៤៩ឆ្នាំ | ៣៤,២៥ | ៣៥ | ៣៣,១៨ | ៣២,៦៥ | ៤២ | ៤៣ |
| ៧. %ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាល២លើក ដោយបុគ្គលិកសុខាភិបាល | ៨១,២ | ៩០,៥ | ៩៣,១៩ | ៩៦,៦ | ៩៣ | ៩៥ |
| ៨. %ស្ត្រីមានគភ៌ទទួលការថែទាំមុនសម្រាល៤លើក ដោយបុគ្គលិកសុខាភិបាល | ៥៦,៤៥ | ៦៦,៤ | ៧១,៥៣ | ៧២,២៣ | ៨៥ | ៨៧ |
| ៩. %នៃស្ត្រីមានគភ៌ផ្ទុកមេរោគអេដស៍ ដែលបានទទួលថ្នាំប្រឆាំងជំងឺអេដស៍សម្រាប់បង្ការការចម្លងពីម្តាយទៅទារក | ៧២ | ៧៧ | ៨៤ | ៩២ | ៨៦ | ៨៨ |
| ១០. សមាមាត្រនៃការសម្រាលដោយបុគ្គលិកសុខាភិបាលមានជំនាញ(%) | ៨៤,0 | ៨៥,0 | ៨៥,២ | ៨៥,0២ | ៨៩ | ៨៩ |
| ១១. សមាមាត្រនៃការសម្រាលនៅមូលដ្ឋានសុខាភិបាល (%) | ៨0,0 | ៨0,0 | ៨0,៣៥ | ៨0,៥២ | ៨៧ | ៨៨ |
| ១២. អត្រាសម្រាលដោយវិធីវះកាត់ (គិតជា%នៃចំនួនស្ត្រីសម្រាលកូនសរុប) | ៤,៣ | ៥,៣៧ | ៥,៣៥ | ៥,៤ | ៧,៥ | ៨,0 |
| ១៣. %នៃទារកបានទទួលការបំបៅដោយទឹកដោះម្តាយក្នុងអំឡុងពេលមួយម៉ោងដំបូងក្រោយកំណើត | | ៦៣ | ៧0 | ៦៤,៦ | ៨៥ | ៩0 |
| ១៤. %ស្ត្រីមានគភ៌បានទទួលជីវជាតិដែក អាស៊ីតហ្វូលីក ៩0គ្រាប់ | ៨៤,0 | ៨៦,១ | ៧៣ | ៨៦,៥ | ៩៣ | ៩៥ |
| ១៥. % នៃកុមារអាយុ១២-៥៩ខែបានទទួលថ្នាំទម្លាក់ព្រូនមេបង់ជាហូរលក្នុងរយៈពេល៦ខែចុងក្រោយ | ៧៤,៥ | ៧៦,0 | ៧0,0 | ៨៨,៤ | ៧៦ | ៧៩ |

| | | | | | | |
|---|---|---|---|---|---|---|
| ១៦. %នៃកុមារក្រោម១ឆ្នាំបានទទួលវ៉ាក់សាំងការពារជំងឺកញ្ជ្រឹល | ៩៣ | ៩៤ | ៩២ | ១០០ | ៩៥ | ៩៥ |
| ១៧. អត្រាគ្របដណ្តប់នៃវ៉ាក់សាំង៣ដូសបង្ការ ជំងឺខាន់ស្លាក់ ស្អិតដៃជើង តេតាណូស រលាកសួត (%) | ៩៥ | ៩៨ | ៩៥ | ១០០ | ៩៥ | ៩៥ |
| ១៨. ចំនួនលើកនៃការពិគ្រោះជំងឺក្រៅករណីថ្មីលើកុមារអាយុក្រោម៥ឆ្នាំម្នាក់ក្នុងមួយឆ្នាំ (ចំនួនលើក) | ១,៤៥ | ១,៤៥ | ១,៥២ | ១,៦៤ | ១,៦០ | ១,៦២ |
| **២ ជម្ងឺឆ្លង** | | | | | | |
| ១៩. អត្រាប្រេវ៉ាឡង់នៃអ្នកផ្ទុកមេរោគអេដស៍ក្នុងចំណោមមនុស្សអាយុ១៥-៤៩ ឆ្នាំ | ០,៧ | ០,៦ | ០,៦ | ០,៦ | ០,៦ | ០,៦ |
| ២០. % នៃមនុស្សពេញវ័យអាយុលើសពី១៤ឆ្នាំផ្ទុកមេរោគអេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៤៦,៦០៧** | ៤៨,៩២០** | ៧៩ | ៧៦.៥ | ៨៦ | ៨៨ |
| ២១. % នៃកុមារអាយុក្រោម១៤ឆ្នាំផ្ទុកមេរោគ អេដស៍បានទទួលការព្យាបាលដោយឱសថប្រឆាំងមេរោគអេដស៍ | ៤,០៥២** | ៣,៩៨៧** | ៩២ | ៩០ | ៩៥ | > ៩៥ |
| ២២. ប្រេវ៉ាឡង់នៃជំងឺរបេងគ្រប់សណ្ឋានលើប្រជាជន ១០០ ០០០ នាក់ | ៧២៥ | ៦៦៨ | ៧១៥ | ៦១២ | ៥៧១ | ៥៣០ |
| ២៣. អត្រាស្លាប់ជំងឺរបេង (ក្នុងចំណោមប្រជាជន ១០០ ០០០នាក់) | ៦៣ | ៥៨ | ៥៥ | ៥២ | ៤៩ | ៤៦ |
| ២៤. អត្រាជាសះស្បើយនៃការព្យាបាលជំងឺរបេង | ៩១ | > ៩០ | > ៩០ | ៩០ | > ៩០ | > ៩០ |
| ២៥. អត្រាស្លាប់នៃជំងឺគ្រុនចាញ់រាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈលើប្រជាជន ១០០ ០០០ នាក់ | ០,០៨ | ០,០៧ | ០,០៦ | ០,០១ | ០,០៨ | ០,០៨ |
| ២៦. ចំនួនករណីគ្រុនចាញ់ ព្យាបាលនៅមូលដ្ឋានសុខាភិបាលសាធារណៈក្នុងចំណោមប្រជាជន១ ០០០នាក់ (អាំងស៊ីដង់) | ១,៥ | ២,២៦ | ២,០ | ១,៥ | ១,៦៥ | ១,៤៥ |
| ២៧. អត្រាស្លាប់ដោយជំងឺគ្រុនឈាមបានរាយការណ៍ដោយសុខាភិបាលសាធារណៈ ក្នុងអ្នកជំងឺ១០០នាក់ | ០,៣ | ០,២ | ០,២ | ០,១ | ០,៥ | ០,៣ |

| | | | | | | |
|---|---|---|---|---|---|---|
| **៣ ជំងឺមិនឆ្លង** | | | | | | |
| ២៨. អត្រាប្រេវ៉ាឡង់នៃភាពពិការភ្នែក | ០,៣៨ | ០,៣៥ | ០,៣២ | ០,២៩ | ០,២៧ | ០,២៥ |
| ២៩. អត្រាវះកាត់ជំងឺភ្នែកឡើងបាយក្នុងចំណោមប្រជាជនមួយលាននាក់ | ១ ២០០ | ១ ៣០០ | ១ ៥០០ | ២ ៣០០ | ១ ៩០០ | ២ ០០០ |
| ៣០. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ថ្នាំជក់ក្នុងចំណោមបុរស និងស្ត្រី | ប: ៤២<br>ស: ១៧ | ប: ៤១<br>ស: ១៦ | ប: ៤០<br>ស: ១៥ | ប: ៣៩<br>ស: ១៤ | ប: ៣៨<br>ស: ១៣ | ប: ៣៧<br>ស: ១២ |
| ៣១. អត្រាប្រេវ៉ាឡង់នៃការប្រើប្រាស់ជាតិអាល់កុលក្នុងចំណោមបុរស និងស្ត្រី | ៥៣ | ៥២ | ៥២ | ៥១ | ៥០ | ៤៩ |
| ៣២. សមាមាត្រប្រជាជនដែលមានជំងឺវិបល្លាសផ្លូវចិត្តធ្ងន់ធ្ងរប្រើប្រាស់សេវាសុខភាពផ្លូវចិត្ត ទៅ តាមប្រភេទជំងឺ÷<br>- ជំងឺវិកលចរិតវ៉ុររ៉ៃ<br>- ជំងឺសៅហ្មងក្នុងចិត្ត | | | ១២ ៦៤៣<br>២២ ៦៨៣ | ១១ ៤១២<br>១៤ ៣៥០ | ១៦ ៦៥៤<br>២៤ ៤៩៨ | ១៧ ២៧០<br>២៥ ៤០៥ |
| ៣៣. សមាមាត្រប្រជាជនប្រើប្រាស់គ្រឿងញៀនបានទទួលសេវាព្យាបាលដោយ ATS និង Heroine (%) | | | ២២ | ២២ | ៥០ | ៦០ |
| **៤ ពង្រឹងប្រព័ន្ធសុខាភិបាល** | | | | | | |
| ៣៤. អត្រានៃការផ្តល់ឈាមដោយអ្នកស្ម័គ្រចិត្តមិនទទួលផលកម្រៃ | ៣៥ | ៣៣.៦ | ៣១ | ២៦,២ | ៣៥ | ៤០ |
| ៣៥. ចំនួនលើកនៃការពិនិត្យពិគ្រោះជំងឺករណីថ្មីសម្រាប់ប្រជាជនមួយនាក់ក្នុងមួយឆ្នាំ | ០,៦១ | ០,៥៩ | ០,៦១ | ០,៦៣ | ០,៧០ | ០,៧៥ |
| ៣៦. សន្ទស្សន៍នៃភាពពេញចិត្តរបស់អតិថិជនចំពោះសេវាសុខាភិបាល | ៨៦ | ៨៧ | ៨៧ | ៨៨ | ៨៨ | ៨៩ |
| ៣៧. អត្រានៃប្រជាជនរស់ក្រោមបន្ទាត់នៃភាពក្រីក្រត្រូវបានការពារដោយមូលនិធិសមធម៌ | ៨០ | ៩០ | ១០០ | ១០០ | ១០០ | ១០០ |
| ៣៨. សមាមាត្រនៃគ្រួសារ (% នៃចំនួនគ្រួសារសរុបទូទាំងប្រទេស) ជួបការចំណាយមានភយន្តរាយដោយសារការថែទាំសុខភាព | ៥,៥ | ៤,៤ | ៤,៧ | ៥ | ៤ | ៣ |
| ៣៩. សន្ទស្សន៍នៃគុណភាពព័ត៌មានសុខាភិបាល | ៨៦ | ៨៩,៣៤ | ៩១,៤៤ | ៩២,៧៨ | ៩៧ | > ៩៧ |

| | | | | | | |
|---|---|---|---|---|---|---|
| ៤០. អត្រានៃគណៈកម្មការគ្រប់គ្រងមណ្ឌលសុខភាពដែលដំណើរការ | ៨០ | ៨៥ | ៨៥ | ៦៤ | ៨៥ | ៨៥ |

## សន្តិសុខស្បៀងនិងអាហារូបត្ថម្ភ

**៣.២២៥-** ភាពក្រីក្រម្ហូបអាហារត្រូវបានកាត់បន្ថយពី២០%ក្នុងឆ្នាំ១៩៩៣មក៤,១%ក្នុងឆ្នាំ ២០១០ និងមក០%ក្នុងឆ្នាំ២០១៤ លើសចំណុចដៅនៅក្នុងគ.អ.ស.ក.មុនពេលកំណត់។ សូនាករសំខាន់សម្រាប់អាហារូបត្ថម្ភបង្ហាញវឌ្ឍនភាពល្អ ប៉ុន្តែបញ្ហាកង្វះអាហារូបត្ថម្ភនៅខ្ពស់នៅឡើយ។ នៅថ្នាក់ជាតិ កុមារក្រិនត្រូវបានកាត់បន្ថយពី៤៤,៦%ក្នុងឆ្នាំ២០០០មក៣២%ក្នុងឆ្នាំ ២០១៤ ប៉ុន្តែនៅខ្ពស់ជាងចំណុចដៅរបស់ផ.យ.អ.ជ.(២៥%)ក្នុងឆ្នាំ២០១៨។ កុមារស្គមស្គាំងនៅថ្នាក់ជាតិជាមធ្យម១០% ខ្ពស់ជាងចំណុចដៅ(៩%)បន្តិចសម្រាប់ឆ្នាំ២០១៥។ កុមារខ្វះទម្ងន់នៅថ្នាក់ជាតិជាមធ្យម២៤,៦%នៅក្នុងឆ្នាំ២០១៤ ដែលបង្ហាញពីវឌ្ឍនភាពច្រើនចាប់តាំងពីឆ្នាំ ២០០០មក។ យោងតាមទិន្នន័យពីអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជាឆ្នាំ២០១៤ ប្រមាណ ៧៨,៨% នៃកុមារអាយុក្រោម៦ឆ្នាំនិង៧៣,៥%ក្នុងក្រុមអាយុ៦-១១ឆ្នាំមានជំងឺខ្វះគ្រាប់ឈាមក្រហម និងមានកម្រិតខុសគ្នាតាមខេត្តនិងក្រុមចំណូល។

**៣.២២៦-** កម្ពុជាមានវឌ្ឍនភាពល្អសម្រាប់ការផ្គត់ផ្គង់ទឹកស្អាតជនបទដែលបានកើនឡើងពី ២៤%ក្នុងឆ្នាំ១៩៩៨ទៅ៤៧%ក្នុងឆ្នាំ២០១៤និងអនាម័យជនបទបានកើនឡើង៨,៦%ក្នុងឆ្នាំ ១៩៩៦ទៅ៤៦%ក្នុងឆ្នាំ២០១៤។ ផ.យ.អ.ជ.បានកំណត់ចំណុចដៅ៦០%សម្រាប់ទឹកស្អាតនិងអនាម័យនៅត្រឹមឆ្នាំ២០១៨។ ផែនការយុទ្ធសាស្ត្រជាតិសម្រាប់ទឹកស្អាតនិងអនាម័យជនបទ ២០១៤-២០២៥ត្រូវបានអនុម័តនៅខែមករា ឆ្នាំ២០១៤។

**៣.២២៧-** យុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ២០១៤-២០១៨ ត្រូវបានរៀបចំ និងសម្ពោធន៍ ដាក់ឲ្យប្រើប្រាស់ជាផ្លូវការកាលពីខែសីហាឆ្នាំ២០១៤ ។ លទ្ធផលដំបូងនៃយុទ្ធសាស្ត្រនេះគឺការរៀបចំផែនទីបង្ហាញផ្លូវសម្រាប់ពន្លឿនការកែលម្អអាហារូបត្ថម្ភ ២០១៤-២០២០ និងកិច្ចពិភាក្សាលើផែនការវិនិយោគរវាងក្រសួងសុខាភិបាល ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ កម្ពុជាបានចូលជាផ្លូវការ ជាសមាជិកទី៥៣នៃចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភ ពិភពលោក នៅខែកក្កដាឆ្នាំ២០១៤។ កិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ ក្រសួងសុខាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិលវិស័យសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ បានរៀបចំក្របខ័ណ្ឌតាមដាននិងរាយការណ៍មួយ ដើម្បីតាមដានវឌ្ឍនភាពធៀបនឹងគោលបំណងនៅក្នុងចលនាបង្កើនកិច្ចអន្តរាគមន៍អាហារូបត្ថម្ភ។

៣.២២៨- ផែនការសកម្មភាពជាតិស្តីពីគំនិតផ្តួចផ្តើមសម្រាប់កាត់បន្ថយភាពអត់ឃ្លានឲ្យដល់កម្រិតសូន្យនៅកម្ពុជា ២០១៦-២០២៥ ត្រូវបានរៀបចំនិងប្រកាសផ្សព្វផ្សាយដាក់ឲ្យអនុវត្តជាផ្លូវការ នៅខែឧសភាឆ្នាំ២០១៦ ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវគ្រប់ជ្រុងជ្រោយមួយ និងការអន្តរាគមន៍ជាអន្តរៈវិស័យ ក្នុងការសម្រេចឲ្យបានគោលដៅទី២នៃគោលដៅអភិវឌ្ឍន៍ដោយប្រកបដោយចីរភាពគឺ "បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង និងកែលម្អអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មដែលមាននិរន្តរភាព"។

**បញ្ហាប្រឈម**

៣.២២៩- ទោះបីមានវឌ្ឍនភាពល្អសម្រាប់សន្តិសុខស្បៀង កង្វះអាហារូបត្ថម្ភនៅតែមានកម្រិតខ្ពស់នៅឡើយ រួមទាំងភាពខុសគ្នាផ្នែកសេដ្ឋកិច្ច សង្គមកិច្ច និងតាមតំបន់។ គ្រួសារនៅគ្រប់ក្រុមចំណូល ជាពិសេសក្នុងក្រុមចំណូលទាបខ្វះព័ត៌មាននិងការយល់ដឹងអំពីអាហារូបត្ថម្ភ។

៣.២៣០- ក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្ម និងជនបទ ក្រសួង ស្ថាប័នពាក់ពន្ធ័ពុំមានកញ្ចប់ថវិកាគ្រប់គ្រាន់សម្រាប់សម្របសម្រួល អនុវត្ត និងតាមដានយុទ្ធសាស្ត្រជាតិស្តីពីសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ និងយុទ្ធសាស្ត្រផ្សេងៗទៀត។ រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ត្រូវកំណត់អាទិភាពវិនិយោគ ដើម្បីកែលម្អប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិក្នុងការវិនិយោគលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ។ មានសារៈសំខាន់ក្នុងការបន្តជាមួយដំណើរការតាមដាន ដូចជាអង្កេតសុខភាព និងប្រជាសាស្ត្រកម្ពុជា។ បញ្ហាទាក់ទងនឹងហិរញ្ញវត្ថុ ស្រាប់ការសិក្សាទាំងនេះនឹងត្រូវដោះស្រាយតាមរយៈការពិភាក្សារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍពាក់ព័ន្ធ។

៣.២៣១- សកម្មភាពបញ្ចូលមីក្រូសារធាតុក្នុងចំណីអាហារដូចជាអំបិលអ៊ីយ៉ូដនិងការបញ្ចូលជាតិដែកទៅក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវត្រូវបានអនុវត្តដោយមានយន្តការរឹងមាំដើម្បីធានាស្តង់ដារគុណភាពខ្ពស់។ ការអនុវត្តអនុក្រឹត្យលេខ១៣៣ ទាក់ទងនឹងការបំបៅទឹកដោះ ក្នុងការកាត់បន្ថយការប្រើប្រាស់ទឹកដោះគោ និងតម្រូវឲ្យមានការចូលរួមរបស់វិស័យឯកជនទាក់ទងនឹងសុវត្ថិភាពនិងសន្តិសុខស្បៀងនិងអាហារូបត្ថម្ភ។

## ៧.៣- ការអភិវឌ្ឍប្រព័ន្ធសុវត្ថិភាពសង្គម

៣.២៣២- រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពល្អក្នុងការពង្រឹងប្រព័ន្ធគាំពារសង្គមនិងបានធ្វើឲ្យប្រព័ន្ធនេះក្លាយជាប្រព័ន្ធមួយដែលមានលក្ខណៈសមាហរណកម្ម សង្គតិភាព និងប្រសិទ្ធភាពដែលគ្របដណ្តប់លើវិស័យសាធារណៈនិងវិស័យឯកជន រួមមានការបែងចែកតួនាទីច្បាស់លាស់រវាងការរៀបចំគោលនយោបាយ ច្បាប់ និងការប្រតិបត្តិ។ សមិទ្ធផលមួយចំនួនស្តីពីសុវត្ថិភាពសង្គម មានដូចខាងក្រោម៖

៣.២៣៣- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធនិងក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្ម និងជនបទ បានដឹកនាំរៀបចំក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសន្តិសុខសង្គម ២០១៦-២០២៥ ដែលមានពីរផ្នែកធំៗគឺជំនួយសង្គមនិងធានារ៉ាប់រងសង្គម។ ដៃគូអភិវឌ្ឍបានសហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្ម និងជនបទនិងរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការសាកល្បង គម្រោងគាំទ្រចំណូលដែលនឹងផ្ដល់ជាមេរៀននិងបទពិសោធន៍សម្រាប់ការរៀបចំសមាសធាតុគាំទ្រចំណូលនៃជំនួយសង្គមនៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសន្តិសុខសង្គម។

៣.២៣៤- កម្មវិធីកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រសម្រេចបានការគ្របដណ្ដប់តំបន់ជនបទទាំងអស់។ ចាប់តាំងពីឆ្នាំ២០១៥ ក្រសួងផែនការមានភាពជាម្ចាស់ពេញលេញលើផ្នែកហិរញ្ញវត្ថុសម្រាប់ការគ្របដណ្ដប់តំបន់ជនបទ។ យន្តការកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រនៅទីប្រជុំជនកំពុងសាកល្បង ដែលបានបញ្ចូលការដាក់ពិន្ទុលើលក្ខណៈវិនិច្ឆ័យភាពងាយរងគ្រោះដូចជាសុខភាព ពិការ ការអប់រំ និងបំណុល។ ការដាក់ពិន្ទុនេះអាចត្រូវបានអនុវត្តជាមួយតំបន់ជនបទ។ មានវឌ្ឍនភាពល្អក្នុងការអភិវឌ្ឍក្របខ័ណ្ឌស្ថាប័នគាំទ្រសុខមាលភាពកុមារ រួមទាំងផែនការកំណែទម្រង់ប្រព័ន្ធព្រហ្មទណ្ឌយុត្តិធម៌អនីតិជន ឆ្នាំ២០១៣។ អង្កេតស្ដីពីអំពើហិង្សាលើកុមារត្រូវបានបោះពុម្ពក្នុងឆ្នាំ២០១៤។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរាយការណ៍ពីវឌ្ឍនភាពទាក់ទងនឹងការអនុវត្តអនុសញ្ញាអន្តរជាតិស្ដីពីសិទ្ធិកុមារ ក្នុងនាមដែលកម្ពុជាជាប្រទេសហត្ថលេខី។

៣.២៣៥- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបន្តគ្រប់គ្រងប្រព័ន្ធស្បៀងបម្រុងដើម្បីគាំទ្រដល់ការសង្គ្រោះបន្ទាន់ពេលមានគ្រោះមហន្តរាយធម្មជាតិឬព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។
ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សម្រេចបានសមិទ្ធផលដូចខាងក្រោម៖

**លើកកម្ពស់សុខុមាលភាពសង្គមនិងកិច្ចការគ្រួសារ**

- បានបង្កើត និងអនុវត្តកម្មវិធីសង្គ្រោះបន្ទាន់ដល់ប្រជាជនក្រីក្រ ទុរគតជន ប្រជាជនរងគ្រោះដោយគ្រោះធម្មជាតិរងគ្រោះដោយគ្រោះមហន្តរាយផ្សេងៗ ព្រមទាំងបានសហការជាមួយអាជ្ញាធរខេត្ត កាកបាទក្រហមកម្ពុជា អង្គការជាតិ អន្តរជាតិ សប្បុរសជននានានាំយកអំណោយជួយដល់ប្រជាជនរងគ្រោះ ប្រជាជនក្រីក្រ ទុរគតជនប្រមាណ៣០៨ ២៧៥ គ្រួសារ ជួយសម្រាលស្ថានភាពលំបាក ទប់ស្កាត់ និង កាត់បន្ថយការធ្វើចំណាកស្រុក។
- បានអភិវឌ្ឍមជ្ឈមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញ និង សមាហរណកម្មជនអនាថា
- បានបង្កើតមជ្ឈមណ្ឌលព្យាបាល និង ថែទាំជននវិបល្លាសស្មារតី។
- បានផ្សព្វផ្សាយ អប់រំ និងបញ្ជ្រាបការយល់ដឹងស្ដីពីការធ្វើចំណាកស្រុកគ្មានសុវត្ថិភាពដល់ប្រជាជន

- បានផ្តល់សេវាថែទាំ និងគាំទ្រនៅសហគមន៍ដល់ជនរងគ្រោះ និងរងផលប៉ះពាល់ដោយសារមេរោគអេដស៍ ជំងឺអេដស៍ និងជំងឺកាចសាហាវផ្សេងៗ ក្នុងនោះ មានការអប់រំផ្សព្វផ្សាយ វគ្គបំណិនជីវិត អប់រំសុខភាព ពន្យារកំណើត សេវាប្រឹក្សាយោបល់ និងការបង្កើតមុខរបរខ្នាតតូចដល់គ្រួសារ និងកុមារដែលរងផលប៉ះពាល់ដោយសារជំងឺអេដស៍
- បានបង្កើត និងអនុវត្តកម្មវិធីស្តីពីការអភិវឌ្ឍគ្រួសារ បំផុសលើកទឹកចិត្តការកសាងគ្រួសារល្អ ទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ
- បានរៀបចំ និងផ្សព្វផ្សាយដាក់ឲ្យអនុវត្តនូវបទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមជ្ឈមណ្ឌល និងឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយនិងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្សទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មជួញដូរមនុស្ស និងសង្គ្រោះជនរងគ្រោះ។

### លើកកម្ពស់សុខុមាលភាពកុមារនិងយុវនីតិសម្បទា

- បានរៀបចំរបាយការណ៍ស្តីពីស្ថានភាពកុមារ និងបានកំពុងរៀបចំរបាយការណ៍ជាតិខួបលើកទី៤ ទី៥ និងទី៦ ស្តីពីការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ។
- បានពង្រឹងការអនុវត្តការចូលរួមរបស់កុមារ តាមរយៈការផ្សព្វផ្សាយ និង ការបណ្តុះបណ្តាលអំពីសិទ្ធិកុមារ គោលការណ៍ណែនាំសម្រាប់អនុវត្តការចូលរួមរបស់កុមារដល់អ្នកពាក់ព័ន្ធ។
- បានពង្រឹងពង្រីកយន្តការតាមដាន និងអនុវត្តសិទ្ធិកុមារ ដោយបានបង្កើតក្រុមការងារកុមារតាមក្រសួង ស្ថាប័នចំនួន១០ និង ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមាររាជធានី ខេត្តទាំង២៥។
- ដើម្បីលើកកម្ពស់សិទ្ធិជាមូលដ្ឋានទាំង៤ និងឧត្តមប្រយោជន៍របស់កុមារ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានខិតខំប្រឹងប្រែងអនុវត្តដោយយកចិត្តទុកដាក់ និងស្មារតីទទួលខុសត្រូវ តាមរយៈការរៀបចំលិខិតបទដ្ឋានគតិយុត្ត ផ្សព្វផ្សាយបំផុសការយល់ដឹងអំពីសិទ្ធិរបស់កុមារ ការអន្តរាគមន៍ជួយសង្គ្រោះ ការផ្តល់ការស្នាក់នៅ និង ការថែទាំសុខភាព។ រាជរដ្ឋាភិបាលកម្ពុជា បានចេញអនុក្រឹត្យចំនួន២ ស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ និង ស្តីពីរបបគោលនយោបាយចំពោះជនរងគ្រោះស្នាក់នៅក្នុងមណ្ឌលរបស់រដ្ឋ ដោយបានដំឡើងប្រាក់ម្ហូបអាហារពី៤ ៥០០រៀល/ខែ ទៅ១៥០ ០០០រៀល/ខែ។
- បានសហការជាមួយអង្គការជាតិ អន្តរជាតិ ទទួលកុមារកំព្រា និងកុមារងាយរងគ្រោះ ឲ្យស្នាក់នៅមណ្ឌលថែទាំកុមារ៦៣៩កន្លែង មានកុមារសរុបចំនួន ២៦ ១៨៧នាក់ ក្នុងនោះមណ្ឌលថែទាំកុមារចំនួន៤០៦កន្លែង មានកុមារសរុបចំនួន ១៦ ៥៧៩នាក់ (មណ្ឌលរដ្ឋចំនួន២២កន្លែង មានកុមារនិងយុវជនចំនួន ១ ៦០១នាក់) ផ្ទះស្នាក់នៅបណ្តោះអាសន្នចំនួន២៥កន្លែង មានកុមារចំនួន៦២៨នាក់។ ផ្ទះស្នាក់នៅជាក្រុមចំនួន៧១កន្លែង មានកុមារចំនួន ១ ៥៩២នាក់ ក្រៅពីនោះមានកុមារមួយចំនួនកំពុងស្នាក់នៅអន្តេវាសិកដ្ឋានវត្តអារាម និង ទីកន្លែងសាសនា និង កុមាររងគ្រោះមួយចំនួនទៀតបានទទួលចិញ្ចឹមថែ ទាំ និងផ្តល់សេវាផ្សេងៗនៅតាមសហគមន៍។ មជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋ និងអង្គការមិនមែនរដ្ឋាភិបាលជាច្រើនកន្លែងបានទទួលការឧបត្ថម្ភដ៏ថ្លៃថ្លាពី សម្តេចអគ្គមហាសេនា

បតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចកិត្តិព្រឹទ្ធបណ្ឌិត មានជាថវិកា អង្ករ និង អាហារជួបជុំ។

- បានទទួលជនរងគ្រោះដោយសារប្រើប្រាស់គ្រឿងញៀន ដើម្បីបន្សាប ព្យាបាលនិងស្តារនីតិសម្បទា បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សមាហរណកម្ម និង តាមដានបន្តតាមសហគមន៍។
- បានអនុវត្តនូវកម្មវិធីយុត្តិធម៌សម្រាប់អនីតិជន ផ្តល់នូវសេវាការពារសិទ្ធិកុមារតាមផ្លូវច្បាប់ និងទប់ស្កាត់អំពើល្មើសច្បាប់ដែលប្រព្រឹត្តដោយអនីតិជន និងយុវជននៅតាមសហគមន៍ និងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័ត និងប្រកាសដាក់ឲ្យប្រើប្រាស់។ លិខិតបទដ្ឋានគតិយុត្តមួយចំនួនត្រូវបានរៀបចំសម្រាប់អនុវត្តច្បាប់នេះ ព្រមទាំងកំពុងរៀបចំផែនការយុទ្ធសាស្ត្រនិងផែនការប្រតិបត្តិរយៈពេល៣ឆ្នាំ។
- បានបង្កើតយន្តការ និងរៀបចំលិខិតបទដ្ឋានគតិយុត្តជាច្រើនទាក់ទងនឹងការសុំកូនអន្តរប្រទេស និងបានសហប្រតិបត្តិការ និងចុះកិច្ចព្រមព្រៀងស្តីពីការកំណត់ចំនួនទីភ្នាក់ងារជាមួយសុំកូនអន្តរប្រទេសជាមួយប្រទេសអ៊ីតាលី ប្រទេសអេស្ប៉ាញ ព្រមទាំងបានធ្វើកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសដែលជាភាគីអនុសញ្ញាក្រុងឡាអេ។

**លើកកម្ពស់សុខុមាលភាពសម្រាប់ជនពិការ**

- បានរៀបចំនិងប្រកាសផ្សព្វផ្សាយដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព ២០១៤-២០១៨ ព្រមទាំងបានចុះផ្សព្វផ្សាយនីថ្នាក់រាជធានី ខេត្តចំនួន១៩។
- បានបើកផ្តល់របបគោលនយោបាយជនពិការក្រីក្រជូនជនពិការក្រីក្រតាមសហគមន៍ នៅក្នុងខេត្តចំនួន៤ គឺ ប៉ៃលិន ត្បូងឃ្មុំ ព្រៃវែង និង ស្វាយរៀង។
- បានរៀបចំ និង ដាក់ឲ្យអនុវត្តអនុក្រឹត្យស្តីពីការផ្តល់ប្រាក់រង្វាន់ចំពោះជ័យលាភីជនពិការក្នុងការប្រកួតមុខជំនាញ ការប្រកួតកីឡាស៊ែរស៊្យាល់អូឡាំពិក និង ប្រាក់ឧបត្ថម្ភសម្រាប់គ្រូបង្វឹក គ្រូបង្វឹកជំនួយ។
- បានផលិត និង ផ្សព្វផ្សាយកិច្ចពិភាក្សាស្តីពីជនពិការភាពបានចំនួន៣៨ប្រធានបទ តាមរយៈស្ថានីយ៍ទូរទស្សន៍ជាតិកម្ពុជា។
- បានបើកផ្តល់ឧបករណ៍តន្ត្រី និង ថវិកាប្រចាំខែជូនក្រុមតន្ត្រីជនពិការ ដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។
- បានប្រគល់រទេះរុញចំនួន៤៩០គ្រឿង ជូនជនពិការ
- បានសហការជាមួយអង្គការដៃគូ ផ្តល់សេវាស្តារលទ្ធភាពពលកម្មប្រកបដោយគុណភាពដោយឥតគិតថ្លៃ ព្រមទាំងផ្តល់ការឧបត្ថម្ភជាប្រាក់អាហារ និងថ្លៃធ្វើដំណើរទៅមកជូនជនពិការ ២០៤ ៦៨៩នាក់។

**លើកកម្ពស់សុខុមាលភាពមនុស្សចាស់**

- បានរៀបចំ និងកែសម្រួលគោលនយោបាយជាតិសម្រាប់មនុស្សចាស់។
- បានរៀបចំទិវាមនុស្សចាស់ ១ តុលា ជារៀងរាល់ឆ្នាំ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ
    - បាននឹងកំពុងអនុវត្តសំខាន់កម្មវិធីពីរ គឺ កម្មវិធីអភិវឌ្ឍមនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារ តាមរយៈ ការផ្សព្វផ្សាយលើកកម្ពស់ប្រពៃណី

ទំនៀមទម្លាប់ល្អរបស់គ្រួសារខ្មែរ និងសកម្មភាពរបស់សមាគមមនុស្សចាស់ ដែលរហូតមកដល់ពេលនេះ សមាគមមនុស្សចាស់នៅតាមឃុំ សង្កាត់មានចំនួន៥១០សហគមន៍។

**លើកកម្ពស់វិស័យអតីតមន្រ្តីរាជការស៊ីវិល**

- បានរៀបចំ និងដាក់ឲ្យដំណើរការជាបន្តបន្ទាប់នូវរបបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ដែលមានតាវកាលិកចំនួន៦ រួមមាន ការចូលនិវត្តន៍ ការបាត់បង់សម្បទាវិជ្ជាជីវៈ មាតុភាព គ្រោះថ្នាក់ការងារ មរណភាព និងអ្នកនៅក្នុងបន្ទុក។ របបសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល ត្រូវបានដំឡើងជារៀងរាល់ឆ្នាំស្របតាមការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និង លទ្ធភាពថវិកាជាតិ។

**លើកកម្ពស់វិស័យអតីតយុទ្ធជន**

- បានដំឡើងប្រាក់របបសន្តិសុខសង្គមជារៀងរាល់ឆ្នាំ គិតត្រឹមឆ្នាំ២០១៦ ប្រាក់របបសន្តិសុខសង្គមទាបបំផុត ៣៦០ ០០០រៀល/ខែ។
- បានអនុវត្តគោលការណ៍ ស្តីពីការកំណត់អត្តសញ្ញាណកងកម្លាំងប្រដាប់អាវុធចូលនិវត្តន៍ ចូលបាត់បង់សមត្ថភាពការងារ ពិការ និងគ្រួសារយុទ្ធជនពលី មរណៈដោយបានទទួលសំណុំលិខិតអ្នកដាក់ពាក្យស្នើសុំសម្បទាជីសង្គមកិច្ចចំនួន១៣,២៤៧គ្រួសារ និងគណៈកម្មាធិការសម្បទាជីសង្គមកិច្ចថ្នាក់ជាតិបានផ្តល់សម្បទានដីសង្គមកិច្ចបានចំនួន៣៣០៤គ្រួសារ។
- បានរៀបចំបង្កើតគណៈកម្មការអភិវឌ្ឍន៍សហគមន៍អតីតយុទ្ធជននៅតាមឃុំ សង្កាត់ចំនួន ៨៥៣ឃុំ សង្កាត់ ដើម្បីកែលម្អជីវភាពរស់នៅរបស់អតីតយុទ្ធជន និង គ្រួសារឲ្យកាន់តែប្រសើរឡើង។

**បង្កើតរបបសន្តិសុខសង្គមសម្រាប់ប្រជាជនទូទៅ**

- ក្រសួងបាននិងកំពុងសិក្សាស្រាវជ្រាវឯកសារនានា ដើម្បីរៀបចំបង្កើតប្រព័ន្ធសន្តិសុខសង្គមទូលំទូលាយសម្រាប់មជ្ឈដ្ឋាននានានិងប្រជាជនទូទៅ។

**ពង្រឹងសមត្ថភាពស្ថាប័ននិងភាពជាដៃគូ**

- បានពង្រឹង និងពង្រីកសកម្មភាពវិទ្យាស្ថានជាតិសង្គមកិច្ច សំដៅបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ដែលពាក់ព័ន្ធនឹងការងារសង្គមកិច្ច។
- ក្រសួងបានលើកទឹកចិត្ត និងសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិនិងដៃគូអភិវឌ្ឍនានា ក្នុងស្មារតីសាមគ្គីធម៌និងកៀរគរប្រភពធនធានទាំងសម្ភារៈ ថវិកា និងបច្ចេកទេស បម្រើឲ្យសំណូមពររបស់ជនរងគ្រោះ និងងាយរងគ្រោះគ្រប់ប្រភេទក្នុងសង្គម និងបានធ្វើសហប្រតិបត្តិការយ៉ាងជិតស្និទ្ធទាំងក្នុងក្របខ័ណ្ឌតំបន់ អាស៊ាន និងពិភពលោកពាក់ព័ន្ធនឹងវិស័យសុខុមាលភាពសង្គម និងការអភិវឌ្ឍ។

**បញ្ហាប្រឈម**

៣.២៣៦- ជំនួយផ្នែកសង្គម សម្រាប់គ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះនិងធានារ៉ាប់រងសង្គម សម្រាប់និយោជិកក្នុងវិស័យផ្លូវការនៅមានកម្រិតនិងមិនទានគ្រប់ដណ្តប់បាន៦០%នៃប្រជាជន រួមទាំងប្រជាជនពិការនិងមនុស្សចាស់ ដែលភាគច្រើនស្ថិតក្នុងវិស័យមិនផ្លូវការ។

- របបសន្តិសុខសង្គមប្រចាំខែរបស់អតីតយុទ្ធជនដែលផ្ទេរមកមុន (ចាស់) និងផ្ទេរមកក្រោយ (ថ្មី) ពុំមានសង្គតិភាពជាមួយគ្នា។
- របបសន្តិសុខសង្គមរបស់និវត្តន៍ជននៃក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃមានការអនុវត្តរបប សោធនខុសគ្នា។

៣.២៣៧- ការគ្រប់គ្រងគម្រោងផ្សេងៗមិនទាន់ត្រូវបានរៀបចំនិងបញ្ចូលគ្នាបានត្រឹមត្រូវ ដែលបណ្តាលឲ្យកង្វះខាតប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធ។ ការសម្របសម្រួលនៅមានកម្រិតនៅកម្រិតគោលនយោបាយនិងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីធានាពីគណនេយ្យភាពនិងតម្លាភាពរបស់ប្រតិបត្តិការនៅកម្រិតគម្រោងឬកម្មវិធី។

៣.២៣៨- ការរៀបចំហិរញ្ញប្បទានសម្រាប់ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសន្តិសុខសង្គមតម្រូវឲ្យមានកិច្ចពិភាក្សារវាងរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍពាក់ព័ន្ធ។ ឧទាហរណ៍ ក្រសួងដែលមានតួនាទីផ្តល់សេវាសង្គមដល់ក្រុមងាយរងគ្រោះ ដូចជាក្រសួងសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងក្រសួងកិច្ចការនារី ពុំទាន់មានធនធានគ្រប់គ្រាន់ដើម្បីសម្រេចបានគោលបំណងគោលនយោបាយនានា។

៣.២៣៩- ការកំណត់អត្តសញ្ញាណនិងការចុះបញ្ជីប្រជាជនទូទៅ ការកំណត់អត្តសញ្ញាណប្រជាជននិងប្រជាជនងាយរងគ្រោះ និងប្រព័ន្ធចុះបញ្ជីប្រតិបត្តិករមិនទាន់មានទំនាក់ទំនងគ្នា ដែលអាចមាន ការកំណត់អត្តសញ្ញាណនិងការចុះបញ្ជីជាន់គ្នានិងការផ្តល់ផលប្រយោជន៍ផ្សេងៗត្រួតគ្នា។ ការពង្រឹងយន្តការកំណត់អត្តសញ្ញាណគ្រួសារក្រីក្រនៅពេលមានការធ្វើចំណាកស្រុកច្រើននិងចំនួនប្រជាជនងាយរងគ្រោះដែលស្ថិតនៅក្បែរខ្សែបន្ទាត់ភាពក្រីក្រ។

៣.២៤០- សមត្ថភាពនៅមានកម្រិតទាក់ទងនឹងកង្វះខាតមន្ត្រីជំនាញសង្គមកិច្ចដែលទទួលបានការបណ្តុះបណ្តាលដើម្បីគ្រប់គ្រងករណីនានាទាក់ទងនឹងសុខាមាលភាពកុមារ សិទ្ធិ និងការការពារ រួមទាំងការថែរក្សាក្នុងមណ្ឌល។

## ៧.៤- ពង្រឹងការអនុវត្តគោលនយោបាយប្រជាជននិងសមភាពយេនឌ័រ

### គោលនយោបាយប្រជាជន

៣.២៤១- អគ្គលេខាធិការប្រជាជននិងការអភិវឌ្ឍត្រូវបានបង្កើតឡើងនៅខែកុម្ភៈ ឆ្នាំ២០១៤ ដែលដើរតួនាទីជាស្ថាប័នបច្ចេកទេសកណ្តាលក្នុងការរៀបចំគោលនយោបាយ យុទ្ធសាស្ត្រ និង កម្មវិធីគាំទ្ររាជរដ្ឋាភិបាលក្នុងការអនុវត្ត និងតាមដានគោលនយោបាយរបស់រាជរដ្ឋាភិបាល ទាក់ទងនឹងប្រជាជននិងការអភិវឌ្ឍ។ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ត្រូវបាន ទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦។ គោល នយោបាយនេះ រួមចំណែកក្នុងការបន្តលើកកម្ពស់គុណភាពជីវិតនិងសុខុមាលភាពរបស់ប្រជា ជនកម្ពុជា និង ការកាត់បន្ថយភាពក្រីក្រ និងផលប៉ះពាល់ នៃប្រែប្រួលប្រជាសាស្ត្រទៅលើការ អភិវឌ្ឍ តាមរយៈការជំរុញឲ្យមានការបញ្ចូលបញ្ហាប្រជាជន និងកត្តា ឌីណាមិកប្រជាសាស្ត្រ ទៅ ក្នុងផែនការអភិវឌ្ឍន៍គ្រប់វិស័យ គ្រប់កម្រិត និងនៅក្នុងក្របខ័ណ្ឌនៃការអភិវឌ្ឍ ជាតិនិងសកល ដោយរក្សានូវតម្លៃវប្បធម៌និងប្រពៃណីខ្មែរ និងការធានាការគោរពសិទ្ធិមនុស្សជាមូលដ្ឋាន។ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ បន្តឈរលើគោលការណ៍ ដែលមានចែងនៅ ក្នុង គោល នយោបាយជាតិប្រជាជនឆ្នាំ២០០៣ ដោយទទួលស្គាល់និងគាំទ្រចំពោះសិទ្ធិរបស់គូ ស្វាមីភរិយានិងបុគ្គលទាំងអស់ ឲ្យមានសិទ្ធិជាមូលដ្ឋានក្នុងការសម្រេចចិត្តដោយសេរី និងដោយ ទទួលខុសត្រូវលើចំនួនកូន និង ការពន្យារកំណើត ហើយឲ្យមានលទ្ធភាពទទួលបាននូវព័ត៌មាន ការអប់រំ សេវា និង មធ្យោបាយ ដើម្បីធ្វើការសម្រេចចិត្តនេះ។ លើសពីនេះទៀត គោល នយោបាយនេះ ក៏បានវិភាគអំពីទិដ្ឋភាពរួមនៃការអភិវឌ្ឍ សេដ្ឋកិច្ចនិងសង្គមកិច្ច និងស្ថានភាព ប្រជាសាស្ត្រ វិភាគអំពីផលវិបាកចម្បងៗផ្នែកប្រជាសាស្ត្រមកលើ ការអភិវឌ្ឍ ក្នុងពេលបច្ចុប្បន្ន និងអនាគត និងដាក់ចេញនូវការតម្រង់ទិសមួយចំនួន ដែលមានលក្ខណៈ គោលនយោបាយនិង កម្មវិធី សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំផែនការសម្មភាព ដែលនឹងត្រូវយកទៅអនុវត្តដោយ ក្រសួង ស្ថាប័នជំនាញ។

៣.២៤២- ដើម្បីអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ អគ្គលេខធិការដ្ឋាន ប្រជាជន និងការអភិវឌ្ឍបានរៀបចំបញ្ចប់ផែនការសកម្មភាព២០១៦-២០១៨ នៅចុងឆ្នាំ២០១៦ ដែលទទួលបានការឯកភាពពី សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះ រាជាណាចក្រកម្ពុជា។

៣.២៤៣- **បញ្ហាប្រឈម**

- ការលើកកម្ពស់ការយល់ដឹងអំពីបញ្ហាប្រជាជននិងការអភិវឌ្ឍនៅគ្រប់កម្រិតនិងនៅក្នុង សង្គម
- ការរៀបចំតម្រូវការទិន្នន័យនិងការស្រាវជ្រាវដែលមានទំនាក់ទំនងជាមួយគោលដៅ អភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

- ការធ្វើសមាហរណកម្មការវិភាគនិន្នាការប្រជាជនទៅក្នុងការរៀបចំផែនការអភិវឌ្ឍតាមវិស័យ ព្រមទាំងទីផ្សារពលកម្មនិងការផ្ដល់សេវាសង្គម។
- ការគៀរគរធនធានពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ ដើម្បីបន្តអនុវត្តផែនការសកម្មភាពនៅក្នុងផ.យ.អ.ជ. រួមទាំងការគៀរគរធនធានសម្រាប់ធ្វើជំរឿនប្រជាជនក្នុងឆ្នាំ២០១៨។

**សមភាពយេនឌ័រ**

៣.២៤៤- រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានសមិទ្ធផលធំៗជាច្រើនល្អសម្រាប់គោលដៅទី៣ លើកកម្ពស់សមភាពយេនឌ័រនិងការផ្ដល់ភាពអង់អាចដល់ដល់ស្ត្រី របស់គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ដែលមានចំណុចដៅចំនួន៤ គឺ(១)កាត់បន្ថយឲ្យបានច្រើននូវគម្លាតយេនឌ័រក្នុងការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ និង ឧត្តមសិក្សា (២)លុបបំបាត់គម្លាតយេនឌ័រក្នុងការងារទទួលប្រាក់កម្រៃនៅក្នុងគ្រប់វិស័យ (៣)លុបបំបាត់គម្លាតយេនឌ័រនៅក្នុងស្ថាប័នសាធារណៈ និង(៤)កាត់បន្ថយឲ្យបានច្រើនរាល់ទម្រង់អំពើហិង្សាប្រឆាំងនឹងស្ត្រីនិងកុមារ។

៣.២៤៥- ផែនការយុទ្ធសាស្ត្រនារីរតនៈ ទី៤ បានបង្ហាញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សមភាពយេនឌ័រ ព្រមទាំងបានបញ្ជ្រាបយេនឌ័រទៅក្នុងកម្មវិធីអភិវឌ្ឍន៍លើគ្រប់វិស័យ ជាពិសេសស្ត្រីជនជាតិដើមតិចនិងស្ត្រីពិការ និងបានផ្ដោតលើ៖ (១)ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី (២)កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី (៣)ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយ (៤)យេនឌ័រនិងសុខភាព (៥)ការអប់រំស្ត្រីនិងក្មេងស្រី និង(៦)យេនឌ័រ ការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ។

**ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី**

៣.២៤៦- ភាគចំណែករបស់ស្ត្រីធ្វើការងារមានប្រាក់កម្រៃក្នុងវិស័យកសិកម្ម និងក្នុងវិស័យឧស្សាហកម្មនៅឆ្នាំ ២០១៥ មានកម្រិតប្រហាក់ប្រហែល គ្នា (កសិកម្ម៤៩% និងឧស្សាហកម្ម៤៦,១%) ប៉ុន្តែស្ថិតនៅក្រោមចំណុចដៅ ៥០% សម្រាប់ឆ្នាំ២០១៤-២០១៥ ។ ភាគចំណែករបស់ស្ត្រីនៅក្នុងវិស័យសេវាកម្មមានការកើនឡើងបន្តិចពី៣៥% ក្នុងឆ្នាំ២០១៣ ទៅ៣៦%ក្នុងឆ្នាំ២០១៥ ប៉ុន្តែនៅមានកម្រិតទាបនៅឡើយបើប្រៀបធៀបទៅនឹងចំណុចដៅ ផ.យ.អ.ជ.។

**កិច្ចការពារផ្លូវច្បាប់សម្រាប់ស្ត្រី និងក្មេងស្រី**

៣.២៤៧- កម្ពុជាជាប្រទេសហត្ថលេខីក្នុងអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ។ រាជរដ្ឋាភិបាលបានអនុម័តបទបញ្ញត្តិ នានា ដើម្បីការពារស្ត្រីដូចជាច្បាប់ស្ដីពីការទប់ស្កាត់ អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះច្បាប់ស្ដីពីការបង្ក្រាប អំពើជួញដូរ

មនុស្សនិងអំពើធ្វើអាជីវកម្ម ផ្លូវភេទលើស្ត្រីក្រមព្រហ្មទណ្ឌ និងក្រមនិតិវិធីព្រហ្មទណ្ឌជាដើម។ ផែនការសកម្មភាពជាតិស្ដីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីឆ្នាំ២០១៤-២០១៨ ទទួលបានការអនុម័តឲ្យមានការប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៤។ រាជរដ្ឋាភិបាលត្រូវពង្រឹងការអនុវត្តច្បាប់ខាងលើនេះនិងផែនការសកម្មភាពជាតិនេះ។

### ស្ត្រីក្នុងតួនាទីធ្វើសេចក្ដីសម្រេចក្នុងវិស័យសាធារណៈនិងនយោបាយ

៣.២៤៨- តំណាងស្ត្រីនៅក្នុងស្ថាប័នរដ្ឋសភាបានកើនឡើង នៅក្នុង៥អាណត្តិចុងក្រោយ និងបានកើនដល់ ២០,៣៣% ក្នុងឆ្នាំ២០១៣ ប៉ុន្តែនៅទាបជាងចំណុចដៅក្នុង គ.អ.ស.ក. (៣០%) ក្នុងឆ្នាំ២០១៥។ ចំណែកឯសមាជិកព្រឹទ្ធសភាជាស្ត្រី បានកើនដល់១៦,៤% ឆ្នាំ២០១៥ ប៉ុន្តែនៅទាបជាងចំណុចដៅក្នុង គ.អ.ស.ក. (៣០%)ក្នុងឆ្នាំ២០១៥ ។

៣.២៤៩- ចំនួនស្ត្រីក្នុងមុខតំណែងជាឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការមានការកើនឡើង ក្នុងឆ្នាំ២០១៣ ធៀបនឹងអាណត្តិមុន ។ មានស្ត្រី១រូប (១០%) ជាឧបនាយករដ្ឋមន្ត្រី ស្ត្រី១រូប ជាទេសរដ្ឋមន្ត្រី ស្ត្រី៣រូប(១០,៧០%) ជារដ្ឋមន្ត្រី៣៨រូប (២០,៥៤%) ជារដ្ឋលេខាធិការ និង៤៨រូប (១៧,៦០%) ជាអនុរដ្ឋលេខាធិការ។

៣.២៥០- សមាមាត្រស្ត្រី ជាមន្ត្រីរាជការកើនឡើងពី៣៨% ក្នុងឆ្នាំ២០១៤ ដល់៤០% ក្នុងឆ្នាំ២០១៦ ។ លើសពីនេះទៀត រាជរដ្ឋាភិបាលបានចេញសេចក្ដីណែនាំស្ដីពីការកែសម្រួលអាយុចូលនិវត្តន៍របស់មន្ត្រីរាជការជានារីដល់អាយុ៦០ឆ្នាំនិងតាមការស្ម័គ្រចិត្ត។

៣.២៥១- បច្ចុប្បន្ន ពុំទាន់មានស្ត្រីជាអភិបាលរាជធានីឬខេត្ត ធៀបនឹងចំណុចដៅ១៥%ក្នុងឆ្នាំ២០១៥។ សមាមាត្រស្ត្រីជាក្រុមប្រឹក្សាឃុំ សង្កាត់បានកើនឡើងពី៩,៤% ក្នុង២០០២ ដល់១៧,៨% ក្នុងឆ្នាំ២០១២ ដែលទាបជាងចំណុចដៅក្នុងឆ្នាំ២០១៥ (២៥%)។ សមាមាត្រស្ត្រីជាមេឃុំ ចៅសង្កាត់បានកើនឡើងតិចតួចពី៦៧នាក់ (៤,១%) ទៅ៩៦នាក់ (៥,៨%) ក្នុងឆ្នាំ២០១២។

### យេនឌ័រនិងសុខភាព

៣.២៥២- អត្រាមរណភាពមាតាបានធ្លាក់ចុះពី៤៧២ ក្នុងឆ្នាំ២០០៥ មក២០៦ ក្នុងឆ្នាំ២០១០ និងមក១៧០ ក្នុងឆ្នាំ២០១៤ ដែលទាបជាងចំណុចដៅក្នុងឆ្នាំ២០១៥ (២៥០)។ ការធ្លាក់ចុះនេះបណ្ដាលមកពីសមាមាត្រស្ត្រីមានផ្ទៃពោះទៅទទួលការថែទាំសុខភាពពីរដងឬច្រើនជាងពីបុគ្គលិកសុខាភិបាលជំនាញបានកើនពី៤៤%ក្នុងឆ្នាំ២០០៥ ដល់៧១%ក្នុងឆ្នាំ២០១០ និងដល់៨៩% ឆ្នាំ២០១៤ ខ្ពស់ជាងចំណុចដៅ (៨៧%)។

### ការអប់រំស្ត្រីនិងក្មេងស្រី

៣.២៥៣- យុគភាពយេនឌ័រក្នុងវិស័យអប់រំបានថយចុះយ៉ាងច្រើន ដោយសន្ទស្សន៍យុគភាពយេនឌ័រ នៃអត្រារួមនៃការសិក្សានៅមធ្យមសិក្សាទុតិយភូមិ សម្រេចបានចំណុចដៅ១០០%។ ការចូលរៀនរបស់សិស្សស្រីសម្រេចបានចំណុចដៅ១០០%។ អត្រារួមនៃការសិក្សារបស់សិស្សស្រីនៅឧត្តមសិក្សាកើនដល់២៧%ក្នុងឆ្នាំ២០១៤ ដែលនឹងអាចសម្រេចបានចំណុចដៅក្នុងឆ្នាំ ២០១៥(២៩%)។

### យេនឌ័រនិងការប្រែប្រួលអាកាសធាតុ ការអភិវឌ្ឍបៃតង និងការគ្រប់គ្រងគ្រោះមហន្តរាយ

៣.២៥៤- ក្រសួងបានធ្វើការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការយុទ្ធសាស្រ្តជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឆ្នាំ២០១៤-២០២៣ និងបានរៀបចំនិងអនុវត្តផែនការយុទ្ធសាស្រ្តស្ដីពីយេនឌ័រ និងការប្រែប្រួល អាកាសធាតុ ឆ្នាំ២០១៤-២០១៨ ។ ក្រៅពីនេះក្រសួងក៏បានចងក្រង ផ្សព្វផ្សាយ និងចែករំលែកបទពិសោធន៍ល្អៗ ស្ដីពីការបញ្ជ្រាបយេនឌ័រនិងផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយដល់អ្នកពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងតាមសាលារៀននិងសហគមន៍។

### បញ្ហាប្រឈម

៣.២៥៥- បទដ្ឋានសង្គមលើទំនាក់ទំនងយេនឌ័រនៅតែជាបញ្ហាចម្បងដែលរារាំងដល់ការបង្កើនឱកាសដល់ស្ត្រី និងក្មេងស្រីក្នុងការទទួលបានការអប់រំ និងការបណ្ដុះបណ្ដាលជំនាញវិជ្ជាជីវៈនានា និងការចូលរួមនិងការទទួលបានសេវាសធារណៈ។ ខ្វះការគាំទ្រ និងលើកទឹកចិត្តពីគ្រួសារ និងសហគមន៍ក្នុងការជំរុញឱ្យស្ត្រីបានចូលរួមក្នុងកិច្ចអភិវឌ្ឍ ។

៣.២៥៦- ស្ត្រីមានសក្ដានុពលច្រើនក្នុងការបង្កើតនិងពង្រីងអាជីវកម្មខ្នាតតូច និងមធ្យម ប៉ុន្តែនៅមាន ឧបសគ្គ ជាច្រើនទាក់ទងនឹងលទ្ធភាពទទួលបានធនធានហិរញ្ញវត្ថុ និងសេវកម្មអភិវឌ្ឍន៍អាជីវកម្ម ហើយស្ត្រីភាគច្រើនស្ថិតក្នុងវិស័យឧស្សាហកម្មដែលមានផលិតភាពទាប ប្រាក់ឈ្នួលនៅមានកម្រិតទាប ល័ក្ខខណ្ឌការងារមិនសូវអំណោយផល។

៣.២៥៧- ការអនុវត្តច្បាប់ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះនៅមានកម្រិតនៅឡើយ ហើយកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធក្នុងការផ្ដល់សេវាផ្លូវច្បាប់មិនទាន់បានសមស្របទៅតាមតម្រូវការជនរងគ្រោះនៅឡើយ។

៣.២៥៨- ស្ត្រី និងកុមារីពិការ នៅតែបន្តរងគ្រោះច្រើនជាងគេ ដោយសារអំពើហិង្សាក្នុងគ្រួសារ និងការរើសអើងពីសង្គម ។

៣.២៥៩- អ្នកផ្តល់សេវាសុខភាពប្រកបដោយជំនាញ នៅតំបន់ដាច់ស្រយាល និងការយល់ដឹងរបស់សហគមន៍ ជាពិសេស ស្ត្រី ក្នុងការមកទទួលសេវាសុខភាពនៅមានកម្រិត និង ការចូលរួមរបស់ស្ត្រីនៅក្នុងវិស័យសាធារណៈ និង នយោបាយនៅមានកម្រិតនៅឡើយ។

**សេចក្តីសន្និដ្ឋាន**

៣.២៦០- ការត្រួតពិនិត្យមើលសូចនាករស្នូលរបស់ផ.យ.អ.ជ.សម្រាប់ការអប់រំ សុខភាព អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ និងសមធម៌យេនឌ័របង្ហាញពីវឌ្ឍនភាពនៃការសម្រេចបានគ.អ.ស.ក. ព្រមអាចឈានទៅសម្រេចបានចំណុចដៅក្នុងផ.យ.អ.ជ.ឆ្នាំ២០១៨ ប៉ុន្តែត្រូវកំណត់ផ្នែកដែលមានវឌ្ឍនភាពតិចតួចជាងផែនការនិងអាចខុសគន្លងសម្រាប់ការសម្រេចបានចំណុចដៅនៅក្នុងផ.យ.អ.ជ. ឆ្នាំ២០១៨។ ចំណុចដៅទាំងនេះអាចមានអត្រាសិក្សា សុខភាព និងអាហារូបត្ថម្ភ (ក្រិន ស្គមស្គាំង)។ ការវាយតម្លៃផ្នែកគុណភាពអាចកំណត់ផ្នែកដែលតម្រូវឲ្យមានកិច្ចប្រឹងប្រែងបន្ថែមដើម្បីសម្រេចបានចំណុចដៅនៅក្នុងផ.យ.អ.ជ. ឆ្នាំ២០១៨ ដូចជាគ្រូបង្រៀនដែលមានគុណភាព អភិបាលកិច្ចវិស័យសុខាភិបាល និងការអប់រំស្តីពីអាហារូបត្ថម្ភ។ ការវាយតម្លៃផ្នែកគុណភាពស្តីពីកិច្ចគាំពារសង្គមបង្ហាញថាមានវឌ្ឍនភាពទាក់ទងនឹងការអភិវឌ្ឍក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។ ការវាយតម្លៃលើសមធម៌យេនឌ័របង្ហាញថាទោះបីសូចនាករការអប់រំនិងសុខភាពបង្ហាញវឌ្ឍនភាពល្អ ក៏ប៉ុន្តែតម្រូវឲ្យមានការយកចិត្តទុកដាក់ក្នុងការដោះស្រាយការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រីនិងការចូលរួមសង្គមរបស់ស្ត្រី ព្រមទាំងដោះស្រាយអំពើហឹង្សា។

## តារាងទី៣.២៨ : វឌ្ឍនភាពរបស់មុំទី៤នៃយុទ្ធសាស្ត្រចតុកោណ: ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស

| ចំណុចដៅ | សកម្មភាពដែលត្រូវអនុវត្ត | វឌ្ឍនភាព |
|---|---|---|
| ១. បង្កើនអត្រាបញ្ចប់ការសិក្សានៅកម្រិតអប់រំមូលដ្ឋាន | ១. បង្កើនអត្រាឡើងថ្នាក់នៃបឋមសិក្សានៅថ្នាក់ដំបូង<br>២. បង្កើនការចូលរៀននៅមធ្យមសិក្សាបឋមភូមិនិងកាត់បន្ថយអត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ<br>៣. លើកកម្ពស់ក្នុងការសិក្សារបស់សិស្សលើមុខវិជ្ជាខ្មែរនិងគណិតវិទ្យានៅថ្នាក់ទី៣និងទី៦ | ១. សម្រេចបានចំណុចដៅខ្លះ: ស្ថិតតាមគន្លង<br>២. អត្រារួមក្រោមចំណុចដៅ សម្រេចបានអត្រាបញ្ចប់ថ្នាក់ទី៩ អត្រាបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិនៅឆ្ងាយពីចំណុចដៅ សម្រេចបានចំណុចដៅសម្រាប់អាហារូបករណ៍នៅមធ្យមសិក្សាបឋមភូមិ<br>៣. សម្រេចបានតាមចំណុចដៅ |
| ដំណើរការនៃប្រព័ន្ធសុខាភិបាលជាតិដោយចីរភាព | ១. លើកកម្ពស់ RMCH តាមរយៈការលើកកម្ពស់គុណភាពនិងភាពស័ក្តិសិទ្ធនៃសេវាថៃទាំងសុខភាពតាមរយៈ(ក) ពង្រីកការគ្រប់ដណ្តប់ការសម្រាលទារកដោយបុគ្គលិកសុខាភិបាលជំនាញនៅមូលដ្ឋានសុខាភិបាល និង(ខ) ពង្រីកសេវាប្រឹក្សាស្តីពីជម្រើសនៃការពន្យាកំណើត<br>២. លើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភតាមរយៈការផ្តល់ការ | ១ក. កំពុងដំណើរការ ១ខ. សម្រេចបានចំណុចដៅខ្លះ: កំពុងដំណើរការ<br>២. មិនទាន់សម្រេចបានចំណុចដៅ |
| លើកកម្ពស់ការប្រើប្រាស់ទឹកស្អាតនិងអនាម័យនៅតំបន់ជនបទ | ១. បង្កើតកម្មវិធីជាតិសម្រាប់ទឹកស្អាតនិងអនាម័យជនបទឆ្លុះបញ្ចាំងពីតួនាទីនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ<br>២. បង្កើនលំហូរធនធានក្នុងវិស័យទឹកស្អាតនិងអនាម័យជនបទ<br>៣. បង្កើតនិងដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានទឹកស្អាតនិងអនាម័យជនបទ | ១. សម្រេចបានចំណុចដៅខ្លះ: ស្ថិតតាមគន្លង<br>២. សម្រេចបានចំណុចដៅខ្លះ: ពន្យាពេលខ្លះ<br>៣. ពន្យាពេល មានវឌ្ឍនភាពតិចតួច |
| កាត់បន្ថយការឆ្លងមេរោគអេដស៍/ជំងឺអេដស៍ថ្មីនិងមរណភាពដោយមេរោគអេដស៍/ជំងឺអេដស៍និងបង្កើនការព្យាបាលដោយថ្នាំពន្យា | ១. ការគ្រប់ដណ្តប់នៃអន្តរគមន៍សម្រាប់បាន MARPs ៨០%<br>២. ការព្យាបាលដោយប្រើថ្នាំពន្យាសម្រាប់យុវជននិងកុមារមានផ្ទុកមេរោគអេដស៍<br>៣. ការធ្វើចំណាយសម្រាប់ NSP IV ដោយប្រើប្រាស់ទិន្នន័យនិងអនុម័តផែនការគៀគរធនធាន | ១. មិនទាន់បានសម្រេចបានចំណុចដៅមានវឌ្ឍនភាពខ្លះ<br>២. សម្រេចបានចំណុចដៅខ្លះ: កំពុងដំណើរការ<br>៣. រង់ចាំការបញ្ចប់ NSPIV |
| លើកកម្ពស់ស្ថានភាព SPFSN និងប្រព័ន្ធគាំពារសុវត្ថិភាពសង្គម | ១. រៀបចំនិងផ្តល់ហិរញ្ញប្បទានសម្រាប់អនុវត្តយុទ្ធសាស្ត្រសុវត្ថិភាពស្បៀងនិងអាហារូបត្ថម្ភ<br>២. អនុម័តផែនការសកម្មភាពគាំពារសុវត្ថិភាពសង្គម ដើម្បីបង្កើនការផ្តល់កម្មវិធីគាំពារសុវត្ថិភាពសង្គម | ១. ជោគជ័យ កំពុងដំណើរការ<br>២. សម្រេចបានចំណុចដៅខ្លះ: ផែនការសកម្មភាពត្រូវបានអនុម័តនៅឆ្នាំ២០១៥ |

| | | |
|---|---|---|
| កែលម្អបរិយាកាសអំណោយផលសម្រាប់សមភាពយេនឌ័រនិងការផ្តល់អំណាចដល់ស្ត្រី | ១. ដាក់ឲ្យអនុវត្តផែនការយុទ្ធសាស្ត្រនារីរតនៈទី៤និងគោលនយោបាយជាតិសម្រាប់សមភាពយេនឌ័រនិង WE<br>២. គោលការណ៍អភិក្រមទូទាំងវិស័យសមភាពយេនឌ័រចំនួន០២ ស្តីពី WEE & NAPVAW មានដំណើរការពេញលេញ<br>៣. បង្កើនការចូលរួមរបស់ស្ត្រីក្នុងការសម្រេចចិត្តក្នុងវិស័យសាធារណៈ ដើម្បីសម្រេចបានគ.អ.ស.ក. | ១. បានបញ្ចប់ អនុម័ត និងផ្សព្វផ្សាយឯកសារគោលនយោបាយ<br>២. បានរៀបចំ ផ្តល់ហិរញ្ញប្បទាន និងអនុវត្ត<br>៣. កំពុងដំណើរ ស្ថិតតាមគន្លង |

## សេចក្តីសន្និដ្ឋានរួមស្តីពីសមិទ្ធផលនិងបញ្ហាប្រឈម

៣.២៦១- រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពជាច្រើនសម្រាប់ការអនុវត្តពាក់កណ្ដាលអាណត្តិនៃផ.យ.អ.ជ.២០១៤-២០១៨ ក្នុងផ្នែកសំខាន់ៗរបស់យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣។ ការសម្រេចបាននេះសំដៅលើការដឹកនាំរបស់រាជរដ្ឋាភិបាល ភាពជាដៃគូក្នុងការវិនិយោគរវាងរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល ព្រមទាំងកំណើនវិនិយោគពីវិស័យសាធារណៈ។

របាយការណ៍នេះ បញ្ជាក់ពីការយកចិត្តទុកដាក់លើអភិបាលកិច្ចល្អដែលជាស្នូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣របស់រាជរដ្ឋាភិបាល ដែលសម្របសម្រួលនិងលើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ ចីរភាពនៃដំណើរការអភិវឌ្ឍ និងសមិទ្ធផលនានា។ របាយការណ៍នេះក៏បានបង្ហាញអំពីការគិតគូរនិងអនុវត្តលើមុំទាំងបួនរបស់យុទ្ធសាស្ត្រចតុកោណ (ការលើកកម្ពស់វិស័យកសិកម្ម ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការអភិវឌ្ឍវិស័យឯកជននិងការងារ និងការអភិវឌ្ឍធនធានមនុស្ស ត្រឹមត្រូវតាមគោលបំណងនិងបរិបទនៃការអភិវឌ្ឍ។

របាយការណ៍ក៏បានបង្ហាញថារាជរដ្ឋាភិបាលបានបង្កើតក្របខ័ណ្ឌគោលនយោបាយគ្រប់ជ្រុងជ្រោយមួយដែលផ្តល់ជាការណែនាំសម្រាប់ការរៀបចំផែនការអភិវឌ្ឍ។ គោលនយោបាយធំៗរួមមានគោលនយោបាយពិពិធកម្មកសិកម្មនិងការនាំចេញស្រូវ គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម គោលនយោបាយជាតិមុខរបរ គោលនយោបាយជាតិប្រជាជន និងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤។

៣.២៦២- របាយការណ៍នេះទទួលស្គាល់ថារាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងសង្គមស៊ីវិល និងវិស័យឯកជននឹងប្រឈមមុខរួមគ្នាជាមួយបញ្ហាប្រឈមដែលកំពុងកើតមាន និងដែលនឹងកើតមានថ្មីៗក្នុងដំណើរការនៃការអភិវឌ្ឍ។ របាយការណ៍ក៏បានបង្ហាញថាធនធានរបស់រាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍ រួមទាំងសង្គមស៊ីវិលនិងវិស័យឯកជនមានមិនគ្រប់គ្រាន់សម្រាប់សម្រេចបានគោលបំណងនៃការអភិវឌ្ឍជាតិ។ បរិបទអភិវឌ្ឍន៍សកល តំបន់ និងក្នុងស្រុកកាន់តែមានលក្ខណៈស្មុគស្មាញតម្រូវឲ្យមានការពង្រីកការវិនិយោគអភិវឌ្ឍន៍ដែលកាន់តែមានប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។ របាយការណ៍បង្ហាញអំពីការសម្រេចបានជាច្រើននៅក្នុងការកសាងសមត្ថភាព ប៉ុន្តែ

ត្រូវការកិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចបានគម្លាតសមត្ថភាពទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

# ជំពូកទី៤

# ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

## ១- សេចក្តីផ្តើម

## ១- សេចក្តីផ្តើម

៤.១- ផ.យ.អ.ជ.២០១៤-២០១៨ បានបញ្ជាក់ពីសារៈសំខាន់នៃការបង្កើតឲ្យមានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយ ដើម្បីអ្នកធ្វើគោលនយោបាយអាចវាស់វែងពីវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅអភិវឌ្ឍន៍នានា។ ផ.យ.អ.ជ.បានបង្ហាញពីក្របខ័ណ្ឌលទ្ធផលដែលជាគោលការណ៍នៃចង្វាក់លទ្ធផលមួយ សម្រាប់វាយតម្លៃទំនាក់ទំនងរវាងធាតុចូល ធាតុចេញ លទ្ធផល និងឥទ្ធិពល។ ផ.យ.អ.ជ.តម្រូវឲ្យមានការបង្កើតក្របខ័ណ្ឌលទ្ធផលនៅ៣កម្រិត គឺនៅកម្រិតជាតិ វិស័យ និងកម្មវិធី។ ផ.យ.អ.ជ.មានសូចនាករស្នូលនិងសូចនាករបន្ថែមសម្រាប់វាស់វែងវឌ្ឍនភាពក្នុងការសម្រេចបានគោលដៅគោលនយោបាយនានា ដែលបញ្ជាក់ឲ្យឃើញថាក្របខ័ណ្ឌលទ្ធផលបង្កើតបានជាវេទិការឹងមាំមួយ សម្រាប់បង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយសម្រាប់រាជរដ្ឋាភិបាលទាំងមូល។

៤.២- របាយការណ៍នេះ បង្ហាញថាសូចនាករស្នូលនិងសូចនាករបន្ថែមដែលមាននៅក្នុងផ.យ.អ.ជ.ល្អ និងអាចវាយតម្លៃអំពីវឌ្ឍនភាពនៅក្នុងវិស័យជាច្រើន ទោះបីការគ្របដណ្តប់នៅក្នុងវិស័យមួយចំនួននៅទាបក៏ដោយ។ ផ.យ.អ.ជ.ក៏បានផ្តល់ជាការណែនាំទាក់ទងនឹងកម្រិតរបស់សូចនាករតាមដានត្រួតពិនិត្យនិងវាយតម្លៃនិងបង្ហាញពីចង្វាក់លទ្ធផលលម្អិតទាក់ទងនឹងសូចនាករធាតុចូល ធាតុចេញ លទ្ធផល និងឥទ្ធិពល។ សូចនាករទាំងងនេះផ្តល់ជាមូលដ្ឋានគ្រឹះសម្រាប់អ្នកធ្វើផែនការក្នុងការផ្លាស់ប្តូរពីគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជាសម្រាប់ឆ្នាំ២០១៥ទៅជាគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាសម្រាប់ឆ្នាំ២០៣០។

៤.៣- របាយការណ៍នេះ បង្ហាញអំពីតម្រូវការនិងការពង្រឹងសត្ថភាពស្ថាប័ននិងធនធានមនុស្សសម្រាប់អនុវត្តប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃប្រកបដោយចីរភាព និងបញ្ជាក់ថាការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃគ្រប់ជ្រុងជ្រោយមួយគឺជាដំណើរការដ៏វែងមួយ ដែលតម្រូវឲ្យមានការប្តេជ្ញាចិត្តនិងការផ្តល់ហិរញ្ញប្បទានប្រកបដោយចីរភាពពីរាជរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍនានា។

## ២- សមិទ្ធផលសំខាន់ៗ

៤.៤- **ការលើកកម្ពស់ការយល់ដឹង៖** ការបន្តយកចិត្តទុកដាក់លើគ.អ.ស.ក.រួមជាមួយក្រុមការងារស្តីពីសូចនាករតាមដានរួមគ្នាបានដើរតួនាទីសំខាន់ក្នុងការលើកកម្ពស់សមត្ថភាពស្ថាប័ននិងធនធានមនុស្សសម្រាប់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ វឌ្ឍនភាពជាច្រើនត្រូវបានសម្រេចបានទាក់ទងនឹងការជូនព័ត៌មានដល់ក្រសួង ស្ថាប័នស្តីពីភាពពាក់ព័ន្ធនិងតួនាទីនៃការងារតាមដានត្រួត

ពិនិត្យនិងវាយតម្លៃក្នុងការគាំទ្រដល់ការរៀបចំផែនការនិងការអនុវត្តការវិនិយោគការអភិវឌ្ឍជាតិ ប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។

៤.៥- **កំណែទម្រង់អភិបាលកិច្ច៖** ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងសម្រេចបានវឌ្ឍនភាពល្អក្នុងការអនុវត្តកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងការអនុវត្តថវិកាកម្មវិធី ដែលបង្កើតបានជាមូលដ្ឋានគ្រឹះសម្រាប់ផ្សារភ្ជាប់គោលនយោបាយជាមួយនឹងការវិភាជថវិកា។ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាបានលើកកម្ពស់ការរៀបចំសូចនាករតាមដានរួមគ្នា ដែលឧបករណ៍មួយសម្រាប់ក្រុមការងារបច្ចេកទេសសម្រាប់តាមដានវឌ្ឍនភាពធៀបនឹងគោលដៅតាមវិស័យ។

៤.៦- **ការគ្រប់គ្រងព័ត៌មាន៖** ប្រព័ន្ធគ្រប់គ្រងព័ត៌មានត្រូវបានបង្កើតឡើងនៅតាមក្រសួង ស្ថាប័នមួយចំនួន ដូចជាក្រសួងសុខាភិបាលនិងក្រសួងអប់រំ យុវជន និងកីឡា។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុកំពុងដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុនៅតាមក្រសួង ស្ថាប័នគោលដៅមួយចំនួន ដែលជាផ្នែកមួយនៃកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្រសួងមហាផ្ទៃនឹងពង្រឹងសមត្ថភាពទាក់ទឹងនឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅថ្នាក់ក្រោមជាតិបន្តិចម្តងៗផងដែរ។ ប្រព័ន្ធព័ត៌មានទាំងនេះតំណាងឲ្យវឌ្ឍនភាពល្អលើការប្រមូលនិងការគ្រប់គ្រងទិន្នន័យ ដែលគាំទ្រដល់ដល់ផ្នែករដ្ឋបាលនិងការរៀបចំគោលនយោបាយ។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានជួយអ្នករៀបចំផែនការតាមដានសូចនាករសំខាន់ៗ សម្រាប់តាមដានវឌ្ឍនភាពធៀបនឹងគោលដៅតាមវិស័យ។

៤.៧- **ការប្រមូលទិន្នន័យ៖** ក្រសួងផែនការ បានផ្តល់ប្រភពទិន្នន័យធំៗមួយចំនួន តាមពេលកំណត់ដែលជួយអ្នករៀបចំផែនការក្នុងការវាយតម្លៃវឌ្ឍនភាពរយៈពេលវែងមួយ។ ទិន្នន័យទាំងនេះរួមមានជំរឿនប្រជាជន ដែលរៀបចំឡើងរៀងរាល់១០ឆ្នាំ អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា អង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា ដែលរៀបចំឡើងរៀងរាល់៤ឆ្នាំ និងទិន្នន័យឃុំ សង្កាត់។ ជំរឿនកសិកម្មលើកដំបូងបានបញ្ចប់ក្នុងឆ្នាំ២០១៥ ដែលនឹងអាចរៀបចំឡើងរៀងរាល់១០ឆ្នាំ។ ជាពិសេស កំពុងរៀបចំបង្កើតក្របខណ្ឌសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងរបាយការណ៍វិភាគស៊ីជម្រៅមួយចំនួនទៀត សម្រាប់តាមដានវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ.។

៤.៨- **សមត្ថភាពស្ថាប័ននិងធនធានមនុស្ស៖** គំនិតផ្តួចផ្តើមសម្រាប់ការងារកសាងសមត្ថភាពទាក់ទងនឹងការតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវបានបង្កើតឡើង។ ឧទាហរណ៍ ក្រសួងផែនការដោយមានកិច្ចសហការជាមួយដៃអភិវឌ្ឍមួយចំនួនដូចជា៖ មូលនិធិសហប្រជាជាតិសម្រាប់កុមារបានវិភាគលើតម្រូវការសម្រាប់រៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ និងបានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការតាមដានត្រួតពិនិត្យនិវាយតម្លៃដល់មន្ត្រីក្រសួង ស្ថាប័នពាក់ព័ន្ធមួយចំនួន និង មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន បាននឹងកំពុងបន្តពង្រឹងសមត្ថភាពដល់មន្ត្រីក្រសួងផែនការតាមការចូលរួមការចូលរួមក្នុងសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលក្នុងតំបន់ និងតាមរយៈជំនួយបច្ចេកទេសដើម្បីរួមចំណែកក្នុងការពង្រឹងប្រព័ន្ធគ្រប់គ្រងទិន្នន័យនិងស្ថិតិជាតិ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដោយមានកិច្ចសហការជាមួយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិជប៉ុនបានវិភាគការរៀបចំការតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅតាមគម្រោងនិងកម្មវិធីដែលបានគាំទ្រ។ ដៃគូអភិវឌ្ឍមួយចំនួនទៀតក៏បានគាំទ្រការវាយតម្លៃតម្រូវការសមត្ថភាពនៅតាមវិស័យ។ សកម្មភាពទាំងនេះបានកំពុងដំណើរការទន្ទឹមគ្នានិងបំពេញឲ្យ

គ្នាទៅវិញទៅមក ប៉ុន្តែតម្រូវឲ្យមានការសម្របសម្រួលនិងធ្វើសមាហរណកម្មគំនិតផ្តួចផ្តើមទាំងអស់នេះ។

**៤.៩- គោលដៅអភិវឌ្ឍន៍ដោយប្រកបដោយចីរភាពសម្រាប់ឆ្នាំ២០៣០៖** ក្រសួងផែនការបានចាប់ ផ្តើមដំណើរការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ដែលបានបន្ថែមលើវឌ្ឍនភាពដែលសម្រេចបានក្នុងការរៀបចំសូចនាករតាមដានសម្រាប់ គ.អ.ស.ក.ត្រឹមឆ្នាំ២០១៥ ព្រមទាំងសូចនាករស្នូលនិងសូចនាករបន្ថែមនៅក្នុង ផ.យ.អ.ជ. ២០១៤-២០១៨។ ដំណើរការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្តល់ឱកាសសម្រាប់រៀបចំសូចនាករតាមដានដែលគាំទ្រដល់ការរៀបចំផែនការថវិកាកម្មវិធីនៅកម្រិតម៉ាក្រូនិងវិស័យ និង ផ្តល់ឱកាសសម្រាប់ការលើកកម្ពស់ការយល់ដឹងនិងការកសាងសមត្ថភាពនៅតាមក្រសួង ស្ថាប័ន។

## ៣- បញ្ហាប្រឈម

**៤.១០-** ផ.យ.អ.ជ.២០១៤-២០១៨ បានកំណត់បញ្ហាប្រឈមចំនួន៤ គឺទី១ ក្រសួង ស្ថាប័នមិនទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការបង្កើតសូចនាករត្រឹមត្រូវសម្រាប់វិស័យរបស់ខ្លួន ទី២ ក្រសួង ស្ថាប័នមិនទាន់មានសមត្ថភាពក្នុងការប្រមូលនិងវិភាគទិន្នន័យសម្រាប់វាស់វែងសូចនាកររបស់ខ្លួន ទី៣ រាជរដ្ឋាភិបាលមិនទាន់មានប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិមួយសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្ត ផ.យ.អ.ជ. និងគម្រោងនានាដែលកំពុងអនុវត្តដោយក្រសួង ស្ថាប័ននៅក្នុងកម្មវិធីវិនិយោគ៣ឆ្នាំរំកិល ទី៤ កិច្ចសហប្រតិបត្តិការរវាងនិងក្នុងក្រសួង ស្ថាប័ននៅមានកម្រិតទាក់ទងនឹងការរៀបចំធាតុចូលសម្រាប់ ផ.យ.អ.ជ. កម្មវិធីវិនិយោគសាធារណៈបីឆ្នាំរំកិល របាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ និងរបាយការណ៍ផ្សេងៗទៀត រួមទាំងរបាយការណ៍ពាក់កណ្តាលអាណត្តិរបស់ ផ.យ.អ.ជ.២០១៤-២០១៨។

**៤.១១-** របាយការណ៍ពាក់កណ្តាលអាណត្តិក៏បានបង្ហាញអំពីភាពខុសគ្នានៃសមត្ថភាពស្ថាប័ន និងធនធានមនុស្សសម្រាប់រាយការណ៍អំពីវឌ្ឍនភាពធៀបនឹងសូចនាករនៅតាមវិស័យ។ ឧទាហរណ៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានរៀបចំសូចនាករស្នូលបានល្អនិងសមត្ថភាពក្នុងការវាស់វែងសម្រាប់តាមដាននិងវិភាគការអនុវត្តផ្នែកម៉ាក្រូសេដ្ឋកិច្ច ចំណែកវិស័យផ្សេងទៀតដូចជាអប់រំនិងសុខាភិបាលបានរៀបចំប្រព័ន្ធព័ត៌គ្រប់គ្រងព័ត៌មានដែលអាចរាយការណ៍អំពីសូចនាករស្នូលជាច្រើនសម្រាប់ជាព័ត៌មានរដ្ឋបាលនិងទិន្នន័យសម្រាប់ការតាមដាន។ ទិន្នន័យទាំងនេះអាចត្រូវបានបង្កើតជាទំនាក់ទំនងរវាងធាតុចេញនិងលទ្ធផល ទោះបីការវិភាគចង្វាក់លទ្ធផលមួយចំនួនតម្រូវឲ្យមានពេលវេលាវែងជាងនេះក៏ដោយ។ វិស័យផ្សេងទៀត ដូចជាអភិបាលកិច្ច ផ្តោតលើដំណើរការអនុវត្តការងារនិងពឹងផ្អែកលើការវាយតម្លៃផ្នែកគុណភាព ដែលអាចមានហានិភ័យមួយចំនួនដែលពាក់ព័ន្ធជាមួយវិស័យមួយចំនួន។ ក្នុងវិស័យផ្សេងទៀត ដូចជាកសិកម្ម មានទិន្នន័យមួយចំនួនប៉ុន្តែការរៀបចំនិងការបង្ហាញព័ត៌មានដែលត្រូវពង្រឹងបន្ថែម សម្រាប់គាំទ្រដល់ការវិភាគលើចង្វាក់លទ្ធផល ដូចជាទំនាក់ទំនងរវាងធាតុចេញនិងលទ្ធផល។ ក្នុងវិស័យមួយចំនួនទៀត ការមិនមានកំណត់អាទិភាពនិងសូចនាករបណ្តាលឲ្យមានការរាយការណ៍ធម្មតាអំពីបញ្ជីសកម្មភាពនានានៅក្នុងវិស័យទាំងនោះ។

**៤.១២- ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ៖** ផ.យ.អ.ជ.បានលើកឡើងអំពីតម្រូវការក្នុងការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិនិងការកសាងសមត្ថភាពការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅតាមក្រសួង ស្ថាប័ន។ វឌ្ឍនភាពមួយចំនួនសម្រេចបាននៅក្នុងវិស័យមួយចំនួនក្នុងការប្រមូលនិងវាយការណ៍ទិន្នន័យ ប៉ុន្តែមិនទាន់បានប្រមូលផ្ដុំគ្នាតែមួយសម្រាប់រាជរដ្ឋាភិបាលទាំងមូល ដោយក្រសួង ស្ថាប័នប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ដែលមិនត្រូវបានណែនាំដោយគោលការណ៍រួម វិធីសាស្ត្របន្ថែម និងការប្រើប្រាស់ពាក្យបច្ចេកទេសដូចគ្នា។ ដូចនេះតម្រូវឲ្យមានកិច្ចសម្របសម្រួល ការត្រួតពិនិត្យ និងគណនេយ្យភាពប្រសើរជាងមុន ហើយការបង្កើតប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ គឺគ្រាន់តែជាដំណាក់កាលដំបូងប៉ុណ្ណោះ។

**៤.១៣-** វិស័យមួយចំនួន ដូចជាវិស័យអប់រំនិងសុខាភិបាល ត្រូវកំណត់ឲ្យបានច្បាស់លាស់អំពីទំនាក់ទំនងរវាងធាតុចូលនិងលទ្ធផល។ វិស័យទាំងពីរនេះបានកសាងសមត្ថភាពលើប្រព័ន្ធគ្រប់គ្រងព័ត៌មានដែលអាចផលិតព័ត៌មានសម្រាប់កំណត់ទំនាក់ទំនងរវាងធាតុចូលនិងលទ្ធផលបាន។ ការបង្កើតប្រព័ន្ធគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុក្នុងវិស័យទាំងពីរនេះក៏អាចជួយផ្សារភ្ជាប់ធាតុចូលជាមួយធាតុចេញ រួមទាំងលទ្ធផលផងដែរ។ ការកសាងសមត្ថភាពលើប្រព័ន្ធគ្រប់គ្រងព័ត៌មានក្នុងវិស័យអប់រំនិងសុខាភិបាលអាចប្រើជាគំរូសម្រាប់អភិវឌ្ឍសមត្ថភាពលើប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅក្នុងវិស័យផ្សេងៗទៀត។

**៤.១៤- ការផ្ដល់អាទិភាពដល់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ៖** ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃមិនទាន់ត្រូវបានអាទិភាពនៅតាមក្រសួង ស្ថាប័ននិងមិនទាន់មានការវិភាជថវិកាគ្រប់គ្រាន់សម្រាប់ការងារនេះនៅឡើយ។ ជាលទ្ធផល ក្រសួង ស្ថាប័នជាច្រើន មានមន្ត្រីតិចដែលទទួលបន្ទុកលើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ និងមានការយល់ដឹងនៅមានកម្រិតទាក់ទងនឹងការគ្រប់គ្រងដោយផ្អែកលើលទ្ធផល ក្របខ័ណ្ឌលទ្ធផល និងការអនុវត្តការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ដូចនេះការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវបានចាត់ទុកជាការងារបន្ថែមមួយទៀតនិងជាបន្ទុកលើធនធានដែលកំពុងតែខ្វះខាត។ ក្រសួង ស្ថាប័នត្រូវពឹងផ្អែកលើការផ្ដល់ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍសម្រាប់រៀបចំនិងពង្រឹងសមត្ថភាពលើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅតាមវិស័យរបស់ខ្លួន។ ទោះបីមានការអភិវឌ្ឍលើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃជាមូលដ្ឋានដោយមានកិច្ចសហការជាមួយដៃគូអភិវឌ្ឍក៏ដោយ ក៏ក្រសួង ស្ថាប័នជាច្រើននៅពុំទាន់មានចំណេះដឹងមូលដ្ឋានសម្រាប់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

**៤.១៥- ចីរភាពនៃការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ៖** ចីរភាពនៃការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃតម្រូវឲ្យមានការប្ដេជ្ញាចិត្តនិងការផ្ដល់ហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល។ ដោយសារជំនួយអភិវឌ្ឍន៍ផ្លូវការប្រែប្រួល ដូចនេះរាជរដ្ឋាភិបាលត្រូវទទួលយកការគាំទ្ររបស់ដៃគូអភិវឌ្ឍដែលមានសម្រាប់ពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស។ ប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃកិច្ចប្រឹងប្រែងនេះអាចត្រូវបានពង្រឹងប្រសិនបើចាប់ផ្ដើមដោយមានផែនការសកម្មភាពជាតិស្ដីពីការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

## ៤- ដំណោះស្រាយ

**៤.១៦- ការប្រមូល ការគ្រប់គ្រង និងការប្រើប្រាស់ទិន្នន័យ៖** ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិនឹងត្រូវរៀបចំបំពេញបន្ថែមរវាងប្រព័ន្ធជាតិនានា ដូចជាអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ដែលគ្រប់គ្រងដោយវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការរួមជាមួយសកម្មភាពតាមវិស័យ ដូចជាជំរឿនប្រជាជន ជំរឿនកសិកម្ម និងអង្កេតសុខភាពនិងប្រជាសាស្ត្រកម្ពុជា រួមទាំងប្រព័ន្ធគ្រប់គ្រងព័ត៌មាននៅតាមវិស័យ ដូចជាវិស័យអប់រំនិងសុខាភិបាលជាដើម។

**៤.១៧-** ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិនឹងធានានូវគុណភាពនិងភាពអាចជឿទុកចិត្តរបស់ទិន្នន័យដែលប្រមូលបាននិងផ្សព្វផ្សាយត្រឹមត្រូវតាមស្តង់ដារ។ ប្រព័ន្ធជាតិនេះនឹងលើកកម្ពស់ការផ្លាស់ប្តូរទិន្នន័យនិងព័ត៌មានតាមវិស័យបានទូលំទូលាយនិងមានតម្លាភាព។ ឧទាហរណ៍ ក្រសួងផែនការ គឺជាកន្លែងសម្អាតទិន្នន័យថ្នាក់ជាតិមួយសម្រាប់សម្របសម្រួលការប្រមូលនិងការរក្សាទុកទិន្នន័យការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិនិងផ្តល់ដល់អ្នកប្រើប្រាស់នានា។ ផ.យ.អ.ជ. ផ្តល់ជាបញ្ជីករណីសិក្សាមួយចំនួនសម្រាប់វិស័យចំនួន៣ តាមរយៈការបង្ហាញពីរបៀបស្រាវជ្រាវដែលអាចជួយបំពេញដល់ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ ដោយមានការវិភាគស៊ីជម្រៅ ជាពិសេសនៅកម្រិតលទ្ធផលនិងឥទ្ធិពល (ឧទាហរណ៍ គោលបំណងគោលនយោបាយ)។

**៤.១៨-** ការផ្សារភ្ជាប់ទិន្នន័យនិងព័ត៌មានគ្រប់វិស័យគឺជាការពិចារណាដែលមានសារៈសំខាន់មួយទៀត។ នៅក្នុងវិស័យមួយចំនួន ដូចជាសុខាភិបាល ការប្រើប្រាស់នៃការប្រមូលព័ត៌មានធំៗមិនទាន់អាចធ្វើទៅបានទេដោយសារកង្វះសមត្ថភាពក្នុងការផ្សារភ្ជាប់ទិន្នន័យពីមួយទៅមួយ។ បញ្ហាប្រឈមដែលស្មុគស្មាញដែលទាក់ទងនឹងការផ្សារភ្ជាប់ទិន្នន័យគឺការប្រមូលផ្តុំទិន្នន័យពីគ្រប់ក្រសួង ស្ថាប័ន។ ភាពស្មុគស្មាញកាន់តែកើនឡើងនៅពេលការវាយតម្លៃពង្រីកដល់ថ្នាក់ក្រោមជាតិ។

**៤.១៩-** សមត្ថភាពសម្រាប់ការវិភាគទិន្នន័យនិងព័ត៌មាននឹងត្រូវពង្រឹងបន្ថែមទៀតនៅគ្រប់កសួង ស្ថាប័ន។ ប្រសិនបើមិនមានសមត្ថភាពសម្រាប់ធ្វើការវិភាគទិន្នន័យទេ ទោះបីគុណភាពទិន្នន័យល្អក៏គ្មានប្រយោជន៍ដែរ។

**៤.២០- សូចនាករគុណភាព៖** ការប្រមូលទិន្នន័យជាទូទៅផ្តោតលើការវាស់វែងចំនួនធាតុចូល ធាតុចេញ និងលទ្ធផល។ ក្នុងករណីខ្លះ វាអាចមានប្រយោជន៍សម្រាប់រៀបចំសូចនាករដែលឆ្លុះបញ្ចាំងអំពីគុណភាពនៃធាតុចូលនិងធាតុចេញ។ ឧទាហរណ៍ សូចនាករសំខាន់មួយដែលទាក់ទងជាមួយការដឹកជញ្ជូនជនបទគឺប្រវែងផ្លូវដែលបានសាងសង់គិតជាគីឡូម៉ែត្រ ប៉ុន្តែមិនបានបង្ហាញអំពីបញ្ហាពាក់ព័ន្ធជាមួយគុណភាពរបស់ផ្លូវដែលបានសាងសង់បន្ទាប់ពីដំណើរបានច្រើនឆ្នាំឡើយ។ ឧទាហរណ៍ស្រដៀងគ្នាត្រូវបានលើកឡើងសម្រាប់ធារាសាស្ត្រ។ សូចនាករបែបគុណភាពអាចមានប្រយោជន៍សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិការអនុវត្តហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ។ សូចនាករបន្ថែមអាចត្រូវបានប្រើប្រាស់សម្រាប់វាយតម្លៃគុណភាពទឹកនិងគុណភាពខ្យល់ ព្រមទាំងសុវត្ថិភាពការងារ។

**៤.២១- ការវិនិយោគអន្តរវិស័យបន្ថែម៖** រាជរដ្ឋាភិបាលនឹងត្រូវរៀបចំសូចនាករត្រឹមត្រូវសម្រាប់វាយតម្លៃវឌ្ឍនភាពនិងការវិនិយោគលើបញ្ហាអន្តរវិស័យ ដែលតម្រូវឲ្យមានប្រភពទិន្នន័យថ្មីនិងសមត្ថភាពក្នុងការវិភាគខ្ពស់ សម្រាប់វាយតម្លៃកត្តាផ្សេងៗដែលចូលរួមចំណែកក្នុងការសម្រេចបានលទ្ធផល (ឧទាហរណ៍ ផលចំណេញពីការវិនិយោគ)។ ឧទាហរណ៍ ការវិនិយោគលើប្រព័ន្ធធារាសាស្ត្រ ការផ្ដល់បច្ចេកទេសដល់កសិករ ផ្លូវជនបទ និងប័ណ្ណកាន់កាប់ដីធ្លីដែលចូលរួមក្នុងការបង្កើនទិន្នផល និងអន្តរាគមន៍នៅក្នុងការអប់រំអំពីអាហារូបត្ថម្ភ កំណើនផលិតកម្មកសិកម្ម ការទទួលបានទឹកស្អាតនិងអនាម័យ និងចំណូលដែលចូលរួមចំណែកក្នុងសម្រេចបានស្ថានភាពអាហារូបត្ថម្ភប្រសើរជាងមុនសម្រាប់ស្ត្រីមានផ្ទៃពោះក្រីក្រនិងកុមារអាយុក្រោម៥ឆ្នាំ។

**៤.២២- រយៈពេលរបស់ធាតុចូល-ធាតុចេញ៖** របាយការណ៍នេះបង្ហាញថាទំនាក់ទំនងរវាងធាតុចូលនិងលទ្ធផលនិងឥទ្ធិពលជាទូទៅមានរយៈពេលច្រើនជាងវដ្តហិរញ្ញវត្ថុ។ ដោយសារសូចនាករតាមដានប្រចាំឆ្នាំពាក់ព័ន្ធទៅនឹងរដ្ឋបាលនិងការគ្រប់គ្រង ដូចនេះវដ្តនៃការវាយតម្លៃត្រូវមានរយៈពេលច្រើនជាង១ឆ្នាំ ដើម្បីស្វែងយល់ពីចង្វាក់លទ្ធផលទាំងអស់។ ឧទាហរណ៍ ការវាយតម្លៃជាទូទៅត្រូវបានរៀបចំឡើងនៅពេលបញ្ចប់គម្រោងឬកម្មវិធីដើម្បីកំណត់អំពីលទ្ធផល។ ការវាយតម្លៃបែបនេះមានប្រយោជន៍ ដោយសារបានជួយបង្កើតជាមេរៀនឬបទពិសោធន៍ ដែលអាចបំពេញបន្ថែមដោយការវាយតម្លៃមុននិងក្រោយ ដើម្បីវាយតម្លៃពីចីរភាពរបស់លទ្ធផល។

**៤.២៣- ភាពជាដៃគូរវាងរដ្ឋនិងវិស័យឯកជន៖** រាជរដ្ឋាភិបាលមិនចាំបាច់ទទួលខុសត្រូវតែម្នាក់ឯងក្នុងការផលិតព័ត៌មានសម្រាប់ការតាមដានទេ។ រាជរដ្ឋាភិបាលអាចផ្ដល់កិច្ចសន្យាជាមួយវិស័យឯកជនឬស្ថាប័នអភិវឌ្ឍន៍នានាសម្រាប់ជួយគាំទ្រដល់ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ ព្រមទាំងការស្រាវជ្រាវនានាសម្រាប់គាំទ្រការវាយតម្លៃ។ រាជរដ្ឋាភិបាលត្រូវមានសមត្ថភាពក្នុងរៀបចំនិងគ្រប់គ្រងកិច្ចសន្យាទាំងនោះ ដែលតម្រូវឲ្យមានចំណេះដឹងនិងការយល់ដឹងអំពីដំណើរការនៃការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ។

## ៥- សកម្មភាពដែលត្រូវអនុវត្ត

**៤.២៤-** រាជរដ្ឋាភិបាលនឹងត្រូវពន្លឿនការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិដែលផ្សារភ្ជាប់ក្របខ័ណ្ឌលទ្ធផលជាមួយថវិកាកម្មវិធី។ ការផ្សារភ្ជាប់នេះនឹងជួយដល់អ្នករៀបចំផែនការនិងអ្នករៀបចំគោលនយោបាយវិភាគផលចំណេញផ្នែកសេដ្ឋកិច្ចលើការវិនិយោគកាន់តែបានប្រសើរ។ លើសពីនេះ អ្នកពាក់ព័ន្ធអាចវាយតម្លៃអាទិភាពទាំងឡាយដែលសម្រេចបានធៀបនឹងថវិកាដោយឆ្លុះបញ្ចាំងអំពីលទ្ធផលនិងឥទ្ធិពល។ គោលការណ៍ក៏អាចជួយគាំទ្រដល់ការរៀបចំផែនការហិរញ្ញវត្ថុនិងការអនុវត្តកម្មវិធីអន្តរវិស័យ។

**៤.២៥-** ក្នុងបរិបទនៃការផ្លាស់ប្ដូរហិរញ្ញប្បទានអភិវឌ្ឍន៍ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងបង្កើនការយកចិត្តទុកដាក់លើការលើកកម្ពស់ប្រសិទ្ធិភាព ភាពស័ក្ដិសិទ្ធិ និងចីរភាពចំណាយ។ ក្រសួង ស្ថាប័ននឹងត្រូវពន្យល់អំពីតម្រូវការថវិកាដោយផ្អែកលើអាទិភាពនិងផលចំណេញ ដែលអាចវាស់វែងបានចំពោះការវិនិយោគ។ ក្រសួង ស្ថាប័នត្រូវពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្សសម្រាប់ការងារ

តាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលតម្រូវឲ្យមានជំនួយបច្ចេកទេសសម្រាប់ការកសាងសមត្ថភាពផ្នែកតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលគាំទ្រដល់ការអនុវត្តកម្មវិធីដោយផ្អែកលើលទ្ធផល។

**៤.២៦-** សម្រាប់រយៈពេលខ្លី ក្រសួង ស្ថាប័ននឹងបន្តត្រូវការការគាំទ្រពីដៃគូអភិវឌ្ឍសម្រាប់ពង្រឹងប្រព័ន្ធគ្រប់គ្រងព័ត៌មាននិងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃនៅតាមវិស័យរបស់ខ្លួន។ ប្រសិនបើមិនមានគោលការណ៍ណែនាំនិងការសម្របសម្រួលច្បាស់លាស់ទេ និន្នាការនេះនឹងបន្តនៅដាច់ៗពីគ្នា ប៉ុន្តែដោយសារមានផែនការសកម្មភាពជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ បញ្ហានេះនឹងអាចដោះស្រាយបាន។

**៤.២៧-** សម្រាប់រយៈពេលមធ្យម ក្រសួងផែនការនឹងជាស្ថាប័នមួយដែលដើរតួនាទីក្នុងការសម្របសម្រួលនិងផ្ដល់បច្ចេកទេសលើការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ ទោះបីបច្ចុប្បន្នក្រសួងផែនការត្រូវការពង្រឹងសមត្ថភាពបន្ថែមលើការងារនេះក៏ដោយ។ ដូចនេះ រាជរដ្ឋាភិបាលនឹងត្រូវយកចិត្តទុកដាក់លើការពង្រឹងសមត្ថភាពរបស់ក្រសួងផែនការសម្រាប់ដើរតួនាទីគាំទ្រនិងគ្រប់គ្រង ដែលនឹងត្រូវការធនធានបន្ថែមពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រួមទាំងជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ។ ផែនការសកម្មជាតិសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ។

**៤.២៨-** របាយការណ៍ពាក់កណ្ដាលអាណត្តិ ស្នើឲ្យមានសកម្មភាពដូចខាងក្រោមសម្រាប់ផ.យ.អ.ជ. ២០១៤-២០១៨៖

- សម្រាប់តួនាទីជាស្ថាប័នដឹកនាំសម្រាប់ផ.យ.អ.ជ.និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ក្រសួងផែនការនឹងធ្វើការកែសម្រួលគណៈកម្មការជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីពិនិត្យលើការរៀបចំផែនការសកម្មភាពជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ផែនការសកម្មភាពជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃត្រូវបង្កើតឲ្យមានការរៀបចំស្ថាប័នសម្រាប់អនុវត្តការងារសម្របសម្រួលដល់ដំណើរការប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃជាតិ រួមទាំងស្តង់ដាបច្ចេកទេសនិងផែនការកសាងសមត្ថភាព។ ការងាររបស់ក្រុមការងារជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃគួរត្រូវបានទទួលជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍ។
- ក្រសួងផែនការនឹងបន្តផ្ដល់ការគាំទ្រដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការធ្វើសមាហរណកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជាទៅក្នុងផ.យ.អ.ជ.២០១៩-២០២៣។ ក្នុងន័យនេះ ក្រសួងផែនការនឹងបន្តរៀបចំក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា បន្ថែមលើសមិទ្ធផលដែលសម្រេចបានកន្លងមក។ ក្នុងករណីមួយចំនួន យន្តការក្នុងការប្រមូលទិន្នន័យមិនទាន់មាន ហើយសូចនាករមួយចំនួនមិនពាក់ព័ន្ធក្នុងបរិបទរបស់កម្ពុជា។ ការប្រមូលទិន្នន័យធំៗសម្រាប់ការពង្រីកគោលដៅ ចំណុចដៅ និងសូចនាករត្រូវការចំណាយច្រើន។ ក្រសួងផែនការនឹងជួយដល់ក្រសួង ស្ថាប័នឲ្យផ្ដោតលើចំណុចដៅនិងសូចនាករអាទិភាពដែលមានលទ្ធភាពផ្នែកទិន្នន័យនិងហិរញ្ញទាន។ ក្រសួងផែនការនឹងធ្វើការជិតស្និតជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងវិស័យសំខាន់ៗក្នុងដំណើរការរៀបចំផ.យ.

អ.ជ.២០១៩-២០២៣ ដើម្បីដាក់ចេញនូវចំណុចដៅនិងសូចនាករបន្ថែមដែលអាចអនុវត្តបាន។

- ក្រសួងផែនការនឹងរៀបចំគោលការណ៍ណែនាំសម្រាប់ក្រសួង ស្ថាប័នអនុវត្តក្នុងរៀបចំផែនការយុទ្ធសាស្ត្រតាមវិស័យរបស់ខ្លួនសម្រាប់ផ.យ.អ.ជ.អាណត្តិក្រោយ។ គោលការណ៍ណែនាំនឹងផ្ដោតលើតម្រូវការក្នុងការរៀបចំផែនការតាមវិស័យដោយផ្អែកលើក្របខ័ណ្ឌលទ្ធផល ដែលផ្សារភ្ជាប់សកម្មភាពអាទិភាពតាមវិស័យទៅនឹងគោលដៅអភិវឌ្ឍន៍តាមវិស័យ។ ដើម្បីធានាថាការរៀបចំផែនការមានលក្ខណៈប្រាកដនិយមនិងរៀបចំដោយផ្អែកលើធនធានដែលមាន សកម្មភាពអាទិភាពទាំងអស់ត្រូវធ្វើការប៉ាន់ប្រមាណចំណាយ ដើម្បីសម្រួលដល់ការកៀរគរធនធាន។ ផែនការយុទ្ធសាស្ត្រតាមវិស័យត្រូវមានសូចនាករសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលមានសង្គតិភាពជាមួយគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និងបង្ហាញអំពីតម្រូវការក្នុងស្រាវជ្រាវនិងការវាយតម្លៃ។
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវបង្កើនការវិភាជថវិកាគាំទ្រដល់ការពង្រឹងសមត្ថភាពរបស់ក្រសួងផែនការ ដើម្បីដើរតួនាទីឲ្យកាន់តែសកម្មបន្ថែមទៀតក្នុងការគាំទ្ររបៀបវារៈអភិបាលកិច្ចល្អ ជាពិសេសកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពាក់ព័ន្ធនឹងការអនុវត្តថវិកាកម្មវិធី។

## ៦- សេចក្ដីសន្និដ្ឋាន

**៤.២៩-** និន្នាការអភិវឌ្ឍន៍បង្ហាញអំពីតម្រូវការពង្រីកនិងពន្លឿនការងារលើការរៀបចំប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ក្នុងន័យនេះ ដំណើរការធ្វើមូលដ្ឋាននីយកម្មគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្ដល់ឱកាសសម្រាប់កម្ពុជាពង្រឹងសមត្ថភាពផ្នែកការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ការអនុវត្តផ.យ.អ.ជ. រួមជាមួយការប្រែប្រួលនៃបរិបទអភិវឌ្ឍន៍តម្រូវឲ្យយកចិត្តទុកដាក់លើក្របខ័ណ្ឌលទ្ធផល ដែលអាចពង្រឹងបានតាមរយៈការបង្កើតទំនាក់ទំនងច្បាស់លាស់រវាងក្របខ័ណ្ឌលទ្ធផលនិងកំណែទម្រង់ថវិកាកម្មវិធី។ ការផ្សារភ្ជាប់ធាតុចូលទៅនឹងលទ្ធផលនិងឥទ្ធិពលមានសារៈសំខាន់សម្រាប់វិភាគផលប្រយោជន៍ផ្នែកសេដ្ឋកិច្ចដល់ការវិនិយោគសាធារណៈ។ មានតម្រូវការចាំបាច់ក្នុងការវាយតម្លៃអាទិភាពលើធនធានសាធារណៈដែលតិចតួចទាក់ទងនឹងលទ្ធផលនិងឥទ្ធិពលជាក់ស្ដែងនិងរំពឹងទុក រួមបញ្ចូលទាំងការប្រើប្រាស់ប្រភពទិន្នន័យក្នុងវិស័យសំខាន់ៗនិងអន្តរវិស័យ។

**៤.៣០-** គោលបំណងរួមរបស់ ផ.យ.អ.ជ. លើកក្រោយ គឺបង្កើតកេរ្តិ៍ឈ្មោះរបស់កម្ពុជាជាឧទាហរណ៍នៃបទពិសោធន៍ល្អក្នុងការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលលើកកម្ពស់ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាពនៃវិនិយោគសាធារណៈនិងលើកកម្ពស់មុខមាត់របស់ប្រទេសកម្ពុជាជាបេក្ខភាពសម្រាប់ប្រភពហិរញ្ញប្បទានអភិវឌ្ឍន៍ថ្មីៗ។ ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃនេះអាចជាករណីមួយដែលកម្ពុជាអាចបង្ហាញយ៉ាងច្បាស់លាស់អំពីផលប្រយោជន៍លើការវិនិយោគសាធារណៈនិងឯកជន។ ការសម្រេចបានគោលដៅអាចពង្រឹងតាមរយៈការបង្កើត "វប្បធម៌ការងារតាមដានត្រួតពិនិត្យនិងវាយតម្លៃ" ដែលជាវិជ្ជាជីវៈខ្ពស់និងកិត្តិយសស្ថាប័ន ដែលភ្ជាប់ទៅនឹងបទពិសោធន៍ល្អ។

## តារាង៤.១ សូចនាករស្នូលសម្រាប់ការតាមដានត្រួតពិនិត្យនៃរបាយការណ៍ពាក់កណ្ដាលអាណត្តិនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

(*)- គោលដៅនិងចំណុចដៅរបស់ ផ.អ.ស.ក.

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| *១* | *ការលុបបំបាត់ភាពក្រីក្រ និង ភាពអត់ឃ្លានធ្ងន់ធ្ងរ* | | | | | | | | |
| ១១.* | អត្រាភាពក្រីក្រ(កម្ពុជា) | % | ១៨,៨ | ១៧,៨ | ១៦,៨ | ១៥,៨ | ១៤,៨ | ១៣,៨ | អ.ស.ស.ក. (វ.ជ.ស.) |
| ១២.* | អត្រាភាពក្រីក្រ(ជនបទ) | % | ១៩,៧ | ១៨,៧ | ១៧,៧ | ១៦,៧ | ១៥,៧ | ១៤,៧ | អ.ស.ស.ក. (វ.ជ.ស.) |
| ១៣.* | អត្រាភាពក្រីក្រផ្នែកម្ហូបអាហារ | % | <៥ | <៥ | <៥ | <៥ | <៥ | <៥ | អ.ស.ស.ក. (វជស) |
| ១៤. | មេគុណ Gini នៃវិសមភាពក្នុងការចំណាយលើការប្រើប្រាស់ | % | ០,៣២ | ០,៣២ | ០,៣២ | ០,៣១ | ០,៣១ | ០,៣០ | អ.ស.ស.ក. |
| ១៥. | អត្រាភាពក្រីក្ររបស់កុមារ | % | ២៣,០ | ២២,០ | ២១,០ | ២០,០ | ១៩,០ | ១៨,០ | អ.ស.ស.ក. |
| *២* | *ការបង្កើនល្បឿនកំណែទម្រង់អភិបាលកិច្ច* | | | | | | | | |
| ២១. | ស្ថានភាពសេដ្ឋកិច្ច(អត្រានៃការសន្សំនិងការវិនិយោគ) | % នៃ *ផ.ស.ស.* | ២៧,២ | ២៥,៨ | ២៦,១ | ២៦,១ | ២៦,៥ | ២៦,៦ | គណនេយ្យជាតិ (វ.ជ.ស.) |
| ២២. | ទំនាស់អំពីដីធ្លីឬកម្មសិទ្ធិ | ក្នុងប្រ/ជ ១រយពាន់នាក់ | ៣០ (២០១១) | <៣០ | <៣០ | <៣០ | <៣០ | <៣០ | អ.ស.ស.ក. |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២៣. | ការមានអារម្មណ៍សុវត្ថិភាព | % ប្រជ/ | ៨០ (២០១១) | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ស.ស.ក. |
| *៣* | *ការលើកកម្ពស់ផលិតភាពនិងផលិតកម្មកសិកម្ម* | | | | | | | | |
| ៣១. | ទិន្នផលស្រូវក្នុងមួយហិកតា | តោន | | ៣,១៥ | ៣,១៨ | ៣,២១ | ៣,២៣ | ៣,២៥ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ៣២. | ផ្ទៃដីដំណាំទាំងអស់ដែលបានស្រោចស្រព | ហ.ត | ១ ៤៨៥ ៦៧០ | ១ ៥១៥ ៦៧០ | ១ ៥៤៥ ៦៧០ | ១ ៥៧៥ ៦៧០ | ១ ៦០៥ ៦៧០ | ១ ៦៣៥ ៦៧០ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ៣៣. | ផ្ទៃដីដាំដំណាំសរុប | ហ.ត | | ៤ ៨១៤ ៥៣៤ | ៥ ០២៤ ៥៣៤ | ៥ ២៣៤ ៥៣៤ | ៥ ៤៤៤ ៥៣៤ | ៥ ៦៥៤៥៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ៣៤. | សន្ទស្សន៍ពិពិធភាវូបនីយកម្មដំណាំ | % នៃតំបន់សរុប | ៣១ | ៣២ | ៣៥ | ៣៥ | ៣៥ | ៣៥ | ក.ក.រ.ន. |
| ៣៥. | សន្ទស្សន៍ទិន្នផលស្រូវលើស | % | ៥៦ | > ៦០ | > ៦០ | > ៦០ | > ៦០ | > ៦០ | ក.ក.រ.ន./វ.ជ.ស. |
| *៤* | *ការលើកកម្ពស់ស្ថានភាពសុខភាព(*)* | | | | | | | | |
| ៤១. | ការសម្រាលកូនដោយបុគ្គលិក សុខាភិបាលដែលបានទទួលការបណ្ដុះបណ្ដាល | % | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ក.) |
| ៤២. | អត្រាស្លាប់ដោយជំងឺគ្រុនចាញ់ដែលត្រូវបានរាយការណ៍ដោយមូលដ្ឋានសុខាភិបាលសាធារណៈ | % | ១,២៥ | ១ | ០,៨ | ០,៦៥ | ០,៥ | ០,៣៥ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ក.) |
| ៤៣. | អត្រាមរណភាពទារក | ក្នុង១០០០ កំណើតរស់ | ៤៥ | | ៣៥ | | | ៣២ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ក.) |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៤៤. | អត្រាមរណភាពកុមារអាយុក្រោម៥ឆ្នាំ | ក្នុង១០០០ កំណើតរស់ | ៥៤ | | ៤៥ | | | ៤២ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤៥.* | អត្រាមរណភាពមាតា | ក្នុង១រយពាន់ កំណើតរស់ | ២០៦ | | ១៤០ | | | ១៣០ | ជ.ទ.ប.ក./អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៤៦. | អត្រាប្រេវ៉ាឡង់មេរោគអេដស៍/ជំងឺអេដស៍ | %នៃ មនុស្សពេញវ័យអាយុពី ១៥-៤៩ឆ្នាំ | ០,៧ | ០,៦ | ០,៥ | ០,៤ | ០,៣ | < ០,១ | ប.ព.រ.ក.ស. (អ.ជ.ប.រ.) |
| ៤៧. | ប្រេវ៉ាឡង់នៃជំងឺរបេងបេកាវិជ្ជមាន | ក្នុងប្រ/ជ ១រយពាន់នាក់ | ៧៣៥ | ៦៩៤ | ៦៥៣ | ៦១២ | ៥៧១ | ៥៣០ | ប.ព.រ.ក.ស. (ក.ស.ភ.) |
| *៥* | *ការលើកកម្ពស់ស្ថានភាពអាហារូបត្ថម្ភ និងទឹកស្អាតនិងអនាម័យ* | | | | | | | | |
| ៥១. | ភាគរយនៃកុមារក្រិនអាយុក្រោម៥ឆ្នាំ (បទដ្ឋានក្រោម) | % នៃកុមារសរុប អាយុពី០-៥៩ខែ | ៤០ (២០១០) | | | | | ២៥ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥២. | ភាគរយនៃកុមារអាយុក្រោម៥ឆ្នាំដែលមិនគ្រប់ទម្ងន់(ក្រោមបទដ្ឋាន) | % នៃកុមារសរុប អាយុពី០-៥៩ខែ | ២៨ (២០១០) | | | | | ១៩ | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥៣. | ភាគរយនៃស្ត្រីអាយុពី១៥-៤៩ឆ្នាំដែលមានភាពស្លេកស្លាំង | % នៃស្ត្រីសរុប អាយុពី១៥-៤៩ ឆ្នាំ | ៤៤ | | | | | - | អ.ប.ស.ក. (វ.ជ.ស./ក.ស.ភ.) |
| ៥៤. | ភាគរយនៃកុមារអាយុពី៦-៥៩ខែ ដែលមានភាពស្លេកស្លាំង | % នៃកុមារសរុប អាយុពី៦-៥៩ខែ | ៥៥ | | | | | ៤២ | អ.ស.ប.ក. (វ.ជ.ស./ក.ស.ភ.) |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៦ | *ការលើកកម្ពស់វិស័យអប់រំ* | | | | | | | | |
| | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៦.១ | *សរុប* | % | ៩៧,០ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.២ | *ស្រី* | % | ៩៧,០ | ៩៧,១ | ៩៧,៨ | ៩៨,៥ | ៩៩,២ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ៦.៣ | *សរុប* | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៤ | *ស្រី* | % | ៥៧,៧ | ៦០,៣ | ៦៦,៥ | ៧៣,១ | ៨០,៤ | ៨៥,៩ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៦ | | | | | | | | |
| ៦.៥ | *សរុប* | % | ៩១,៥ | ៩៨,៣ | ១០០ | ១០០ | ១០០ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៦ | *ស្រី* | % | ៩១,០ | ៩៨,០ | ១០០ | ១០០ | ១០០ | ១០០ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| | អត្រាបញ្ចប់ការសិក្សាថ្នាក់ទី៩ | | | | | | | | |
| ៦.៧ | *សរុប* | % | ៤២,២ | ៤៤,៤ | ៦១,៦ | ៥៧,២ | ៦៧,៣ | ៧៦,៤ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៨ | *ស្រី* | % | ២៥,៥ | ២៧,៣ | ៣១,៦ | ៣៥,១ | ៤១,៦ | ៤៧ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| ៦.៩ | សមាមាត្រកុមារក្នុងសាលាដែលមានអាយុពី៦-១៧ឆ្នាំ | %កុមារសរុបដែលមានអាយុពី៦-១៧ឆ្នាំ | >៨០ | >៨០ | >៨០ | >៨០ | >៨០ | >៨០ | អ.ស.ស.ក. (វ.ជ.ស.) |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៦.១០ | ភាគរយនៃអ្នកបានបញ្ចប់មហាវិទ្យាល័យដែលមានអាយុពី១៨-៣៥ឆ្នាំ | % | > ៥ | > ៥ | > ៥ | > ៥ | > ៥ | > ៥ | ប.ព.វ.ក.ស./អ.ស.ស.ក. (ក.អ.យ.ក./វ.ជ.ស.) |
| *៧* | *ទឹកស្អាតអនាម័យ និងការអភិវឌ្ឍ/ជនបទ* | | | | | | | | |
| ៧១. | លទ្ធភាពទទួលបានប្រភពទឹកស្អាតនៅទីប្រជុំជន | % | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | > ៨៥ | អ.ស.ស.ក. (វ.ជ.ស.) |
| ៧២. | លទ្ធភាពទទួលបានអនាម័យប្រសើរជាងមុននៅទីប្រជុំជន | % | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | > ៨០ | អ.ស.ស.ក. (វ.ជ.ស.) |
| ៧៣. | ផ្លូវជនបទដែលបានស្តារលើ ប្រវែងផ្លូវសរុប៤០ ០០០ គ.ម. | គ.ម. | ២៧ ៧៥០ | ២៨ ៦០០ | ២៩ ៤៥០ | ៣០ ៣០០ | ៣១ ១៥០ | ៣២ ០០០ | ប.ព.វ.ក.ស. (ក.អ.ជ.) |
| ៧៤. | លទ្ធភាពទទួលបានប្រភពទឹកស្អាតបរិភោគនៅជនបទ | % | ៤៤,២ | ៤៦,៧ | ៥០,០ | ៥៣,០ | ៦៧,០ | ៦៧,០ | អ.ស.ស.ក. (វ.ជ.ស.) |
| ៧៥. | លទ្ធភាពអនាម័យប្រសើរជាងមុននៅទីប្រជុំជន | % | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ៦០ | អ.ស.ស.ក. (វ.ជ.ស.) |
| *៨* | *ចីរភាពបរិស្ថាន* | | | | | | | | |
| ៨១. | ផ្ទៃដីតំបន់ការពារធម្មជាតិទាំង២៣កន្លែង | ហ.ត. | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ៣០៩៨៦៦៣ | ប.ព.វ.ក.ស. (ក.ក.វ.ន.) |
| ៨២. | សហគមន៍តំបន់ការពារធម្មជាតិ | ចំនួន | ១២០ | ១៣០ | ១៤០ | ១៤២ | ១៤៥ | ១៥០ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ៨៣. | ផ្ទៃដីគ្របដណ្តប់ដោយព្រៃឈើ | % នៃផ្ទៃដីសរុប | ៥៨,៤ (២០១០) | ៥៩,២ (ប៉ាន់ស្មាន) | ៦០ | ៦០ | ៦០ | ៦០ | ប.ព.វ.ក.ស. (ក.ប.ស.) |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៨៤. | អត្រាបណ្ណកម្មសិទ្ធិដីធ្លីដែលផ្តល់ជូនប្រជាពលរដ្ឋទូទៅ | % នៃក្បាលដីសរុប | | ៥២ | ៥៧ | ៦២ | ៦៦ | ៧០ | ប. ព. រ. ក. ស. (ក. រ. ជ. ន. ស.) |
| ៨៥. | ភាគរយនៃប្រជាជនដែលប្រើប្រាស់អុសធ្យូងសម្រាប់ចម្អិនអាហារ | % | | | | | | | ប. ព. រ. ក. ស. (ក. ប. ស.) |
| *៩* | *សមធម៌យេនឌ័រ* | | | | | | | | |
| ៩.១ | សមាមាត្រស្ត្រីដែលកាន់មុខតំណែងជាអ្នកសម្រេចចិត្តក្នុងវិស័យសាធារណៈ | % | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ប. ព. រ. ក. ស. (កកន) |
| ៩.២ | សមាមាត្រស្ត្រីក្នុងវិស័យសាធារណៈ | % | ៣៥ | ៣៦ | ៣៦,៥ | ៣៧ | ៣៧ | ៣៧ | ប. ព. រ. ក. ស. (ក. ក. ន.) |
| | ការចូលរួមរបស់ស្ត្រីក្នុងការងារទទួលកម្រៃ | | | | | | | | |
| ៩.៣ | *កសិកម្ម* | % | ៥២ | ៥១ | ៥០ | ៥០ | ៥០ | ៥០ | ជ. ទ. ប. ក. (វ. ជ. ស.) |
| ៩.៤ | *ឧស្សាហកម្ម* | % | ៦០ | ៥៥ | ៥០ | ៥០ | ៥០ | ៥០ | ជ. ទ. ប. ក. (វ. ជ. ស.) |
| ៩.៥ | *សេវា* | % | ៣០ | ៣៥ | ៤០ | ៤០ | ៤០ | ៤០ | ជ. ទ. ប. ក. (វ. ជ. ស.) |
| ៩៦. | សមាមាត្រស្ត្រីដែលបានបញ្ចប់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលវែង | នាក់ | ៨ ០០០ | ៨ ៥០០ | ៩ ០០០ | ៩ ៥០០ | ១០ ០០០ | ១១ ០០០ | ប. ព. រ. ក. ស. (ក. ក. ប. វ.) |
| | យេនឌ័រនិងការអប់រំ | | | | | | | | |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៩៧. | អត្រារួមនៃស្ត្រីសិក្សានៅមធ្យមសិក្សាទុតិយភូមិ | % | ២៧,៦ | ២៧,២ | ២៨,៤ | ៣១,៥ | ៣៥,៦ | ៤១,៩ | ក.អ.យ.ក. |
| ៩៨. | អត្រារួមនៃស្ត្រីសិក្សានៅឧត្តមសិក្សា | % | ១២ | ១៣ | ១៤ | ១៦ | ១៨ | ២០ | ក.អ.យ.ក. |
| | យេនឌ័រនិងសុខភាព | | | | | | | | |
| ៩៩. | ភាគរយស្ត្រីទៅពិនិត្យផ្ទៃពោះយ៉ាងតិច ២ដង | % | ៨៧ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ | ប.ព.វ.ក.ស. (ក.ស.ភ.) |
| | យេនឌ័រនិងអំពើហិង្សា | | | | | | | | |
| ៩.១០ | ចំនួនគ្រួសារដែលរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ | ចំនួន | ២៧ ០០០ | ២៥ ០០០ | ២៣ ០០០ | ២០ ០០០ | ១៨ ០០០ | ១៥ ០០០ | ប.ព.វ.ក.ស. (ក.ក.ន.) |
| | យេនឌ័រនិងបម្រែបម្រួលអាកាសធាតុ | | | | | | | | |
| ៩.១១ | មេគ្រួសារជាស្ត្រីដែលបានទទួលផលពីកម្មវិធីប្រែប្រួលអាកាសធាតុ | ចំនួន | ៥០ ០០០ | ៧០ ០០០ | ៩០ ០០០ | ១១០ ០០០ | ១៣០ ០០០ | ១៥០ ០០០ | ប.ព.វ.ក.ស. (ក.ក.ន.) |
| ៩.១២ | ចំនួនគ្រួសារដែលមានលទ្ធភាពទទួលបានទឹកស្អាតពេញមួយឆ្នាំ | ចំនួន | ១ ៩០០ ០០០ | ២ ០០០ ០០០ | ២ ១០០ ០០០ | ២ ២០០ ០០០ | ២ ៣០០ ០០០ | ២ ៤០០ ០០០ | ប.ព.វ.ក.ស. (ក.ក.ន.) |
| *១០* | *សមាហរណកម្មកម្ពុជាទៅក្នុងពិភពលោក* | | | | | | | | |
| ១០១. | វិនិយោគផ្ទាល់ពីបរទេស | % *ផ.ស.ស.* | ១៣,៤ | ១៣,០ | ១៣,១ | ១៣,១ | ១៣,១ | ១៣,២ | ប.ព.វ.ក.ស. (ធ.ជ.ក.) |
| ១០២. | ការនាំចេញ នាំចូល(ទំនិញ) | % *ផ.ស.ស.* | ១០៤,៦ | ១០៥,៨ | ១០៨,២ | ១០៨,៩ | ១១១ | ១១១,២ | ប.ព.វ.ក.ស. (ធ.ជ.ក.) |
| ១០៣. | តុល្យភាពគណនីចរន្ត | % *ផ.ស.ស.* | -៩,៥ | -៩,៣ | -៨,៨ | -៨,១ | -៦,៧ | -៥,២ | ក.ស.ហ. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១០៤. | និន្នាការនៃជំនួយអភិវឌ្ឍ | លានដុល្លារ | ១ ៥៦៦,៤ | ១ ២៤២,២ | ១ ០០០,៨ | | | | ក.អ.ក. |
| ១១ | ការធ្វើឱ្យមានស្ថិរភាពកំណើន ម៉ាក្រូសេដ្ឋកិច្ចខ្ពស់ | | | | | | | | |
| ១១១. | កំណើន ផ.ស.ស .ប្រចាំឆ្នាំ | % | ៧,៦ | ៧,០ | ៧,០ | ៧,០ | ៧,០ | ៧,០ | ក.ស.ហ. |
| ១១២. | ផ.ស.ស.សម្រាប់មនុស្សម្នាក់ (តម្លៃបច្ចុប្បន្ន) | ពាន់រៀល | ៤ ២៤៨ | ៤ ៦៧០ | ៥ ០៧២ | ៥ ៥២៣ | ៥ ៩៤៩ | ៦ ៤៧២ | ក.ស.ហ. |
| ១១៣. | សន្ទស្សន៍កំណើនបរិយាប័ន្ន (ឆ្នាំគោល = ២០១៣=១០០) | ចំនួន | ១០៧ | ១១៤,៥ | ១២២,៥ | ១៣១,១ | ១៤០,៣ | | ក.ស.ហ. |
| | រចនាសម្ព័ន្ធនៃផសស | | | | | | | | |
| ១១៤. | កសិកម្ម | % នៃ ផ.ស.ស. សរុប | ២៦,៦ | ២៥,៦ | ២៥,១ | ២៤,៤ | ២៣,៨ | ២៣,១ | ក.ស.ហ. |
| ១១៥. | ឧស្សាហកម្ម | % នៃ ផ.ស.ស. សរុប | ៣១,៦ | ៣២,៦ | ៣៣,២ | ៣៣,៨ | ៣៤,៤ | ៣៥,០ | ក.ស.ហ. |
| ១១៦. | សេវា | % នៃ ផ.ស.ស. សរុប | ៤១,៨ | ៤១,៨ | ៤១,៧ | ៤១,៨ | ៤១,៨ | ៤១,៩ | ក.ស.ហ. |
| | ការប្រែប្រួលអត្រាកំណើនតាមវិស័យតម្លៃថេរ) ឆ្នាំ២០០៦( | | | | | | | | |
| ១១៧. | កសិកម្ម | % នៃ ផ.ស.ស. សរុប | ៤,២ | ៤,២ | ៤ | ៤ | ៤ | ៤ | ក.ស.ហ. |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១១៨. | ឧស្សាហកម្ម | % នៃផ.ស.ស. សរុប | ៩,៣ | ៩,៩ | ៩,៣ | ៩,១ | ៨,៨ | ៨,៨ | ក.ស.ហ. |
| ១១៩. | សេវា | % នៃផ.ស.ស. សរុប | ៨,៨ | ៦,៨ | ៧,១ | ៧,១ | ៧,២ | ៧,២ | ក.ស.ហ. |
| | អត្រាអតិផរណា( ការប្រែប្រួលជា%) | | | | | | | | |
| ១១១០. | ការប្រែប្រួលជាមធ្យមប្រចាំឆ្នាំ | % | ៣ | ៣,៣ | ៣,៥ | ៣,៥ | ៣,៥ | ៣,៥ | គណនេយ្យជាតិ (វ.ជ.ស.) |
| ១២ | ការកែលម្អការគ្រប់គ្រងថវិកា | | | | | | | | |
| ១២១. | ចំណូលថវិការដ្ឋសរុប | % ផ.ស.ស. | ១៤,៣ | ១៥,១ | ១៥,៦ | ១៦,១ | ១៦,៥ | ១៦,៩ | ប.ព.វ.ក.ស. (ក.ស.ហ.) |
| ១២២. | ចំណាយថវិការដ្ឋសរុប | % ផ.ស.ស. | ១៩,៥ | ១៩,៩ | ១៩,៨ | ១៩,៩ | ១៩,៩ | ១៩,៩ | ប.ព.វ.ក.ស. (ក.ស.ហ.) |
| ១៣ | ការងារ | | | | | | | | |
| | ការបែងចែកភាពមានការងារធ្វើ តាមវិស័យ (១៥-៦៤ឆ្នាំ) | | | | | | | | |
| ១៣១. | កសិកម្ម | % | ៦២ (២០១១) | ៦០ | ៥៩ | ៥៨ | ៥៧ | ៥៧ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ១៣២. | ឧស្សាហកម្ម | % | ១០ (២០១១) | ១១ | ១១ | ១២ | ១២ | ១៣ | ជ.ទ.ប.ក. (វ.ជ.ស.) |
| ១៣៣. | សេវា | % | ២៨ | ២៩ | ៣០ | ៣០ | ៣១ | ៣១ | ជ.ទ.ប.ក. |

| | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | | | (២០១១) | | | | | | (រ.ជ.ស.) |
| ១៤ | *ហេដ្ឋារចនាសម្ព័ន្ធ* | | | | | | | | |
| ១៤.១. | ប្រវែងផ្លូវកៅស៊ូ នៃប្រវែងសរុប១១.៩៧៤គម .(ផ្លូវជាតិនិងផ្លូវខេត្ត) | គ.ម. | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ១២ ២៦៣ | ប.ព.វ.ក.ស. (ក.ស.ដ.) |
| ១៤២. | ផ្លូវដែកដែលបានស្ដារឡើងវិញនិងសង់ថ្មី | គ.ម. | ២៦៦ | ៣៨៦ | ២៥៧ | ៣១៩ | ២៤៨ | ២៤៨ | ប.ព.វ.ក.ស. (ក.ស.ដ.) |
| ១៤៣. | ទេសចរអន្តរជាតិ | លាននាក់ | ៤,០៥ | ៤,៥៣ | ៥,០០ | ៥,៥២ | ៦,១០ | ៦,៧០ | ប.ព.វ.ក.ស. (ក.ទ.) |
| | លទ្ធភាពទទួលបានព័ត៌មានសាធារណៈ នៃប្រជាជនសរុប | | | | | | | | |
| ១៤.៤ | *វិទ្យុនិងទូរទស្សន៍* | % | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ | ៩០ | ប.ព.វ.ក.ស. (ក.ព.ម.) |
| ១៤.៥ | *ទស្សនាវដ្ដី/សារព័ត៌មាន* | % | ៤,២ | ៤,៦ | ៥,០ | ៥,២ | ៥,៥ | ៥,៨ | ប.ព.វ.ក.ស. (ក.ព.ម.) |
| ១៥ | *ថាមពល* | | | | | | | | |
| ១៥១. | លទ្ធភាពទទួលបានអគ្គិសនី | គវម៉ | ២៧២ | ៣០០ | ៣៣០ | ៣៦៣ | ៣៩៩ | ៤៣៩ | ប.ព.វ.ក.ស. (ក.រ.ថ.) |
| ១៦ | *ការបោសសម្អាតមីន ការជួយសង្គ្រោះជនរងគ្រោះ* | | | | | | | | |

| សូចនាករ | | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១៦១. | ជនរងគ្រោះដោយសារមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាមប្រចាំឆ្នាំ | ចំនួន | ១៦៧ | ១៥១ | ១៣៦ | ១២២ | ១១០ | ៩៩ | ប.ព.រ.ក.ស. (អ.ម.ក.) |
| ១៦២. | ផ្ទៃដីសរុបដែលបានបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | ហ.ត. | ៨ ៧០៨ | ៩ ១៤៣ | ៩ ៦០០ | ១០ ០៨០ | ១០ ៥៨៤ | ១១ ១១៣ | ប.ព.រ.ក.ស. (អ.ម.ក.) |

# ជំពូកទី៥

# ការងារដែលត្រូវអនុវត្តបន្តដល់ឆ្នាំ២០១៨ និង តទៅមុខទៀត

## ១- សេចក្តីផ្តើម

**៥.១-** ជំពូកនេះ បានកំណត់នូវបញ្ហាសំខាន់ៗចំនួន៧ ពីការពិនិត្យវាយតម្លៃនូវវឌ្ឍនភាពតាមវិស័យ និងផ្តល់អនុសាសន៍ដែលពាក់ព័ន្ធនិងទិសដៅសំខាន់ៗនៃការអភិវឌ្ឍ សម្រាប់ការអនុវត្តនៅក្នុងពាក់កណ្តាលអាណត្តិបន្ទាប់នៃ *ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ(ផ.យ.អ.ជ.) ២០១៤-២០១៨* ក៏ដូចជា សម្រាប់ធ្វើជាមូលដ្ឋាននៃការរៀបចំ*ផ.យ.អ.ជ. ២០១៩-២០២៣*។ អនុសាសន៍ទាំងនេះ ផ្អែកលើសមិទ្ធផលដែលសម្រេចបាន និងការដោះស្រាយនូវបញ្ហាប្រឈមនានាដែលបានជួបប្រទះ នៅក្នុងរយៈពេលនៃការអនុវត្តរយៈពេល ២ឆ្នាំកន្លះ នៃពាក់កណ្តាលអាណត្តិដំបូងរបស់ *ផ.យ.អ.ជ. ២០១៤-២០១៨*។ ដើម្បីធានាបាននូវការទទួលបានការដោះស្រាយប្រកបដោយ ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងស្ថេរភាព លើបញ្ហាទាំង៧ ដែលមានលក្ខណៈទូលំទូលាយនិងអន្តរវិស័យនេះ ត្រូវទាមទារឲ្យមានយន្តការនិងកិច្ចសហប្រតិបត្តិការខ្លាំងក្លាជាងមុន រវាងស្ថាប័ននានារបស់រាជរដ្ឋាភិបាលកម្ពុជា។

**៥.២-** លទ្ធផលនៃការពិភាក្សា បានផ្តោតការយកចិត្តទុកដាក់លើបណ្តាសកម្មភាពនៅក្នុងវិស័យជាអាទិភាពនានា សម្រាប់រយៈពេលពាក់កណ្តាលអាណត្តិបន្ទាប់របស់ ផ.យ.អ.ជ. ពីឆ្នាំ២០១៦-២០១៨ និងសម្រាប់ ផ.យ.អ.ជ. បន្ទាប់។ ការពិនិត្យវាយតម្លៃបានបញ្ជាក់ពីការផ្តោតការយកចិត្តទុកដាក់របស់យុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ទៅលើអភិបាលកិច្ចល្អ ដែលជាស្នូលរបស់យុទ្ធសាស្ត្រចតុកោណ និងចតុកោណ៤ទៀត ដែលជាវិស័យពាក់ព័ន្ធសំខាន់ៗ។ តាមការប៉ាន់ស្មាន ធនធានសាធារណៈទាំងពីរាជរដ្ឋាភិបាលនិងពីដៃគូអភិវឌ្ឍន៍ ព្រមទាំងពីផ្នែកឯកជន នឹងមានការខ្វះខាតសម្រាប់គាំទ្រដល់ទិសដៅនានានៃការអភិវឌ្ឍ។ ដូចនេះ សម្រាប់ការរៀបចំ ផ.យ.អ.ជ. នៅអាណត្តិកាលបន្ទាប់ ចាំបាច់ត្រូវកំណត់អាទិភាពឲ្យបានច្បាស់លាស់ និងត្រូវផ្សារភ្ជាប់ផែនការតាមវិស័យជាមួយនឹងទិសដៅរបស់ ផ.យ.អ.ជ. ជាមួយគ្នានឹងការដោះស្រាយបញ្ហាអន្តរវិស័យ និងការពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

## ២- បញ្ហាប្រឈមសំខាន់ៗ និង សំណើដោះស្រាយ

**៥.៣-** សំណើមួយចំនួន ផ្តើមចេញពីការវិភាគក្នុងរបាយការណ៍នេះ មានដូចខាងក្រោម៖

ការកាត់បន្ថយភាពក្រីក្រ និងកំណើនប្រកបដោយបរិយាប័ន្ន៖ កម្ពុជាសម្រេចបាននូវវឌ្ឍនភាពជាច្រើនគួរឲ្យកត់សម្គាល់ នៅក្នុងការងារកាត់បន្ថយភាពក្រីក្រ។ ប្រជាជនកម្ពុជាជាច្រើនបានរួចចាកផុតពីភាពក្រីក្រ។ ទោះជាដូចនេះក្តី ប្រជាជនទាំងនោះគ្រាន់តែបានរួចចាកផុតពីភាពក្រីក្រក្រប៉ុណ្ណោះ ហើយប្រជាជនទាំងនោះងាយនឹងរងគ្រោះធ្លាក់ទៅក្នុងភាពក្រីក្រវិញ នៅពេលពួកគាត់ជួបប្រទះនឹងបញ្ហាផ្សេងៗដូចជា ការឈឺថ្កាត់ធ្ងន់ធ្ងរ គ្រោះថ្នាក់ដោយគ្រោះធម្មជាតិជាដើម។ កម្រិតនៃភាពក្រីក្រ ក៏នៅមានគម្លាតពីតំបន់មួយទៅតំបន់មួយក្នុងប្រទេស ហើយការទទួលបានសេវាអប់រំ និងសេវាសុខាភិបាល ក៏មានភាពខុស

គ្នាដែរ។ បញ្ហាប្រឈមចម្បងនៅក្នុងការកាត់បន្ថយភាពក្រី នឹងនៅតែបណ្ដាលមកពីសមត្ថភាពរបស់ប្រជាជននៅមានកម្រិត ក្នុងការស្រូបយកផលប្រយោជន៍ពីកំណើនសេដ្ឋកិច្ច។ ប្រជាជនក្រីក្រទាំងនោះ ភាគច្រើនរស់នៅក្នុងតំបន់ដាច់ស្រយាល ដែលមានការលំបាកនិងចំណាយច្រើនដើម្បីទៅដល់តំបន់ទាំងនោះ។ ការលំបាកនៅក្នុងការដោះស្រាយពីភាពក្រីក្រនិងភាពងាយរងគ្រោះ រួមទាំងជនបាត់បង់សមត្ថភាពពលកម្ម និងប្រជាជនវ័យចាស់ ទាមទារឲ្យមានយុទ្ធសាស្ត្រនិងអន្តរាគមន៍ដាច់ដោយឡែក រួមទាំងប្រភេទនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃផងដែរ។

**ការជំរុញវិស័យកសិកម្ម៖** សេដ្ឋកិច្ចកម្ពុជាកំពុងមានការផ្លាស់ប្ដូរគួរឲ្យកត់សម្គាល់ នៅក្នុងការរួមចំណែករបស់វិស័យនានាក្នុងផលិតផលក្នុងស្រុកសរុប។ ការរួមចំណែករបស់វិស័យកសិកម្មមានការថយចុះ ហើយមានការកើនឡើងរបស់វិស័យឧស្សាហកម្មនិងសេវា។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា វិស័យកសិកម្មនឹងនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ នៅក្នុងការសម្របសម្រួលការកែទម្រង់រចនាសម្ព័ន្ធ និងត្រូវស្វែងរកការវិនិយោគបន្ថែមទៀត ដើម្បីបង្កើនកត្តាផលិតកម្ម។ ការពង្រីកផ្ទៃដីកសិកម្មនិងផលិតផល ហាក់ដូចជានៅមានកម្រិតនៅឡើយ ដូចនេះ ទិសដៅសំខាន់គឺ ត្រូវបង្កើនកត្តានៃផលិតភាព ដើម្បីធ្វើឲ្យប្រសើរឡើងនូវផលប្រយោជន៍សម្រាប់កសិករដែលមានផ្ទៃដីកសិកម្មតូចតាច។ បញ្ហាប្រឈមដែលត្រូវដោះស្រាយនៅក្នុងវិស័យកសិកម្មគឺ ប្រជាជនមិនសូវមានទម្លាប់ទទួលយកមកប្រើប្រាស់នូវពូជថ្មីដែលមានគុណភាព ការខ្វះខាតសេវាផ្សព្វផ្សាយនិងប្រព័ន្ធធារាសាស្ត្រ ការប្រើប្រាស់ជីមិនបានត្រឹមត្រូវ ខ្វះការសម្របសម្រួលរវាងក្រសួងស្ថាប័នពាក់ព័ន្ធនិងវិស័យកសិកម្ម ខ្វះការគ្រប់គ្រងប្រភពធនធានទឹក និងការអភិវឌ្ឍជនបទនៅមានកម្រិត។ សារប្បកម្មជាអនុវិស័យមិនសូវមានការរីកចម្រើនទេ ដែលទាមទារឲ្យមានការវិនិយោគបន្ថែមទៀតនៅក្នុងអនុវិស័យនេះ ដើម្បីបង្កើនផលិតភាពនិងផលិតកម្មបន្លែសរុប។

**ការប្រកួតប្រជែង៖** ការបើកទូលាយរបស់សេដ្ឋកិច្ចកម្ពុជា ពឹងផ្អែកយ៉ាងខ្លាំងលើពាណិជ្ជកម្ម និងការវិនិយោគពីបរទេស។ ដោយសារតែពាណិជ្ជកម្មក្នុងតំបន់និងក្នុងពិភពលោក មានការប្រកួតប្រជែងខ្លាំង ជាពិសេស នៅក្នុងបរិការណ៍នៃការធ្វើសមាហរណកម្មទៅក្នុងសេដ្ឋកិច្ចអាស៊ាន កម្ពុជានឹងត្រូវធ្វើការវិនិយោគច្រើនបន្ថែមទៀត ក្នុងវិស័យអប់រំ សុខាភិបាល និងក្នុងផ្នែកជំនាញ ដើម្បីបង្កើនផលិតភាពឲ្យស្របគ្នានឹងការកើនឡើងយ៉ាងឆាប់រហ័សនៃកម្លាំងពលកម្ម។ កម្ពុជានឹងត្រូវជំរុញការធ្វើឲ្យប្រសើរឡើងនូវបរិស្ថានក្នុងវិស័យឯកជន សម្រាប់ការវិនិយោគពីក្នុងនិងក្រៅប្រទេស តាមរយៈ ការផ្សព្វផ្សាយលិខិតបទដ្ឋានពាណិជ្ជកម្ម ចូលរួមយ៉ាងសកម្មនៅក្នុងការសម្របសម្រួលពាណិជ្ជកម្ម និងធ្វើការវិនិយោគនៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដើម្បីធ្វើឲ្យប្រសើរឡើងការតភ្ជាប់ការដឹកជញ្ជូន និងការកាត់បន្ថយការចំណាយលើថាមពល។

**ការផ្លាស់ប្ដូរទីលំនៅនិងនគរូបនីយកម្ម៖** ចំនួនដ៏ច្រើននៃប្រជាជនប្រុសនិងស្រីវ័យក្មេង បានធ្វើចំណាកស្រុកពីភូមិកំណើត ទៅស្វែងរកការងារធ្វើនៅទីក្រុងនានាក្នុងស្រុក ឬទីកន្លែងផ្សេងទៀតនៅក្នុងតំបន់។ ចលនានេះ បណ្ដាលឲ្យមានផលប៉ះពាល់ដល់រចនាសម្ព័ន្ធសង្គមនៅក្នុងតំបន់ជនបទ ហើយបង្កឲ្យមានបញ្ហាប្រឈមចម្បងៗដល់ការផ្ដល់សេវាសង្គមនិងសន្តិសុខ ដល់ជនផ្លាស់ប្ដូរទីលំនៅនិងគ្រួសាររបស់ពួកគាត់។ បម្លាស់ទីលំនៅដ៏ច្រើនរបស់ប្រជាជនប្រុស ស្រី វ័យក្មេង រួមជាមួយនឹង ការទទួលបាន

ចំណូលកើនឡើង កំពុងធ្វើឲ្យមានការផ្លាស់ប្ដូរទិដ្ឋភាពទូទៅរបស់តំបន់ទីប្រជុំជនរបស់កម្ពុជា។ នគរូបនីយកម្មដែលកំពុងដំណើរការយ៉ាងឆាប់រហ័ស បានបង្កើនសម្ពាធ លើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ដូចជា តម្រូវការលើ ថាមពល អនាម័យ និងការដឹកជញ្ជូន និង ធនធានធម្មជាតិ ដូចជា ទឹក ដី និងអាកាសធាតុ។ ករណីនេះបង្កឲ្យកើតមាននូវបញ្ហាប្រឈមថ្មីថែមទៀត សម្រាប់រយៈពេលវែង ពាក់ព័ន្ធនឹងការរៀបចំផែនការ ផែនការថវិកា និងការផ្ដល់សេវា។

**ការប្រែប្រួលអាកាសធាតុ និងការកាប់ព្រៃឈើ៖** កម្ពុជាគឺជាប្រទេសមួយ ក្នុងចំណោមបណ្ដាប្រទេសក្នុងតំបន់ ដែលងាយនឹងរងគ្រោះពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ហើយក៏ជាប្រទេសដែលកំពុងមានស្ថានភាពប្រហាក់ប្រហែលនឹងប្រទេសដែលទទួលរងនូវឥទ្ធិពលអវិជ្ជមាន ពាក់ព័ន្ធនឹងព្រឹត្តិការណ៍អាកាសធាតុធ្ងន់ធ្ងរ។ ការប្រែប្រួលអាកាសធាតុ នឹងបន្តមានផលប៉ះពាល់ទៅលើប្រជាជនកម្ពុជាទាំងអស់ ទោះបីជាផលប៉ះពាល់នោះមានទម្រង់ខុសគ្នាខ្លាំង ទៅលើគ្រួសារក្រីក្រដែលងាយទទួលរងផលប៉ះពាល់អវិជ្ជមានក៏ដោយ។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ពីសេចក្ដីត្រូវការចាំបាច់ ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ នៅក្នុងតំបន់ជនបទនិងតំបន់ទីប្រជុំជន ក៏ដូចជា លើការពង្រឹងសមត្ថភាពសម្រាប់ការឆ្លើយតបនិងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ។ តម្រូវចាំបាច់និងជាបន្ទាន់ក្នុងពេលបច្ចុប្បន្ននេះគឺ ការទប់ស្កាត់និន្នាការនៃការកាប់បំផ្លាញព្រៃឈើយ៉ាងឆាប់រហ័សនាពេលនេះ។ ការទប់ស្កាត់នេះ មានសារសំខាន់ណាស់ សម្រាប់ការទទួលបាននូវបរិស្ថានធម្មជាតិ ដែលត្រូវបានផ្ដល់ដោយព្រៃឈើ។

**ការងារអភិបាលកិច្ច៖** កម្ពុជាបានធ្វើឲ្យមានការរីកចម្រើនគួរឲ្យកត់សម្គាល់ នៅក្នុងផ្នែកនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ វិមជ្ឈការនិងវិសហមជ្ឈការ និងកំណែទម្រង់រដ្ឋបាលសាធារណៈ។ ផ្នែកទាំងនេះ មានសារសំខាន់ណាស់ និងត្រូវតែបន្តដំណើរការកែទម្រង់ទៅមុខទៀត។ ការកែទម្រង់ទាំងនេះនឹងត្រូវរួមចំណែកដោយ ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ដែលជាការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការពង្រឹងសិទ្ធិមនុស្ស និងផ្ដល់នូវតុលាការឯករាជ្យនិងតម្លាភាព សម្រាប់ប្រជាជនទូទៅ។ សកម្មភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីដែលពាក់ព័ន្ធ និងការអនុវត្តនានា ដោយផ្អែកលើផែនការថវិកា តំណាងឲ្យកាលានុវត្តភាពសំខាន់ៗ ការធ្វើសមាហរណកម្មកំណែទម្រង់ទាំងនោះ ទៅក្នុងប្រព័ន្ធសមស្រប ដែលជំរុញឲ្យមានការវិនិយោគប្រកបដោយ ប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងចីរភាព។ ប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលមានលក្ខណៈទូលំទូលាយមួយ នឹងត្រូវបានរៀបចំឡើងដើម្បីធ្វើជាបង្អែកយ៉ាងសំខាន់របស់ប្រព័ន្ធខាងលើ។

**ការអភិវឌ្ឍធនធានមនុស្ស៖** ភាពវឌ្ឍនភាពគួរឲ្យកត់សម្គាល់ត្រូវសម្រេចបាននៅក្នុងអាណត្តិកាលរបស់ ផ.យ.អ.ជ. ២០១៤-២០១៨ ក្នុងការផ្ដល់សេវាសង្គមក្នុងវិស័យនានា ដូចជា វិស័យអប់រំ សុខាភិបាលនិងអាហារូបត្ថម្ភ និងការគាំពារសង្គម។ ទោះជាដូចនេះក្ដី ការវិនិយោគនឹងត្រូវការបន្ថែមទៀត សម្រាប់ធ្វើឲ្យប្រសើរឡើងភាពអាចទទួលបាននិងមានគុណភាពនៃសេវាការអប់រំ (ដូចជាគ្រូដែលមានគុណភាព) ការអភិវឌ្ឍជំនាញ (ដូចជា ការបណ្ដុះបណ្ដាលមុខវិជ្ជាជីវៈ) ការថែទាំសុខភាព (ដូចជា សុខភាពផ្លូវភេទ និងសុខភាពបន្តពូជ) និងការគាំពារសង្គម (ដូចជា ជនបាត់បង់សមត្ថភាពពលកម្ម ជនក្រីក្រ)។ សកម្ម

ភាពនិងការវិនិយោគរួមគ្នាផ្សេងទៀត ក៏តម្រូវឲ្យសម្រេចផងដែរ ដើម្បីលើកកម្ពស់អំណាចសេដ្ឋកិច្ចរបស់ស្ត្រី ក៏ដូចជា លុបបំបាត់អំពើហិង្សាលើស្ត្រី។ ផែនការអភិវឌ្ឍន៍ នឹងបន្តដាក់បញ្ចូលនូវការវិភាគពីនិន្នាការប្រជាសាស្ត្រ (ដូចជា គោលនយោបាយជាតិប្រជាជន) ដើម្បីធានាថា ការវិនិយោគជាទូទៅ បានឆ្លើយតបទៅនឹងវដ្តនៃការរៀបចំផែនការ។

## គ. ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងអភិបាលកិច្ចល្អ

**៥.៤-** ស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច៖ ការបន្តគ្រប់គ្រងបរិស្ថានម៉ាក្រូសេដ្ឋកិច្ចប្រកបដោយភាពរឹងមាំ របស់រាជរដ្ឋាភិបាលកម្ពុជា នឹងផ្តល់នូវគោលនយោបាយមួយសម្រាប់ឆ្លើយតបដោយមានភាពបត់បែន ទៅនឹងការកើនឡើងនៃបរិស្ថានប្រកួតប្រជែងពាណិជ្ជកម្ម នៅក្នុងតំបន់និងក្នុងពិភពលោក។ បញ្ហាគួរឲ្យព្រួយបារម្ភដែលអាចកើតឡើងពាក់ព័ន្ធនឹងធនាគារនិងឥទ្ធិពលនៃទ្រព្យសកម្ម (ដូចជា អចលនទ្រព្យ) នឹងទាមទារឲ្យយើងត្រូវតែផ្តោតការយកចិត្តទុកដាក់។ វឌ្ឍនភាពនៅក្នុងផ្នែកបដិដុល្លារូបនីយកម្មសេដ្ឋកិច្ច នឹងជួយពង្រឹងសមត្ថភាពរបស់រាជរដ្ឋាភិបាល សម្រាប់អនុវត្តគោលនយោបាយហិរញ្ញវត្ថុ រួមជាមួយនឹងគោលនយោបាយសារពើពន្ធ។

**៥.៥-** ការប្រឆាំងនឹងអំពើពុករលួយ៖ អំពើពុករលួយបានធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែង ដើម្បីជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។ កិច្ចខិតខំប្រឹងប្រែងដែលកំពុងអនុវត្ត ដើម្បីប្រឆាំងនឹងអំពើពុករលួយ គឺជាសមាសភាគមួយយ៉ាងសំខាន់នៃរបៀបវារៈកំណែទម្រង់អភិបាលកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីធ្វើការវាស់វែងនិងវាយតម្លៃពីវឌ្ឍនភាពក្នុងការងារនេះ សូចនាករមួយចំនួនពាក់ព័ន្ធនឹងវិស័យនេះ គួរតែត្រូវបានរៀបចំឡើង។

**៥.៦-** ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងបន្តពង្រីកនិងពង្រឹងការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស នៅក្នុងផ្នែកថវិកាកម្មវិធីនិងអនុវត្តថវិកា និង ការគ្រប់គ្រងព័ត៌មានហិរញ្ញវត្ថុ ដើម្បីបង្កើនប្រសិទ្ធភាព ភាពស័ក្តិសិទ្ធ និងស្ថេរភាព ការវិនិយោគសាធារណៈ។ ការរួមបញ្ចូលក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃដោយផ្អែកលើលទ្ធផល ជាមួយនឹងកំណែទម្រង់នឹងធ្វើឲ្យរាជរដ្ឋាភិបាលកម្ពុជាមានលទ្ធភាពអាចធ្វើការវាយតម្លៃបានល្អប្រសើរជាងមុន ពីការផ្សារភ្ជាប់រវាងការវិនិយោគសាធារណៈជាមួយនឹងលទ្ធផលនៃគោលនយោបាយអភិវឌ្ឍន៍ ក៏ដូចជា ការវាស់វែងពីលទ្ធផលដែលទទួលបានពីការវិនិយោគសាធារណៈ។

**៥.៧-** ការកែទម្រង់រដ្ឋបាលសាធារណៈ៖ ក្រសួងមុខងារសាធារណៈ នឹងបន្តពង្រឹងកិច្ចសហការយ៉ាងជិតស្និទ្ធ រវាងការកែទម្រង់រដ្ឋបាលសាធារណៈ កម្មវិធីជាតិសម្រាប់ការអនុវត្តតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ការរួមបញ្ចូលនេះ នឹងបន្តជំរុញការអនុវត្តប្រកបដោយគណនេយ្យភាព ជាមួយគ្នានឹងកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ ការរួមបញ្ចូលនេះ ក៏នឹងបន្តជំរុញការអនុវត្តប្រព័ន្ធនានា នៅក្នុងរដ្ឋបាលសាធារណៈ។

**៥.៨-** **វិមជ្ឈការនិងវិសហមជ្ឈការ៖** ការផ្តល់សេវាសាធារណៈដែលបានកែលម្អ នឹងទាមទារឲ្យមានការបង្កើនធនធានបន្ថែមទៀត រួមទាំង ថវិការបស់ក្រុង ស្រុក ខណ្ឌ ក៏ដូចជា ចំណូលដែលប្រមូលបានដោយខ្លួនឯង និងកាធ្វើប្រតិភូកម្មនៃប្រមូលពន្ធដារ។ គ.ជ.អ.ប. នឹងបន្តអនុវត្តការផ្ទេរមុខងារ ដោយមានការចូលរួមពីអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់។ ក្រសួងមហាផ្ទៃនឹងរៀបចំនិងអនុវត្ត ប្រព័ន្ធព័ត៌មានសម្រាប់គ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីបំពេញតម្រូវការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងក៏ដើម្បីផ្សារភ្ជាប់ជាមួយនឹងប្រព័ន្ធជាតិសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ការអភិវឌ្ឍយន្តការគណនេយ្យភាពសង្គមនឹងត្រូវពង្រីកពី៥៤ស្រុក ទៅ១២០ស្រុក ត្រឹមឆ្នាំ២០១៨ (គឺចប់អាណត្តិកាលរបស់ ផ.យ.អ.ជ. ២០១៤-២០១៨)។ *អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន* នឹងបន្តអនុវត្តផែនការជាតិស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឲ្យកាន់តែមានប្រសិទ្ធភាព។

**៥.៩-** **ការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌៖** កិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងយុត្តិធម៌ក្នុងការធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃនីតិវិធីច្បាប់ នឹងតម្រូវឲ្យបង្កើនចំណាយសាធារណៈ។ ភាពជឿជាក់និងសុច្ចរិតភាពនៃការកែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ រួមទាំង ការប្តេជ្ញាចិត្តគាំទ្រនិងការពារសិទ្ធិមនុស្ស អាចត្រូវបានលើកកម្ពស់ជាមួយនឹងតម្លាភាពប្រសើរជាងមុន (ដូចជា ការពិគ្រោះយោបល់ជាសាធារណៈប្រកបដោយអត្ថន័យ លើសំណើច្បាប់នានា ការបោះពុម្ពផ្សាយនូវករណីនានាដែលបានរកឃើញ) និងឯករាជ្យភាពនៃតុលាការ។

**៥.១០-** **ចីរភាពបរិស្ថាន៖** បញ្ហាដែលជាប់ពាក់ព័ន្ធនឹងចីរភាពបរិស្ថាន នឹងក្លាយជាបញ្ហាយ៉ាងសំខាន់។ ផែនការសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព នឹងទាមទារឲ្យមានការប៉ាន់ប្រមាណពីបញ្ហាបរិស្ថានដែលមានលក្ខណៈអន្តរវិស័យ ឲ្យបានច្បាស់លាស់បន្ថែមទៀត។ យុទ្ធសាស្ត្រតាមវិស័យ គួរតែត្រូវបានបញ្ចូលទៅក្នុងយុទ្ធសាស្ត្រកៀរគរធនធានសម្រាប់ចីរភាពបរិស្ថាន នៅក្នុងផែនការសកម្មភាពរៀងៗខ្លួន។ ការកៀរគរនិងការគ្រប់គ្រងធនធានហិរញ្ញវត្ថុប្រកបដោយតម្លាភាព នឹងទាមទារឲ្យមានផែនការជាក់លាក់ និងគណនេយ្យភាពថវិកាដែលបានធ្វើឲ្យប្រសើរឡើង។

**៥.១១-** **ការពង្រឹងយន្តការភាពជាដៃគូ៖** ការផ្លាស់ប្តូរកម្រិតនិងវិធីសាស្ត្រនានាសម្រាប់ការអភិវឌ្ឍហិរញ្ញវត្ថុ រួមទាំង ភាពជាដៃគូត្បូង-ត្បូង ការធ្វើឲ្យមានការពាក់ព័ន្ធពីវិស័យឯកជន និងភាពជាដៃគូរវាងផ្នែកឯកជន និងរដ្ឋ បាននាំមកទាំងកាលានុវត្តភាពទាំងបញ្ហាប្រឈម។ យន្តការហិរញ្ញវត្ថុដែលថ្មីជាងមុន នឹងទាមទារឲ្យមានការពង្រឹងសមត្ថភាពស្ថាប័ននិងធនធានមនុស្ស សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ។ ការកើនឡើងនៃបរិស្ថានការអភិវឌ្ឍដែលមានភាពស្មុគ្រស្មាញ បង្ហាញថា មានការលេចចេញនូវបញ្ហាប្រឈម និងកាលានុវត្តភាពអន្តរវិស័យថ្មីៗ។ យន្តការបច្ចុប្បន្ននៃក្រុមការងារបច្ចេកទេសចម្រុះ អាចត្រូវការកែសម្រួល ដើម្បីអាចសម្របសម្រួលនៅក្នុងក្របខ័ណ្ឌអន្តរវិស័យបានល្អប្រសើរជាងមុន។

## ខ. ការជំរុញវិស័យកសិកម្ម

**៥.១២-** កត្តាដែលបានទាមទារសម្រាប់លើកស្ទួយវិស័យនិងអភិវឌ្ឍជនបទ ត្រូវបានទទួលស្គាល់។ បញ្ហាប្រឈមចម្បងៗនៅក្នុងវិស័យកសិកម្ម គឺការជួយឲ្យកសិករកម្ពុជាដែលមានផ្ទៃដីតូចតាច ឲ្យធ្វើការផ្លាស់ប្តូរ

យ៉ាងទូលំទូលាយនិងប្រកបដោយចីរភាព ពីធ្វើកសិកម្មដើម្បីចិញ្ចឹមជីវិត ទៅជាការធ្វើកសិកម្មដោយផ្អែកលើការតម្រង់ទិសទៅរកការធ្វើពាណិជ្ជកម្ម។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តពង្រឹងបរិស្ថានអាជីវកម្ម ដោយគាំទ្រដល់ពាណិជ្ជកម្មក្នុងវិស័យកសិកម្ម ដែលដឹកនាំដោយវិស័យឯកជន។

**៥.១៣- ការបង្កើនផលិតភាព និងពិពិធកម្មផលិតកម្ម៖** កត្តាដែលបានទាមទារសម្រាប់លើកស្ទួយផលិតភាពកសិកម្ម ត្រូវបានទទួលស្គាល់។ កត្តាទាំងនេះរួមមាន ការប្រើប្រាស់ធាតុចូលក្នុង វិស័យកសិកម្ម (ដូចជាជី) ប្រកបដោយសមស្របនិងមានគុណភាព សេវាផ្សព្វផ្សាយនិងធារាសាស្ត្រល្អប្រសើរជាងមុន ហិរញ្ញវត្ថុមានតម្លៃសមរម្យ និងមានទីផ្សារសម្រាប់ផលិតផល។ ត្រូវផ្ដោតការយកចិត្តទុកដាក់និងវិនិយោគលើការស្រាវជ្រាវ ការផ្សព្វផ្សាយ ហើយការស្វែងរកទីផ្សារ ក៏ត្រូវទាមទារឲ្យកាត់បន្ថយការពឹងផ្អែកលើផលិតកម្មស្រូវ ហើយជំរុញការធ្វើពិពិធកម្មទៅក្នុងការធ្វើពាណិជ្ជកម្មផលិតផលបន្លែនិងផ្លែឈើ និងផលិតផលកសិកម្មផ្សេងទៀត។

**៥.១៤- ការប្រែប្រួលអាកាសធាតុនិងការកាប់បំផ្លាញព្រៃឈើ៖** ការអភិវឌ្ឍបច្ចេកវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងអាកាសធាតុ មានសារសំខាន់ណាស់នៅកម្ពុជា សម្រាប់ធ្វើឲ្យវិស័យកសិកម្ម ដំណើរការឆ្ពោះទៅមុខ។ ការផ្លាស់ប្ដូរនិន្នាការក្នុងការកាប់បំផ្លាញព្រៃឈើ ក៏មានសារសំខាន់ផងដែរ ដែលផ្ដល់នូវសេវា បរិស្ថានដ៏សំខាន់ ដោយព្រៃឈើ។ ការប្រែប្រួលអាកាសធាតុជាក់ស្ដែងបង្ហាញថា ការគ្រប់គ្រងគ្រោះមហន្តរាយនិងសន្ទុតន្ទវត្តនាទីសំខាន់ៗជាច្រើនទៀត ជាមួយនឹងការគោរពទៅតាមផែនការនិងហិរញ្ញវត្ថុអន្តរវិស័យ។ កិច្ចខិតខំប្រឹងប្រែងក្នុងការបញ្ចូលការគ្រប់គ្រងគ្រោះមហន្តរាយ ទៅក្នុងយុទ្ធសាស្ត្រជាក់លាក់តាមវិស័យ គួរតែត្រូវបានផ្ដោតការយកចិត្តទុកដាក់។

**៥.១៥- ការគ្រប់គ្រងធនធានទឹក៖** រាជរដ្ឋាភិបាលនឹងផ្ដោតការយកចិត្តទុកដាក់លើការធ្វើឲ្យប្រសើរឡើងនូវ ការសម្របសម្រួលរវាងសេវាកសិកម្ម (ដូចជា ការផ្សព្វផ្សាយ) និងការវិនិយោគលើផ្នែកធារាសាស្ត្រ។ ការវិនិយោគលើការថែទាំនិងដំណើរការធារាសាស្ត្រ នឹងធ្វើឲ្យប្រសើរឡើងនូវប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធនៃរចនាសម្ព័ន្ធនិងគម្រោងថ្មី ជាពិសេស គម្រោងខ្នាតតូចនិងមធ្យម។ ការគ្រប់គ្រងធនធានទឹកដែលបានបញ្ចូលតាមវិស័យ ទាមទារឲ្យមានការដោះស្រាយប្រកបដោយប្រសិទ្ធភាពនូវការកើនឡើងនៃសម្ពាធទៅលើប្រភពធនធានទឹក ពីការធ្វើនគរូបនីយកម្ម ការធ្វើឧស្សាហូបនីយកម្ម ឋាមពល និងវិស័យកសិកម្មដែលត្រូវការកម្លាំងពលកម្មច្រើន។

**៥.១៦- ការគ្រប់គ្រងធនធានដីកសិកម្ម៖** ធនធានដីកសិកម្មជាកត្តាចម្បងសម្រាប់បង្កើនផលិតភាពនិងពិពិធកម្មកសិកម្ម និង ការអភិវឌ្ឍសេដ្ឋកិច្ចកសិកម្ម និង សេដ្ឋកិច្ចជាតិដោយនិរន្តរភាព។ ប្រភេទធនធានដីកសិកម្មដែលមានគុណភាពខ្ពស់ មានជីវជាតិល្អពីធម្មជាតិ មានទំហំមានកម្រិត ក្នុងចំណោមដីដែលអាចដាំដុះបានពី ៤,៥លានហ.ត. ទៅ៦លានហ.ត. របស់កម្ពុជា។ ដូចនេះ ការគ្រប់គ្រងតម្រង់ទិសរក្សាការប្រើប្រាស់ដី ដែលមានផលិតភាពខ្ពស់ពីធម្មជាតិនេះឲ្យមាននិរន្តរភាពក្នុងផលិតកម្មកសិកម្មនោះជាការចាំបាច់ដែលត្រូវតែបន្តធ្វើជាមួយនឹងការខិតខំអនុវត្តវិធានបច្ចេកទេសផ្សេងៗ ដូចជាវិធានការរៀបចំដី វិធានការដាំដំណាំផ្លាស់ដើម្បីកែលម្អគុណភាពដី ដែលកំពុងបានរិចរិលខ្សោះជីវជាតិដោយសារដាំដំណាំដដែលយូរឆ្នាំ ឬដោយវិធានការរៀបចំដីមិនសមស្រប។ ដីកសិកម្មដែលមានគុណភាពខ្ពស់ ផលិតភាពខ្ពស់ពីធម្ម

ជាតិគួរតែត្រូវបានរក្សាការពារ ដើម្បីទុកប្រើប្រាស់ក្នុងវិស័យផលិកម្មកសិកម្មជាអាទិភាពខ្ពស់បំផុតបើអាចធ្វើទៅបាន។

**៥.១៧-** ការស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និង សេដ្ឋកិច្ចកសិកម្ម៖ ការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍ គឺជាការងារចាំបាច់សម្រាប់គ្រប់វិស័យសេដ្ឋកិច្ច និង សង្គមកម្ពុជា ក៏ដូចជាបណ្ដាប្រទេសក្នុងតំបន់និងពិភពលោក។ បច្ចេកវិទ្យាកសិកម្ម និង នយោបាយយុទ្ធសាស្ត្រសេដ្ឋកិច្ចកសិកម្ម ត្រូវបានបណ្ដាប្រទេសនានាក្នុងតំបន់ និង ពិភពលោកកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ជាពិសេសក្នុងស្ថានភាពនៃការប្រែប្រួលអាកាសធាតុ និងក្នុងស្ថានភាពសមាហរណកម្មនិងការប្រកួតប្រជែងតំបន់ និង ពិភពលោក។ វិស័យកសិកម្មនៅតែជាវិស័យអាទិភាពខ្ពស់របស់កម្ពុជា ថ្វីត្បិតតែចំណែកភាពរយផលិតផលក្នុងស្រុកសរុបពីវិស័យកសិកម្មកំពុងថយចុះ។ លទ្ធផលជាវិជ្ជមាន និង មានប្រសិទ្ធភាពខ្ពស់នៃការសិក្សាស្រាវជ្រាវដើម្បីអភិវឌ្ឍបច្ចេកវិទ្យា និង សេដ្ឋកិច្ចកសិកម្មជាមូលដ្ឋានបង្អែក គាំទ្រការកសាងគោលនយោបាយ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្ម និង សង្គមសេដ្ឋកិច្ចរបស់កម្ពុជា។

**៥.១៨-** តម្លៃទំនិញ និងការប្រកួតប្រជែងនៅកម្រិតតំបន់និងសាកល៖ ការកើនឡើងឬថយចុះនៃតម្លៃផលិតផលកសិកម្ម ធ្វើឲ្យការសម្រេចចិត្តលើការវិនិយោគមានការលំបាក សម្រាប់កសិករដែលមានលក្ខណៈគ្រួសារ និងកសិករកម្រិតធំ។ផលវិបាកនៃការធ្លាក់ចុះថ្លៃ អាចជាបញ្ហាជាពិសេសសម្រាប់អ្នកផលិតដែលបានទទួលហិរញ្ញប្បទានលើការផលិតតាមរយៈការផ្ដល់ឥណទាន។ ការប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារក្នុងស្រុក តំបន់ និងសាលកលោក នឹងត្រូវបានលើកកម្ពស់ ជាមួយនឹងផលិតកម្មនិងការដឹកជញ្ជូនមានកម្រិតទាបជាងមុន និងថ្លៃដឹកជញ្ជូនទាប។

**៥.១៩-** សុវត្ថិភាពកម្មសិទ្ធិដីធ្លី និងការបោសសម្អាតមីន៖ កិច្ចខិតខំប្រឹងប្រែងដើម្បីជំរុញការផ្ដល់កម្មសិទ្ធិដីធ្លីដល់ដីកសិកម្មបែបគ្រួសារ និងដីបែបសមូហភាព នឹងធានាថា កសិករនឹងទទួលបានផលប្រយោជន៍ពីការវិនិយោគរបស់ខ្លួន។ ជម្លោះដីធ្លីរវាង បុគ្គលនិងសហគមន៍នៅជនបទ និងអ្នកអភិវឌ្ឍន៍នៅខាងក្រៅ គួរតែត្រូវបានដោះស្រាយដោយសន្តិភាពនិងដោយស្មើភាព។ កិច្ចខិតខំប្រឹងប្រែង កំពុងតែបន្តធ្វើ ដើម្បីសម្អាតមីននិងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះពីសង្គ្រាម នឹងធ្វើឲ្យប្រជាជនអាចប្រើប្រាស់ដីសម្រាប់បង្កបង្កើនផលនិងទទួលបានផលិតផលជាធនធានធម្មជាតិនៅតំបន់ដែលជាអតីតសមរភូមិប្រយុទ្ធ។

**៥.២០-** នុវានុវត្តន៍បច្ចេកទេស និងការគ្រប់គ្រងហានិភ័យ៖ នុវានុវត្តន៍បច្ចេកទេស គឺជាកត្តាមួយសម្រាប់ជំរុញការអនុវត្តថែមទៀតនូវកសិកម្មដែលពឹងផ្អែកលើកម្លាំងពលកម្មច្រើន។ សេវាផ្សព្វផ្សាយនិងស្រាវជ្រាវ គឺជាកត្តាយ៉ាងសំខាន់សម្រាប់ជំរុញនុវានុវត្តន៍បច្ចេកទេសកសិកម្ម។ ទោះជាដូចនេះក្ដី ការទទួលយកបច្ចេកទេសថ្មី បានបង្កឲ្យមានមានហានិភ័យសម្រាប់ប្រជាកសិករកម្ពុជាជាច្រើន។ រាជរដ្ឋាភិបាលកម្ពុជាគួរតែធ្វើការឲ្យបានជិតស្និទ្ធ ជាមួយផ្នែកឯកជន ដើម្បីអភិវឌ្ឍគម្រោងធានារ៉ាប់រងក្នុងវិស័យកសិកម្ម ដើម្បីជួយកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងការទទួលយកបច្ចេកវិទ្យាថ្មី ក៏ដូចជា ការបាត់បង់នានាពីគ្រោះមហន្តរាយផ្សេងៗបណ្ដាលមកពីអាកាសធាតុ។

**៥.២១-** ការសម្របសម្រួលក្នុងការវិនិយោគ៖ វិស័យកសិកម្មនៅកម្ពុជា ត្រូវបានវាយតម្លៃដោយអ្នកដែលមានចំណែកពាក់ព័ន្ធថា ការវិនិយោគនៅក្នុងវិស័យនេះមានលក្ខណៈផុយស្រួយ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀតទាមទារឲ្យមាន ដើម្បីជំរុញការវិនិយោគឲ្យបានពេញលេញ នៅក្នុងវិស័យពាក់ព័ន្ធនានា (ដូចជា សេវាផ្សព្វផ្សាយ ធារាសាស្ត្រ និងផ្លូវជនបទ)។ ផែនការសកម្មភាពជាយុទ្ធសាស្ត្រមួយដែលមានបង្ហាញយ៉ាងច្បាស់ពីសកម្មភាពជាអាទិភាព និងតម្រូវការហិរញ្ញវត្ថុ និងមានការគាំទ្រពីអ្នកដែលមានចំណែកពាក់ព័ន្ធទាំងអស់ រួមទាំង រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍ និងផ្នែកឯកជន គឺជាតម្រូវការចាំបាច់។ ថវិកាកម្មវិធីនឹងធ្វើឲ្យប្រសើរឡើងនូវតម្លាភាពនិងកិច្ចសហប្រតិបត្តិការ។

**៥.២២-** គុណភាពផលិតផល និងការស្វែងរកទីផ្សារ៖ រាជរដ្ឋាភិបាលកម្ពុជា នឹងធ្វើការឲ្យបានជិតស្និទ្ធជាមួយផ្នែកឯកជន ដើម្បីធានាថា ធាតុចូលសម្រាប់វិស័យកសិកម្មដែលមានគុណភាព នឹងមានគ្រប់គ្រាន់សម្រាប់កសិករ ក្នុងតម្លៃសមស្រប។ រាជរដ្ឋាភិបាលក៏នឹងធ្វើការឲ្យបានជិតស្និទ្ធជាមួយ ផលិតករនានា និងពាណិជ្ជករទាំងឡាយ ដើម្បីធានាថា ស្តង់ដារគុណភាពផលិតផលកសិកម្មត្រូវបានរក្សាសម្រាប់ទីផ្សារ ក្នុងស្រុក ក្នុងតំបន់ និងសាកលលោក។ រាជរដ្ឋាភិបាលកម្ពុជានឹងធានានូវសុច្ចរិតភាពនៃវិញ្ញាបនបត្ររបស់ប្រភពដើមនៃផលិតផល។

## គ. ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត

**៥.២៣-** ការតភ្ជាប់ដែលជាអាទិភាព៖ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នឹងកាន់តែមានប្រសិទ្ធភាពនិងមានភាពស័ក្តិសិទ្ធិ នៅពេលដែលមានការណែនាំដោយយុទ្ធសាស្ត្រមួយ ដើម្បីធ្វើឲ្យប្រសើរឡើងការដឹកជញ្ជូន ដែលមានការតភ្ជាប់ក្នុងវិស័យដឹកជញ្ជូននិងវិស័យថាមពល ដោយមានតម្លៃប្រើប្រាស់ទាប។ តម្លៃនៃការដឹកជញ្ជូននេះ អាចត្រូវបានប្រើប្រាស់ជាសូចនាករតាមដានត្រួតពិនិត្យ ចំពោះផលិតផលពិសេសមួយចំនួន។

**៥.២៤-** ស្តង់ដារនៃគុណភាព៖ ដើម្បីធានាថែរក្សានូវស្តង់ដារគុណភាពខ្ពស់នៅក្នុងការសាងសង់និងថែទាំហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត ដូចជា ផ្លូវជនបទ ស្ពាន និងការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន ចាំបាច់ត្រូវផ្តោតការយកចិត្តទុកដាក់បន្ថែមទៀត។ ការបំពាក់នូវបច្ចេកវិទ្យាដែលធន់នឹងការប្រែប្រួលអាកាសធាតុ គឺមានសារសំខាន់ណាស់ នៅក្នុងវិស័យនេះ។

**៥.២៥-** ការអភិវឌ្ឍវិស័យអគ្គិសនី៖ គោលដៅនៃការអភិវឌ្ឍវិស័យអគ្គិសនីរបស់រាជរដ្ឋាភិ បាល គឺរួមគ្នាខិតខំអភិវឌ្ឍន៍ដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ ប្រកបដោយចីរភាព ស្ថិរភាព គុណភាព និងតម្លៃកាន់តែទាបទូទាំងព្រះរាជាណាចក្រកម្ពុជា"។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបានកំណត់យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលកម្ពុជាដោយបន្តបង្កើនសមត្ថភាពផលិតកម្មថាមពលអគ្គិសនី និងបន្តអភិវឌ្ឍន៍បណ្តាញបញ្ជូន អគ្គិសនីគ្រប់កម្រិតសំដៅធានាភាពគ្រប់គ្រាន់នៃប្រភពអគ្គិសនី និងបន្តទាក់ទាញការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគលើការផលិត ការបញ្ជូន និងការចែកចាយអគ្គិសនី ព្រមទាំងបន្តពង្រឹង និងពង្រីកអគ្គិសនីភាវូបនីយកម្មឲ្យបានទូទាំងប្រទេស ដើម្បីឈានទៅសម្រេចគោលដៅជាយុទ្ធសាស្ត្រចំនួនពីរ៖ ទី១ ដល់ឆ្នាំ២០២០ ភូមិទាំងអស់ទូ

ទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីប្រើប្រាស់ពីប្រភពអគ្គិសនីផ្សេងៗ និង ទី២ ដល់ឆ្នាំ២០៣០ យ៉ាងហោច៧០ %នៃគ្រួសារទាំងអស់ទូទាំងព្រះរាជាណាចក្រកម្ពុជានឹងមានអគ្គិសនីដែលមានគុណភាព ដូចអគ្គិសនីពីខ្សែបណ្ដាញជាតិប្រើប្រាស់។ ជាមួយគ្នានេះដែរ រាជរដ្ឋាភិបាលនឹងអនុវត្តន៍វិធានការណ៍វិចារណកម្មនៃការប្រើប្រាស់ថាមពលអគ្គិសនី តាមរយៈការលក់អគ្គិសនីក្នុងតម្លៃទាបជូនអតិថិជនដែលប្រើប្រាស់អគ្គិសនីក្នុងរយៈពេលមានសេចក្តីត្រូវការទាបក្នុងគោលដៅបម្រើប្រព័ន្ធផលិតកម្មនិងការស្រោចស្រព សំដៅលើកម្ពស់ផលិតភាពកសិកម្ម និងជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្ម និងសិប្បកម្ម។

**៥.២៦- នគរូបនីយកម្ម និងការកំណត់តំបន់៖** ការធ្វើនគរូបនីយកម្មយ៉ាងឆាប់រហ័ស ជាពិសេស នៅរាជធានីភ្នំពេញ រួមជាមួយនឹងការប្រែប្រួលអាកាសធាតុ នឹងប៉ះពាល់ដល់ការផ្គត់ផ្គង់នៃហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត នៅក្នុងលក្ខខណ្ឌនៃការដឹកជញ្ជូន ថាមពល ការសាងសង់គេហដ្ឋាន ការគ្រប់គ្រងទឹក ដូចជា ទឹកបរិភោគ ការបង្ហូរទឹក និងការគ្រប់គ្រងសំណល់ និងអនាម័យ។ ការពង្រីកការវិនិយោគលើការដឹកជញ្ជូនធន់ធ្ងន់ គឺជាតម្រូវការចាំបាច់។ ការវិភាជធនធានប្រកបដោយប្រសិទ្ធភាពនិងមានភាពស័ក្តិសិទ្ធិច្រើនថែមទៀត នឹងអាចសម្រេចបាន តាមរយៈ ការបញ្ចូល(និងបង្ខំឲ្យអនុវត្ត) នូវបទបញ្ញត្តិតឹងតែងក្នុងតំបន់ ទៅក្នុងផែនការមេអភិវឌ្ឍន៍តំបន់ទីប្រជុំជន។

**៥.២៧- ប្រភពធនធានទឹក៖** ផែនការសកម្មភាពជាយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងធនធានទឹកដោយ រួមមានការបញ្ចូល ការអភិវឌ្ឍនិងអនុវត្ត ដើម្បីឲ្យការសម្របសម្រួលការគ្រប់គ្រងធនធានទឹកនៅកម្ពុជា មានភាពប្រសើរជាងមុន។ ក្រសួងធនធានទឹកនិងឧតុនិយម នឹងពង្រឹងសមត្ថភាពផ្នែកជលសាស្ត្រនិងឧតុនិយម ដើម្បីការពារនិងការបន្ថយផលប៉ះពាល់នៃបាតុភូតអាកាសធាតុនិងការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើឲ្យប្រសើរឡើងនូវភាពត្រឹមត្រូវនៃការព្យាករណ៍អាកាសធាតុ។

**៥.២៨- ការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ៖** ការកើនឡើងនៃការវិនិយោគ ក៏ដូចជា កិច្ចដំណើរការនិងការថែទាំប្រព័ន្ធធារាសាស្ត្រដែលមានភាពធន់នឹងអាកាសធាតុ ជាមួយគ្នានឹង ការផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតលើគម្រោងខ្នាតតូចនិងមធ្យម នឹងគាំទ្រដល់ការធ្វើឲ្យកើនឡើងផលិតកម្មកសិកម្ម។ ក្រសួងធនធានទឹកនិងឧតុនិយម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងផ្សេងៗទៀត អាចធ្វើការសម្របសម្រួលឲ្យបានប្រសើរជាងមុន ក្នុងរៀបចំផែនការ ការអនុវត្ត និងការតាមដានត្រួតពិនិត្យនិងវាយតម្លៃរួមគ្នា ដើម្បីធានាការវិនិយោគលើផ្នែកធារាសាស្ត្រ សម្រាប់បំពេញឲ្យសេវាវិស័យកសិកម្មនិងអភិវឌ្ឍន៍ជនបទ (ដូចជា ការផ្សព្វផ្សាយ ការផ្តល់បណ្ណកម្មសិទ្ធិដីធ្លី ផ្លូវជនបទ)។ ការវិនិយោគទាំងនេះ អាចត្រូវបានរៀបចំផែនការនិងការអនុវត្តប្រកបដោយប្រសិទ្ធភាព នៅកម្រិតថ្នាក់ក្រោមជាតិ។

**៥.២៩- ការវិនិយោគអន្តរវិស័យ៖** កត្តាផលិតកម្មត្រូវបានបង្កើន នៅពេលដែលការវិនិយោគក្នុងវិស័យដឹកជញ្ជូននិងថាមពល បំពេញឲ្យការវិនិយោគក្នុងវិស័យផ្សេងទៀត ដូចជា ប្រព័ន្ធធារាសាស្ត្រជាដើម។ ការវិនិយោគទាំងនេះ អាចត្រូវបានរៀបចំផែនការនិងអនុវត្តប្រកបដោយប្រសិទ្ធភាព នៅកម្រិតថ្នាក់ក្រោមជាតិ។

**៥.៣០- ភាពជាដៃគូរវាងរដ្ឋនិងឯកជន៖** ភាពជាដៃគូរវាងរដ្ឋនិងឯកជន អាចជាវិធីសាស្ត្រនៃការអភិវឌ្ឍហិរញ្ញវត្ថុដ៏មានសារសំខាន់ សម្រាប់អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ បន្ថែមទៅលើហិរញ្ញវត្ថុ ភាពជាដៃគូនេះ នឹងអាច

ជួយលើកកម្ពស់នូវានុវត្តបច្ចេកទេសនៅក្នុងវិស័យនានា ដូចជា វិស័យថាមពលនិងដឹកជញ្ជូន។ ការគ្រប់គ្រងនិងរដ្ឋបាល រួមទាំងការតាមដានត្រួតពិនិត្យនិងវាយតម្លៃ នៃភាពជាដៃគូទាំងនេះ កំពុងជួបទះបញ្ហាប្រឈម ហើយសមត្ថភាពស្ថាប័ន ក៏ត្រូវការពង្រឹងផងដែរ។

**៥.៣១- សុវត្ថិភាពផ្លូវថ្នល់៖** ប្រព័ន្ធផ្លូវថ្នល់ ត្រូវបានពង្រីកយ៉ាងទូលំទូលាយនៅទូទាំងប្រទេសកម្ពុជាឲ្យស្របតាមការកើនឡើងនៃចំនួនយានយន្ត ប៉ុន្តែសុវត្ថិភាពយានយន្តនិងផ្លូវថ្នល់នឹងនៅតែជាបញ្ហាគួរឲ្យព្រួយបារម្ភមួយ។ ការអនុវត្តយ៉ាងតឹងតែងនូវការអនុវត្តច្បាប់ចរាចរណ៍ និងការចុះបញ្ជីយានយន្ត នឹងអាចធ្វើឲ្យមានភាពល្អប្រសើរខ្លាំងពីស្ថានភាពបច្ចុប្បន្ន។

**៥.៣២- សន្តិសុខ និងសុវត្ថិភាពដឹកជញ្ជូនតាមផ្លូវអាកាស៖** វិស័យដឹកជញ្ជូនតាមផ្លូវអាកាសត្រូវបានចាត់ទុកថាជាកត្តាផលិតកម្មយុទ្ធសាស្ត្រមួយដែលជាចំណុចដ៏សំខាន់នៃដំណើរការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។ ឧស្សាហកម្មនេះ មានតួនាទីសំខាន់ពីរគឺជា សេវាកម្មពាណិជ្ជកម្ម និងជាយានសម្រាប់កិច្ចការពាណិជ្ជកម្មនៅក្នុងវិស័យសេវាកម្មផ្សេងៗទៀត។ វិស័យដឹកជញ្ជូនផ្លូវអាកាសដែលមានប្រសិទ្ធភាពមិនត្រឹមតែជួយសម្រួលដល់ការដឹកជញ្ជូនអ្នកធ្វើដំណើរ និងទំនិញនានា ក្នុងរយៈពេលដ៏ខ្លីតាមដែលអាចធ្វើទៅបានប៉ុណ្ណោះទេ ប៉ុន្តែវិស័យនេះក៏បានជួយដោយផ្ទាល់ដល់ការបង្កើនសកម្មភាពពាណិជ្ជកម្ម ទេសចរណ៍ ចំណូលជាតិ និងលើកកម្ពស់ទំនាក់ទំនងសង្គម និងផ្តល់នូវផលប្រយោជន៍ផ្សេងៗទៀតសម្រាប់ប្រទេសជាតិផងដែរ។ ការលើកកម្ពស់សមត្ថភាព និងគុណភាពសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសគឺជាកិច្ចការអាទិភាពរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធានាឲ្យបាននូវ សន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រតិបត្តិការដឹកជញ្ជូនអ្នកដំណើរ និងទំនិញតាមផ្លូវអាកាស។

**៥.៣៣- ការអភិវឌ្ឍទូរគមនាគមន៍- បច្ចេកវិទ្យាគមនាគមន៍ និង ព័ត៌មាន (ទ-ប.គ.ព.)៖** បានកំណត់យុទ្ធសាស្ត្រគោលដើម្បីការអភិវឌ្ឍវិស័យ ទ-ប.គ.ព. រួមមានការពង្រឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍ ការពង្រឹងសន្តិសុខនិងការអភិវឌ្ឍឧស្សាហកម្ម និងជំរុញការប្រើប្រាស់ ប.គ.ព។ វិធានការដើម្បីឲ្យយុទ្ធសាស្ត្រទទួលបានជោគជ័យរួមមានការការបង្កើតក្របខ័ណ្ឌគោលនយោបាយនិងគតិយុត្ត ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធការកាត់បន្ថយគម្លាតឌីជីថល ការលើកកម្ពស់កម្រិតអក្ខរកម្ម ការអភិវឌ្ឍធនធានមនុស្ស ជំនាញ ការពង្រឹងសន្តិសុខ ទ-ប.គ.ព. ការអភិវឌ្ឍឧស្សាហកម្ម ទ-ប.គ.ព. ការអភិវឌ្ឍ និងប្រើប្រាស់សុសវែរកម្មវិធីក្នុងក្របខ័ណ្ឌរដ្ឋាភិបាលអេឡិកត្រូនិក ការជំរុញពាណិជ្ជកម្មអេឡិកត្រូនិក ការប្រើប្រាស់ប្រព័ន្ធ ទ-ប.គ.ព. សម្រាប់ការពារបរិស្ថាន ការសម្របនឹងការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ។

## ឃ. ការអភិវឌ្ឍវិស័យឯកជននិងការងារ

**៥.៣៤- ការធ្វើអាទិភាពការវិនិយោគ៖** គោលនយោបាយសម្រាប់ជំរុញផលិតកម្មស្រូវនិងនាំចេញអង្ករ (គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម) និងគោលនយោបាយជាតិមុខរបរនិងការងារ ផ្តល់នូវការបំពេញបន្ថែមដល់ផែនទីបង្ហាញផ្លូវ សម្រាប់ពង្រឹងការប្រកួតប្រជែងរបស់កម្ពុជានៅក្នុងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម។ ការកំណត់អាទិភាពវិស័យដែលនឹងរួមបញ្ចូលសមាសធាតុសំខាន់ៗនៃគោលនយោ

បាយស្ថាបត្យកម្ម ដើម្បីផ្តល់ដំណឹងនិងសម្របសម្រួលការកៀរគរធនធានរដ្ឋនិងឯកជននិងការផ្តល់នូវការណែនាំការអនុវត្ត គឺជាសេចក្តីត្រូវការចាំបាច់។

**៥.៣៥- ការវិនិយោគក្នុងនិងពីក្រៅប្រទេស និងពាណិជ្ជកម្ម៖** បញ្ហាសំខាន់ក្នុងវិស័យឯកជនសម្រាប់បង្កើនការវិនិយោគទាំងក្នុងនិងពីក្រៅប្រទេសគឺ ការចំណុចខ្លាំងនៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច។ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តប្រើប្រាស់វិធីសាស្ត្រគ្រប់គ្រងដ៏រឹងមាំ សម្រាប់រក្សាស្ថេរភាពបរិស្ថានម៉ាក្រូសេដ្ឋកិច្ច។ ក្រសួងពាណិជ្ជកម្មនឹងបន្តកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការធ្វើឲ្យប្រសើរឡើងនូវកិច្ចសម្រួលពាណិជ្ជកម្ម តម្រង់ទិសបរិយាកាសអាជីវកម្ម ការផ្តល់សេវាសាធារណៈ ការធ្វើពិពិធកម្មទីផ្សារ និងការជំរុញការធ្វើសមាហរណកម្មពាណិជ្ជកម្មទៅក្នុងតំបន់ និងពិភពលោក។

**៥.៣៦- ការពិគ្រោះយោបល់រវាងវិស័យឯកជន និងរដ្ឋ៖** រាជរដ្ឋាភិបាលនឹងបន្តចូលរួមយ៉ាងសកម្មក្នុងការពិគ្រោះយោបល់ ជាមួយវិស័យឯកជន រួមទាំងសហព័ន្ធស្រូវអង្ករកម្ពុជា សភាពាណិជ្ជកម្មកម្ពុជា ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ក៏ដូចជា ជាមួយសភាពាណិជ្ជកម្មជាតិផ្សេងទៀត (ដូចជា សហរដ្ឋអាមេរិក ចក្រភពអង់គ្លេស បារាំង)។

**៥.៣៧- គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម/សហគ្រាសធុនតូចនិងមធ្យម៖** ការទាក់ទាញឧស្សាហកម្មថ្មីៗ តាមរយៈការលើកទឹកចិត្តឲ្យមានការវិនិយោគផ្ទាល់ពីបរទេសនៅក្នុងវិស័យមួយចំនួនដូចជា ការតម្លើងម៉ាស៊ីន និង ឧបករណ៍អគ្គិសនីនិងដឹកជញ្ជូន និងតាមរយៈការជំរុញសហគ្រាសធុនតូចនិងមធ្យមនៅក្នុងវិស័យមួយចំនួន ដូចជា ថ្នាំពេទ្យ ហត្ថកោសល្យ សម្ភារសំណង់ ការវេចខ្ចប់។ ជំរុញឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម តាមរយៈ ការធ្វើទំនើបកម្មបច្ចេកទេសនិងបច្ចេកវិទ្យាកែច្នៃ ការវេចខ្ចប់និងការពង្រឹងចង្វាក់ផលិតផល។

**៥.៣៨- អភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ និង ធម្មជាតិ៖** ពង្រីកចំនួននៃគោលដៅដែលមានគុណភាព និងធ្វើឲ្យប្រសើរឡើងគុណភាពនៃ សេវា។ អភិរក្សនិងការពារ តំបន់ទេសចរណ៍វប្បធម៌។ លើកទឹកចិត្តវិស័យឯកជនឲ្យវិនិយោគក្នុងការបណ្តុះបណ្តាលពាក់ព័ន្ធនឹងការធ្វើបដិសណ្ឋារកិច្ច និងព័ត៌មានពីការងារ។ ជំរុញសហគ្រាសធុនតូចនិងមធ្យមក្នុងស្រុក សិល្បៈនៃផលិតកម្ម និងសិប្បកម្ម។

**៥.៣៩- ការបណ្តុះបណ្តាលបច្ចេកទេសនិងមុខវិជ្ជាជីវៈ និងការអភិវឌ្ឍជំនាញ៖** ផែនការយុទ្ធសាស្ត្រសកម្មភាពជាតិ ទាមទារឲ្យមានការណែនាំពីការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងអន្តរក្រសួង ដើម្បីអភិវឌ្ឍការបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈនិងអភិវឌ្ឍជំនាញ។ ផែនការនេះ នឹងជួយណែនាំពីការពិគ្រោះយោបល់ រវាងវិស័យឯកជននិងរដ្ឋ ពីការបែងចែកកម្លាំងពលកម្មឲ្យបានត្រឹមត្រូវនិងមានប្រសិទ្ធភាព (ដូចជា ផែនការ ការអនុវត្ត និងការស្វែងរកធនធាន)។ ការផ្គត់ផ្គង់និងតម្រូវការធនធាន សម្រាប់ទីផ្សារពលកម្មក្នុងស្រុកនិងតំបន់ទាមទារឲ្យមានការព្យាករប្រសើរជាងមុន។

**៥.៤០- ការបង្កើតការងារ៖** ប្រជាជនដែលមានក្នុងស្ថិតិអាយុធ្វើការងារ នឹងកើនឡើងប្រមាណ ៣% ក្នុងមួយឆ្នាំ សម្រាប់ក្នុងរយៈពេលជាច្រើនឆ្នាំទៅមុខទៀត។ ការបង្កើតការងារថ្មីៗ នៅក្នុងរយៈពេល ២ទសវត្សរ៍ខាង

មុខ គឺជាការចាំបាច់សម្រាប់ផ្ដល់ដល់ប្រជាជនដែលទើបចូលក្នុងអាយុការងារ បើមិនដូច្នោះទេ នឹងមានការកើនឡើងភាពគ្មានការងារធ្វើជាទូទៅ និងភាពមិនមានការងារធ្វើមិនពេញលេញ នៅក្នុងតំបន់ជនបទ។

## ង. ការកសាងសមត្ថភាព និងការអភិវឌ្ឍធនធានមនុស្ស

### ង១. ការងារអប់រំ យុវជន និង កីឡា

**៥.៤១-** ការចូលរៀន៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តផ្ដោតការយកចិត្តទុកដាក់លើការប្រមូលសិស្សចុះឈ្មោះចូលរៀននៅគ្រប់កម្រិតសិក្សា និង អត្រាបោះបង់ការសិក្សា នៅទូទាំងប្រទេស ជាពិសេស នៅកម្រិតមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ។ សកម្មភាពសំខាន់ៗនានា គួររួមបញ្ចូល ទាំងការលើកកម្ពស់គុណភាពគ្រូបង្រៀន និងសម្ភារូបវ័ន្ត ក៏ដូចជា ការផ្ដល់អាហារូបករណ៍ដល់សិស្ស ដែលរស់នៅក្នុងគ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយផ្ដោតការយកចិត្តទុកដាក់បន្ថែមទៀតលើតំបន់ដាច់ស្រយាល និងសហគមន៍ជនជាតិភាគតិច។

**៥.៤២-** គុណភាពគ្រូបង្រៀន៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តកិច្ចខិតខំប្រឹងប្រែង រួមទាំងការវិភាជថវិកា ដើម្បីអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដូចជា ការបណ្ដុះបណ្ដាលគ្រូបង្រៀន និងការធ្វើវិក្រឹតការគ្រូបង្រៀន សម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ និងជំនាញខ្ពស់ជាងនេះ។

**៥.៤៣-** ការជំរុញការអប់រំបច្ចេកទេសនិងមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកទេស វិស្វកម្ម និងគណិតវិទ្យា៖ ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តអភិវឌ្ឍប្រព័ន្ធអប់រំបច្ចេកទេស សម្រាប់ការងារផលិតកម្ម នៅក្នុងពិពិធកម្មសេដ្ឋកិច្ច។ ក្រសួងអប់រំ យុវជន និងកីឡា នឹងជំរុញការសិក្សា លើមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា នៅកម្រិតមធ្យមសិក្សា ការអប់រំបច្ចេកទេស និងឧត្តមសិក្សា ដើម្បីអភិវឌ្ឍកម្លាំងពលកម្មជំនាញបន្ថែមទៀត។

**៥.៤៤-** ការអភិវឌ្ឍយុវជន៖ រាជរដ្ឋាភិបាលកម្ពុជា នឹងសហការជាមួយអង្គការសង្គមស៊ីវិល និងផ្នែកឯកជន ដើម្បីជំរុញជំនាញទន់ និង សហគ្រិនភាព ក៏ដូចជា កាលានុវត្តភាពអ្នកស្ម័គ្រចិត្តនិងភាពជាអ្នកដឹកនាំសម្រាប់ស្ត្រីនិងបុរសវ័យក្មេង។

**៥.៤៥-** ការអប់រំកាយ និងកីឡា៖ រាជរដ្ឋាភិបាលកម្ពុជា នឹងបង្កើនការគាំទ្រដល់ការធ្វើឲ្យប្រសើរឡើងនូវការអប់រំ និងកម្មវិធីអភិវឌ្ឍកីឡាជម្រើសជាតិ។ ភាពជាដៃគូរវាងផ្នែកឯកជន និងរដ្ឋ អាចនឹងដើរតួរយ៉ាងសំខាន់ នៅក្នុងការងារនេះ។ រាជរដ្ឋាភិបាលកម្ពុជានឹងជំរុញដៃគូ ដំណើរការត្រៀម ធ្វើជាម្ចាស់ផ្ទះក្នុងការប្រកួតកីឡាស៊ីហ្គេម នៅឆ្នាំ២០២៣។

### ង២. សុខាភិបាល និង អាហារូបត្ថម្ភ

**៥.៤៦-** ការបង្កើនការវិភាជថវិកាទៅក្នុងវិស័យសុខាភិបាល ត្រូវការធ្វើឡើងជាថ្មីម្ដងទៀត នៅក្នុងផ្នែកអាទិភាពផ្សេងទៀត ដូចបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល ឆ្នាំ២០១៦-២០២០។ ការ

បង្កើនតម្លាភាពនិងប្រសិទ្ធភាពក្នុងការវិភាជនិងអនុវត្តថវិកា ត្រូវបានទាមទារឲ្យមាន សម្រាប់ផ្នែកដូចខាងក្រោម៖

- ប្រជាពលរដ្ឋទទួលបានសេវាសុខភាពគ្រប់ជ្រុងជ្រោយ មានគុណភាព សុវត្ថិភាព និងស័ក្តិសិទ្ធិភាព នៅមូលដ្ឋានសុខាភិបាលសាធារណៈនិងឯកជន។
- ហិរញ្ញប្បទានសេវាថៃទាំសុខភាពមានស្ថេរភាព និងនិរន្តរភាព ព្រមទាំងបង្កើនការបង្ការហានិភ័យហិរញ្ញវត្ថុ ក្នុងការប្រើប្រាស់សេវាថៃទាំសុខភាព។
- ប្រព័ន្ធសុខាភិបាលមានបុគ្គលិកបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ មានសមត្ថភាពពហុជំនាញ ទទួលបានការលើកទឹកចិត្តសមស្របនិងមានក្រមសីលធម៌វិជ្ជាជីវៈ។
- មូលដ្ឋានសុខាភិបាលសាធារណៈបានទទួលការផ្គត់ផ្គង់គ្រប់គ្រាន់នូវ ឱសថ បរិក្ខារ សម្ភារៈ និងគាំទ្រដោយសេវាជាសារវ័ន្តមានប្រសិទ្ធភាព។
- មូលដ្ឋានសុខាភិបាលសាធារណៈមានហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋានសមស្រប ក្នុងនោះមានឧបករណ៍ពេទ្យ បច្ចេកវិទ្យាវេជ្ជសាស្ត្រទំនើប និងបច្ចេកវិទ្យាព័ត៌មានវិទ្យា។
- ធានាមានទិន្នន័យ/ព័ត៌មានសុខាភិបាល ឬទាក់ទងសុខាភិបាលដែលមានមានភាពគុណភាពខ្ពស់ ត្រឹមត្រូវ និងទាន់ពេលវេលាត្រូវបានប្រើប្រាស់ រួមជាមួយលទ្ធផលនៃការសិក្សាស្រាវជ្រាវសុខា ភិបាល។
- អភិវឌ្ឍស្ថាប័នសុខាភិបាលគ្រប់ជាន់ថ្នាក់ ក្នុងនោះរួមមានសមត្ថភាពដឹកនាំ គ្រប់គ្រង និងនិយតកម្ម និងពង្រឹងគណនេយ្យភាពលើសុខភាពនៅមូលដ្ឋាន។

**៥.៤៧**- ការផ្តល់ហិរញ្ញប្បទានដល់វិស័យសុខាភិបាល និងអភិបាលកិច្ច៖ ធនធានបន្ថែមទៀតនឹងត្រូវការសម្រាប់ការបន្តកិច្ចខិតខំប្រឹងប្រែងដើម្បីធានាថា ប្រជាជនកម្ពុជាទាំងអស់ទទួលបានសេវាថៃទាំសុខភាពដែលមានគុណភាពល្អនិងមានតម្លៃសមរម្យ។ កិច្ចខិតខំប្រឹងប្រែងបន្ថែមទៀត នឹងត្រូវធ្វើឡើង ដើម្បីពង្រឹងអភិបាលកិច្ចក្នុងវិស័យសុខាភិបាល រួមទាំង ការរៀបចំថវិកានិងលទ្ធកម្ម ថ្នាំពេទ្យនិងការប្រើប្រាស់។ កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមទាំងថវិកាកម្មវិធី និងប្រព័ន្ធព័ត៌មានការគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) នឹងត្រូវបានពង្រឹង។

**៥.៤៨**- សុខភាពបន្តពូជ៖ ការផ្តោតការយកចិត្តទុកដាក់ទាមទារឲ្យមានបន្ថែមទៀត ដើម្បីសម្រេចឲ្យបានលទ្ធផលនៃសុខភាពបន្តពូជនិងផែនការគ្រួសារល្អប្រសើរជាងមុន ជាពិសេស សម្រាប់ស្ត្រីនិងបុរសចំណាកស្រុកវ័យក្មេង។

**៥.៤៩**- ជំងឺមិនឆ្លង៖ ការផ្តោតការយកចិត្តទុកដាក់ទាមទារឲ្យមានបន្ថែមទៀត ដើម្បីការពារនិងកាត់បន្ថយជំងឺមិនឆ្លង (ដូចជា ជំងឺទឹកនោមផ្អែម ជំងឺសម្ពាធឈាមខ្ពស់)។

**៥.៥០**- មូលនិធិសមធម៌សុខភាព៖ ក្រសួងសុខាភិបាល បានសម្រេចនូវការគ្របដណ្តប់ជាតិពេញលេញនៃមូលនិធិសមធម៌សុខភាព។ ជំហានបន្ទាប់ទៀត គឺត្រូវបង្កើនការប្រើប្រាស់មូលនិធិសមធម៌ដោយគ្រួសារក្រីក្រនិងជនងាយរងគ្រោះ និងបង្កើនការគ្របដណ្តប់ហិរវត្ថុ ពី៤០ ទៅ១០០%។ ការគ្របដណ្តប់

ជាសាកលនៃសេវាថែទាំសុខភាពសម្រាប់ប្រជាជនកម្ពុជាទាំងអស់ គឺជាទិសដៅរយៈពេលវែងរបស់រាជរដ្ឋាភិបាលកម្ពុជា។

**៥.៥១-** ផែនទីបង្ហាញផ្លូវយ៉ាងឆាប់រហ័ស សម្រាប់អាហារូបត្ថម្ភ៖ ក្រសួងសុខាភិបាលនឹងបន្តអនុវត្តផែនទីបង្ហាញផ្លូវយ៉ាងឆាប់រហ័ស សម្រាប់អាហារូបត្ថម្ភ។ ការបង្កើនការចំណាយសាធារណៈ គឺជាសេចក្ដីត្រូវការសម្រាប់ការធ្វើឲ្យប្រសើរឡើង អាហារូបត្ថម្ភរបស់មាតានិងទារក (ដូចជា ក្រិន ស្គមស្គាំង)។

**៥.៥២-** ការបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ៖ ក្រសួងផែនការនឹងបន្តការអនុវត្តនិងកិច្ចខិតខំប្រឹងប្រែងជំរុញសកម្មភាពបញ្ចូលមីក្រូសារជាតិក្នុងចំណីអាហារ រួមទាំង ការបញ្ចូលជាតិអ៊ីយ៉ូតក្នុងអំបិលជាសាកល ការបញ្ចូលជាតិដែកក្នុងទឹកត្រីនិងទឹកស៊ីអ៊ីវ ការបញ្ចូលមីក្រូសារជាតិក្នុងអង្ករ និងការបញ្ចូលវីតាមីន បេ១ ក្នុងទឹកត្រី។

**៥.៥៣-** ការផ្គត់ផ្គង់ទឹក និងអនាម័យ៖ រាជរដ្ឋាភិបាល នឹងបង្កើនការវិភាជធនធាន ហើយក្រសួងអភិវឌ្ឍន៍ជនបទនឹងបន្តសហការជាមួយដៃគូអភិវឌ្ឍនិងអង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ ដើម្បីបន្តធ្វើឲ្យមានវឌ្ឍនភាពក្នុងការផ្គត់ផ្គង់ទឹក ការប្រើប្រាស់បង្គន់អនាម័យល្អប្រសើរជាមុន និងធ្វើឲ្យប្រសើរឡើងអនាម័យ។

**៥.៥៤-** ការស្រាវជ្រាវ និងសុវត្ថិភាពចំណីអាហារ៖ ការស្រាវជ្រាវបន្ថែមទៀតទាមទារឲ្យមាន ដើម្បីស្វែងយល់ឲ្យបានល្អប្រសើរជាមុន ឌីណាមិចសេដ្ឋកិច្ចសង្គមកិច្ច ពាក់ព័ន្ធនឹងកង្វះអាហារូបត្ថម្ភ និងការកំណត់ចំណុចចាប់ផ្ដើមសម្រាប់ការធ្វើអន្តរាគមន៍។ ការព្រួយបារម្ភពីសុវត្ថិភាពម្ហូបអាហារកំពុងមានការកើនឡើង។

## ង៣. ការគាំពារសង្គម

**៥.៥៥-** ក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម៖ ផែនការសកម្មភាពជាយុទ្ធសាស្ត្រប្រកបដោយទូលំទូលាយមួយ នឹងទាមទារឲ្យមាន និងអនុម័តជាផ្លូវការ ដើម្បីចង្អុលបង្ហាញពីការរៀបចំថវិកា និងអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។ ផែនការសកម្មភាពនេះនឹងបញ្ជាក់ច្បាស់ពីគោលដៅនិងគោលបំណង សម្រាប់សមាសភាគនីមួយៗ ការរៀបចំស្ថាប័ន ការកៀរគរធនធាន និងក្របខ័ណ្ឌនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ ដែលស្របគ្នាជាមួយនឹង ប្រព័ន្ធជាតិមួយសម្រាប់ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ។ សកម្មភាពនឹងរួមបញ្ចូលទាំង៖

- ការរៀបចំកម្មវិធីជំនួយសង្គមមួយ ដើម្បីធានានូវការការពារគ្រួសារក្រីក្រនិងគ្រួសារងាយរងគ្រោះឲ្យបានប្រសើរជាងមុន។
- ការអនុវត្តនិងការគ្របដណ្ដប់គម្រោងដែលមានស្រាប់ (ដូចជា កម្មវិធីផ្ដល់ប្រាក់ដល់ជនបាត់សមត្ថភាពពលកម្ម កម្មវិធីផ្ដល់ចំណីអាហារដល់សិស្សនៅសាលារៀន កម្មវិធីធានារ៉ាប់រងសុខភាព) និងការរៀបចំកម្មវិធីសុវត្ថិភាពសង្គមថ្មី (ដូចជាកម្មវិធីសម្រាប់មនុស្សចាស់) ដើម្បីធានាការការពារឲ្យបានប្រសើរជាងមុន ចំពោះប្រជាជាជនគ្រប់រូប។

- ការធ្វើបច្ចុប្បន្នភាពគោលនយោបាយមនុស្សឆ្នាំ២០០៣ ទៅជាគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ ដើម្បីលើកកម្ពស់និងការកែលម្អនូវគុណភាពជីវិតរបស់មនុស្សចាស់នៅកម្ពុជា ដោយធានាឲ្យមនុស្សចាស់ទទួលបានសិទ្ធិ និងឱកាសស្មើគ្នា។
- ការរៀបចំផែនការសកម្មភាព៣ឆ្នាំនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០។
- ការបង្កើតឡើងនូវរចនាសម្ព័ន្ធស្ថាប័នមួយ ដែលមានការបែងចែកតួនាទីច្បាស់លាស់នៅកម្រិតនយោបាយ កម្រិតនិយ័តករ និងកម្រិតអនុវត្ត។
- ការរួមបញ្ចូលគ្នារវាង ការកំណត់និងការចុះបញ្ជីប្រជាជន ការកំណត់ប្រជាជនក្រីក្រនិងងាយរងគ្រោះ និងការកំណត់ប្រព័ន្ធចុះបញ្ជីប្រតិបត្តិករ ទៅក្នុងប្រព័ន្ធតែមួយ គឺដើម្បីកាត់បន្ថយចំណាយនិងពេលវេលាអនុវត្ត។
- ការជំរុញឲ្យប្រជាជនស្វែងយល់និងយល់ដឹងពីការគាំពារសង្គម។

**៥.៥៦-** យន្តការកំណត់គោលដៅនៃកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ៖ ក្រសួងផែនការនឹងសហការជាមួយអ្នកប្រើប្រាស់ទិន្នន័យ ដើម្បីធ្វើឲ្យប្រសើរឡើងយន្តការកំណត់គោលដៅកម្មវិធីអត្តសញ្ញាណកម្មគ្រួសារក្រីក្រ រួមទាំង ការដាក់ឲ្យអនុវត្តនីតិវិធីសម្រាប់អនុវត្តនៅតំបន់ទីប្រជុំជន។

**៥.៥៧-** សុខុមាលភាពកុមារ៖ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការការពារនិងឆ្លើយតបទៅនឹងអំពើហិង្សាប្រឆាំងនឹងកុមារ ដោយធ្វើការបង្កើនការវិភាជថវិកាសម្រាប់ការការពារនិងសេវា រួមទាំង ការអភិវឌ្ឍន៍យុទ្ធសាស្ត្រមួយសម្រាប់បណ្តុះបណ្តាលនិងអភិវឌ្ឍក្រុមការងារសង្គមដែលមានជំនាញ ។

## ង៤. គោលនយោបាយជាតិប្រជាជន

**៥.៥៨-** គោលនយោបាយជាតិប្រជាជន៖ បន្តលើកកម្ពស់ការអនុវត្តគោលនយោបាយជាតិប្រជាជនឲ្យកាន់តែទូលំទូលាយនៅគ្រប់កម្រិត និង តាមដានត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងបញ្ហាប្រជាជន ដូចដែលបានស្នើឡើងក្នុងការតម្រង់ទិសគោលនយោបាយ និងកម្មវិធី។ ផ.យ.អ.ជ បន្ទាប់ នឹងបញ្ចូលគោលនយោបាយជាតិប្រជាជន ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ ពាក់ព័ន្ធទាំងអស់ និងការវិភាជថវិកា។ អាទិភាពដែលត្រូវធ្វើបន្ត ដើម្បីទាញយកអត្ថប្រយោជន៍ពីភាគលាភប្រជាសាស្ត្រមានដូចខាងក្រោម៖

- ការពង្រឹងសមត្ថភាពស្ថាប័នអំពីឌីណាមិកប្រជាសាស្ត្រក្នុងការអភិវឌ្ឍ និង ការរៀបចំគោលនយោបាយពាក់ព័ន្ធនឹងប្រជាជន ដោយបញ្ចូលអថេរសំខាន់ៗទាក់ទឹងនឹងប្រជាជន ដូចជា ស្ថានភាពប្រជាសាស្ត្រ សុខភាពផ្លូវភេទ សុខភាពបន្តពូជ អំពើហឹង្សាលើស្ត្រី។ល។ និង ពង្រឹងសមត្ថភាពលើ ការប្រមូល ការផលិតនិងការផ្សព្វផ្សាយទិន្នន័យតាមវិធីសាស្ត្រថ្មីៗ ដើម្បីឲ្យទិន្នន័យ និងព័ត៌មានកាន់តែសម្បូរបែប និងកាន់តែជឿជាក់ពីអ្នកប្រើប្រាស់ ក្នុងគោលបំណងផ្តល់ទិន្នន័យ

សម្រាប់ ប្រើប្រាស់ក្នុងការតាមដានត្រួតពិនិត្យ ផ.យ.អ.ជ និងការរៀបចំក្របខណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

- ការរៀបចំផែនការ និងក្របខណ្ឌគតិយុត្តៈ ក្រសួងផែនការនឹងបន្តរៀបចំផែនការ យុទ្ធសាស្ត្រជាតិអភិវឌ្ឍស្ថិតិ ២០១៩-២០២៣ និង ឯកសារគតិយុត្តនានា គាំទ្រដល់ ដំណើរការអនុវត្តជំរឿនប្រជាជនទូទៅឆ្នាំ២០១៩ និង អង្កេតនានា។
- ការបន្តផ្សព្វផ្សាយការអនុវត្តគោលនយោបាយជាតិប្រជាជននៅថ្នាក់ក្រោមជាតិ ដើម្បីឲ្យបញ្ហាប្រជាជនត្រូវបានដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។

ង៥. សមធម៌យេនឌ័រ

**៥.៥៩- ការផ្តល់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី៖** ដើម្បីលើកកម្ពស់ភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី ការទាមទារឲ្យមានការចូលរួមយ៉ាងទូលំទូលាយក្នុងកម្លាំងពលកម្ម គាំទ្រការអភិវឌ្ឍសហគ្រាសធុនតូច និងមធ្យមនិងការអភិវឌ្ឍជំនាញ លទ្ធភាពទទួលបានសេវាឥណទាននិងមីក្រូហិរញ្ញវត្ថុសមស្រប រួមទាំងការអប់រំនិងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រសើរជាងមុន។

**៥.៦០-** សេវាសង្គម៖ បន្តការធ្វើឲ្យប្រសើរឡើងការទទួលបានសេវាសង្គមពេញលេញ ចំពោះស្ត្រី ក្មេងស្រី និងក្រុមងាយរងគ្រោះ រួមទាំងការអប់រំ សុខាភិបាល អាហារូបត្ថម្ភ និង សេវាសុខភាពបន្តពូជ៖

- **អំពើហិង្សាលើស្ត្រី៖** ទាមទារឲ្យមានកិច្ចខិតខំប្រឹងប្រែងរួមគ្នា នៅគ្រប់កម្រិត។ ក្រសួងកិច្ចនារី នឹងពង្រឹងស្ថាប័ន ពង្រីកបណ្តាញអ្នកផ្តល់សេវាដល់ជនរងគ្រោះ និង ជំរុញការអនុវត្តច្បាប់ គោលនយោបាយ ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រី ការជួញដូរស្ត្រីនិងកុមារនិងគ្រឿងញៀន និង ពិការភាព ជាពិសេសស្ត្រីនិងកុមារពិការ។
- **ការកៀរគរធនធាន៖** រាជរដ្ឋាភិបាលនឹងពង្រឹងការកៀរគរធនធាននេះ ដោយផ្តោតលើ ការសម្រេចបានសមធម៌យេនឌ័រ តាមរយៈការរៀបចំថវិកាឆ្លើយតបនឹងយេនឌ័រ នៅក្នុងផែនការ ៥ឆ្នាំខាងមុខ ក៏ដូចជា ផ្តល់នូវថវិកាកម្មវិធី សម្រាប់ក្រសួងកិច្ចនារីអនុវត្តសកម្មភាពអាទិភាព ដែលបានកំណត់ នៅក្នុងផែនការយុទ្ធសាស្ត្រនារីរតនៈទី៤។
- **សមត្ថភាពស្ថាប័ន៖** ពង្រឹងសមត្ថភាពធនធានមនុស្សនិងធនធានស្ថាប័ន របស់ក្រសួងកិច្ចនារី និង ក្រសួង ស្ថាប័នសំខាន់ៗ ដើម្បីតាមដានត្រួតពិនិត្យនិងវាយតម្លៃវឌ្ឍនភាពនៅក្នុងសមធម៌យេនឌ័រ ឲ្យស្របជាមួយសូចនាករគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- **ការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យសាធារណៈនិងនយោបាយ៖** ក្នុងផ្នែកនេះ នឹងបន្តតាមដាននិង ជំរុញការអនុវត្តគោលនយោបាយ ច្បាប់ និងវិធានការសមស្របនានា បង្កើនការចូលរួមរបស់ស្ត្រី នៅក្នុងការធ្វើសេចក្តីសម្រេចក្នុងវិស័យសាធារណៈ និងនយោបាយ និងទាមទារឲ្យមានការចូលរួមលើកទឹកចិត្តបន្ថែមទៀតពីគ្រប់ស្ថាប័ននិងគណបក្សនយោបាយ។

## ៣. តម្លៃដែលត្រូវចំណាយ ធនធាន និងការកំណត់កម្មវិធីចំណាយ

**៥.៦១-** ធនធាន៖ គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា ថ្មីៗនេះបានបញ្ចប់របាយការណ៍វាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍សម្រាប់រយៈពេល១០ឆ្នាំ ខាងមុខ។ ក្នុងនោះ ការវិវត្តនៃលំហូរហិរញ្ញប្បទានសំខាន់ៗដែលស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់រាជរដ្ឋាភិបាល រួមមានៈ ចំណូលក្នុងស្រុក ហិរញ្ញប្បទានសហប្រតិបត្តិការ និងបំណុល និងធនធានដ៏ទៃទៀត ដែលមិនស្ថិតក្រោមការគ្រប់គ្រងទាំងស្រុងរបស់រាជរដ្ឋាភិបាល ដូចជា ការវិនិយោគផ្ទាល់ពីបរទេស ប្រាក់បង្វែររបស់ទេសន្តប្រវេសជន និងការវិនិយោគឯកជនក្នុងស្រុក។

**៥.៦២-** សក្តានុពលធនធានហិរញ្ញប្បទានសម្រាប់កិច្ចអភិវឌ្ឍន៍ ទាំងផ្នែកឯកជននិងសាធារណៈ ទាំងក្នុងស្រុកនិងពីបរទេសអាចនឹងមានទំនាក់ទំនងផ្សារភ្ជាប់ជាមួយនឹងការផ្តល់ហិរញ្ញប្បទាន ពេលអនាគតសម្រាប់គាំទ្រគោលនយោបាយអភិវឌ្ឍន៍ជាតិ និងរបៀបវារៈអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។ ការវាយតម្លៃស្ថានភាពហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ បានផ្តល់អនុសាសន៍កម្រិតគោលនយោបាយតម្រង់ទិសឲ្យកម្ពុជាអាចគ្រប់គ្រងឲ្យបានល្អប្រសើរនូវធនធានហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍ ក្នុងដំណាក់កាលអន្តរកាល ជាប្រទេសដែលមានចំណូលមធ្យម។ ក្នុងរយៈពេលខ្លី កម្ពុជាត្រូវការយ៉ាងខ្លាំងនូវការធ្វើពិពិធកម្មធនធានហិរញ្ញប្បទានសម្រាប់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ហើយហិរញ្ញប្បទានសហប្រតិបត្តិការមានតួនាទីជាកាតាលីករក្នុងការកៀរគរប្រភពធនធានហិរញ្ញប្បទានដទៃទៀត ទាំងផ្នែកឯកជននិងសាធារណៈ។

**៥.៦៣-** កិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍៖ រាជរដ្ឋាភិបាលបានកៀរគរធនធានហិរញ្ញប្បទានសហប្រតិបត្តិការប្រមាណជាង១ ០០០លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០០៨ សម្រាប់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច។ ឆ្នាំ២០១១ ការផ្តល់ហិរញ្ញប្បទានបានកើនខ្ពស់៣០% ធៀបនឹងឆ្នាំ២០១០ ដែលមានប្រមាណ១ ១០០លានដុល្លារអាមេរិក ដោយសារកំណើនហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិន។ ក្នុងឆ្នាំ២០១៥ ការបើកផ្តល់ហិរញ្ញប្បទានមានប្រមាណ១ ៣៤០លានដុល្លារអាមេរិក ក្នុងនោះ៨៣% ជាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ និង១៧%ទៀតជាហិរញ្ញប្បទានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល។ វិស័យសង្គមកិច្ចបានទទួលហិរញ្ញប្បទានច្រើនជាងវិស័យដទៃ ស្មើនឹង៣៧% នៃហិរញ្ញប្បទានសរុប ហើយបន្ទាប់មក គឺវិស័យហេដ្ឋារចនាសម្ព័ន្ធ៣០% វិស័យសេដ្ឋកិច្ច២០% និងអន្តរវិស័យ១៣%។

**៥.៦៤-** ការវិវត្តនៃទម្រង់ផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍លើការគាំទ្រផ្នែកកិច្ចសហប្រតិបត្តិការបច្ចេកទេសមានទំហំនឹងនរប្រមាណ៣០០លានដុល្លារអាមេរិក ក្នុងមួយទសវត្សន៍ចុងក្រោយ (២០០៦-២០១៥)។ ប៉ុន្តែហិរញ្ញប្បទានសម្រាប់វិនិយោគមានទំហំជិតបីដងធៀបនឹងកិច្ចសហប្រតិបត្តិការបច្ចេកទេសគឺ ប្រមាណមួយពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១១ មក។ ហិរញ្ញប្បទានសម្រាប់វិនិយោគផ្តោតលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត រីឯហិរញ្ញប្បទានសម្រាប់កិច្ចសហប្រតិបត្តិការបច្ចេកទេសបានផ្តោតលើការគាំទ្រការកែទម្រង់របស់រាជរដ្ឋាភិបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសមត្ថភាព។ ហិរញ្ញប្បទានឥតសំណងបានថយចុះពីជាង៨០% នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០០៦ មក

ត្រឹមតិចជាង៦០% នៃហិរញ្ញប្បទានសរុបក្នុងឆ្នាំ២០១៥។ ការកើនឡើងនៃទម្រង់ការផ្ដល់ហិរញ្ញប្បទានកម្ចី គឺមានសង្គតិភាពជាមួយនិន្នាការដែលកម្ពុជាកំពុងឈានចូលទៅក្នុងស្ថានភាពនៃប្រទេសដែលមានចំណូលមធ្យមកម្រិតទាប។

៥.៦៥- ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍មានស្ថេរភាព ប្រមាណ២២៥-២៣០លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ សម្រាប់រយៈពេល៣ ឆ្នាំចុងក្រោយ (២០១៣ -២០១៥)។ ជាក់ស្ដែងធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល មានប្រមាណ២២៨លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ (ប្រមាណ១៧% នៃហិរញ្ញប្បទានសហប្រតិបត្តិការសរុប)។ បើគិតបញ្ចូលហិរញ្ញប្បទានដែលទទួលពីដៃគូអភិវឌ្ឍន៍ ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល មានប្រមាណ២៤% នៃហិរញ្ញប្បទានសរុប។ ធនធានស្ទើរតែទាំងអស់របស់អង្គការមិនមែនរដ្ឋាភិបាលត្រូវបានប្រើប្រាស់សម្រាប់គាំទ្រវិស័យសុខាភិបាល វិស័យអប់រំ និងសុខុមាលភាពសហគមន៍។

៥.៦៦- លំហូរហិរញ្ញវត្ថុរបស់ផ្នែកឯកជន៖ ការវិនិយោគផ្ទាល់ពីបរទេសបានកើនឡើងទាំងបរិមាណទឹកប្រាក់ទាំងចំណែកក្នុងផលិតផលក្នុងស្រុកសរុប។ បរិមាណនៃការវិនិយោគផ្ទាល់ពីបរទេស ត្រូវបានប៉ាន់ស្មានថាមានប្រមាណ១,៧៣ពាន់លានដុល្លារអាមេរិក ប្រហែលជា៩,៦% នៃផ.ស.ស.។ និន្នានៃការវិនិយោគផ្ទាល់ពីបរទេសបានផ្ដោតលើវិស័យចំនួន៤ គឺ៖ វិស័យ កាត់ដេរ ទេសចរណ៍ សំណង់ និងកសិកម្ម។ ការវិនិយោគនេះ ក៏មានការកើនឡើងខ្លះដែរនៅក្នុងវិស័យកម្មន្តសាលមិនមែនវាយនភ័ណ្ឌ (អេឡិចត្រូនិច) ភាគច្រើនវិនិយោគពីប្រទេសជប៉ុន ចិន កូរ៉េខាងត្បូង។ ជាមួយគ្នានេះ មានវិសាលភាពគួរឲ្យកត់សម្គាល់សម្រាប់ពង្រីកកម្រិតការវិនិយោគដោយធនធានក្នុងប្រទេស។

## ៤. ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

៥.៦៧- ផែនការសកម្មភាពជាតិសម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃ៖ ការពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ គឺជាតម្រូវការចាំបាច់។ ក្រសួងផែនការ នឹងបន្តដឹកក្រុមការងារជាតិសម្រាប់តាមដានត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីរៀបចំផែនការសកម្មភាពជាយុទ្ធសាស្ត្រ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ។ ផែនការសកម្មភាពជាយុទ្ធសាស្ត្រ នឹងត្រូវរៀបចំឡើង ការរៀបចំស្ថាប័នតម្រូវឲ្យមានដើម្បីអនុវត្តវិធីសាស្ត្រសម្របសម្រួលទាំងមូលរបស់រាជរដ្ឋាភិបាលនៃការតាមដានត្រួតពិនិត្យនិងវាយតម្លៃ រួមទាំង ស្តង់ដារអភិវឌ្ឍសមត្ថភាព ការប្រមូលនិងគុណភាពទិន្នន័យ ការផ្សព្វផ្សាយ និងការវិភាគ។ ការអនុវត្តផែនការសកម្មភាពនឹងចាប់ផ្តើមនៅថ្នាក់ជាតិ និងបន្ទាប់មក ពង្រីកទៅថ្នាក់ក្រោមជាតិ ផ្អែកលើសមត្ថភាពនិងធនធានដែលមាន។

៥.៦៨- គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច.)៖ ផែនការនឹងបន្តការងារក្នុងការអភិវឌ្ឍ សូចនាករដែលមានលក្ខណៈជាក់លាក់ អាចវាស់វែងបាន អាចសម្រេចបាន មានការទាក់ទងនឹងគោលដៅដែលចង់បាន មានពេលវេលាច្បាស់លាស់ (SMART) និងពាក់ព័ន្ធនឹងការធ្វើមូលដ្ឋានីយកម្ម គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (គ.អ.ច.) មកក្នុងបរិការណ៍កម្ពុជា។ ក្រសួងផែនការនឹងបន្តផ្តល់ការណែនាំ ដល់

ក្រសួង ស្ថាប័នទាំងអស់ ពីការបញ្ចូលនិងការធ្វើសមាហរណកម្ម គ.អ.ច.ក. ទៅក្នុង ផ.យ.អ.ជ. អាណត្តិបន្ទាប់។

៥.៦៩- យុទ្ធសាស្ត្រនិងអាទិភាពតាមវិស័យ៖ ក្រសួងផែនការ នឹងបន្តរៀបចំការណែនាំដល់ក្រសួង ស្ថាប័ន ឲ្យអនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍តាមវិស័យ សម្រាប់អាណត្តិកាលបន្ត។ ផែនការយុទ្ធសាស្ត្រតាមវិស័យ នឹងផ្តោតការយកចិត្តទុកដាក់លើ សកម្មភាពជាអាទិភាព ដែលបានវាយតម្លៃពីតម្រូវការថវិកាសម្រាប់អនុវត្តនិងគាំទ្រដោយផែនការកៀរគរធនធាន ដែលផ្តល់ព័ត៌មានដោយកិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍ។ ផែនការយុទ្ធសាស្ត្រតាមវិស័យ នឹងរួមបញ្ចូលនូវសូចនាករសំខាន់ៗដែលផ្សារភ្ជាប់ជាមួយនឹងក្របខ័ណ្ឌ គ.អ.ច.ក.។ ក្រសួងផែនការនឹងធានានូវការស្របគ្នារវាងសូចនាករទាំងនេះជាមួយនឹងសូចនាករជាតិ និងថវិកាកម្មវិធី។

## ៥. សេចក្តីសន្និដ្ឋាន

៥.៧០- អាណត្តិកាលពីរឆ្នាំកន្លះដែលនៅសល់របស់ ផ.យ.អ.ជ. ២០១៤-២០១៨ ជាមួយគ្នានឹង ផ.យ.អ.ជ. បន្ទាប់ ២០១៩-២០២៣ គឺជាពេលវេលាដ៏សំខាន់សម្រាប់កម្ពុជា នៅក្នុងអន្តរកាលនៃការឈានចូលទៅក្នុងស្ថានភាពប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ការកសាងនូវសមិទ្ធផលដ៏រឹងមាំទៅតាមកាលបរិច្ឆេទកំណត់ ក៏ដូចជា ការដោះស្រាយបញ្ហាប្រឈមដែលកាន់តែមានការស្មុគស្មាញនៅក្នុងទិដ្ឋភាពនៃការអភិវឌ្ឍយ៉ាងឆាប់រហ័សនៅក្នុងប្រទេស ក្នុងតំបន់ និងក្នុងសាកលលោក គឺមានសារសំខាន់ណាស់សម្រាប់ប្រទេសជាតិនិងប្រជាជន។ កម្ពុជានឹងត្រូវរៀបចំអភិវឌ្ឍន៍ប្រភពធនធានថ្មីៗ ក៏ដូចជាពិចារណាទៅលើការកៀរគរចំណូលក្នុងស្រុក សម្រាប់ផ្តល់ហិរញ្ញប្បទានដល់ការអភិវឌ្ឍជាតិ និងការរក្សានិងការរួមបញ្ចូលនូវវឌ្ឍនភាពសេដ្ឋកិច្ច សង្គមកិច្ច។ ការបង្កើនតម្លាភាពថវិកា គឺជាតម្រូវការចាំបាច់ដើម្បីគាំទ្រដល់ការពិគ្រោះយោបល់ពីការគាំទ្រហិរញ្ញប្បទានអភិវឌ្ឍន៍ និងជំរុញការផ្តួចផ្តើមការកែទម្រង់ថវិកាកម្មវិធីប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការបង្កើនតម្លាភាពនេះ នឹងទាមទារឲ្យមានភាពខ្លាំងក្នុងភាពជាអ្នកដឹកនាំ និងភាពជាដៃគូ ក៏ដូចជា ប្រជាជនដែលមានការចូលរួមយ៉ាងសកម្ម ដើម្បីធានានូវកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាពនិងបរិយាប័ន្ន។

៥.៧១- តាមការពិនិត្យឡើងវិញ បានផ្តល់អនុសាសន៍ថា ផ.យ.អ.ជ. បន្ទាប់ គួរតែផ្តោតការយកចិត្តទុកដាក់លើ៖

១. កំណត់អាទិភាពតាមវិស័យ និងការកៀរគរធនធាន ឲ្យស្របតាមទិសដៅអភិវឌ្ឍន៍ជាតិ
២. ជំរុញការរៀបចំនិងអនុវត្តផែនការអន្តរវិស័យ
៣. ពង្រីកវិសាលភាពសារពើពន្ធ តាមរយៈ ធ្វើពិពិធកម្មចំណូលនៃហិរញ្ញប្បទានអភិវឌ្ឍន៍
៤. បន្តពង្រឹងសមត្ថភាពស្ថាប័ន និងធនធានមនុស្ស
៥. បញ្ជ្រាប គ.អ.ច.ក ទៅក្នុងផែនការតាមវិស័យនិងផែនការអន្តរវិស័យ
៦. ពង្រឹងប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃ។

**៥.៧២**- ការវាយតម្លៃនេះ ក៏បានផ្តល់អនុសាសន៍ថា ក្រសួងផែនការគួររៀបចំឯកសារណែនាំសម្រាប់

ក្រសួង ស្ថាប័ន ដើម្បីរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យ សម្រាប់អាណត្តិកាលបន្ទាប់។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យ នឹងផ្តោតការយកចិត្តទុកដាក់លើអាទិភាពច្បាស់លាស់ និងសកម្មភាពដែលអាចសម្រេចបាន ដែលបានវាយតម្លៃពីតម្រូវការថវិកាសម្រាប់អនុវត្តនិងគាំទ្រដោយផែនការគៀរគរធនធាន ដែលផ្តល់ព័ត៌មានដោយកិច្ចពិគ្រោះយោបល់រវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍដែលពាក់ព័ន្ធ។ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍តាមវិស័យនឹងរួមបញ្ចូលនូវសូចនាករសំខាន់ៗ ដែលស្របគ្នាជាមួយ គ.អ.ច.ក.។

## ឧបសម្ព័ន្ធទី១

## សូចនាករបន្ថែមសម្រាប់របាយការណ៍ពាក់កណ្តាលអាណត្តិនៃការអនុវត្ត ផ.យ.អ.ជ. ២០១៤-២០១៨

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ១.១ | ផ.ស.ស. ពិត (តម្លៃថេរឆ្នាំ២០០០) | ពាន់លានរៀល | ៦៤ ១៤១ | ៧០ ៧១៨ | ៧៧ ៥១០ | ៨៤ ៨៣៨ | ៩២៨២១ | ១០១ ៥៣៧ | គណនេយ្យជាតិ (វ.ជ.ស.) |
| ១.២ | ទុនបម្រុងបរទេសដុល | ចំនួនខែនាំ ចូលទំនិញ និងសេវា | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ៤,៥ | ប.ព.រ.ក.ស. (ធ.ជ.ក.) |
| ១.៣ | ការអនុវត្តអភិក្រមគ្រប់គ្រងទូទាំងកម្មវិធី | % | | ២៨ | | | | ៥០ | ប.ព.រ.ក.ស. (គ.ជ.នា/ក.អ.ក.) |
| ១.៤ | ការប្រើប្រាស់ប្រព័ន្ធជាតិ | % | | ៣២ | | | | ៥០ | ប.ព.រ.ក.ស. (គ.ជ.នា/ក.អ.ក.) |
| ២.១ | ផ្ទៃដីដាំដុះដំណាំស្រូវ | លានហ.ត. | | ៣,១០ | ៣,១៥ | ៣,២០ | ៣,២៨ | ៣,៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.២ | រៀបចំនិងពង្រឹងសមត្ថភាពកសិករប្រើប្រាស់ទឹក | កន្លែង | ៤៣៤ | ៥ | ៥ | ៥ | ៥ | ៥ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៣ | សាងសង់ស្ថានីយបូមទឹក | កន្លែង | ៣០ | ៥ | ៥ | ៥ | ៥ | ៥ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៤ | ដំឡើងស្ថានីយជលសាស្ត្រ | កន្លែង | ១៩ | ៨ | ៨ | ៨ | ៨ | ៨ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |
| ២.៥ | ដំឡើងស្ថានីយឧតុនិយម | កន្លែង | ២១ | ៤ | ៤ | ៤ | ៤ | ៤ | ប.ព.រ.ក.ស. (ក.ធ.ទ.ឧ.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.៦ | ផ្ទៃដីដាំដុះដំណាំកៅស៊ូ | ពាន់ហ.ត. | | ៣០៦ ៥០០ | ៣៣៤ ៥០០ | ៣៦២ ៥០០ | ៣៨៤ ៥០០ | ៤០៤ ៥០០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.៧ | ផលិតកម្មជ័រស្ងួត | តោន | | ១៣៧ ៥២០ | ១៨១៥៦០ | ២៤០ ៨០០ | ៣០០ ៨០០ | ៣៤០ ៩៣០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| | ផលិតកម្មចិញ្ចឹមសត្វ | | | | | | | | |
| ២.៨ | ផលិតកម្មសត្វគ្រប់ប្រភេទក្នុងកំណើន៣% | លានក្បាល | | ៣៥,៨៦ | ៣៦,៩៣ | ៣៨,០៣ | ៣៩,១៧ | ៤០,៣៤ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.៩ | សត្វដែលទទួលបានវ៉ាក់សាំង | % | | ១០ | ១២ | ១៥ | ១៧ | ២០ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| ២.១០ | ចំនួនសត្តឃាតដ្ឋានដែលអនុវត្តអនាម័យល្អតាម**បទដ្ឋាន**បច្ចេកទេស | ចំនួនកន្លែង | | ២៥ | ៥០ | ៧៥ | ១០០ | ១២៥ | ប.ព.រ.ក.ស. (ក.ក.រ.ន.) |
| | *ការអភិវឌ្ឍជនបទ* | | | | | | | | |
| ២.១១ | ប្រវែងផ្លូវជនបទដែលបានក្រាលកៅស៊ូពីរជាន់ ឬបេតុង | គ.ម. | ១២៥ | ៥៥០ | ៩៨០ | ១ ៤៣០ | ១ ៨៨០ | ២ ៣៣០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១២ | ចំនួនសហគមន៍ជនជាតិដើមភាគតិចដែលបានទទួលស្គាល់អត្តសញ្ញាណ | ក្រុម | ៨០ | ១០០ | ១៣០ | ១៦០ | ១៩០ | ២២០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៣ | ចំនួនភូមិដែលបានបណ្ដុះបណ្ដាលគ.អ.ភ. ស្ដីពីផែនការអភិវឌ្ឍន៍ភូមិ | ភូមិ | ៦៧៣ | ១ ៦១០ | ១ ៨០០ | ២ ០០០ | ២ ២០០ | ២ ៤០០ | ប.ព.រ.ក.ស. (ក.អ.ជ.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភព ទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.១៤ | សិក្សានិងសាងសង់សាកល្បងផ្លូវជនបទក្រាលកៅស៊ូ៤៥០គមដែលអាចទប់ទល់នឹងការប្រែប្រួលអាកាសធាតុ១០០% | គ.ម. | 0 | 0 | ៦៧,៥០ | ១៥៧,៥ | ២៧០ | ៣៦០ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៥ | កសាងសមត្ថភាពគ.អ.ភស្តីពីជម្រើសនៃបន្សុំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុនិងប្រើប្រាស់ចំណេះដឹងវិទ្យាសាស្ត្រសមស្របមួយដែលអាចទទួលយកបាននៅថ្នាក់មូលដ្ឋាន | គ.អ.ភ. | 0 | 0 | ១ ៨៥៤ | ២ ៤៧២ | ៣ ០៩០ | ៣ ៧០៨ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៦ | ភាគរយប្រជាជនជនបទទទួលបានការផ្គត់ផ្គង់ទឹក ដែលមានការកែលម្អប្រកបដោយចីរភាព (ក្រុមចំណាយ២៥%ទាបបំផុត) | % | ៤២ | ៤៤,២ | ៤៦,៧០ | ៥០ | ៥៣ | ៦៧ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៧ | ភាគរយប្រជាជនជនបទទទួលបានសេវាអនាម័យ ដែលមានការកែលម្អប្រកបដោយចីរភាព (ក្រុមចំណាយ២៥%ទាបបំផុត) | % | ៣៣,៣ | ៣៧,៥ | ៤២ | ៤៦ | ៥០ | ៥៥ | ប.ព.រ.ក.ស. (ក.អ.ជ.) |
| ២.១៨ | សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជី | ចំនួនសហគមន៍ | - | ១៨ | ២៨ | ៣៨ | ៤៨ | ៥៨ | ប.ព.រ.ក.ស. (ក.រ.ជ.ន.ស.) |
| ២.១៩ | ដំណោះស្រាយទំនាស់ដីធ្លី | ករណី | | ៤ ៨៥០ | ៥ ០៥០ | ៥ ២៥០ | ៥ ៤៥០ | ៥ ៦៥០ | ប.ព.រ.ក.ស. (ក.រ.ជ.ន.ស.) |
| ២.២០ | សម្បទានដីសង្គមកិច្ចសម្រាប់គ្រួសារប្រជាពលរដ្ឋ | ចំនួនគ្រួសារ | | ៣៥ ០០០ | ៣៧ ០០០ | ៣៩ ០០០ | ៤១ ០០០ | ៤៣ ០០០ | ប.ព.រ.ក.ស. (ក.រ.ជ.ន.ស.) |
| ២.២១ | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ | ចំនួន | | ១៤៥ | ១៦៥ | ១៨៥ | ២០៥ | ២២៥ | ប.ព.រ.ក.ស. (ក.រ.ជ.ន.ស.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.២២ | ប្លង់គោលថ្នាក់ស្រុក ខណ្ឌ | ចំនួន | | ២២ | ២៥ | ២៨ | ៣១ | ៣៤ | ប.ព.វ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២៣ | ប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង | ចំនួន | | ១៨ | ២០ | ២២ | ២៤ | ២៦ | ប.ព.វ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២៤ | ផែនការរៀបចំដែនដីថ្នាក់ខេត្ត | ចំនួន | | ១ | ២ | ៣ | ៤ | ៥ | ប.ព.វ.ក.ស. (ក.រ.ដ.ន.ស.) |
| ២.២៥ | សមាមាត្រនៃផ្ទៃដីបានបោសសម្អាតមីននិងសំណល់ជាតិផ្ទុះពីសង្គ្រាម | % | ៥,៥ | ៤,៧ | ៥ | ៥,៣ | ៥,៥ | ៥,៨ | ប.ព.វ.ក.ស. (អ.ម.ក.) |
| ២.២៦ | ផលិតកម្មវារីវប្បកម្មកើន១៥% (តោន) | តោន | | ៩៧ ៨០០ | ១១២ ៥០០ | ១២៩ ៤០០ | ១៤៨ ៨០០ | ១៧១ ១៧០ | ប.ព.វ.ក.ស. (ក.ក.រ.ន.) |
| ២.២៧ | សហគមន៍នេសាទ | ចំនួន | | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ៥១៦ | ប.ព.វ.ក.ស. (ក.ក.រ.ន.) |
| ២.២៨ | ផលិតកម្មនេសាទ | ពាន់តោន | | ៧៥២ | ៧៩០ | ៨២៩ | ៨៧០ | ៩១០ | ប.ព.វ.ក.ស. (ក.ក.រ.ន.) |
| ២.២៩ | សហគមន៍ព្រៃឈើ | សហគមន៍ | | ៥០០ | ៥២០ | ៥៥០ | ៥៧០ | ៦០០ | ប.ព.វ.ក.ស. (ក.ក.រ.ន.) |
| ២.៣០ | ការដាំដុះឈើឡើងវិញ (គិតចាប់ពីឆ្នាំ១៩៨៥) | ពាន់ហ.ត. | | ២០ ២៨០ | ២២ ៣០០ | ២៤ ៥០០ | ២៧០០០ | ២៩ ៧០០ | ប.ព.វ.ក.ស. (ក.ក.រ.ន.) |
| ២.៣១ | ឧទ្យានុរក្សក្នុងតំបន់ការពារធម្មជាតិ | ចំនួន | ៩៦០ | ១ ០០០ | ១ ០៥០ | ១ ១០០ | ១ ១០០ | ១ ១៥០ | ប.ព.វ.ក.ស. (ក.ប.ស.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ២.៣២ | ការកំណត់ព្រំប្រទល់និងផែនទី សម្រាប់តំបន់ការពារធម្មជាតិ | ចំនួនបង្គោលព្រំ | ៨២០ | ៨២០ | ៩០៦ | ១ ១៥៦ | ១ ២៥៦ | ១ ៣៥៦ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ២.៣៣ | តំបន់រ៉ាមសារ | ចំនួន | ៣ | ៤ | ៤ | ៥ | ៥ | ៥ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ២.៣៤ | ផលធៀបនៃចំណាយពាក់ព័ន្ធនឹងអាកាសធាតុធៀបនឹងផ.ស.ស. | % | ១,៣០ | ១,៣៥ | ១,៣៩ | ១,៤៣ | ១,៤៧ | ១,៥០ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ២.៣៥ | ការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុទៅក្នុងផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ | ក្រសួងស្ថាប័ន | ១១ | ១៣ | ១៥ | ១៧ | ១៩ | ២១ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ២.៣៦ | ចំនួនឃុំដែលងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ | ឃុំ | ៦៥០ | ៦០០ | ៥៥០ | ៥០០ | ៤៥០ | ៤០០ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ២.៣៧ | ឥណទានកាបូនបានពីយន្តការអភិវឌ្ឍន៍ស្អាត និងយន្តការផ្សេងៗ (REDD+ និងទីផ្សារស្ម័គ្រចិត្ត) | $GgCO_2$-eq | ២ ០៥០ ០០០ | ២ ១០០ ០០០ | ២ ១៥០ ០០០ | ២ ២០០ ០០០ | ២ ២៥០ ០០០ | ២ ៣០០ ០០០ | ប.ព.វ.ក.ស. (ក.ប.ស.) |
| ៣.១ | ជើងហោះហើរ | | | | | | | | |
| ៣.១.១ | *អន្តរជាតិ* | ចំនួន | ៤៤ ២៦០ | ៤៨ ៦៨៦ | ៥៣ ៥៥៥ | ៥៨ ៩១០ | ៦៤ ៨០១ | ៧១ ២៨១ | ប.ព.វ.ក.ស. (រ.អ.ស.វ.) |
| ៣.១.២ | *ក្នុងស្រុក* | ចំនួន | ៩ ៤០០ | ១០ ៣៤០ | ១១ ៣៧៤ | ១២ ៥១២ | ១៣ ៧៦៣ | ១៥ ១៣៩ | ប.ព.វ.ក.ស. (រ.អ.ស.វ.) |
| ៣.២ | អ្នកដំណើរតាមផ្លូវអាកាស | | | | | | | | |
| ៣.២.១ | *អន្តរជាតិ* | នាក់ | ៤ ៣១១ ៥៤៩ | ៤ ៧៤២ ៧០៤ | ៥ ២១៦ ៩៧៤ | ៥ ៧៣៨ ៦៧១ | ៦ ៣១២ ៥៣៨ | ៦ ៩៤៣ ៧៩២ | ប.ព.វ.ក.ស. (រ.អ.ស.វ.) |
| ៣.២.២ | *ក្នុងស្រុក* | នាក់ | ២៩៦ ៤១៣ | ៣២៦ ០៥៤ | ៣៥៨ ៦៥៩ | ៣៩៤ ៥២៥ | ៤៣៣ ៩៧៧ | ៤៧៧ ៣៧៥ | ប ប.ព.វ.ក.ស. |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| | | | | | | | | | (រ.អ.ស.រ.) |
| ៣.៣ | បរិមាណទំនិញ | | | | | | | | |
| ៣.៣.១ | *អន្តរជាតិ* | តោន | ៣១ ៩៧៧ | ៣៥ ១៧៥ | ៣៨ ៦៩៣ | ៤២ ៥៦២ | ៤៦ ៨១៨ | ៥១ ៤៩៩ | ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.៣.២ | *ក្នុងស្រុក* | តោន | ៥១៦ | ៥៦៨ | ៦២៥ | ៦៨៧ | ៧៥៦ | ៨៣២ | ប.ព.រ.ក.ស. (រ.អ.ស.រ.) |
| ៣.៤ | ការផលិតអគ្គិសនីក្នុងស្រុក | លាន គវម៉ | ១ ៨១៩ | ២ ៤៤០,៤៤ | ៣ ១០៧,៤៤ | ៣ ៨១៤,៤៤ | ៤ ២៣៤,០៣ | ៤ ៦១៥,០៩ | ប.ព.រ.ក.ស. (ក.ឧ.រ.ថ.) |
| ៣.៥ | ការនាំចូលអគ្គិសនី | លាន គវម៉ | ២ ៤៧៨,១៦ | ២ ៦០៩,៥៦ | ២ ៦០៩,៥៦ | ២ ៦០៩,៥៦ | ៤ ១៨៦,៣៦ | ៤ ១៨៦,៣៦ | ប.ព.រ.ក.ស. (ក.ឧ.រ.ថ.) |
| ៣.៦ | អត្រាអ្នកប្រើប្រាស់ទូរស័ព្ទ | ក្នុងចំណោមប្រជាជន ១០០នាក់ | ១៥៩,១៩ | ១៨៩,៨៦ | ២២៦,៤១ | ២៧០,០៥ | ៣២២,២៣ | ៣៨៤,៥០ | ប.ព.រ.ក.ស. (ក.ប.ទ.) |
| ៣.៧ | អត្រាអ្នកប្រើប្រាស់អ៊ិនធឺណិត | ១០០នាក់ | ៤,៣៣ | ៦,៩៣ | ១១,០៩ | ១៣,៤១ | ១៦,២៣ | ១៩,៦៤ | ប.ព.រ.ក.ស. (ក.ប.ទ.) |
| ៤.១ | សេវាចុះបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ៣ ៦០៣ | ៣ ៧៨២ | ៣ ៩៧១ | ៤ ១៦៩ | ៤ ៣៧៧ | ៤ ៥៩៥ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.២ | សេវាកម្មចុះឈ្មោះក្រុមហ៊ុនក្នុងបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ៤ ៦៣៦ | ៤ ៧២៨ | ៤ ៨២១ | ៤ ៩១៤ | ៥ ០០៧ | ៥ ០៩៩ | ប.ព.រ.ក.ស. (ក.ព.ណ.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៤.៣ | សេវាចុះឈ្មោះការិយាល័យតំណាងពាណិជ្ជកម្មនិងសាខាក្រុមហ៊ុនបរទេសក្នុងបញ្ជីពាណិជ្ជកម្ម | ក្រុមហ៊ុន | ២៧ | ២៨ | ២៩ | ៣០ | ៣២ | ៣២ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.៤ | ចំណូលទេសចរណ៍ | លានដុល្លារ | ២ ៥៤៧ | ២ ៨០២ | ៣ ០៥៤ | ៣ ៣៥៩ | ៣ ៧២៩ | ៤ ១៣៩ | ប.ព.រ.ក.ស. (ក.ព.ណ.) |
| ៤.៥ | ជួសជុលប្រាសាទបុរាណ | កន្លែង | ០៣ | ០២ | ០៣ | ០៣ | ០៣ | ០៣ | ប.ព.រ.ក.ស. (ក.វ.វ.) |
| ៤.៦ | កំណាយស្ថានីយបុរាណវិទ្យា | កន្លែង | ០១ | ០១ | ០២ | ០២ | ០២ | ០២ | ប.ព.រ.ក.ស. (ក.វ.វ.) |
| ៤.៧ | និវត្តជននិងជនបាត់បង់សម្បទាវិជ្ជាជីវៈ | ចំនួន | ៤០ ០០០ | ៤៥ ០០០ | ៥០ ០០០ | ៥៥ ០០០ | ៦០ ០០០ | ៦៥ ០០០ | អ.ស.ស.ក. (វ.ជ.ស.) |
| ៤.៨ | អតីតយុទ្ធជនដែលកំពុងទទួលរបប | ចំនួន | ៩៤ ៩៥៩ | ៩៨ ៦៣៤ | ១០១ ៣០៩ | ១០៣ ៩៨៤ | ១០៦ ៦៥៩ | ១០៩ ៣៣៤ | អ.ស.ស.ក./ជ.ទ.ប .ក. ( វ.ជ.ស.) |
| ៤.៩ | ជនពិការទទួលបានសេវាស្ដារលទ្ធភាពពលកម្មកាយសម្បទា | ចំនួន | ២៥ ៩៦៧ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ២៨ ០០០ | ប.ព.រ.ក.ស. (ក.ក.ប.វ.) |
| ៤.១០ | ចំនួនកុមារដែលរស់នៅក្នុងមណ្ឌលថែទាំកុមារក្នុងចំណោមកុមារ១០០ ០០០នាក់ | ចំនួន | ១០៦៧៩ | ១០៣១០ | ៩៩៤២ | ៩៥៧៤ | ៩២០៥ | ៨ ៨៣៧ | ប.ព.រ.ក.ស. (ក.ស.អ.យ.) |
| ៤.១១ | កុមារទទួលបានការថែទាំនៅសហគមន៍ | ចំនួន | ៨៥ ៩២១ | ៩០ ០០០ | ៩៥ ០០០ | ១០០ ០០០ | ១០៥ ០០០ | ១១០ ០០០ | ប.ព.រ.ក.ស. (ក.ស.អ.យ.) |
| ៥.១ | អត្រាពិតនៃការសិក្សានៅបឋមសិក្សា | | | | | | | | |
| ៥.១.១ | *សរុប* | % | ៩៧,០ | ៩៧,៣ | ៩៧,៩ | ៩៨,៦ | ៩៩,៣ | ១០០ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៥.១.២ | *ទីប្រជុំជន* | % | ៨៩,៨ | ៩១,៨ | ៩៣,៩ | ៩៥,២ | ៩៧,៩ | ១០០ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.១.៣ | *ជនបទ* | % | ៩៨,៦ | ៩៨,៩ | ៩៩,២ | ៩៩,៤ | ៩៩,៧ | ១០០ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២ | អត្រារួមនៃការសិក្សានៅមធ្យមសិក្សាបឋមភូមិ | | | | | | | | |
| ៥.២.១ | *សរុប* | % | ៥៦,៥ | ៦០,៤ | ៦៦,៩ | ៧៣,៧ | ៨១,៣ | ៨៧,៤ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២.២ | *ទីប្រជុំជន* | % | ៧៨,៤ | ៨០,៧ | ៨៤,៨ | ៨៨,២ | ៩២,៣ | ៩៤,៣ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.២.៣ | *ជនបទ* | % | ៥២,៦ | ៥៦,៧ | ៦៣,៦ | ៧១,២ | ៧៩,២ | ៨៦,១ | ប.ព.រ.ក.ស./អ.ស.ស.ក. (ក..អ.យ.ក./វ.ជ.ស.) |
| ៥.៣ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សានៅបឋមសិក្សា | % | ១ | ០,៩៩ | ០,៩៩ | ០,៩៩ | ០,៩៩ | ១ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៤ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សា នៅមធ្យមសិក្សាបឋមភូមិ | % | ០,៩៧ | ០,៩៧ | ០,៩៦ | ០,៩៦ | ០,៩៧ | ០,៩៦ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៥ | សន្ទស្សន៍យុត្តភាពយេនឌ័រនៃអត្រាពិតនៃការសិក្សា នៅមធ្យមសិក្សាទុតិយភូមិ | % | ០,៨៦ | ០,៨៩ | ០,៩១ | ០,៩០ | ០,៨៦ | ០,៨៣ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៦ | សន្ទស្សន៍យុត្តភាពយេនឌ័រនៅឧត្តមសិក្សា | % | ០,៧២ | ០,៧៣ | ០,៧៥ | ០,៧៧ | ០,៧៨ | ០,៨ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| | អត្រាត្រួតថ្នាក់ | | | | | | | | |
| ៥.៧ | *បឋមសិក្សា* | % | ៤ | ៤ | ៣ | ៣ | ៣ | ២ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |
| ៥.៨ | *មធ្យមសិក្សាបឋមភូមិ* | % | ១,៥ | ១,៥ | ១,៣ | ១,៣ | ១ | ១ | ប.ព.រ.ក.ស. (ក.អ.យ.ក.) |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៥.៩ | សមាមាត្រស្ត្រីមានផ្ទៃពោះដែលបានប្រើប្រាស់សេវាថែទាំសុខភាពមុនពេលសម្រាល២ដង ឬច្រើនដង ដោយបុគ្គលិកសុខាភិបាលដែលបានទទួលការបណ្ដុះបណ្ដាល | % | ៨៧ | ៨៨ | ៩០ | ៩១ | ៩៣ | ៩៥ | ប.ព.រ.ក.ស. (ក.ស.ភ.) |
| ៥.១០ | សមាមាត្រអាសនៈនៅក្នុងព្រឹទ្ធសភា | % | ១៤,៧ | ១៤,៧ | ១៤,៧ | ១៤,៧ | ៣០ | ៣០ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១១ | សមាមាត្រស្ត្រីក្នុងរដ្ឋសភា | % | ២០ | ២០ | ២០ | ២០ | ២០ | ៣០ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២ | សមាមាត្រស្ត្រីជាសមាជិកក្រុមប្រឹក្សា | | | | | | | | |
| ៥.១២.១ | *រាជធានី ខេត្ត* | % | ១០ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២.២ | *ខណ្ឌ ស្រុក* | % | ១២,៦៨ | ១៥ | ១៥ | ១៥ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១២.៣ | *ក្រុមប្រឹក្សាឃុំ/សង្កាត់* | | ១៨ | ១៨ | ១៨ | ១៨ | ២៥ | ២៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៣ | សមាមាត្រស្ត្រីជាអគ្គនាយក | % | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៤ | សមាមាត្រស្ត្រីជាប្រធាននាយកដ្ឋាន | % | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៦ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៥ | សមាមាត្រស្ត្រីជាប្រធានខុទ្ទកាល័យ/ ប្រធានមន្ទីរ | % | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ប.ព.រ.ក.ស. (ក.ក.ន.) |
| ៥.១៦ | អត្រាប្រេវ៉ាឡង់អំពើហិង្សាក្នុងគ្រួសារ | ចំនួន | ១២,៨ | ១២,៨ | ១១,៥ | ១១,៥ | ១១,៥ | ១១,៥ | មូលដ្ឋានទិន្នន័យឃុំសង្កាត់ |

| ល.រ | សូចនាករ | ឯកតា | ២០១៣ | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | ប្រភពទិន្នន័យ |
|---|---|---|---|---|---|---|---|---|---|
| ៥.១៧ | អត្រាប្រវ៉ាឡង់នៃការប្រើប្រាស់មធ្យោបាយពន្យារកំណើតទំនើប | % | ៣៧ | ៣៩ | ៥១ | ៥២ | ៥៣ | ៥៤ | ប.ព.វ.ក.ស. (ក.ស.ភ.) |

**ឧបសម្ព័ន្ធទី២**

# ពាក្យបំប្រួញ

| | |
|---|---|
| ក.ក.ប.វ. | ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| ក.ក.ន. | ក្រសួងកិច្ចការនារី |
| ក.ក.រ.ន. | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| ក.ធ.ទ.ឧ. | ក្រសួងធនធានទឹកនិងឧតុនិយម |
| ក.ទ.ច. | ក្រសួងទេសចរណ៍ |
| ក.ទ.រ.ព.អ. | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច |
| ក.ប.ទ. | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| ក.ប.ស. | ក្រសួងបរិស្ថាន |
| ក.រ.ដ.ន.ស. | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ |
| ក.ស.ដ. | ក្រសួងសាធារណការនិងដឹកជញ្ជូន |
| ក.ស.ភ. | ក្រសួងសុខាភិបាល |
| ក.ស.ហ. | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| ក.ស.អ.យ. | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| ក.អ.ជ. | ក្រសួងអភិវឌ្ឍន៍ជនបទ |
| ក.អ.យ.ក. | ក្រសួងអប់រំ យុវជន និងកីឡា |
| ក.វ.វ. | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ |
| ក.វ.ស. | កម្មវិធីវិនិយោគសាធារណៈ |
| គ.ជ.នា./ក.អ.ក. | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| គ.ជ.អ.ប. | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| គ.ម. | គីឡូម៉ែត្រ |
| គ.ម.$^{២}$ | គីឡូម៉ែត្រការ៉េ |
| គ.វ.ម៉. | គីឡូវ៉ាត់ម៉ោង |
| គ.អ.ស.ក. | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា |
| គ.អ.ភ. | គណៈកម្មាធិការអភិវឌ្ឍន៍ភូមិ |
| ជ.ទ.ប.ក. | ជំរឿនទូទៅនូវប្រជារាស្ត្ររបស់ប្រទេសកម្ពុជា |
| ធ.ជ.ក. | ធនាគារជាតិនៃកម្ពុជា |
| ទ.ឃ.ស. | ទិន្នន័យឃុំ សង្កាត់ |
| ប.ព.រ.ក.ស. | ប្រព័ន្ធព័ត៌មានរដ្ឋបាលរបស់ក្រសួង ស្ថាប័ន |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| ផ.យ.អ.ជ. | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ |
| ម. | ម៉ែត្រ |

| | |
|---|---|
| *ម.៣* | ម៉ែត្រត្រីគុណ |
| *ម.ជ.គ.ច.* | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ |
| រ.ល.អ.ស. | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល |
| វ.ជ.ស. | វិទ្យាស្ថានជាតិស្ថិតិ |
| ហ.ត. | ហិកតា |
| អ.ជ.ប.អ. | អាជ្ញាធរជាតិប្រឆាំងនឹងជំងឺអេដស៍ |
| អ.ធ.ម. | អាជ្ញាធរមីន |
| អ.ប.ស.ក. | អង្កេតប្រជាសាស្ត្រនិងសុខភាពកម្ពុជា |
| អ.ស.ស.ក. | អង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា |

**ឧបសម្ព័ន្ធទី៣**

## គេហទំព័ររបស់ក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលកម្ពុជា

| | ក្រសួង ស្ថាប័ន | គេហទំព័រ(www) |
|---|---|---|
| ១ | គណៈកម្មាធិការនីតិសម្បទានិងអភិវឌ្ឍន៍កម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cdc- crdb.gov.kh |
| ២ | គណៈកម្មាធិការវិនិយោគកម្ពុជា/ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | cib-cdc.gov.kh |
| ៣ | រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | civilaviation.gov.kh |
| ៤ | អាជ្ញាធរជាតិកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន | cmaa.gov.kh |
| ៥ | ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | mih.gov.kh |
| ៦ | សន្តិសុខស្បៀងនិងអាហារូបត្ថម្ភនៅកម្ពុជា | card.gov.khf |
| ៧ | ក្រសួងព័ត៌មាន | information.gov.kh |
| ៨ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | maff.gov.kh |
| ៩ | ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ | mcfa.gov.kh |
| ១០ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | mef.gov.kh |
| ១១ | ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | mfaic.gov.kh |
| ១២ | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | mlmupc.gov.kh |
| ១៣ | ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | mlvt.gov.kh |
| ១៤ | ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | mnasrl.gov.kh |
| ១៥ | ក្រសួងពាណិជ្ជកម្ម | moc.gov.kh |
| ១៦ | ក្រសួងធម្មការនិងសាសនា | mocar.gov.kh |
| ១៧ | ក្រសួងការពារជាតិ | mod.gov.kh |
| ១៨ | ក្រសួងបរិស្ថាន | moe.gov.kh |
| ១៩ | ក្រសួងអប់រំ យុវជន និងកីឡា | moeys.gov.kh |
| ២០ | ក្រសួងសុខាភិបាល | moh.gov.kh |
| ២១ | ក្រសួងមហាផ្ទៃ | moi.gov.kh |
| ២២ | ក្រសួងយុត្តិធម៌ | moj.gov.kh |
| ២៣ | ក្រសួងផែនការ | mop.gov.kh |
| ២៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | mosalvy.gov.kh |
| ២៥ | ក្រសួងទេសចរណ៍ | mot.gov.org |
| ២៦ | ក្រសួងកិច្ចការនារី | mowa.gov.kh |
| ២៧ | ក្រសួងធនធានទឹកនិងឧតុនិយម | mowram.gov.kh |
| ២៨ | ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | mptc.gov.kh |
| ២៩ | ក្រសួងសាធារណការនិងដឹកជញ្ជូន | mpwt.gov.kh |
| ៣០ | ក្រសួងអភិវឌ្ឍន៍ជនបទ | mrd.gov.kh |
| ៣១ | ក្រសួងមុខងារសាធារណៈ | sspf.gov.kh |

| | | |
|---|---|---|
| ៣២ | ក្រសួងរ៉ែ និង ថាមពល | mme.gov.kh |
| ៣៣ | អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ | naa.org.kh |
| ៣៤ | ធនាគារជាតិនៃកម្ពុជា | nbc.org.kh |
| ៣៥ | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ | ncdd.gov.kh |
| ៣៦ | គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | ncdm.gov.kh |
| ៣៧ | គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា | cnmc.gov.h |
| ៣៨ | មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺគ្រុនចាញ់ | cnm.gov.kh |
| ៣៩ | អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន | nacd.gov.kh |
| ៤០ | វិទ្យាស្ថានជាតិស្ថិតិ | nis.gov.kh |
| ៤១ | សាលារាជធានីភ្នំពេញ | phnompenh.gov.kh |
| ៤២ | ទីស្តីការគណៈរដ្ឋមន្ត្រី | pressocm.gov.kh |
| ៤៣ | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ | snec.gov.kh |